ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ
# សម្រាប់គ្រូបង្រៀនថ្នាក់ទី១

## ស្ដីអំពីសម្ភារៈជំនួយបន្ថែម
## លើសៀវភៅសិក្សាគោល ភាសាខ្មែរ
## អាន - សរសេរ

## ភាគ២

ឆ្នាំ២០២១

ហាមលក់
NOT FOR SALE

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews

# មាតិកា

## ខ្លឹមសារ

ទំព័រ


បុព្វកថា.....III

អារម្ភកថា.....V

សេចក្តីផ្តើម.....VII

លំនាំបង្រៀន

- លំនាំបង្រៀន សញ្ញាមូសិកទន្ត និងត្រីសព្ទ (ពីមេរៀនទី ៣០-៤០)..... 1
- លំនាំបង្រៀន មេរៀនប្រកប (ពីមេរៀនទី៤២-៦៤).....33
- លំនាំបង្រៀន មេរៀនស្រៈពេញតួ (ពីមេរៀនទី៦៥-៦៦).....124
- លំនាំបង្រៀន មេរៀនព្យញ្ជនៈ និងជើងព្យញ្ជនៈ (មេរៀនទី៦៧).....140
- លំនាំបង្រៀន មេរៀនផ្ញើជើង (ពីមេរៀនទី៦៨-៩៤).....144
- លំនាំបង្រៀន មេរៀនព្យាង្គតម្រួត ង្ក ង្ខ ង្គ ង្ឃ ង្ក ង្អ (ពីមេរៀនទី៩៥-១០២).....204

ឧបសម្ព័ន្ធ

- បំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរថ្នាក់ទី១ ប្រចាំឆ្នាំ .....229
- សម្ភារៈបង្រៀននិងរៀន.....231
- ការផ្តល់ជាគំនិតទាក់ទងសៀវភៅរឿងសម្រាប់សិស្សអាន-ដឹកនាំដោយគ្រូ.....235
- ការផ្តល់ជាគំនិតទាក់ទងសៀវភៅរឿងសម្រាប់សិស្សអាន-ដឹកនាំដោយសិស្ស.....236
- បញ្ជីសកម្មភាពល្បែងសិក្សាមួយចំនួន.....238
- ផ្នែកមួយចំនួននៃវេយ្យាករណ៍ខ្មែរ.....241


t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# បុព្វកថា

ប្រទេសកម្ពុជាមានមហិច្ឆតា ប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចមហិច្ឆតានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលការអភិវឌ្ឍធនធានមនុស្ស គឺជាផ្នែកមួយនៃការសម្របសម្រួលគោលនយោបាយគាំទ្រ។

កំណែទម្រង់វិស័យអប់រំ សំដៅលើកកម្ពស់គុណភាពអប់រំ និងអភិវឌ្ឍធនធានមនុស្ស ស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៥-២០៣០។ ការអប់រំនៅកម្រិតថ្នាក់ដំបូង ជាមូលដ្ឋានគ្រឹះក្នុងការសិក្សាលើមុខវិជ្ជាដទៃ និងជំនាញវិជ្ជាជីវៈផ្សេងៗ ព្រមទាំងបន្តការសិក្សាពេញមួយជីវិត។

ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបរៀងនូវកញ្ចប់សម្ភារៈបង្រៀននិងរៀន ដើម្បីជាធនធានសម្ភារៈ គាំទ្រដល់សៀវភៅភាសាខ្មែរ "អាន-សរសេរ" ថ្នាក់ទី១។ ខ្លឹមសារក្នុងសៀវភៅនេះ បានពីការប្រមូលផ្តុំបញ្ចូលគ្នានូវបទពិសោធនិងវិធីសាស្ត្របង្រៀនរបស់អង្គការពាក់ព័ន្ធ និងគ្រូបង្រៀនឆ្នើម។ សៀវភៅណែនាំនេះ ជួយផ្តល់គំនិតដល់គ្រូក្នុងការរៀបចំកិច្ចតែងការបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សា តាមរយៈលំនាំសកម្មភាពបង្រៀនមេរៀននីមួយៗ។ ម្យ៉ាងវិញទៀត សៀវភៅនេះផ្តោតលើវិធីសាស្ត្រសំយោគ ដោយឱ្យសិស្សរៀនចងចាំស្រៈនិស្ស័យទាំង២៣តួ រួចហើយទើបរៀនព្យញ្ជនៈពួក "អ" ផ្សំជាមួយស្រៈ។ បន្ទាប់មកឱ្យសិស្សស្គាល់សូរស្រៈទាំងអស់ ដែលត្រូវលំឱនទៅតាមព្យញ្ជនៈពួក "អ៊" ទើបរៀនព្យញ្ជនៈពួក "អ៊" ផ្សំជាមួយស្រៈ ដែលអាចនិយាយបានថា ជាមេរៀនស្ពានសម្រាប់ជួយសិស្សមានមូលដ្ឋានគ្រឹះរឹងមាំក្នុងការអាននិងសរសេរភាសាខ្មែរនៅថ្នាក់ដំបូង។ ក្នុងកញ្ចប់សម្ភារៈនេះ ក៏មានការបញ្ចូលអត្ថបទរឿងងាយៗ ភ្ជាប់ដោយរូបភាព ការប្រើបណ្ណអក្សររូបភាព និងសកម្មភាពល្បែងសិក្សា ចម្រៀង ព្រមទាំងសកម្មភាពដទៃទៀត ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យកុមារសប្បាយរីករាយចូលរួមគ្រប់សកម្មភាពក្នុងថ្នាក់រៀន។

ក្រសួងសង្ឃឹមថា គ្រប់ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ជាពិសេសគ្រូបង្រៀនថ្នាក់ទី១ នឹងគាំទ្រយ៉ាងពេញទំហឹង ដោយប្រើប្រាស់សៀវភៅនេះ ដើម្បីពង្រឹងសមត្ថភាពអាន និងសរសេរនៅថ្នាក់ទី១ ឈានទៅបង្កើនលទ្ធផលសិក្សា និងអត្រាឡើងថ្នាក់របស់សិស្ស ប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ថ្ងៃសុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# អារម្ភកថា

សៀវភៅណែនាំគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ ថ្នាក់ទី១ ត្រូវបានរៀបរៀងឡើងដោយក្រុមការងារក្រសួងអប់រំ យុវជន និងកីឡា រួមមាននាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអង្គការដៃគូនានា។

ការរៀបរៀងសៀវភៅនេះ គឺផ្អែកតាមលទ្ធផលនៃការចុះអង្កេតគ្រូចំនួនជិត៩០០នាក់ ក្នុងឆ្នាំសិក្សា ២០១៥-២០១៦។ ក្រៅពីនេះ ក្រុមអ្នករៀបរៀងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាច្រើនលើក ជាមួយថ្នាក់ដឹកនាំក្រសួង និងអ្នកពាក់ព័ន្ធនានា រួមមានការប្រជុំគណៈកម្មការដឹកនាំនិងសម្របសម្រួលកម្មវិធីអំណានថ្នាក់ដំបូង សិក្ខាសាលាពិគ្រោះយោបល់ ជាមួយលោកគ្រូ អ្នកគ្រូដែលមានបទពិសោធល្អៗក្នុងការបង្រៀន និងអង្គការដៃគូជាច្រើនទៀត ដើម្បីប្រមូលអនុសាសន៍និងព័ត៌មានត្រឡប់ ជាធាតុផ្សំសំខាន់ៗសម្រាប់ជាទុនដាក់បញ្ចូលបន្ថែមក្នុងសៀវភៅនេះ។

សៀវភៅនេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងគាំទ្រគ្រូបង្រៀនថ្នាក់ទី១ ដើម្បីបង្រៀនតាមខ្លឹមសារសៀវភៅសិក្សាគោលភាសាខ្មែរ "អាន-សរសេរ" ថ្នាក់ទី១ និងឆ្លើយតបទៅនឹងលទ្ធផលសិក្សា ដែលបានកំណត់ក្នុងកម្មវិធីសិក្សាលម្អិតរបស់ក្រសួង។ ការរៀបរៀងសៀវភៅនេះ ផ្តោតលើសម្ភារៈបង្រៀននិងរៀនសំខាន់ៗមួយចំនួនបន្ថែមលើសម្ភារៈដែលមាននៅក្នុងថ្នាក់រៀន ដោយជួយលោកគ្រូ អ្នកគ្រូក្នុងការបង្រៀន ទៅតាមខ្លឹមសារសៀវភៅសិក្សាគោល។ សម្ភារៈទាំងនេះ អាចជួយក្នុងការដឹកនាំសិស្សធ្វើសកម្មភាពរៀន ដោយមានអន្តរកម្មរវាងគ្រូនិងសិស្ស សិស្សនិងសិស្ស ដែលធ្វើឱ្យមានការ-ចូលរួមយ៉ាងសកម្មពីសិស្ស។ ក្រៅពីនេះ មេរៀនស្ពានដែលផ្តល់នូវមូលដ្ឋានគ្រឹះដល់សិស្សទាក់ទងនឹងការផ្សំព្យញ្ជនៈពួក "អ" និងព្យញ្ជនៈពួក "អ៊" នឹងស្រៈនិស្ស័យទាំង២៣តួ ត្រូវបានបញ្ចូលជាជំនួយបន្ថែម។ សៀវភៅនេះ ក៏មានបន្ថែមជូនអំណាន អត្ថបទខ្លីងាយៗភ្ជាប់ជាមួយរូបភាពសម្រាប់ឱ្យសិស្សអាចអានដោយខ្លួនឯងនៅក្នុងថ្នាក់រៀននិងនៅផ្ទះបាន ព្រមទាំងភ្ជាប់ នូវការបង្រៀនអក្សរផ្ចង់តាមទម្រង់អក្សរទ្រេតផងដែរ។

គណៈកម្មការរៀបរៀងសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងបានជាប្រយោជន៍ដល់ការបង្រៀនរបស់អ្នកពាក់ព័ន្ធ ជាពិសេសគ្រូបង្រៀនសម្រាប់ជួយដល់កុមារថ្នាក់ទី១ ឱ្យមានសមត្ថភាពអាន និងសរសេរប្រកបដោយគុណភាពនិង ប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ការរៀបរៀងក៏នៅមានចំណុចខ្វះខាតដោយជៀសមិនផុត យើងខ្ញុំសង្ឃឹមថា ប្រិយមិត្តអ្នកអាន លោកគ្រូ អ្នកគ្រូនឹងផ្តល់ជាមតិរិះគន់ក្នុងន័យកែលម្អឱ្យកាន់តែប្រសើរថែមទៀត។

**គណៈកម្មការរៀបរៀង**

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# សេចក្តីផ្តើម

## គោលបំណងនៃសៀវភៅនេះ

សៀវភៅនេះរៀបចំឡើង ក្នុងគោលបំណងគាំទ្រដល់ការបង្រៀនរបស់គ្រូថ្នាក់ទី១ ទៅតាមខ្លឹមសារក្នុង សៀវភៅសិក្សាគោលភាសាខ្មែរ "អាន-សរសេរ" ថ្នាក់ទី១ ប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទៅនឹងលទ្ធផលសិក្សាដែលបានកំណត់ក្នុងកម្មវិធីសិក្សាលម្អិតរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## សម្ភារៈសំខាន់ៗប្រើក្នុងកម្មវិធីអំណាន

សៀវភៅនេះរៀបចំឡើងដើម្បីយកទៅប្រើប្រាស់អមជាមួយសៀវភៅជំនួយសិស្ស សម្រាប់ភាសាខ្មែរ ថ្នាក់ទី១។

លទ្ធផលអង្កេតគ្រូបង្រៀនចំនួនប្រមាណ ៩០០នាក់ បង្ហាញថា លោកគ្រូ អ្នកគ្រូភាគច្រើន ត្រូវការលំនាំ បង្រៀនប្រចាំថ្ងៃគ្រប់មេរៀន ដែលលោកគ្រូអ្នកគ្រូអាចប្រើលំនាំបង្រៀននេះជាជំនួយក្នុងការរៀបចំ កិច្ចតែងការ បង្រៀន និងសម្ភារៈបង្រៀន និងរៀន ដើម្បីដឹកនាំសិស្សអាន និងសរសេរ ។

## រចនាសម្ព័ន្ធនៃសៀវភៅនេះ

រចនាសម្ព័ន្ធនៃសៀវភៅនេះ រួមមាន៖

- **ផ្នែកទី១ : សេចក្តីផ្តើម**
  - គោលបំណងនៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១
  - សម្ភារៈសំខាន់ៗប្រើក្នុងកម្មវិធីអំណាន
  - រចនាសម្ព័ន្ធនៃសៀវភៅ
  - និមិត្តសញ្ញាដែលប្រើប្រាស់
  - បំណែងចែកកម្មវិធីសិក្សា ក្នុងមួយឆ្នាំសិក្សា។
- **ផ្នែកទី២ : គោលការណ៍ក្នុងលំនាំបង្រៀន និងរៀន**
  - សមត្ថភាពទាំង ៤ ក្នុងការរៀនភាសាខ្មែរ
  - សមាសភាគទាំង៥ នៃអំណាន និងសំណេរ
  - គោលការណ៍ "ខ្ញុំធ្វើ ខ្ញុំនិងអ្នកធ្វើ អ្នកធ្វើ" ។
- **ផ្នែកទី៣: លំនាំនៃការបង្រៀន**

  គ្រប់ប្រភេទមេរៀននីមួយៗ មានលំនាំបង្រៀនលម្អិតមួយជាគំរូមួយ និងលំនាំបង្រៀនប្រចាំថ្ងៃគ្រប់មេរៀនទាំងអស់។ លំនាំបង្រៀនលម្អិត រៀបរាប់អំពីព័ត៌មាន ដូចខាងក្រោម៖
  - វត្ថុបំណងមេរៀន
  - រយៈពេលបង្រៀន
  - លំនាំបង្រៀនក្នុងសកម្មភាពគោល និងសកម្មភាពរងនីមួយៗ
  - គន្លឹះ ឬចំណុចគួរចងចាំសម្រាប់គ្រូ ដើម្បីជួយគាំទ្រសិស្សទាំងអស់ឱ្យរៀនបានល្អ
  - សម្ភារៈបង្រៀននិងរៀន ដែលត្រូវការ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

_ **ផ្នែកទី៤:**

  - ឧបសម្ពន្ធ៖ បំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរថ្នាក់ទី១ ប្រចាំឆ្នាំ

## និមិត្តសញ្ញាដែលប្រើក្នុងសៀវភៅនេះ

- ⏱ រយៈពេល
- ◎ វត្ថុបំណងមេរៀន
- ❐ សម្ភារៈដែលត្រូវការ
- ✓ ការវាយតម្លៃ និងការជួយសិស្ស
- ★ ល្បិចទូទៅក្នុងការជួយសិស្ស
- ✍ ល្បិចជួយសិស្សខ្សោយគំហើញ
- ៗ ល្បិចជួយសិស្សមានបញ្ហាស្តាប់។

## សម្ភារៈបង្រៀន និងរៀនសម្រាប់ឆមាសទី២

សម្ភារៈខាងក្រោមនេះ មានសារៈសំខាន់សម្រាប់សកម្មភាពក្នុងសៀវភៅណែនាំនេះ។

- សៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី១ របស់ក្រសួងអប់រំ យុវជន និងកីឡា
- អក្សរចល័ត
- ប័ណ្ណអក្សររូបភាព
- សៀវភៅជំនួយសិស្ស
- ក្តារឆ្នួន និងសៀវភៅកិច្ចការសិស្ស (សៀវភៅសរសេរ)

## កាលវិភាគសង្ខេបក្នុងមួយឆ្នាំសិក្សា

សៀវភៅនេះ មានសកម្មភាព និងបច្ចេកទេសបង្រៀនមួយចំនួន ដើម្បីគាំទ្រសៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ របស់ក្រសួងអប់រំ យុវជន និងកីឡា។ វាផ្តល់យោបល់ទាក់ទងនឹងពេលវេលា និងម៉ោងបង្រៀន ដែលអាចឱ្យគ្រូបង្រៀនខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោលបានចប់សព្វគ្រប់ នៅចុងឆ្នាំសិក្សា។ នៅក្នុងឧបសម្ព័ន្ធ គឺការបង្ហាញគម្រោងផែនការមេរៀនប្រចាំថ្ងៃតាមសប្តាហ៍នីមួយៗក្នុងមួយឆ្នាំសិក្សា ដើម្បីធានាថាគ្រូនឹងអាចបង្រៀនចប់មេរៀនទាំងអស់។

យោងតាមសៀវភៅសិក្សាគោល មេរៀនប្រកបទាំងអស់មាន២៣មេរៀន ហើយមេរៀននីមួយៗ គឺជាមេរៀនប្រកបគ្មានបន្តក់ និងមានបន្តក់ដាក់បញ្ចូលគ្នា។ ក្រោយពីទទួលបានព័ត៌មានត្រឡប់ពីលោកគ្រូ អ្នកគ្រូថ្នាក់ទី១ ដែលយល់ឃើញថា កុមារមានការលំបាក ក្នុងការចាប់យកមេរៀនប្រកបគ្មានបន្តក់ និងមានបន្តក់ ក្នុងមួយថ្ងៃ ឬក្នុងពីរម៉ោងសិក្សា ក្រុមការងារបច្ចេកទេសរបស់ក្រសួង បានបំបែកមេរៀនទាំងនេះជាពីរមេរៀនដាច់ពីគ្នា។ ជាសរុប មេរៀនប្រកបទាំងអស់មាន៤២មេរៀន ដូចដែលបានបង្ហាញក្នុងឧបសម្ព័ន្ធក្នុងទំព័រក្រោយបង្អស់ នៃសៀវភៅនេះ។ ទោះយ៉ាងនេះក្តី ក្នុងលំនាំបង្រៀនប្រចាំថ្ងៃ លេខរៀងនៃមេរៀននីមួយៗត្រូវបានរក្សាទុកដដែល ដោយគ្រាន់តែបន្ថែម ចំណុច ក ឬ ចំណុច ខ នៅក្រោយលេខរៀងតែប៉ុណ្ណោះ (ឧ. មេរៀនទី ៤២- ក ប្រកបនឹង ក (អ) មេរៀនទី ៤២- ខ ប្រកបនឹង ក់ (អ)។

ដោយឡែក ចាប់ពីមេរៀនប្រកបរហូតដល់មេរៀនចុងក្រោយ គឺពុំមានមេរៀនសាឡើងវិញដាក់បញ្ចូលក្នុងបំណែងចែកកម្មវិធីសិក្សាទេ ហើយក៏ពុំមានលំនាំបង្រៀនក្នុងសៀវភៅណែនាំគ្រូនេះដែរ។ នោះមិនមែនមានន័យថា មេរៀនសាឡើងវិញទាំងអស់នោះ មិនត្រូវបានយកមកបង្រៀននោះឡើយ តែគ្រូត្រូវយកវាទៅបង្រៀននៅម៉ោងបត់បែនវិញ។

ពេលវេលា និងម៉ោងបង្រៀននៅក្នុងសៀវភៅនេះ គឺរៀបចំឡើងដើម្បីជួយសិស្សឱ្យមានមូលដ្ឋានគ្រឹះរឹងមាំ ទៅលើបំណិនសំខាន់ៗ។ ប្រសិនបើសិស្សស្គាល់ស្រៈ និងព្យញ្ជនៈច្បាស់ហើយ ពួកគេនឹងអាចចាប់យកមេរៀនបន្តបន្ទាប់ទៀតយ៉ាងឆាប់រហ័ស។ តាមបទពិសោធនៃការប្រើប្រាស់វិធីសាស្ត្រនេះ បានបង្ហាញឱ្យឃើញថាមានប្រសិទ្ធភាពនៅតាមបណ្ដាប្រទេសផ្សេងទៀតក៏ដូចជានៅប្រទេសកម្ពុជាដែរ។

ប្រភេទមេរៀនទាំងអស់ រួមជាមួយបំណែងចែកកម្មវិធីសិក្សាតាមខែនីមួយៗ ប្រចាំឆ្នាំ ត្រូវបានស្នើឡើងដូចក្នុងតារាងខាងក្រោម៖

| អំឡុងខែ | ប្រភេទមេរៀន | លេខរៀងមេរៀនក្នុងសៀវភៅសិក្សាគោល |
|---|---|---|
| វិច្ឆិកា | រៀនគូសបន្ទាត់ ចម្រៀងស្រៈ ចម្រៀងព្យញ្ជនៈ<br>មេរៀនស្ពាន*១ ក ខ ច ឆ និងមេរៀនស្រៈ ា - ស្រៈ ឿ | មេរៀនទី១-៤<br>មេរៀនស្ពានទី១ |
| ធ្នូ | មេរៀនស្ពានទី១ មេរៀនស្រៈ ៀ- ស្រៈ ោះ<br>មេរៀនក្នុងសៀវភៅសិក្សាគោល ព្យញ្ជនៈផ្សំស្រៈ ក - ណ | មេរៀនស្ពានទី១ (ត)<br>មេរៀនទី៥-១១ |
| មករា | មេរៀនក្នុងសៀវភៅសិក្សាគោល ព្យញ្ជនៈផ្សំស្រៈ ត-អ<br>មេរៀនស្ពានទី២ គ ជ ទ ល និងមេរៀនស្រៈ ា ិ - ែ ៃ | មេរៀនទី១២-១៥<br>មេរៀនស្ពានទី២ |
| កុម្ភៈ | មេរៀនស្ពានទី២ ស្រៈ ោ ៅ- ស្រៈ ោះ<br>មេរៀនក្នុងសៀវភៅសិក្សាគោល ព្យញ្ជនៈផ្សំស្រៈ គ - ម | មេរៀនស្ពានទី២ (ត)<br>មេរៀនទី១៦- ២៦ |
| មីនា | មេរៀនក្នុងសៀវភៅសិក្សាគោល ព្យញ្ជនៈផ្សំស្រៈ យ - វ<br>ចម្រៀង<br>មេរៀនមូសិកទន្ត និងត្រីសព្ទ ង៉- អ៊<br>មេសូត្រតែមាត់ | មេរៀនទី២៧- ២៨<br>មេរៀនទី២៩<br>មេរៀនទី៣០-៤០<br>មេរៀនទី៤១ |
| មេសា- ឧសភា | មេរៀនប្រកប<br>មេរៀនស្រៈពេញតួ (ចុងខែឧសភា) | មេរៀនទី៤២- ៦៤<br>មេរៀនទី៦៥- ៦៦ |
| មិថុនា-កក្កដា | ព្យញ្ជនៈ និងជើងព្យញ្ជនៈ<br>មេរៀនព្យញ្ជនៈផ្ញើជើង<br>មេរៀនព្យាង្គតម្រួត | មេរៀនទី៦៧<br>មេរៀនទី៦៨-៩៤<br>មេរៀនទី៩៥-៩៩ |
| សីហា | មេរៀនព្យាង្គតម្រួត (ត)<br>អត្ថបទអំណាន<br>មេរៀនរំឭក | មេរៀនទី៩៩-១០២<br>មេរៀនទី១០៣-១០៤ |

*សម្គាល់ : មេរៀនស្ពាន (តម្រូវឱ្យសិស្សប្រើប្រាស់សៀវភៅជំនួយសិស្ស)*

គម្រោងសកម្មភាពក្នុងសៀវភៅនេះ ត្រូវបានរៀបចំឡើង ដើម្បីបន្ស៊ីគ្នាទៅនឹងកាលវិភាគ សាលាបឋមសិក្សាសម្រាប់មុខវិជ្ជាភាសាខ្មែរ ដែលមាន ១៣ម៉ោង ក្នុងមួយសប្ដាហ៍។

សៀវភៅនេះសំណូមពរឱ្យគ្រូ បង្រៀនពីរម៉ោង សម្រាប់មួយមេរៀនក្នុង១ថ្ងៃ(៥ថ្ងៃ មាន១០ម៉ោងសិក្សា)។ ម៉ោងសិក្សាដែលនៅសល់ចំនួន៣ម៉ោងទៀតអាចបត់បែនបានតាមស្ថានភាពជាក់ស្ដែង។ ម៉ោងបត់បែនដែលនៅតែបានប្រើប្រាស់

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

គឺដើម្បីគាំទ្រខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោល។ ម៉ោងបត់បែនអាចជាម៉ោងទី៣ក្នុងថ្ងៃចន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ ហើយប្រើសម្រាប់គាំទ្របន្ថែមទៅតាមតម្រូវការគ្រូ និងសិស្ស ឬអាចធ្វើសកម្មភាពបន្ថែមសម្រាប់សិស្ស ដែលជួបការលំបាកក្នុងការអាន និងសរសេរ មានដូចជា៖

- ការរំឭកមេរៀនចាស់
- ហាត់សរសេរបន្ថែម (សំណេរ ដែលមានន័យ ឬអក្សរផ្ទង់)
- សកម្មភាពអំណានបន្ថែម
    - គ្រូអានរឿង (សិស្សស្តាប់)
    - សិស្សអានរឿង និងចូលរួមសកម្មភាពអំណានផ្សេងៗទៀត ៣ម៉ោងក្នុងមួយសប្តាហ៍។

ខាងក្រោមនេះជាផែនការសកម្មភាពបង្រៀនប្រចាំថ្ងៃក្នុងសប្តាហ៍៖

| ម៉ោង | ចន្ទ | អង្គារ | ពុធ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|
| ទី១ | លំនឹងថ្នាក់ និងរំឭកមេរៀន<br>១- ការស្គាល់សូរអក្សរថ្មី<br>២- ការស្គាល់តួអក្សរថ្មី<br>៣- ការអានព្យាង្គ និងពាក្យ<br>៤- វាក្យសព្ទ | លំនឹងថ្នាក់ និងរំឭកមេរៀន<br>១- ការស្គាល់សូរអក្សរថ្មី<br>២- ការស្គាល់តួអក្សរថ្មី<br>៣- ការអានព្យាង្គ និងពាក្យ<br>៤- វាក្យសព្ទ | លំនឹងថ្នាក់ និងរំឭកមេរៀន<br>១- ការស្គាល់សូរអក្សរថ្មី<br>២- ការស្គាល់តួអក្សរថ្មី<br>៣- ការអានព្យាង្គ និងពាក្យ<br>៤- វាក្យសព្ទ | លំនឹងថ្នាក់ និងរំឭកមេរៀន<br>១- ការស្គាល់សូរអក្សរថ្មី<br>២- ការស្គាល់តួអក្សរថ្មី<br>៣- ការអានព្យាង្គ និងពាក្យ<br>៤- វាក្យសព្ទ | លំនឹងថ្នាក់ និងរំឭកមេរៀន<br>១- ការស្គាល់សូរអក្សរថ្មី<br>២- ការស្គាល់តួអក្សរថ្មី<br>៣- ការអានព្យាង្គ និងពាក្យ<br>៤- វាក្យសព្ទ |
| ទី២ | ៥- ការអានល្បះ<br>៦- ការអានអត្ថបទខ្លី<br>៧- ការសរសេរ | ៥- ការអានល្បះ<br>៦- ការអានអត្ថបទខ្លី<br>៧- ការសរសេរ | ៥- ការអានល្បះ<br>៦- ការអានអត្ថបទខ្លី<br>៧- ការសរសេរ | ៥- ការអានល្បះ<br>៦- ការអានអត្ថបទខ្លី<br>៧- ការសរសេរ | ៥- ការអានល្បះ<br>៦- ការអានអត្ថបទខ្លី<br>៧- ការសរសេរ |
| ទី៣ | បត់បែន | X | បត់បែន | បត់បែន | X |

# គោលការណ៍ក្នុងលំនាំបង្រៀន និងរៀន

## សមាសភាគទាំង ៥ នៃអំណាន និងសំណេរ

### ១-សមត្ថភាពទាំង ៤ នៃការរៀនភាសា

យើងបានដឹងហើយថា បំណិនទាំង៤ ក្នុងភាសា មានទំនាក់ទំនងគ្នាទៅវិញទៅមក។ បំណិននិយាយ និងស្តាប់ គាំទ្របំណិនអាន និងសរសេរ ហើយគ្រប់សកម្មភាពអាន និងសរសេរ ក៏ត្រូវការ ការនិយាយ និងការស្តាប់។ ការសរសេរជួយដល់ការអាន ហើយបញ្ច្រាស់មកវិញ ការអានក៏ជួយដល់ការសរសេរផងដែរ។ ដូច្នេះ ការបញ្ច្រាប ឬបញ្ចូលបំណិនទាំង៤ នេះរួមគ្នា ក្នុងការបង្រៀនភាសា ធ្វើឱ្យមេរៀនមានប្រសិទ្ធភាពខ្ពស់។




### ២-សមាសភាគទាំង ៥ នៃអំណាន (និងសំណេរ)[1]

សមត្ថភាពជាក់លាក់ក្នុងការអាន និងសរសេរ ដែលសិស្សត្រូវទទួលបានពីខ្លឹមសារមេរៀន ក្នុងសៀវភៅសិក្សាគោល ត្រូវបានប្រមូលផ្តុំសម្រាប់មេរៀនណាមួយ ពីអ្វីដែលហៅថា «កម្រិតស្តង់ដា»។ ដើម្បីឱ្យកម្រិតស្តង់ដាអំណាន (និងសរសេរ) មានប្រសិទ្ធភាព គ្រូបង្រៀនត្រូវដឹងអំពីសមាសភាគគន្លឹះទាំង៥ ដែលឆ្លុះបញ្ចាំងកម្រិតស្តង់ដានីមួយៗ។ ការកត់សម្គាល់សមាសភាគទាំងនោះ គឺយោងតាមការស្រាវជ្រាវអន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ និយមន័យនៃសមាសភាគទាំងនោះ មានដូចតទៅ៖

#### សមាសភាគទី១-ការស្គាល់សូរ

ការស្គាល់សូរ គឺសំដៅលើការបង្រៀន ដើម្បីជួយឱ្យសិស្សមានសមត្ថភាពក្នុងការកំណត់ ប្រើប្រាស់ និងញែកសូរ ក្នុងភាសានិយាយ។ ការស្គាល់សូរ គឺបង្រៀនដោយការនិយាយផ្ទាល់មាត់ និងស្តាប់ តែគ្មានការសរសេរ។ ការស្គាល់សូរមានសារៈសំខាន់ក្នុងការជួយសិស្សឱ្យចេះកំណត់ ផ្សំប្រកប និងបំបែកសូរ។

#### សមាសភាគទី២-ការស្គាល់តួអក្សរថ្មី

ការស្គាល់តួអក្សរថ្មី គឺសំដៅដល់ការបង្រៀនដែលជួយសិស្សអាន និងអនុវត្តចំណេះដឹងស្តីពីទំនាក់ទំនងរវាងតួអក្សរ និងសូរ។ បំណិននេះមានសារៈសំខាន់ក្នុងការជួយឱ្យសិស្សចេះផ្សំប្រកបអក្សរ ហើយអានព្យាង្គ និងពាក្យ។

#### សមាសភាគទី៣-ការចេះវាក្យសព្ទ

ការចេះវាក្យសព្ទ គឺសំដៅលើការបង្រៀន ដើម្បីឱ្យសិស្សមានចំណេះដឹងស្តីពីពាក្យ ជាការយល់ន័យនៃពាក្យថ្មី និងដឹងអំពីរបៀបប្រើប្រាស់ពាក្យនោះ។ សិស្សរៀនពាក្យថ្មីបានល្អប្រសើរ កាលណាគ្រូបង្រៀនអំពីនិយមន័យនៃពាក្យតាមភាសាសាមញ្ញដែលសិស្សងាយយល់ ហើយហាត់តែងល្បះដោយប្រើពាក្យនោះបាន។ ការរៀនវាក្យសព្ទមានសារៈសំខាន់ក្នុងការជួយសិស្សឱ្យយល់ន័យនៃពាក្យថ្មីដែលគេបានរៀន និងឈានទៅយល់នូវអ្វីដែលគេបានអាន។

#### សមាសភាគទី៤-ការចេះអានស្ទាត់

ការចេះអានស្ទាត់ គឺសំដៅលើការបង្រៀន ដែលជួយពង្រឹងសមត្ថភាពអានបានត្រឹមត្រូវ ក្នុងល្បឿនសមស្រប និងមានការលើកដាក់សំឡេងតាមចេនាសម្ព័ន្ធនៃល្បះ។ ប្រសិនបើសិស្សអានយឺតពេក ហើយរវល់តែប្រកបពាក្យនីមួយៗ គេនឹងភ្លេចន័យនៃពាក្យនោះ នៅពេលអានល្បះចប់។ ការអានស្ទាត់មានសារៈសំខាន់ក្នុងការជួយសិស្សឱ្យយល់នូវអ្វីដែលគេបានអាន។

[1] ស្តង់ដាអំណាន សៀវភៅណែនាំគ្រូបង្រៀនដើម្បីពង្រឹងសមត្ថភាពអំណានដល់សិស្សថ្នាក់ទី២ ខែកញ្ញា ២០១៩ ក្រសួងអប់រំ យុវជន និងកីឡា



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

### សមាសភាគទី ៥-ការអានដើម្បីយល់ន័យ

ការអានដើម្បីយល់ន័យ គឺសំដៅលើការបង្រៀនដែលឱ្យសិស្សមានសមត្ថភាពចូលរួមបញ្ចេញន័យ ឬសង្ខេបខ្លឹមសារអត្ថបទដែលបានអានដោយប្រើពាក្យសម្ដីផ្ទាល់ខ្លួន។ សារៈសំខាន់របស់វា គឺការយល់អត្ថន័យនៃអត្ថបទទាំងមូល។

## ៣-សកម្មភាពគោលក្នុងលំនាំបង្រៀន

សកម្មភាពគោលក្នុងលំនាំបង្រៀនគ្រប់មេរៀនទាំងអស់ ក្នុងសៀវភៅណែនាំគ្រូថ្នាក់ទី១នេះ គឺស្របទៅនឹងសមាសភាគទាំង៥នៃអំណាន ដូចដែលបានរៀបរាប់ខាងលើ។ សកម្មភាពគោលទាំងនោះរួមមាន ៖

១- ការស្គាល់សូរអក្សរថ្មី ២- ការស្គាល់តួអក្សរថ្មី ៣- ការអានព្យាង្គ និងពាក្យ ៤- វាក្យសព្ទ ៥- ការអានល្បឿន ៦- ការអានអត្ថបទ ៧- ការសរសេរ។

## គោលការណ៍បង្រៀនតាមរបៀប ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ

«ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ» ជាគោលការណ៍បង្រៀន និងរៀនដ៏សំខាន់ ដែលជានាំនូវការចូលរួមរបស់សិស្សក្នុងសកម្មភាពរៀនប្រកបដោយទំនុកចិត្ត និងមោទនភាព។ វាគឺជាការបង្រៀនបំណិនថ្មី ដោយផ្ដល់ការទទួលខុសត្រូវដល់សិស្សបន្តិចម្ដងៗ តាមរយៈការអនុវត្តជាជំហានៗដោយមានការជួយគាំទ្រដល់ដំណើរការនៃការរៀន។

ឧទាហរណ៍ដូចជាការរៀនជិះកង់របស់កុមារម្នាក់។ មុនដំបូង កុមារត្រូវការសង្កេតមើលគេជិះកង់ជាមុនសិន បន្ទាប់មកគេត្រូវការនរណាម្នាក់ជួយបង្រៀនគេឱ្យចេះជិះកង់ដោយជិះរួមគ្នាសិន។ ទីបំផុតគេមានទំនុកចិត្តអាចជិះកង់ដោយខ្លួនឯងបាន។

ការរៀនបំណិនថ្មីដទៃទៀត ជាពិសេសការអាន និងសរសេរក្នុងថ្នាក់រៀន ក៏ដូចគ្នានឹងឧទាហរណ៍ខាងលើនេះដែរ។ ដើម្បីរៀនបានល្អប្រសើរ សិស្សត្រូវការ ៖ ១- គ្រូធ្វើជាគំរូឱ្យសិស្សមើល ២- គ្រូ និងសិស្ស ហាត់រួមគ្នាក្នុងថ្នាក់ទាំងមូល និង ៣- សិស្សហាត់ជាបុគ្គល ឬជាដៃគូ។

សូមមើលតារាងខាងក្រោម៖

| អ្នកណា | ធ្វើដូចម្ដេច ? | ហេតុអ្វីបានជាសំខាន់ ? | ត្រូវផ្ដោតលើអ្វី ? |
|---|---|---|---|
| ខ្ញុំធ្វើ (គ្រូ) | គ្រូពន្យល់ពីអ្វីដែលសិស្សត្រូវធ្វើ រួចគ្រូធ្វើបង្ហាញជាគំរូដល់សិស្ស។ | សិស្សបានសង្កេតសកម្មភាពគ្រូ តាមដំណាក់កាលនីមួយៗ មុនពេលអនុវត្តជាមួយគ្រូ។ | គ្រូត្រូវប្រាកដថា សិស្សទាំងអស់បានឃើញសកម្មភាពគ្រូ។ |
| យើងធ្វើ (គ្រូ និង សិស្ស) | គ្រូនិងសិស្សអនុវត្ត ឬហាត់ជាមួយគ្នា ក្នុងថ្នាក់ទាំងមូល។ | សិស្សមានឱកាសធ្វើមួយជំហានម្ដងៗ ជាមួយគ្រូមុននឹងពួកគេធ្វើដោយខ្លួនឯង។ | គ្រូត្រូវប្រាកដថាសិស្សទាំងអស់បានធ្វើជាមួយគ្រូ។ |
| អ្នកធ្វើ (សិស្ស) | សិស្សអនុវត្ត ឬហ្វឹកហាត់ ជាដៃគូ ឬជាបុគ្គល។ | សិស្សមានឱកាសធ្វើដោយខ្លួនឯងនូវបំណិនថ្មី។ | គ្រូដើរតាមតុសិស្ស ដើម្បីឱ្យប្រាកដថាសិស្សទាំងអស់បានអានម្ដងម្នាក់ៗ ដោយប្ដូរវេនគ្នាគ្រូស្ដាប់សិស្សអាន៣-៥នាក់ ជាពិសេសសិស្សរៀនយឺត។ |

# លំនាំបង្រៀន

# សញ្ញាមូសិកទន្ត និងត្រីសព្ទ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| មេរៀនទី៣០ | ង៉ | ⌚ ៨០នាទី |
|---|---|---|

**គន្លឹះត្រូវចងចាំ**

- ✓ គ្រប់សកម្មភាពត្រូវអនុវត្តទៅតាមលំនាំក្នុងសៀវភៅណែនាំគ្រូ និងប្រើប្រាស់ពាក្យពេចន៍ជាអក្សរផិត។
- ✓ ក្នុងពេលអាន សិស្សត្រូវប្រើភ្នែក និងចង្អុលដៃរេតាមតួអក្សរ។
- ✓ គ្រូត្រូវដើរតាមតុសិស្ស ស្ដាប់សិស្សអានជាដៃគូ និងជួយកែតម្រូវសិស្សណាអានមិនទាន់ត្រឹមត្រូវ។
- ✓ ប្រសិនបើសិស្សណាលំបាកអាន គ្រូត្រូវជួយសិស្សនោះ។ គ្រូអាចអានពាក្យជាគំរូ អានពាក្យនោះម្ដងទៀតជាមួយសិស្ស និងឱ្យសិស្សអានពាក្យនោះខ្លួនឯងម្ដងទៀត។
- ✓ ប្រសិនបើសិស្សភាគច្រើនមានការលំបាក គ្រូត្រូវណែនាំឡើងវិញដោយប្រើ វិធីគ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើជាមួយសិស្សទាំងអស់ក្នុងថ្នាក់។
- ✓ សម្រាប់ការបង្រៀនតួអក្សរថ្មី គ្រូត្រូវសរសេរតួអក្សរដែលត្រូវរៀនធំៗលើក្ដារខៀន។
- ✓ អនុវត្ត គ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើ ដូចដែលបានលម្អិតក្នុងសៀវភៅណែនាំគ្រូ។
- ✓ គ្រូដើរតាមតុក្នុងថ្នាក់ ពេលគ្រូនិងសិស្សធ្វើ សិស្សធ្វើ ក្នុងគ្រប់សកម្មភាពអាន និងសរសេរដើម្បីជួយសិស្ស។
- ✓ សម្រាប់សកម្មភាពអាន ឱ្យសិស្សអានលើសពីម្ដង។
- ប្រសិនបើមានសិស្សខ្សោយគំហើញ និងខ្សោយស្ដាប់ រាល់ការបង្ហាញ និងការណែនាំរបស់គ្រូត្រូវប្រាកដថា សិស្សទាំងនោះស្ដាប់ឮ និងឃើញច្បាស់។
- គ្រូប្រើប័ណ្ណពាក្យ ល្បះសម្រាប់សិស្សខ្សោយស្ដាប់ និងខ្សោយគំហើញ។

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

◉ រំឭកពាក្យដែលបានរៀន

🗐 គ្មានសម្ភារៈ

⌚ ៥ នាទី

គ្រូសរសេរពាក្យ **លំនៅ វិថី យីកេ គិរី ភាសា** មួយម្ដងៗ ឱ្យសិស្សអាន ឬហៅឱ្យសិស្សសរសេរលើក្ដារឆ្នួន ហើយអាន។ គ្រូកែតម្រូវសិស្សដែលអាន ឬសរសេរមិនបានត្រឹមត្រូវ។

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥ នាទី

ល្បែងទស្សន៍ទាយ

◉ កំណត់ព្យាង្គ ឬពាក្យដែលផ្ដើមដោយព្យញ្ជនៈ ង៉

🗐 ប័ណ្ណអក្សររូបភាព

⌚ ៥នាទី

គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ (សូរអក្សរថ្មី។

- គ្រូ : ធ្វើកាយវិការបើកូនង៉ែត រួចសួរសិស្សថា **តើគ្រូកំពុងធ្វើអ្វី? (បើកូនង៉ែត)**។ គ្រូថា **ង៉ែត** រួចសួរសិស្ស **តើពាក្យង៉ែតមានសូរដើមអ្វី?** (**ង៉**) ។
- គ្រូនិងសិស្ស : ថាទាំងអស់គ្នា **ង៉** ។
- សិស្ស : ថាទាំងអស់គ្នា **ង៉** ។

**គន្លឹះត្រូវចងចាំ**

★ គ្រូត្រូវបន្លឺសូរដែលត្រូវរៀនឱ្យបានឮៗ និងច្បាស់ៗ។
★ មានវិធីជាច្រើនយ៉ាង ក្នុងការបំផុសរកពាក្យថ្មី ក្នុងនោះរួមមាន ការលើកឧទាហរណ៍ ការពិពណ៌នា ការបង្ហាញវត្ថុជាក់ស្តែង ការបង្ហាញរូបភាព និងការធ្វើកាយវិការ។ល។ ការធ្វើកាយវិការត្រូវបានលើកទឹកចិត្តឱ្យគ្រូប្រើញឹកញាប់ ព្រោះវាអាចជួយឱ្យមានអន្តរកម្មរវាង គ្រូនិងសិស្ស សិស្សនិងសិស្ស ។
★ លើកទឹកចិត្តសិស្សឱ្យលើកដៃប្រកបព្យាង្គ និងពាក្យ ដូចដែលគ្រូបានធ្វើឱ្យមើល ដើម្បីឱ្យពួកគេធ្វើចលនាដៃគ្រប់គ្នា និងផ្ចង់អារម្មណ៍ក្នុងសកម្មភាពរៀន។
✓ ពិនិត្យមើលពេលសិស្សប្រកប ដើម្បីដឹងថាសិស្សណាខ្លះបន្លឺសូរប្រកប និងអានពាក្យបានត្រឹមត្រូវ សិស្សណាខ្លះដែលត្រូវការជួយបន្ថែម។
✓ បង្រៀនទៅតាមពេលវេលាដែលបានកំណត់ក្នុងសៀវភៅណែនាំគ្រូ ក្នុងសកម្មភាពណែនាំឱ្យសិស្សស្គាល់សូរអក្សរថ្មី។
៑ ត្រូវប្រាកដថា សិស្សអាចមើលឃើញគ្រូច្បាស់។ គ្រូទាញចំណាប់អារម្មណ៍សិស្សមើលគ្រូ និងចូលរួមសកម្មភាព។ ខណៈពេលដែលគ្រូប្រកបសូរ និងអានពាក្យ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## ២- ការស្គាល់តួអក្សរថ្មី ◷ ៥នាទី

◎ អានព្យញ្ជនៈ ង៉

🗐 គ្មានសម្ភារៈ

◷ ៥នាទី

- គ្រូសរសេរ ក ខ គ ឃ ង លើក្តារខៀនរៀនរួចប្រាប់សិស្សថា **ក្នុងចំណោមព្យញ្ជនៈមានសូរគូរបស់វា ដូចជា ក សូរគូនឹង គ ខ សូរគូនឹងឃ** ដូចសញ្ញាគូសភ្ជាប់ : ក ខ គ ឃ ង ។
- គ្រូពន្យល់សិស្សថា **ព្យញ្ជនៈ ង ពុំទាន់មានសូរគូរបស់វាទេ ដើម្បីឱ្យ ង មានសូរគូ យើងត្រូវប្រើសញ្ញាមូសិកទន្ត ឬធ្មេញកណ្តុរ ឬសញ្ញា អ (៉) ដាក់លើ ង ( ង៉ )**។
- ម្យ៉ាងទៀត គ្រូអាចប្រាប់សិស្សពីឧទាហរណ៍ងាយៗដូចខាងក្រោម៖
  - **ក មានមិត្តភក្តិ គ**
  - **ខ មានមិត្តភក្តិ ឃ**
  - **ចំណែក ង មិនទាន់មានមិត្តភក្តិទេ។ ដូច្នេះយើងត្រូវរកមិត្តភក្តិឱ្យវា ដោយបន្ថែមមូសិកទន្ត (៉) ពីលើ ង។ ដូច្នេះវានឹងមានមិត្តភក្តិនឹងគេ គឺ ង៉។** គ្រូសរសេរ ង៉ បន្ទាប់ពី ង រួចគូសភ្ជាប់ពី **ង ទៅ ង៉**។
    - គ្រូ : សរសេរ ង៉ មួយទៀតលើក្តារខៀនឱ្យធំ។ គ្រូអានថា **ង សម្លាប់ពីរ ង៉**។
    - គ្រូនិងសិស្ស : អាន **ង សម្លាប់ពីរ ង៉**។
    - សិស្ស : អាន **ង សម្លាប់ពីរ ង៉** ។
- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន។

## ៣- ការអានព្យាង្គ និងពាក្យ ◷ ១៨នាទី

៣.១- ការអានព្យាង្គលើក្តារខៀន និងក្នុងសៀវភៅជំនួយសិស្ស

◎ អានព្យាង្គដែលផ្សំប្រកបនឹង ង៉

🗐 គ្មានសម្ភារៈ

🕒 ៨ នាទី

**ក- ករណីទូទៅ**

- គ្រូ : សរសេរ **ង៉ា** នៅលើក្ដារខៀន។ គ្រូអាន **ង៉ អា ង៉ា** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ និងព្យាង្គ។
- គ្រូ និងសិស្ស : គ្រូសរសេរ **ង៉ែ**។ គ្រូ និងសិស្សអាន **ង៉ អែ ង៉ែ** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ និងព្យាង្គ។
- សិស្ស : គ្រូសរសេរ **ង៉ូ** ឱ្យសិស្សអាន **ង៉ អូ ង៉ូ** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ និងព្យាង្គ។

**ខ- ករណីមូសិកទន្តប្ដូរមកជាបុកជើង ( ុ )** ង៉ី ↘ ង៊ី

- គ្រូសរសេរ **ង៉** រួចពន្យល់ថា **កាលណាសញ្ញាមូសិកទន្ត ( ៉ ) ប្រើជាមួយស្រៈ៦តួ គឺស្រៈ ិ ី ឹ ឺ ើ ាំ វាប្ដូររូបរាងរបស់វា មកជាបុកជើងវិញ ( ុ ) វិញ។ ឧទាហរណ៍**
- គ្រូអាចពន្យល់សិស្សតាមបែបងាយយល់ថា **ស្រៈទាំង៦តួខាងលើមានទីតាំងនៅពីលើព្យញ្ជនៈ។ ឧទាហរណ៍ ពេល ង៉ ផ្សំជាមួយស្រៈណាមួយខាងលើ ង៉ ត្រូវទូលពីរត្រួត ដែលធ្វើឱ្យវាធ្ងន់។ ដូច្នេះ សញ្ញាមូសិកទន្ត ( ៉ ) ត្រូវធ្លាក់មកខាងក្រោមប្ដូរជាមកបុកជើងវិញ** ( ុ )។
  - គ្រូ : សរសេរ **ង៊ិ** នៅលើក្ដារខៀន។ គ្រូអាន **ង៉ អិ ង៊ិ** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ។
  - គ្រូនិងសិស្ស : គ្រូសរសេរ **ង៊ើ**។ គ្រូ និងសិស្សអាន **ង៉ អើ ង៊ើ** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ។
  - សិស្ស : គ្រូសរសេរ **ង៊ាំ** ឱ្យសិស្សអាន **ង៉ អាំ ង៊ាំ** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ។

**គ- ករណីស្រៈដែលមិនចាំបាច់ប្រើជាមួយមូសិកទន្ត ( ៉ )**

- គ្រូពន្យល់សិស្សថា **ចំពោះស្រៈ ួ ឿ ៀ មិនចាំបាច់ប្រើមូសិកទន្ត ( ៉ ) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ។ ឧទាហរណ៍ : ងួ ងឿ ងៀ**។

**ឃ- អានសៀវភៅជំនួយសិស្ស**

- សិស្ស **:** អានព្យាង្គក្នុងសៀវភៅជំនួយសិស្សក្នុងតារាងទី១ និងទី២ជាដៃគូដោយប្ដូរវេនគ្នា ម្នាក់ចង្អុល ម្នាក់ទៀតអាន។

៣.២-ការអានពាក្យ

◎ អានពាក្យដោយផ្សំប្រកប

🗐 ប័ណ្ណពាក្យ សៀវភៅសិក្សាគោល មេរៀន **ង៉**

🕒 ១០នាទី

- គ្រូ : សរសេរពាក្យ **ង៉ែង៉រ** ដាក់លើក្ដារខៀនរួចអានដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ **ង៉ អែ ង៉ែ ង៉ និងរ ង៉រ** រួចអូសម្រាមដៃអានពាក្យ **ង៉ែង៉រ**។
- គ្រូ និងសិស្ស : គ្រូសរសេរពាក្យ **ង៊ាំ** នៅលើក្ដារខៀន។ គ្រូ និងសិស្សអាន ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ **ង៉ អាំ ង៊ាំ** រួមគ្នា។
- សិស្ស :
  - គ្រូសរសេរ **ង៉ា** រួចចង្អុលឱ្យសិស្សអាន **ង៉ អា ង៉ា**។
  - សិស្សអានពាក្យក្នុងតារាងពាក្យនៃសៀវភៅជំនួយសិស្សជាដៃគូដោយម្នាក់ចង្អុល ម្នាក់ជាអ្នកអានរួចប្ដូរវេនគ្នា។
  - សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ (ពាក្យ **ង៉ែង៉រ**) ដោយចង្អុលចំតួអក្សរនីមួយៗ និងពាក្យ។

## ៤- វាក្យសព្ទ ◷ ៨នាទី

◎ យល់ន័យ និងប្រើប្រាស់ពាក្យ

🗐 សៀវភៅសិក្សាគោល មេរៀន ង៉

◷ ៨ នាទី

**ក-ង៉េះៗ**

- គ្រូ : សរសេរពាក្យ **ង៉េះៗ** លើក្ដារខៀន រួចអាន និងពន្យល់ន័យ។ ក្នុងករណីពាក្យត្រូវពន្យល់មានសរសេរលើក្ដារខៀនម្ដងហើយ គ្រាន់តែគូសវង់លើពាក្យនោះក៏បាន។ **ពាក្យ ង៉េះៗ គឺជាសំឡេងកូនឆ្កែយំ។ ឥឡូវនេះគ្រូនឹងបង្កើតល្បះមួយ ដោយប្រើពាក្យ ង៉េះៗ។ កូនឆ្កែយំង៉េះៗតោងជើងខ្ញុំ។**
- គ្រូ និងសិស្ស : **អានពាក្យ ង៉េះៗ ព្រមគ្នា។ ឥឡូវនេះយើងនឹងបង្កើតល្បះមួយរួមគ្នាដោយប្រើពាក្យ ង៉េះៗ ដោយគ្រូជាអ្នកផ្ដើម ហើយកូនៗជាអ្នកបំពេញ ពេលគ្រូបង្អាក់បន្តិច។** គ្រូថា **គីគីឆ្កែខ្ញុំយំ ...ពេលវារងា។** សិស្សថា **ង៉េះៗ។ ឥឡូវនេះយើងនឹងថាល្បះនេះឡើង វិញទាំងអស់គ្នា : គីគីឆ្កែខ្ញុំយំង៉េះៗពេលវារងារ។**
- សិស្ស : អានពាក្យ **ង៉េះៗ** និងបង្កើតល្បះដោយប្រើពាក្យ **ង៉េះៗ** ជាដៃគូ។

**ខ-ង៉ោះៗ**

- គ្រូ : សរសេរពាក្យ **ង៉ោះៗ** លើក្ដារខៀន រួចអាន និងពន្យល់ន័យ។ ក្នុងករណីពាក្យត្រូវពន្យល់មានសរសេរលើក្ដារខៀនម្ដងហើយ គ្រាន់តែគូសវង់លើពាក្យនោះក៏បាន។ **ពាក្យ ង៉ោះៗ មានន័យថា និយាយមិនច្បាស់។ ឥឡូវនេះគ្រូនឹងបង្កើតល្បះមួយ ដោយប្រើពាក្យ ង៉ោះៗ ។ បូណានិយាយង៉ោះៗពេលវាផ្ដាសាយ។**
- គ្រូ និងសិស្ស : អានពាក្យ **ង៉ោះៗ** ព្រមគ្នា។ **ឥឡូវនេះយើងនឹងបង្កើតល្បះមួយ រួមគ្នាដោយប្រើពាក្យ ង៉ោះៗ ដោយគ្រូជាអ្នកផ្ដើម ហើយកូនៗជាអ្នកបំពេញ ពេលគ្រូបង្អាក់បន្តិច។** គ្រូថា **ចៅម៉ូនិយាយ ... ទារទិញនំ។** សិស្សថា **ង៉ោះៗ។ ឥឡូវនេះយើងនឹងថាល្បះនេះឡើងវិញទាំងអស់គ្នា : ចៅម៉ូនិយាយង៉ោះៗទារទិញនំ។**
- សិស្ស : អានពាក្យ **ង៉ោះៗ** និងបង្កើតល្បះដោយប្រើពាក្យ **ង៉ោះៗ** ជាដៃគូ។

**គន្លឹះត្រូវចងចាំ**

✓ សម្រាប់ការបង្រៀនវាក្យសព្ទ គ្រូត្រូវដើរតាមតុ ស្ដាប់សិស្សបង្កើតល្បះជាមួយដៃគូ។

✓ សកម្មភាពនេះទាមទារឱ្យសិស្សស្គាល់សូរ ចេះអានពាក្យ យល់ន័យពាក្យ ចេះប្រើប្រាស់ពាក្យបានត្រឹមត្រូវ។ គ្រូ និងសិស្សបង្កើតល្បះដោយផ្ទាល់មាត់ ពុំមានការសរសេរទេ។

✓ ពេលសិស្សបង្កើតល្បះ គ្រូស្ដាប់ហើយសួរបញ្ជាក់ បើល្បះនោះមិនទាន់មានន័យគ្រប់គ្រាន់។

✓ គ្រូត្រូវដើរទៅជិតសិស្ស នៅពេលគ្រូពន្យល់ និងបង្កើតល្បះជាឧទាហរណ៍ដល់សិស្ស។

## ៥- ការអានល្បះ ◷ ៥នាទី

◎ អានល្បះដោយមិនផ្សំប្រកប

🗐 គ្មានសម្ភារៈ

◷ ៥ នាទី

ក -គ្រូបង្ហាញរូបភាពទាក់ទងនឹងល្បះ ប្រសិនបើមាន។ គ្រូបំផុសសំណួរទាក់ទងនឹងល្បះ។

ខ- គ្រូសរសេរល្បះ **ចៅម៉ូចេះដើរតេះតះ។** លើក្ដារខៀន។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

គ្រូសួរសិស្សថា **តើល្បះនេះមានពាក្យអ្វីខ្លះ?** ពេលសិស្សឆ្លើយ គ្រូប្រើសញ្ញា ( / ) លើល្បះ ដើម្បីញែកពាក្យ **ចៅង៉ូ/ចេះ/ដើរ/តេះតះ។**

គ- គ្រូនាំសិស្សហ្វឹកហាត់អានៈ

- គ្រូ : អានល្បះ **ចៅង៉ូចេះដើរតេះតះ។**
- គ្រូ និងសិស្ស : អានល្បះព្រមគ្នា **ចៅង៉ូចេះដើរតេះតះ។**
- សិស្ស : អានល្បះទាំងអស់គ្នា **ចៅង៉ូចេះដើរតេះតះ។**

ឃ-គ្រូសួរសំណួរដែលផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់សិស្ស ដើម្បីឱ្យសិស្សយល់ពីអត្ថន័យនៃល្បះ។

ង-ឱ្យសិស្សហ្វឹកហាត់អានល្បះទាំងអស់ជាដៃគូ ក្នុងសៀវភៅសិក្សាគោល ដោយម្នាក់ចង្អុលម្នាក់ទៀតអានរួចប្តូរវេនគ្នា។

**គន្លឹះត្រូវចងចាំ**

✓ គ្រូស្រង់ល្បះមួយ ពីក្នុងសៀវភៅសិក្សាគោល។ ប្រសិនបើមានរូបភាពក្នុងសៀវភៅនោះ គ្រូលើករូបភាពបង្ហាញ ដើម្បីបំផុសសំណួរដែលទាក់ទងនឹងល្បះដែលត្រូវរៀន។

✓ គ្រូឱ្យសិស្សប្រាប់ពាក្យពិបាក (បើមាន) ។

## ៦- ការអានអត្ថបទខ្លី ◷ ១២ នាទី

◎ ហាត់អានស្ទាត់ និងយល់ន័យខ្លឹមសារអត្ថបទ

▤ សៀវភៅជំនួយសិស្ស

◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងនឹងរូបភាព : **តើកូនបានឃើញអ្វីខ្លះក្នុងរូបភាពនេះ?** រួចអានចំណងជើងអត្ថបទ។

ខ -គ្រូឱ្យសិស្សទស្សន៍ទាយសាច់រឿង : **តើរឿងនេះនិយាយអំពីអ្វី?**

គ- អានអត្ថបទខ្លី

- គ្រូ : អានរឿងយឺតៗ ដោយលើកដាក់សំឡេងគោរពតាមឃ្លា ល្បះ ក្នុងសាច់រឿង។
- គ្រូ និងសិស្ស : អានព្រមគ្នា។ គ្រូណែនាំសិស្សយកចង្អុលដៃអូសពីក្រោមពាក្យនៅពេលអាន។
- សិស្ស: អានជាដៃគូ ដោយប្តូរវេនគ្នា ម្នាក់ជាអ្នកចង្អុលម្នាក់ទៀតជាអ្នកអាន រួចអានជាបុគ្គល។ ប្រសិនបើមានពេល ឱ្យសិស្សអានឱ្យបានច្រើនដង។

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរម្តងមួយៗ ដោយទុកពេលឱ្យសិស្សគិត (បើរកចម្លើយមិនឃើញ គ្រូ និងសិស្សអានអត្ថបទរឿងឡើងវិញ)។

**១- តើចៅង៉ូដើរទៅណា?**

**២- តើអាគីបានទៅជាមួយចៅង៉ូដែរឬទេ?**

**៣- តើកូនគិតថា ហេតុអ្វីបានជាចៅង៉ូចង់នាំអាគីទៅសាលា?**

**៤- តើកូនចូលចិត្តចិញ្ចឹមឆ្កែឬទេ? ហេតុអ្វី?**

**គន្លឹះត្រូវចងចាំ**

★ សកម្មភាពគ្រូធ្វើ គ្រូត្រូវអានស្ទាត់ជាគំរូដល់សិស្ស។
✓ សកម្មភាពគ្រូនិងសិស្សធ្វើ គ្រូនិងសិស្សត្រូវអានរួមគ្នា (មិនមែនសិស្សអានតាមគ្រូទេ)។
✓ សម្រាប់សំណួរដែលមានចម្លើយលើសពីមួយ ទុកពេលសមល្មមឱ្យសិស្សប្រើបទពិសោធ ឬគំនិតផ្ទាល់ខ្លួនពិភាក្សាជាដៃគូ។
✓ ប្តូរសំណួរតែរក្សាន័យដដែល ពេលដែលសិស្សស្តាប់សំណួរគ្រូមិនយល់។
✓ ជួយសិស្ស ដោយប្រើសំណួរប្រដេញ ប្រសិនបើពួកគេនៅតែមិនទាន់យល់សំណួរ។

## ៧- ការសរសេរ 🕐 ១៦នាទី

៧.១- ការសរសេរពាក្យ

◎ បន្លឺសូរ និងសរសេរពាក្យបានត្រឹមត្រូវ
🗐 ប័ណ្ណពាក្យ
🕒 ១១នាទី

- គ្រូ : បន្លឺពាក្យ **ង៉ែង៉រ** ។ គ្រូគិត និងថាឮៗ **ង៉ែង៉រ មាន ង ៉ ស្រៈ ែ ង ៉ និង រ** រួចសរសេរពាក្យ **ង៉ែង៉រ** លើក្ដារខៀន។
- គ្រូ និងសិស្ស : គ្រូបន្លឺពាក្យ **ចៅង៉ា** ។ គ្រូ និងសិស្សគិត និងថាឮៗ **ចៅង៉ា មាន ច ស្រៈ ៅ ង ៉ ស្រៈ ា** ។ គ្រូសរសេរ **ចៅង៉ា** លើក្ដារខៀន ចំណែកសិស្សសរសេរ **ចៅង៉ា** លើក្ដារឆ្នួន។
- សិស្ស : គ្រូបន្លឺពាក្យ **ង៉េះ**។ សិស្សគិត និងថាឮៗ **ង៉ ង ស្រៈ េះ** រួចសរសេរពាក្យ **ង៉េះ** លើក្ដារឆ្នួន។ សិស្សលើកបង្ហាញគ្រូ។ គ្រូសរសេរ **ង៉េះ** លើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។

គ្រូធ្វើដូចគ្នានឹងពាក្យ **ង៉េះ** ដែរ ចំពោះពាក្យ **ង៉ោះ តាង៉ោ**។

៧.២- សរសេរឃ្លា

◎ សរសេរឃ្លាក្នុងសៀវភៅកិច្ចការបានត្រឹមត្រូវ
🗐 ប័ណ្ណពាក្យ
🕒 ៥ នាទី

គ្រូប្រាប់សិស្សថា **ពេលនេះយើងនឹងហ្វឹកហាត់សរសេរឃ្លា។ គ្រូនឹងហៅឃ្លាយឺតៗចំនួន៣ដងឱ្យកូនសរសេរ។**

ក- គ្រូហៅឃ្លា **យំង៉ាៗ** គ្រូហៅឃ្លាយឺតៗ ច្បាស់ៗ ចំនួន៣ដង។
ខ- សិស្សសរសេរឃ្លាខាងលើចូលក្នុងសៀវភៅកិច្ចការ។
គ- គ្រូសរសេរឃ្លាលើក្ដារខៀន ឱ្យសិស្សផ្ទៀងផ្ទាត់ និងកែតម្រូវ។

**គន្លឹះត្រូវចងចាំ**

✓ គ្រូថាពាក្យយឺតៗ ច្បាស់ៗ និងសរសេរធំៗ លើក្ដារខៀន ឧ (ចំណែក) ។
✓ នៅពេលគ្រូហៅឱ្យសិស្សសរសេរ គ្រូគួរហៅពាក្យនីមួយៗពី ២-៣ដង ហើយប្រមាណ៣វិនាទីហៅម្ដង។
✓ គ្រូដើរពិនិត្យពេលសិស្សសរសេរ ហើយជួយកែតម្រូវនៅពេលដែលកំពុងសរសេរ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ 🕒 ៦នាទី

➢ គ្រូពង្រឹង ឬពង្រីកចំណេះដឹងរបស់សិស្សលើការអាន និងការសរសេរ៖
  ○ ការអាន៖ ឧទាហរណ៍: គ្រូប្រើប័ណ្ណអក្សរ ឬប័ណ្ណពាក្យដែលសិស្សបានរៀន ឱ្យសិស្សអាន ឬឱ្យក្រុមសិស្សរៀបតួអក្សរឱ្យបានជាពាក្យ ឬលេងល្បែងសិក្សានានា...ដែលសំដៅដល់ការពង្រឹង ឬពង្រីកចំណេះដឹងដល់សិស្ស។
  ○ ការសរសេរ៖ ឧទាហរណ៍: គ្រូអាចហៅពាក្យដែលរៀនរួច ឱ្យសិស្សសរសេរលើក្ដារឆ្នួន ឬសៀវភៅកិច្ចការ...។
➢ គ្រូដាក់កិច្ចការឱ្យសិស្សធ្វើ៖
  ○ ឱ្យសិស្សចម្លងស្រៈ ព្យញ្ជនៈ ពាក្យ ឃ្លា ឬល្បះ... ដាក់ក្នុងសៀវភៅសរសេរ។ (ឱ្យសិស្សចម្លងនៅផ្ទះបើគ្មានពេល)។
  ○ ដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## មេរៀនទី៣០ ង៉ ⏲ ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន ⏲ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **លំនៅ វិថី យីកេ គិរី ភាសា។**

### ១- ការស្គាល់សូរអក្សរថ្មី ⏲ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ង៉ែត**។ គ្រូបន្លឺ **ង៉ែត**។ **តើ ង៉ែត មានសូរដើមអ្វី?** ង៉។ គ្រូបន្លឺ **ង៉** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ង៉** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ង៉** រួមគ្នា។ |

### ២- ការស្គាល់តួអក្សរថ្មី ⏲ ៥នាទី

- គ្រូបង្ហាញតារាងព្យញ្ជនៈ ឬសរសេរលើក្ដារខៀនវគ្គទី១ រួចគូសភ្ជាប់អក្សរតាមសូរគូរបស់វា។ **អក្សរ ង មិនទាន់មានសូរគូ។ ដើម្បីឱ្យវាមានសូរគូ យើងត្រូវបន្ថែមមូសិកទន្ត (៉) ទៅលើ ង (ង៉)** ក ខ គ ឃ ង ង៉ ។

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **ង៉** ធំៗ លើក្ដារខៀន រួចចង្អុលនិងអានជាគំរូ **ង សម្លាប់ពីរ ង៉** ។ |
| គ្រូនិងសិស្ស | - អាន **ង សម្លាប់ពីរ ង៉** រួមគ្នា។ |
| សិស្ស | - អាន **ង សម្លាប់ពីរ ង៉** ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន។

### ៣- ការអានព្យាង្គនិងពាក្យ ⏲ ១៨នាទី

#### ៣.១ - ការអានព្យាង្គ

ក- ករណីទូទៅ

| | |
|---|---|
| គ្រូ | - សរសេរ **ង៉ា** លើក្ដារខៀនរួចចង្អុលនិងអាន **ង៉ អា ង៉ា** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ង៉ែ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ង៉ូ** ដោយផ្សំប្រកប។ |

ខ- ករណីមូសិកទន្តប្ដូរមកជាបុកជើង ( ុ )

- គ្រូប្រាប់ថា **ចំពោះស្រៈ៦តួគឺស្រៈ ិ ី ឹ ឺ េី ំ សញ្ញាមូសិកទន្ត (៉) ត្រូវប្ដូរមកជាបុកជើងវិញ ( ុ)។**

| | |
|---|---|
| គ្រូ | - សរសេរ **ង៊ិ** លើក្ដារខៀនរួចចង្អុលនិងអាន **ង៉ អិ ង៊ិ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ង៊ើ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ង៊ាំ** ដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១ និង២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

គ- គ្រូពន្យល់ទៀតថាចំពោះ **ស្រៈ ួ ឿ ៀ មិនចាំបាច់ប្រើសញ្ញាមូសិកទន្ត (៉) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ។**

#### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ង៉ែង៉រ** លើក្ដារខៀនរួចចង្អុលនិងអាន **ង៉ អែ ង៉ែ ង៉ និង រ ង៉រ ង៉ែង៉រ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ង៉ាំ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ង៉ា** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៥នាទី

ក- ង៉េះៗ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ង៉េះៗ មានន័យថា សំឡេងកូនឆ្កែយំ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ង៉េះៗ ។ កូនឆ្កែយំង៉េះៗតោងជើងខ្ញុំ។** ។ |
| គ្រូនិងសិស្ស | - អានពាក្យ **ង៉េះៗរួមគ្នា** ។ គ្រូផ្តើម **គីគីឆ្កែខ្ញុំយំ ... ពេលវាវង្វេង។** សិស្សថាង៉េះៗ រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ង៉េះៗ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ង៉េះៗ** ជាដៃគូ។ |

ខ- ង៉ោះៗ បង្រៀនដូចពាក្យខាងលើ។ **ង៉ោះៗ មានន័យថា និយាយមិនច្បាស់។ ឧ.បូណានិយាយង៉ោះៗពេលផ្ដាសាយ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ចៅង៉ូចេះដើរតេះតះ** ។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ចៅង៉ូ/ចេះ/ដើរ/តេះតះ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ចៅង៉ូចេះដើរតេះតះ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ចៅង៉ូចេះដើរតេះតះ។** |
| សិស្ស | - សិស្សអានល្បះ **ចៅង៉ូចេះដើរតេះតះ។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើចៅង៉ូដើរទៅណា?**

**២- តើអាគីបានទៅជាមួយចៅង៉ូដែរឬទេ?**

**៣- តើកូនគិតថា ហេតុអ្វីបានជាចៅង៉ូចង់នាំអាគីទៅសាលា?**

**៤- តើកូនចូលចិត្តចិញ្ចឹមឆ្កែឬទេ? ហេតុអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាព្យាង្គៗ **ង៉ែង៉រ ង ៉ ែ ង ៉ និង រ** រួចសរសេរ **ង៉ែង៉រ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាព្យាង្គៗ **ចៅង៉ា ច ៅ ង ៉ ា** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ង៉េះ ង៉ោះ តាង៉ោ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាព្យាង្គៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **យំង៉ាៗ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## មេរៀនទី៣១ ញ៉ ◷ ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន ◷ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ង៉ែង៉រ ង៉ាំ នាវា លំហែ រំពេ**។

### ១- ការស្គាល់សូរអក្សរថ្មី ◷ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ញ៉ាំ**។ គ្រូបន្លឺ **ញ៉ាំ**។ **តើញ៉ាំ មានសូរដើមអ្វី**? **ញ៉**។ គ្រូបន្លឺ **ញ៉** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ញ៉** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ញ៉** រួមគ្នា។ |

### ២- ការស្គាល់តួអក្សរថ្មី ◷ ៥នាទី

- គ្រូបង្ហាញតារាងព្យញ្ជនៈ ឬសរសេរលើក្ដារខៀនវគ្គទី២ រួចគូសភ្ជាប់អក្សរតាមសូរគូរបស់វា។ **អក្សរ ញ មិនទាន់មានសូរគូ។ ដើម្បីឱ្យវាមានសូរគូ យើងត្រូវបន្ថែមសញ្ញាមូសិកទន្ត ( ៉ ) ទៅលើ ញ ( ញ៉ )**។ ច ឆ ជ ឈ ញ ញ៉

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **ញ៉** ធំៗ លើក្ដារខៀន រួចចង្អុលនិងអានជាគំរូ **ញ សម្លាប់ពីរ ញ៉** ។ |
| គ្រូនិងសិស្ស | - អាន **ញ សម្លាប់ពីរ ញ៉** រួមគ្នា។ |
| សិស្ស | - អាន **ញ សម្លាប់ពីរ ញ៉** ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន។

### ៣- ការអានព្យញ្ជនៈនិងពាក្យ ◷ ១៨នាទី

#### ៣.១ - ការអានព្យង្គ

ក- ករណីទូទៅ

| | |
|---|---|
| គ្រូ | - សរសេរ **ញ៉ា** លើក្ដារខៀនរួចចង្អុលនិងអាន **ញ៉ អា ញ៉ា** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ញ៉ៃ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ញ៉ៅ** ដោយផ្សំប្រកប។ |

ខ- ករណីមូសិកទន្តប្ដូរមកបុកជើង ( ុ )

- គ្រូប្រាប់ថា **ចំពោះស្រះ៦តួគឺស្រះ ិ ី ឹ ឺ ើ ំ សញ្ញាមូសិកទន្ត ( ៉ ) ត្រូវប្ដូរមកជា បុកជើងវិញ ( ុ )**។

| | |
|---|---|
| គ្រូ | - សរសេរ **ញុី** លើក្ដារខៀនរួចចង្អុលនិងអាន **ញ៉ អី ញុី**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ញុឹ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ញុើ** ដោយផ្សំប្រកប។<br>- សិស្សអានព្យង្គក្នុងតារាងទី១និង២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

គ- គ្រូពន្យល់ទៀតថាចំពោះ ស្រះ ួ ឿ ៀ **មិនចាំបាច់ប្រើសញ្ញាមូសិកទន្ត ( ៉ ) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ**។

#### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ញ៉េះញ៉ោះ** លើក្ដារខៀនរួចចង្អុលនិងអាន **ញ៉ អេះ ញ៉េះ ញ៉ អោះ ញ៉ោះ ញ៉េះញ៉ោះ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ញុាំ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ញុាំញុើ** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យទាំងអស់ក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ 🕒 ៨នាទី

ក- ញុាំញុើ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ញុាំញុើ** **មានន័យថា** **ញុិកញុ័ក, ញុៃងញុ័ង។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ** **ញុាំញុើ** ។ **បូផាដើរញុាំញុើទៅសាលារៀន។** |
| គ្រូនិងសិស្ស | - អានពាក្យ **ញុាំញុើ** រួមគ្នា។ គ្រូផ្ដើម **ជីតាដើរ.......ទៅផ្ទះ** ។ សិស្សថា **ញុាំញុើ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ញុាំញុើ** និង បង្កើតល្បះដោយប្រើប្រាស់ពាក្យ **ញុាំញុើ** ជាដៃគូ។ |

ខ- ញ៉េះញ៉ោះ បង្រៀនដូចពាក្យខាងលើ។ **ញ៉េះញ៉ោះ** **មានន័យថា** **រឡេះរឡោះដោយលេង ដោយប្រឡែង។**

**ឧ. សុខាមិនចូលចិត្តនិយាយញ៉េះញ៉ោះ។**

## ៥- ការអានល្បះ 🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **សុភីញ៉េះញ៉ោះបូណា** ។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **សុភី/ញ៉េះញ៉ោះ/បូណា។**

| | |
|---|---|
| គ្រូ | - គ្រូអាន **សុភីញ៉េះញ៉ោះបូណា** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **សុភីញ៉េះញ៉ោះបូណា។** |
| សិស្ស | - សិស្សអានល្បះ **សុភីញ៉េះញ៉ោះបូណា។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី 🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី ?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនរណាញ៉េះញ៉ោះចៅញុ៉ ?**

**២- តើចៅញុ៉កំពុងធ្វើអ្វី ?**

**៣- តើកូនគិតថា ចៅញ៉ា និងចៅញុ៉ញុាំមីរាល់ថ្ងៃឬទេ ?ហេតុអ្វី ?**

**៤- តើកូនធ្លាប់មានមិត្តភក្តិញ៉េះញ៉ោះដែរឬទេ ?**

## ៧- ការសរសេរ 🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ញុើ** **រ ញ ុ ើ (រ ញ បុកជើង ( ុ ) ស្រៈ ើ )** រួចសរសេរ **ញុើ** លើក្ដារខៀន។ ។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ញ៉េះញ៉ោះ ញ ៉ េះ ញ ៉ ោះ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ញុាំ ញុាំញុើ ញុៃ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ញុាំញុាំ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ 🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| មេរៀនទី៣២ | ប៉ | ⌚ ៨០នាទី |
|---|---|---|

| លំនឹងថ្នាក់ និងរំឭកមេរៀន | ⌚ ៥នាទី |
|---|---|

- គ្រូរំឭកពាក្យដែលបានរៀនរួច **ញ៉ាំ ញ៉េះញ៉ោះ ង៉ែង៉រ ចៅង៉ា គិរី។**

| ១- ការស្គាល់សូរអក្សរថ្មី | ⌚ ៥នាទី |
|---|---|

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ប៉ះ**។ គ្រូបន្លឺ **ប៉ះ**។ **តើ ប៉ះ មានសូរដើមអ្វី?** ប៉។ គ្រូបន្លឺ ប៉ ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ប៉** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ប៉** រួមគ្នា។ |

| ២- ការស្គាល់តួអក្សរថ្មី | ⌚ ៥នាទី |
|---|---|

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **ប៉** ធំៗ លើក្តារខៀន រួចចង្អុលនិងអានជាគំរូ **ប សម្លាប់ពីរ ប៉** ។ |
| គ្រូនិងសិស្ស | - អាន **ប សម្លាប់ពីរ ប៉** រួមគ្នា។ |
| សិស្ស | - អាន **ប សម្លាប់ពីរ ប៉** ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន។

| ៣- ការអានព្យាង្គនិងពាក្យ | ⌚ ១៨នាទី |
|---|---|

**៣.១ - ការអានព្យាង្គ**

ក- ករណីទូទៅ

| | |
|---|---|
| គ្រូ | - សរសេរ **ប៉ា** លើក្តារខៀនរួចចង្អុលនិងអាន **ប៉ អា ប៉ា** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ប៉េះ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ប៉ែ** ដោយផ្សំប្រកប។ |

ខ- ករណីមូសិកទន្តប្តូរមកបុកជើង (ុ)

- គ្រូប្រាប់ថា **ចំពោះស្រៈ៦តួគឺស្រៈ ិ ី ឹ ឺ ើ ាំ សញ្ញាមូសិកទន្ត (៉) ត្រូវប្តូរមកជា បុកជើងវិញ (ុ)។**

| | |
|---|---|
| គ្រូ | - សរសេរ **ប៊ិ** លើក្តារខៀនរួចចង្អុលនិងអាន **ប៉ អិ ប៊ិ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ប៉ាំ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ប៊ឺ** ដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១និង២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ចាប៊ី** លើក្តារខៀនរួចចង្អុលនិងអាន **ច អា ចា ប៉ អី ប៊ី ចាប៊ី** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ប៊ឺអ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ហោប៉ៅ** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ 🕒 ៨នាទី

ក- ប៉ះ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ប៉ះ មានន័យថា ទង្គិច ធ្វើឱ្យជិត។** គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ **ប៉ះ** ។ **ម៉ែប៉ះខោអាវ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ប៉ះ** រួមគ្នា។ គ្រូផ្ដើម **បងសុភា...ខោរហែក។** សិស្សថា **ប៉ះ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ប៉ះ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ប៉ះ** ជាដៃគូ។ |

ខ- ប៉ី បង្រៀនដូចពាក្យខាងលើ។ **ប៉ី មានន័យថា ឈ្មោះឧបករណ៍ភ្លេងផ្លុំមួយប្រភេទ។ ឧ. ខ្ញុំហែកស្លឹកចេកធ្វើប៉ីផ្លុំលេង។**

## ៥- ការអានល្បះ 🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **តាប៉ូកេះចាប៉ី។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **តាប៉ូ/កេះ/ចាប៉ី។**

| | |
|---|---|
| គ្រូ | - គ្រូអាន **តាប៉ូកេះចាប៉ី។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **តាប៉ូកេះចាប៉ី។** |
| សិស្ស | - សិស្សអានល្បះ **តាប៉ូកេះចាប៉ី។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី 🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើតាប៉ោចេះធ្វើអ្វីខ្លះ?**

**២- តើចៅប៉េទៅណា?**

**៣- ក្រៅពីប៉ះខោ និងកេះចាប៉ី តើតាប៉ោគាត់ចេះធ្វើអ្វីទៀត?**

**៤- តើកូនធ្លាប់ឃើញនរណាចេះប៉ះហោប៉ៅខោ?**
**ហេតុអ្វីបានគាត់ប៉ះ?**

## ៧- ការសរសេរ 🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ចាប៉ី ច ា ប ុ ី** រួចសរសេរ **ចាប៉ី** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ចំប៉ី ច ំ ប ុ ី** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ប៉ះ ប៉ីអ ហោប៉ៅ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **កេះចាប៉ី** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ 🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## មេរៀនទី៣៣ ម៉ ⌚ ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ប៉ះ ហោប៉ៅ ញ៉ាំញ៉ី ញ៉េះញ៉ោះ ង៉ែង៉រ។**

### ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ម៉ែ**។ គ្រូបន្លឺ **ម៉ែ**។ **តើ ម៉ែ មានសូរដើមអ្វី?** ម៉។ គ្រូបន្លឺ ម៉ ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ ម៉ រួមគ្នា។ |
| សិស្ស | - បន្លឺសូរ ម៉ រួមគ្នា។ |

### ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

- **អក្សរ ម មិនទាន់មានសូរគូ។ ដើម្បីឱ្យវាមានសូរគូ យើងត្រូវបន្ថែមសញ្ញាអ ឬ មូសិកទន្តទៅលើ ម (ម៉) ។**

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ ម៉ ធំៗ លើក្តារខៀន រួចចង្អុលនិងអានជាគំរូ **ម សម្លាប់ពីរ** ម៉ ។ |
| គ្រូនិងសិស្ស | - អាន **ម សម្លាប់ពីរ** ម៉ រួមគ្នា។ |
| សិស្ស | - អាន **ម សម្លាប់ពីរ** ម៉ ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន។

### ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

#### ៣.១ - ការអានព្យាង្គ

ក- ករណីទូទៅ

| | |
|---|---|
| គ្រូ | - សរសេរ **ម៉ែ** លើក្តារខៀនរួចចង្អុលនិងអាន **ម៉ អែ ម៉ែ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ម៉ៅ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ម៉េះ** ដោយផ្សំប្រកប។ |

ខ- ករណីមូសិកទន្តប្តូរមកបុកជើង ( ុ )

- គ្រូប្រាប់ថា **ចំពោះស្រៈ៦តួគឺស្រៈ ិ ី ឹ ឺ េី ំ សញ្ញាមូសិកទន្ត ( ៉ ) ត្រូវប្តូរមកជា បុកជើងវិញ ( ុ )។**

| | |
|---|---|
| គ្រូ | - សរសេរ **មុី** លើក្តារខៀនរួចចង្អុលនិងអាន **ម៉ អី មុី**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **មុាំ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **មុិ** ដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១និង២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

- គ្រូពន្យល់ទៀតថាចំពោះស្រៈ ួ **ឿ ៀ មិនចាំបាច់ប្រើមូសិកទន្ត ( ៉ ) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ។**

#### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **មួម៉ៅ** លើក្តារខៀនរួចចង្អុលនិងអាន **ម អួ មួ ម ៉ ៅ ម៉ៅ មួម៉ៅ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចៅមូ៉** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **រម៉េះរម៉ោះ** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- មួម៉ៅ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **មួម៉ៅ មានន័យថា ដែលក្ដាញ់, ខឹងខ្វល់ក្នុងចិត្ត, វង្វេងស្មារតី។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ មួម៉ៅ ។ ចៅម៉ូមួម៉ៅមិនឈប់។** |
| គ្រូនិងសិស្ស | - អានពាក្យ **មួម៉ៅ** រួមគ្នា។ គ្រូផ្ដើម **ម៉ែ...ដាក់កូនៗដែលឡូឡា។** សិស្សថា **មួម៉ៅ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **មួម៉ៅ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **មួម៉ៅ** ជាដៃគូ។ |

ខ- រម៉េះរម៉ោះ បង្រៀនដូចពាក្យខាងលើ។ **រម៉េះរម៉ោះ មានន័យថា មិនប្រាកដ ដែលចេញអាការលេងៗ។** ខ. **ចៅម៉ៅសរសេរដោយរម៉េះរម៉ោះ។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ម៉ែបួណាប៉ះហោប៉ៅខោ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ម៉ែ/បួណា/ប៉ះ/ហោប៉ៅ/ខោ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ម៉ែបួណាប៉ះហោប៉ៅខោ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ម៉ែបួណាប៉ះហោប៉ៅខោ។** |
| សិស្ស | - សិស្សអានល្បះ **ម៉ែបួណាប៉ះហោប៉ៅខោ។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើចៅម៉ៃធ្វើអ្វី?**

**២- តើដើមគគីរចៅម៉ៃរលំព្រោះអ្វី?**

**៣- តើចៅម៉ៃធ្វើដូចម្ដេចចំពោះដើមគគីរដែលរលំនោះ?**

**៤- តើកូនធ្លាប់មួម៉ៅដាក់នរណាទេ? ព្រោះអ្វី?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **មួម៉ៅ** ម ◌ួ ម ◌៉ ◌ៅ រួចសរសេរ **មួម៉ៅ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **មុាំ** ម ◌ុ ◌ាំ រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ម៉ែ ម៉ៅ រម៉េះរម៉ោះ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ម៉ែមួម៉ៅ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| មេរៀនទី៣៤ | យ៉ | ⌚ ៨០នាទី |
|---|---|---|

| លំនឹងថ្នាក់ និងរំឭកមេរៀន | ⌚ ៥នាទី |
|---|---|

- គ្រូរំឭកពាក្យដែលបានរៀនរួច **មួម៉ៅ មុាំ ហោប៉ៅ ចាប៉ី ប៉ះ** ។

| ១- ការស្គាល់សូរអក្សរថ្មី | ⌚ ៥នាទី |
|---|---|

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ឆៃយ៉ាំ**។ គ្រូបន្លឺ **យ៉ាំ**។ **តើ យ៉ាំ មានសូរដើមអ្វី? យ៉**។ គ្រូបន្លឺ **យ៉** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **យ៉** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **យ៉** រួមគ្នា។ |

| ២- ការស្គាល់តួអក្សរថ្មី | ⌚ ៥នាទី |
|---|---|

- **អក្សរ យ មិនទាន់មានសូរគូ។ ដើម្បីឱ្យវាមានសូរគូ យើងត្រូវបន្ថែមសញ្ញាមូសិកទន្តទៅលើ យ (យ៉)**។

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **យ៉** ធំៗ លើក្តារខៀន រួចចង្អុលនិងអានជាគំរូ **យ សម្លាប់ពីរ យ៉** ។ |
| គ្រូនិងសិស្ស | - អាន **យ សម្លាប់ពីរ យ៉** រួមគ្នា។ |
| សិស្ស | - អាន **យ សម្លាប់ពីរ យ៉** ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន។

| ៣- ការអានព្យាង្គនិងពាក្យ | ⌚ ១៨នាទី |
|---|---|

**៣.១ - ការអានព្យាង្គ**

ក- ករណីទូទៅ

| | |
|---|---|
| គ្រូ | - សរសេរ **យ៉ា** លើក្តារខៀនរួចចង្អុលនិងអាន **យ៉ អា យ៉ា** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **យ៉ៃ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **យ៉ះ** ដោយផ្សំប្រកប។ |

ខ- ករណីមូសិកទន្តប្តូរមកបុកជើង ( ុ )

- គ្រូប្រាប់ថា **ចំពោះស្រៈ៦តួគឺស្រៈ ិ ី ឹ ឺ ើ ំ សញ្ញាមូសិកទន្ត ( ៉ ) ត្រូវប្តូរមកជា បុកជើងវិញ ( ុ )**។

| | |
|---|---|
| គ្រូ | - សរសេរ **យុី** លើក្តារខៀនរួចចង្អុលនិងអាន **យ៉ អី យុី** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **យុឺ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **យុំ** ដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១និង២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

- គ្រូពន្យល់ទៀតថាចំពោះស្រៈ ួ ឿ ៀ **មិនចាំបាច់ប្រើមូសិកទន្ត ( ៉ ) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ។** ។

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **អាយ៉ៃ** លើក្តារខៀនរួចចង្អុលនិងអាន **អ អា អា យ៉ អៃ យ៉ៃ អាយ៉ៃ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ឆៃយ៉ាំ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **រយ៉ា** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ⏲ ៨នាទី

ក- រយ៉ា

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **រយ៉ា** **មានន័យថា គ្រឿងសម្រាប់ស្ត្រីពាក់នឹងត្រចៀកស្រដៀងនឹងក្រវិល។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ រយ៉ា ។ នារីពាក់រយ៉ាមាស។** |
| គ្រូនិងសិស្ស | - អានពាក្យ **រយ៉ា** រួមគ្នា។ គ្រូផ្ដើម **បងភីពាក់.....ស្អាតណាស់។** សិស្សថា **រយ៉ា** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **រយ៉ា** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **រយ៉ា** ជាដៃគូ។ |

ខ- ឆៃយ៉ាំ បង្រៀនដូចពាក្យខាងលើ។ **ឆៃយ៉ាំ មានន័យថា ឈ្មោះភ្លេងមួយបែបដែលគេលេងក្នុងពិធីបុណ្យផ្កា ឬកឋិន។**

**ឧ. ពូខ្ញុំចេះឡកឆៃយ៉ាំ។**

## ៥- ការអានល្បះ ⏲ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **នារីរាំឆៃយ៉ាំ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **នារី/រាំ/ឆៃយ៉ាំ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **នារីរាំឆៃយ៉ាំ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **នារីរាំឆៃយ៉ាំ។** |
| សិស្ស | - សិស្សអានល្បះ **នារីរាំឆៃយ៉ាំ។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⏲ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនរណារាំឆៃយ៉ាំ?**

**២- តើនរណាមានរយ៉ា?**

**៣- ហេតុអ្វីបានជាចៅម៉ូពាក់រយ៉ា?**

**៤- តើកូនចង់ពាក់រយ៉ាឬទេ? ហេតុអ្វី?**

## ៧- ការសរសេរ ⏲ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **អាយ៉ៃ** **អ** ា **យ** ៉ ែ រួចសរសេរ **អាយ៉ៃ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ឆៃយ៉ាំ ឆ** ែ **យ** ុ ំ រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **រយ៉ៃ រយ៉ា រយ៉ីរយ៉ៃ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើ ក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **រាំឆៃយ៉ាំ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⏲ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| មេរៀនទី៣៥ | រ៉ | ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **អាយ៉ៃ ឆៃយ៉ុំ មួម៉ៅ ម៉ែ ចាប៉ី**។

## ១- ការស្គាល់សូរអក្សរថ្មី ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុដាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **រ៉ាំរ៉ែ**។ គ្រូបន្លឺ **រ៉ែ**។ **តើ រ៉ែ មានសូរដើមអ្វី? រ៉**។ គ្រូបន្លឺ **រ៉** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **រ៉** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **រ៉** រួមគ្នា។ |

## ២- ការស្គាល់តួអក្សរថ្មី ៥នាទី

- **អក្សរ រ មិនទាន់មានសូរគូ។ ដើម្បីឱ្យវាមានសូរគូ យើងត្រូវបន្ថែមសញ្ញាមូសិកទន្តទៅលើ រ (រ៉)**។

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ រ៉ ធំៗ លើក្ដារខៀន រួចចង្អុលនិងអានជាគំរូ **រ សម្លាប់ពីរ រ៉** ។ |
| គ្រូនិងសិស្ស | - អាន **រ សម្លាប់ពីរ រ៉** រួមគ្នា។ |
| សិស្ស | - អាន **រ សម្លាប់ពីរ រ៉** ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ ១៨នាទី

### ៣.១ - ការអានព្យាង្គ

ក- ករណីទូទៅ

| | |
|---|---|
| គ្រូ | - សរសេរ **រ៉ា** លើក្ដារខៀនរួចចង្អុលនិងអាន **រ៉ អា រ៉ា** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រ៉ៅ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **រ៉ែ** ដោយផ្សំប្រកប។ |

ខ- ករណីមូសិកទន្តប្ដូរមកបុកជើង ( ុ )

- គ្រូប្រាប់ថា **ចំពោះស្រៈ ៦តួគឺស្រៈ** ិ ី ឹ ឺ េី ាំ **សញ្ញាមូសិកទន្ត ( ៉ ) ត្រូវប្ដូរមកជា បុកជើងវិញ ( ុ )**។

| | |
|---|---|
| គ្រូ | - សរសេរ **រុី** លើក្ដារខៀនរួចចង្អុលនិងអាន **រ៉ អី រុី**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រុឹ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **រុាំ** ដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១និង២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

- គ្រូពន្យល់ទៀតថាចំពោះស្រៈ ួ ឿ ៀ **មិនចាំបាច់ប្រើមូសិកទន្ត ( ៉ ) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ។** ។

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **រណារ៉** លើក្ដារខៀនរួចចង្អុលនិងអាន **រ ណ អា ណា និង រ ណារ រ សម្លាប់ពី រ៉ រណារ៉**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រ៉ាំរ៉ៃ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **រ៉ែរ៉ៃ** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- ពាំរ៉ៃ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ពាំរ៉ៃ មានន័យថា ត្រាំត្រែង យូរ។** គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ពាំរ៉ៃ ។ **ជីតាខ្ញុំឈើពាំរ៉ៃ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ពាំរ៉ៃ** រួមគ្នា។ គ្រូផ្ដើម **មីងសានឈឺ** ... ។ សិស្សថា **ពាំរ៉ៃ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ពាំរ៉ៃ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ពាំរ៉ៃ** ជាដៃគូ។ |

ខ- រ៉ែរ៉ែ បង្រៀនដូចពាក្យខាងលើ។ **រ៉ែរ៉ែ មានន័យថា បង្អែបង្អង់ចាំ។ ឧ. មេអំបៅហើររ៉ែរ៉ែលើផ្កា។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **តាឈុំឈឺពាំរ៉ៃ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **តាឈុំ/ឈឺ/ពាំរ៉ៃ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **តាឈុំឈឺពាំរ៉ៃ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **តាឈុំឈឺពាំរ៉ៃ។** |
| សិស្ស | - សិស្សអានល្បះ **តាឈុំឈឺពាំរ៉ៃ។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី ?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនរណាឈឺពាំរ៉ៃ ?**

**២- តើរ៉ៃធ្វើអ្វីនៅលើដើមកកោះ ?**

**៣- ហេតុអ្វីបានជាតារ៉ូមួម៉ៅ ?**

**៤- តើកូនធ្លាប់ឮរ៉ៃយំឬទេ ?នៅខែណា ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **រណារ៉ៃ** រ ណ ា រ ៃ រួចសរសេរ **រណារ៉ៃ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ពាំរ៉ៃ** រ ុ ំ រ ៉ ៃ រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **រ៉ែរ៉ែ រ៉េះ រ៉ៃ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ឈឺពាំរ៉ៃ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## មេរៀនទី៣៦ រ៉ ⌚ ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **រណារ៉ រ៉ាំរ៉ៃ ផៃយ៉ាំ រយ៉ា រម៉េះរម៉ោះ**។

### ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **វ៉ើ**។ គ្រូបន្លឺ **វ៉ើ**។ **តើ វ៉ើ មានសូរដើមអ្វី?** **រ៉**។ គ្រូបន្លឺ **រ៉** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **រ៉** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **រ៉** រួមគ្នា។ |

### ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

- **អក្សរ រ មិនទាន់មានសូរគូ។ ដើម្បីឱ្យវាមានសូរគូ យើងត្រូវបន្ថែមសញ្ញាមូសិកទន្តទៅលើ រ (រ៉)**។

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **រ៉** ធំៗ លើក្ដារខៀន រួចចង្អុលនិងអានជាគំរូ **រ សម្លាប់ពីរ រ៉** ។ |
| គ្រូនិងសិស្ស | - អាន **រ សម្លាប់ពីរ រ៉** រួមគ្នា។ |
| សិស្ស | - អាន **រ សម្លាប់ពីរ រ៉** ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន។

### ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

#### ៣.១ - ការអានព្យាង្គ

ក- ករណីទូទៅ

| | |
|---|---|
| គ្រូ | - សរសេរ **រ៉ែ** លើក្ដារខៀនរួចចង្អុលនិងអាន **រ៉ អែ រ៉ែ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រ៉ះ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **រ៉ោះ** ដោយផ្សំប្រកប។ |

ខ- ករណីមូសិកទន្តប្ដូរមកបុកជើង ( ុ )

- គ្រូប្រាប់ថា **ចំពោះស្រៈ៦តួគឺស្រៈ ិ ី ឹ ឺ ើ ំ សញ្ញាមូសិកទន្ត ( ៉ ) ត្រូវប្ដូរមកជា បុកជើងវិញ ( ុ )**។

| | |
|---|---|
| គ្រូ | - សរសេរ **រុី** លើក្ដារខៀនរួចចង្អុលនិងអាន **រ៉ អី រុី**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រុឺ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **រុឺ** ដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១និង២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

- គ្រូពន្យល់ទៀតថាចំពោះស្រៈ ួ ឿ ៀ **មិនចាំបាច់ប្រើមូសិកទន្ត ( ៉ ) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ**។

#### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ចៅរ៉ា** លើក្ដារខៀនរួចចង្អុលនិងអាន **ច អៅ ចៅ រ៉ អា រ៉ា**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រ៉ៃ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ពូរ៉ៅ** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- វ៉ៃ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **វ៉ៃ មានន័យថា វាយ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ វ៉ៃ** ។ **សុខវ៉ៃវទេះ។** |
| គ្រូនិងសិស្ស | - អានពាក្យ **វ៉ៃ** រួមគ្នា។ គ្រូផ្ដើម **កុំលេង.....គ្នា។** សិស្សថា **វ៉ៃ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - សិស្សបង្កើតល្បះដោយប្រើប្រាស់ពាក្យ **វ៉ៃ** ជាដៃគូ។ |

ខ- តវ៉ា បង្រៀនដូចពាក្យខាងលើ។ **តវ៉ា មានន័យថា ជជែក ប្រកែករកឱ្យឃើញការពិតដោយមិនទាន់សុខចិត្ត។**

**ឧ. នារីយំតវ៉ាជាមួយបងស្រី។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ចៅវ៉ាចេះវារ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ចៅវ៉ា/ចេះ/វារ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ចៅវ៉ាចេះវារ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ចៅវ៉ាចេះវារ។** |
| សិស្ស | - សិស្សអានល្បះ **ចៅវ៉ាចេះវារ។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនរណាដាំដំណាំ?**

**២- ហេតុអ្វីបានជាពូវ៉ៃវ៉ៃគោវ៉ារី?**

**៣- តើវ៉ារីគួរធ្វើដូចម្ដេចកុំឱ្យគោប៉ះពារដំណាំពូវ៉ៃ?**

**៤- តើផ្ទះកូនមានដំណាំអ្វីខ្លះ?នរណាជាអ្នកដាំ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **វ៉ៃ** វ ៉ ែ រួចសរសេរ **វ៉ៃ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ចៅវ៉ា ច ៅ វ** ៉ ា រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ពូវៅ តវ៉ា ណាំវ៉ា** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **វ៉ៃគោ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| រៀនសាឡើងវិញ | ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ | ៨០ នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូអនុវត្តសកម្មភាពលំនឹងថ្នាក់ដូចមេរៀនមុនៗ។

## ១ -ការអានពាក្យ ⌚ ១៨នាទី

| | |
|---|---|
| សិស្ស | - អានពាក្យ **ង៉ា... រហូតដល់ ហោប៉ៅ** ក្នុងសៀវភៅសិក្សាគោលដោយមិនបាច់ផ្សំប្រកប ជាដៃគូ។ |

## ២- វាក្យសព្ទ ⌚ ៨នាទី

ក- រ៉ែរ៉ែ

| | |
|---|---|
| គ្រូ | - សួរសិស្សថា **តើពាក្យរ៉ែរ៉ែ មានន័យដូចម្ដេច? បង្ហែបង្អង់ចាំ។** ឱ្យសិស្សបង្កើតល្បះជាដៃគូ។ |
| សិស្ស | - អានពាក្យ **រ៉ែរ៉ែ**បង្កើតល្បះដោយប្រើប្រាស់ពាក្យ **រ៉ែរ៉ែ** ជាដៃគូ។ |

ខ- រម៉េះរម៉ោះ បង្រៀនដូចពាក្យខាងលើ។ **រម៉េះរម៉ោះ មានន័យថា ដែលមិនប្រាកដ ដែលចេញអាការលេងៗ។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ម៉ែបូណាប៉ះហោប៉ៅខោ**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ម៉ែ/បូណា/ប៉ះ/ហោប៉ៅ/ខោ។**

| | |
|---|---|
| សិស្ស | - គ្រូចង្អុលឱ្យសិស្សអានល្បះ **ម៉ែបូណាប៉ះហោប៉ៅខោ**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើតាង៉ោឈរចាំអ្នកណា?**

**២- តើម៉ែនាំរ៉ារីទៅញ៉ាំអ្វី?**

**៣- តើរ៉ារីជាកូនដូចម្ដេច?**

**៤- តើម្ដាយឪពុករបស់កូនធ្លាប់ធ្វើដូចម្ដេច នៅពេលកូនយំ?**

## ៧- ការសរសេរ ⌚ ២៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ញ៉េះញ៉ោះ ញ ◌៉ េ◌◌ះ ញ ◌៉ ោ◌ះ** រួចសរសេរ **ញ៉េះញ៉ោះ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **រម៉េះរម៉ោះ រ ម ◌៉ េ◌◌ះ រ ម ◌៉ ោ◌ះ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ចាប៉ី រ៉ាំរ៉ៃ ហោប៉ៅ** ។ ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **កុំញ៉េះញ៉ោះ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

សូមអានទំព័របន្ទាប់!

| មេរៀនទីៗ៣៧ | បិ | ⌚ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **តវ៉ា ចៅវ៉ា វណារ៉ រ៉ាំរ៉ៃ អាយ៉ៃ**។

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **សាប៊ូ**។ គ្រូបន្លឺ **ប៊ូ**។ **តើប៊ូ មានសូរដើមអ្វី?** បិ។ គ្រូបន្លឺ **បិ** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **បិ** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **បិ** រួមគ្នា។ |

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

- **អក្សរ ប មិនទាន់មានសូរគូ។ ដើម្បីឱ្យវាមានសូរគូ យើងត្រូវបន្ថែមសញ្ញាត្រីសព្ទ ឬ សក់ ក ទៅលើ ប (ប៊)**។

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **បិ** ធំៗ លើក្តារខៀន រួចចង្អុលនិងអានជាគំរូ **ប ត្រីសព្ទ បិ** ។ |
| គ្រូនិងសិស្ស | - អាន **ប ត្រីសព្ទ បិ** រួមគ្នា។ |
| សិស្ស | - អាន **ប ត្រីសព្ទ បិ** ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន។

**៣- ការអានព្យាង្គនិងពាក្យ** ⌚ ១៨នាទី

**៣.១ - ការអានព្យាង្គ**

| | |
|---|---|
| គ្រូ | - សរសេរ **ប៉ៃ** លើក្តារខៀនរួចចង្អុលនិងអាន **បិ អៃ ប៉ៃ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ប៊ិះ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ប៊ី ប៊ូ ប៉ោះ** ដោយផ្សំប្រកប។ |

- គ្រូពន្យល់ទៀតថាចំពោះស្រៈ ូ ឿ ៀ **មិនចាំបាច់ប្រើសញ្ញាត្រីសព្ទ ឬសក់ក (៊) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ**។

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **សាប៊ូ** លើក្តារខៀនរួចចង្អុលនិងអាន **ស អា សា បិ អ៊ូ ប៊ូ សាប៊ូ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចៃប៉ុំ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ចៅប៊ី**ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

**៤- វាក្យសព្ទ** ⌚ ៨នាទី

ក- សាប៊ូ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **សាប៊ូ មានន័យថា គ្រឿងសម្រាប់ប្រើលាងដៃ ដុសខ្លួន បោកខោអាវ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ សាប៊ូ ។ ខ្ញុំលាងដៃនឹងសាប៊ូមុនពេលញ៉ាំអាហារ។** |
| គ្រូនិងសិស្ស | - អានពាក្យ **សាប៊ូ** រួមគ្នា។ គ្រូផ្តើម **យើងកក់សក់នឹង......ពេលងូតទឹក**។<br>- សិស្សថា **សាប៊ូ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **សាប៊ូ** បង្កើតល្បះដោយប្រើប្រាស់ពាក្យ **សាប៊ូ** ជាដៃគូ។ |

ខ- ប៊ីយេរ បង្រៀនដូចពាក្យខាងលើ។ **ប៊ីយេរ មានន័យថា ស្រាបៀ។ ឧ. ប៊ីយេរជាគ្រឿងស្រវឹង**។

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **សាប៊ូពីរដុំ**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **សាប៊ូ/ពីរ/ដុំ**។

| | |
|---|---|
| គ្រូ | - គ្រូអាន **សាប៊ូពីរដុំ**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **សាប៊ូពីរដុំ**។ |
| សិស្ស | - សិស្សអានល្បះ **សាប៊ូពីរដុំ**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើថៅប៊ីដាំដំណាំនៅឯណា?**

**២- តើតាប៉ុំបោះអ្វី?**

**៣- ហេតុអ្វីបានជាថៅប៊ីដាំដំណាំ? ដាំដំណាំអ្វីខ្លះ?**

**៤- តើកូនធ្លាប់ដាំដំណាំអ្វីដែរឬទេ? តើកូនដាំវាដូចម្ដេច?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ប៊ីយេរ** **ប ៊ ី យ េ រ** រួចសរសេរ **ប៊ីយេរ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **តាប៉ុំ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **សាប៊ូ ថៅប៊ី តាប៉ូ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **សុំសាប៊ូ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៣៨ | ស៊ | ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន (៥នាទី)

- គ្រូរំឭកពាក្យដែលបានរៀនរួច **សាប៊ូ ចៃប៊ី តាំ ប៉ៃ ពុំរ៉ៃ**។

## ១- ការស្គាល់សូរអក្សរថ្មី (៥នាទី)

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **កៅស៊ូ**។ គ្រូបន្លឺ **ស៊ូ**។ **តើស៊ូ មានសូរដើមអ្វី? ស៊**។ គ្រូបន្លឺ **ស៊** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ស៊** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ស៊** រួមគ្នា។ |

## ២- ការស្គាល់តួអក្សរថ្មី (៥នាទី)

- **អក្សរ ស មិនទាន់មានសូរគូ។ ដើម្បីឱ្យវាមានសូរគូ យើងត្រូវបន្ថែមសញ្ញាត្រីសព្ទ ឬ សក់ ក ទៅលើ ស (ស៊)។**

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **ស៊** ធំៗ លើក្តារខៀន រួចចង្អុលនិងអានជាគំរូ **ស ត្រីសព្ទ ស៊** ។ |
| គ្រូនិងសិស្ស | - អាន **ស ត្រីសព្ទ ស៊** រួមគ្នា។ |
| សិស្ស | - អាន **ស ត្រីសព្ទ ស៊** ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ (១៨នាទី)

### ៣.១ - ការអានព្យាង្គ

ក- ករណីទូទៅ

| | |
|---|---|
| គ្រូ | - សរសេរ **ស៊ា** លើក្តារខៀនរួចចង្អុលនិងអាន **ស៊ អ៊ា ស៊ា** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ស៊ុះ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ស៊ែ** ដោយផ្សំប្រកប។ |

ខ- ករណីមូសិកទន្តប្តូរមកបុកជើង ( ុ )

- គ្រូប្រាប់ថា **ចំពោះស្រះ៦តួគឺស្រះ ិ ី ឹ ឺ ើ ាំ សញ្ញាត្រីសព្ទ ( ៊ ) ត្រូវប្តូរមកជា បុកជើងវិញ ( ុ )**។

| | |
|---|---|
| គ្រូ | - សរសេរ **ស៊ី** លើក្តារខៀនរួចចង្អុលនិងអាន **ស៊ អ៊ី ស៊ី**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ស៊ុំ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ស៊ើ** ដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១និង២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

- គ្រូពន្យល់ទៀតថាចំពោះស្រះ ូ ឿ ៀ **មិនចាំបាច់ប្រើសញ្ញាត្រីសព្ទ ឬសក់ក ( ៊ ) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ**។

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **សាប៊ូ** លើក្តារខៀនរួចចង្អុលនិងអាន **ស អា សា ប៊ អ៊ូ ប៊ូ សាប៊ូ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ស៊ូ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ភាស៊ី** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- តស៊ូ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **តស៊ូ មានន័យថា ខំប្រឹង ព្យាយាម ស៊ូទ្រាំ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ តស៊ូ ។ ប៉ាស៊ីតស៊ូទៅសាលារៀន។** |
| គ្រូនិងសិស្ស | - អានពាក្យ **តស៊ូ** រួមគ្នា។ គ្រូផ្ដើម **កូនត្រូវ...រៀនសូត្រ។** សិស្សថា **តស៊ូ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **តស៊ូ** បង្កើតល្បះដោយប្រើប្រាស់ពាក្យ **តស៊ូ** ជាដៃគូ។ |

ខ- ភាស៊ី បង្រៀនដូចពាក្យខាងលើ។ **ភាស៊ី មានន័យថា ពន្ធទំនិញ។ ឧ. អ្នកលក់ដូរទាំងអស់ត្រូវបង់ភាស៊ីឱ្យរដ្ឋ។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **យោធាតស៊ូការពារដីកោះ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **យោធា/តស៊ូ/ការពារ/ដី/កោះ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **យោធាតស៊ូការពារដីកោះ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **យោធាតស៊ូការពារដីកោះ។** |
| សិស្ស | - សិស្សអានល្បះ **យោធាតស៊ូការពារដីកោះ។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនរណាទៅសាលាជាមួយប៉ាស៊ី?**

**២- តើប៉ាស៊ីទារយកអ្វីពីថៅស៊ា?**

**៣- តើកូនគិតថាហេតុអ្វីបានជាប៉ាស៊ីទារយកកៅស៊ូពីថៅស៊ា?**

**៤- តើកូនធ្លាប់យកកៅស៊ូកងធ្វើអ្វីខ្លះ?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ស៊ូ ស ៊ ូ** រួចសរសេរ **ស៊ូ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **តស៊ូ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ភាស៊ី ស៊ាំ កៅស៊ូ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **តស៊ូការងារ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## មេរៀនទី៣៩ ហ៊ 🕒 ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន 🕒 ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **កៅស៊ូ ភាស៊ី សាប៊ូ ថៅប៊ី តវ៉ា**។

### ១- ការស្គាល់សូរអក្សរថ្មី 🕒 ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ហ៊ោ**។ គ្រូបន្លឺ **ហ៊ោ**។ **តើ ហ៊ោ មានសូរដើមអ្វី?** ហ៊។ គ្រូបន្លឺ **ហ៊** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ហ៊** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ហ៊** រួមគ្នា។ |

### ២- ការស្គាល់តួអក្សរថ្មី 🕒 ៥នាទី

- **អក្សរ ហ មិនទាន់មានសូរគូ។ ដើម្បីឱ្យវាមានសូរគូ យើងត្រូវបន្ថែមសញ្ញាត្រីសព្ទ ឬ សក់ ក ទៅលើ ហ (ហ៊)**។

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **ហ៊** ធំៗ លើក្ដារខៀន រួចចង្អុលនិងអានជាគំរូ **ហ ត្រីសព្ទ ហ៊** ។ |
| គ្រូនិងសិស្ស | - អាន **ហ ត្រីសព្ទ ហ៊** រួមគ្នា។ |
| សិស្ស | - អាន **ហ ត្រីសព្ទ ហ៊** ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន។

### ៣- ការអានព្យាង្គនិងពាក្យ 🕒 ១៨នាទី

**៣.១ - ការអានព្យាង្គ**

ក- ករណីទូទៅ

| | |
|---|---|
| គ្រូ | - សរសេរ **ហ៊ា** លើក្ដារខៀនរួចចង្អុលនិងអាន **ហ៊ អា ហ៊ា** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ហ៊ូ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ហ៊ៅ** ដោយផ្សំប្រកប។ |

ខ- ករណីមូសិកទន្តប្ដូរមកបុកជើង ( ុ )

- គ្រូប្រាប់ថា **ចំពោះស្រៈ៦តួគឺស្រៈ ិ ី ឹ ឺ ើ ំ សញ្ញាត្រីសព្ទ ( ៊ ) ត្រូវប្ដូរមកជា បុកជើងវិញ ( ុ )**។

| | |
|---|---|
| គ្រូ | - សរសេរ **ហុិ** លើក្ដារខៀនរួចចង្អុលនិងអាន **ហ៊ អិ ហុិ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ហ៊ោ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ហុី** ដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១និង២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

- គ្រូពន្យល់ទៀតថាចំពោះស្រៈ ួ ឿ ៀ **មិនចាំបាច់ប្រើសញ្ញាត្រីសព្ទ ឬសក់ក ( ៊ ) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ**។

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **តៅហ៊ូ** លើក្ដារខៀនរួចចង្អុលនិងអាន **ត អៅ តៅ ហ៊ អូ ហ៊ូ តៅហ៊ូ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **តាហុី** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ហុឹហា** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ 🕒 ៨នាទី

ក- តៅហ៊ូ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **តៅហ៊ូ មានន័យថា ចាហួយធ្វើដោយម្សៅសណ្ដែក។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ តៅហ៊ូ ។ ប្អូនចង់ញ៉ាំតៅហ៊ូ។** |
| គ្រូនិងសិស្ស | - អានពាក្យ **តៅហ៊ូ** រួមគ្នា។ គ្រូផ្ដើម **ខ្ញុំចូលចិត្តញ៉ាំ...។** សិស្សថា **តៅហ៊ូ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **តៅហ៊ូ** បង្កើតល្បះដោយប្រើប្រាស់ពាក្យ **តៅហ៊ូ** ជាដៃគូ។ |

ខ- ហ៊ឺហា បង្រៀនដូចពាក្យខាងលើ។ **ហ៊ឺហា មានន័យថា លេងខ្លួន។ ឧ. តារាចម្រៀងតែងខ្លួនហ៊ឺហា។**

## ៥- ការអានល្បះ 🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **តាប៊ីពិសាតៅហ៊ូ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **តាប៊ី/ពិសា/តៅហ៊ូ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **តាប៊ីពិសាតៅហ៊ូ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **តាប៊ីពិសាតៅហ៊ូ។** |
| សិស្ស | - សិស្សអានល្បះ **តាប៊ីពិសាតៅហ៊ូ។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី 🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូហ៊ុំពូកែធ្វើអ្វីខ្លះ?**

**២- តើចៅហ៊ីទះដៃហ៊ោសរសើរនរណា?**

**៣- ហេតុអ្វីបានជាចៅហ៊ីថាពូហ៊ុំពូកែធាតៅហ៊ូ?**

**៤- តើកូនចូលចិត្តតៅហ៊ូដែរឬទេ? ព្រោះអ្វី?**

## ៧- ការសរសេរ 🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ហ៊ោ ហ ៊ ោ** រួចសរសេរ **ហ៊ោ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ហ៊ី ហ** ៊ ី រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **តៅហ៊ូ ហ៊ឺហា ហ៊ូ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ធាតៅហ៊ូ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ 🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## មេរៀនទី៤០ អ៊ ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **តៅហ៊ូ ហ៊ោ កៅស៊ូ ភាស៊ី ថៅប៊ី**។

### ១- ការស្គាល់សូរអក្សរថ្មី ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **រអ៊ូ**។ គ្រូបន្លឺ **អ៊ូ**។ **តើ អ៊ូ មានសូរដើមអ្វី? អ៊**។ គ្រូបន្លឺ **អ៊** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **អ៊** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **អ៊** រួមគ្នា។ |

### ២- ការស្គាល់តួអក្សរថ្មី ៥នាទី

- **អក្សរ អ មិនទាន់មានសូរគូ។ ដើម្បីឱ្យវាមានសូរគូ យើងត្រូវបន្ថែមសញ្ញាត្រីសព្ទ ឬ សក់ ក ទៅលើ អ (អ៊)** ។

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **អ៊** ធំៗ លើក្ដារខៀន រួចចង្អុលនិងអានជាគំរូ **អ ត្រីសព្ទ អ៊** ។ |
| គ្រូនិងសិស្ស | - អាន **អ ត្រីសព្ទ អ៊** រួមគ្នា។ |
| សិស្ស | - អាន **អ ត្រីសព្ទ អ៊** ដោយខ្លួនឯង។ |

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន។

### ៣- ការអានព្យាង្គនិងពាក្យ ១៨នាទី

#### ៣.១ - ការអានព្យាង្គ

ក- ករណីទូទៅ

| | |
|---|---|
| គ្រូ | - សរសេរ **អ៊ំ** លើក្ដារខៀនរួចចង្អុលនិងអាន **អ៊ អ៊ំ អ៊ំ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **អ៊ោ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **អ៊ូ** ដោយផ្សំប្រកប។ |

ខ- ករណីមូសិកទន្តប្ដូរមកបុកជើង ( ◌ុ )

- គ្រូប្រាប់ថា **ចំពោះស្រះ៦តួគឺស្រះ** ◌ិ ◌ី ◌ឹ ◌ឺ ◌ើ ◌ំ **សញ្ញា ត្រីសព្ទ (** ◌៊ **) ត្រូវប្ដូរមកជា បុកជើងវិញ (** ◌ុ **)**។
- ចំណាំ : មានករណីលើកលែងមួយចំនួនដូចជា អ៊ីចឹង អ៊ិកអ៊ាក អ៊ឹកអធឹក ...។

| | |
|---|---|
| គ្រូ | - សរសេរ **អុិ** លើក្ដារខៀនរួចចង្អុលនិងអាន **អ៊ អុិ អុិ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **អុី** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **អុើ** ដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១និង២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

- គ្រូពន្យល់ទៀតថាចំពោះស្រៈ ◌ួ ◌ឿ ◌ៀ **មិនចាំបាច់ប្រើសញ្ញាត្រីសព្ទ ឬសក់ក (** ◌៊ **) ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ**។

#### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **រអ៊ូ** លើក្ដារខៀនរួចចង្អុលនិងអាន **រ អ៊ អ៊ូ អ៊ូ រអ៊ូ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **អ៊ូអរ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **តាអ៊ូ** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- អ៊ូអរ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **អ៊ូអរ មានន័យថា ទីដែលមានមនុស្សជួបជុំច្រើន ឈូឆរដោយមានអំណរ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ អ៊ូអរ។ នៅផ្សារមានមនុស្សអ៊ូអរ។** |
| គ្រូនិងសិស្ស | - អានពាក្យ **អ៊ូអរ** រួមគ្នា។ គ្រូផ្ដើម **ក្មេងៗលេង...នៅសួនកុមារ។** សិស្សថា **អ៊ូអរ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **អ៊ូអរ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **អ៊ូអរ** ជាដៃគូ។ |

ខ- រអ៊ូ បង្រៀនដូចពាក្យខាងលើ។ **រអ៊ូ មានន័យថា សូរឮអ៊ូៗរឿយៗមិនច្បាស់ជាថាអ្វី។ ឧ. កូនៗនៅតុខាងក្រោយខ្សឹបគ្នា រអ៊ូ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ទីនេះអ៊ូអរ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ទីនេះ/អ៊ូអរ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ទីនេះអ៊ូអរ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ទីនេះអ៊ូអរ។** |
| សិស្ស | - សិស្សអានល្បះ **ទីនេះអ៊ូអរ។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើចៅអ៊ានាំជាទៅទីណា?**

**២- ហេតុអ្វីបានជាអ៊ំអួ ឈររអ៊ូ?**

**៣- តើកូនគិតថាមុននឹងស៊ីនំ ជាបានសុំអ៊ំអួឬទេ? ហេតុអ្វី?**

**៤- តើកូនគួរយករបស់អ្នកដទៃដោយមិនមានការអនុញ្ញាតឬទេ? ព្រោះអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **រអ៊ូ រ អ ិ ូ** រួចសរសេរ **រអ៊ូ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **អ៊ូអរ អ ិ ូ អ រ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **អ៊ំ តាអ៊ូ អ៊ូអែ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ឈររអ៊ូរទាំ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## មេរៀនសាឡើងវិញ ប ស ហ អ ⌚ ៨០នាទី

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូអនុវត្តសកម្មភាពលំនឹងថ្នាក់ដូចមេរៀនមុនៗ។

## ១ -ការអានពាក្យ ⌚ ១៨នាទី

| | |
|---|---|
| សិស្ស | - អានពាក្យ **សាប៊ូ... រហូតដល់ ហ៊ីហា** ក្នុងសៀវភៅសិក្សាគោលដោយមិនបាច់ផ្សំប្រកប ជាដៃគូ។ |

## ២- វាក្យសព្ទ ⌚ ៨នាទី

ក -ហ៊ីហា

| | |
|---|---|
| គ្រូ | - សួរសិស្សថា **តើពាក្យហ៊ីហា មានន័យដូចម្ដេច? លេងខ្លួន។** ឱ្យសិស្សបង្កើតល្បះជាដៃគូ។ |
| សិស្ស | - អានពាក្យ **ហ៊ីហា** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ហ៊ីហា** ជាដៃគូ។ |

ខ- រអ៊ូ បង្រៀនដូចពាក្យខាងលើ។ **រអ៊ូ មានន័យថា សូរឮអ៊ូៗរឿយៗមិនច្បាស់ជាថាអ្វី។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ចៅប៊ីថាទីនេះអ៊ូអរ**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ចៅប៊ី/ថា/ទីនេះ/អ៊ូអរ។**

| | |
|---|---|
| សិស្ស | - គ្រូចង្អុលឱ្យសិស្សអានល្បះ **ចៅប៊ីថាទីនេះអ៊ូអរ**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦ -ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើអ្នកណាខ្លះពិសាតៅហ៊ូ?**

**២- ហេតុអ្វីអ៊ំពូប៊ីរអ៊ូ?**

**៣- ហេតុអ្វីបានជាអ៊ំពូប៊ីមិនឱ្យញ៉ាំតៅហ៊ូ?**

**៤-តើរបស់ផៅអ្វីខ្លះដែលយើងមិនត្រូវញ៉ាំ?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **កៅស៊ូ ក េា ស ូ** រួចសរសេរ **កៅស៊ូ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ហ៊ីហា ហ ុ ី ហ ា** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **សាប៊ូ តៅហ៊ូ អ៊ូអរ** ។ ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **សាប៊ូពីរដុំ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

# លំនាំបង្រៀន

# មេរៀនប្រកប

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**គន្លឹះត្រូវចងចាំ**

- ✓ គ្រប់សកម្មភាពត្រូវអនុវត្តទៅតាមលំនាំក្នុងសៀវភៅណែនាំគ្រូនិងប្រើប្រាស់ពាក្យពេចន៍ជាអក្សរដិត។
- ✓ ក្នុងពេលអាន សិស្សត្រូវប្រើភ្នែក និងចង្អុលដៃទៅតាមតួអក្សរ។
- ✓ គ្រូត្រូវដើរតាមតុសិស្ស ស្តាប់សិស្សអានជាដៃគូ និងជួយកែតម្រូវសិស្សណាអានមិនទាន់ត្រឹមត្រូវ។
- ✓ ប្រសិនបើសិស្សណាលំបាកអាន គ្រូត្រូវជួយសិស្សនោះ។ គ្រូអាចអានពាក្យជាគំរូ អានពាក្យនោះម្តងទៀតជាមួយសិស្ស និងឱ្យសិស្សអានពាក្យនោះខ្លួនឯងម្តងទៀត។
- ✓ ប្រសិនបើសិស្សភាគច្រើនមានការលំបាក គ្រូត្រូវណែនាំឡើងវិញដោយប្រើ វិធីគ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើជាមួយសិស្សទាំងអស់ក្នុងថ្នាក់។
- ✓ សម្រាប់ការបង្រៀនតួអក្សរថ្មី គ្រូត្រូវសរសេរតួអក្សរដែលត្រូវរៀនធំៗលើក្តារខៀន។
- ✓ អនុវត្ត គ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើ ដូចដែលបានលម្អិតក្នុងសៀវភៅណែនាំគ្រូ។
- ✓ គ្រូដើរតាមតុក្នុងថ្នាក់ ពេលគ្រូនិងសិស្សធ្វើ សិស្សធ្វើ ក្នុងគ្រប់សកម្មភាពអាន និងសរសេរដើម្បីជួយសិស្ស។
- ✓ សម្រាប់សកម្មភាពអាន ឱ្យសិស្សអានលើសពីម្តង។
- ប្រសិនបើមានសិស្សខ្សោយគំហើញ និងខ្សោយស្តាប់ រាល់ការបង្ហាញ និងការណែនាំរបស់គ្រូត្រូវប្រាកដថាសិស្សទាំងនោះស្តាប់ឮ និងឃើញច្បាស់។
- គ្រូប្រើប័ណ្ណពាក្យ ល្បះសម្រាប់សិស្សខ្សោយស្តាប់ និងខ្សោយគំហើញ។

## លំនឹងថ្នាក់ និង រំឭកមេរៀន ⌚ ៥នាទី

- ◎ រំឭកពាក្យដែលបានរៀន
- ប័ណ្ណពាក្យ ក្តារឆ្នួន
- ⌚ ៥ នាទី

គ្រូសរសេរពាក្យ **អ៊ូអរ អ៊ើ ហ៊ោ តៅហ៊ូ ភាស៊ី** មួយម្តងៗ ឱ្យសិស្សអាន ឬហៅឱ្យសិស្សសរសេរលើក្តារឆ្នួន ហើយអាន។

គ្រូកែតម្រូវសិស្សដែលអាន ឬសរសេរមិនបានត្រឹមត្រូវ។

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥ នាទី

ការប្រកបសូរដោយប្រើដៃជាជំនួយ

- ◎ កំណត់សូរព្យាង្គ ឬពាក្យថ្មី ប្រកបនឹង ក
- សម្ភារៈ
- ⌚ ៥ នាទី

គ្រូប្រាប់សិស្សថា **ថ្ងៃនេះយើងនឹងរៀនសូរថ្មីដែលប្រកបនឹង "ក"**។

គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរនៃពាក្យ (សូរអក្សរថ្មី)។

- គ្រូ : ធ្វើកាយវិការបកចេក រួចសួរសិស្សថា **តើគ្រូកំពុងធ្វើអ្វី?** (បក) ។ គ្រូថា **បក** ។
- គ្រូ និងសិស្ស : ថា **បក** រួមគ្នា។
- សិស្ស : ថា **បក** ទាំងអស់គ្នា ។

**ពេលនេះយើងនឹងហាត់ប្រកបសូរព្យាង្គដោយដៃជំនួយ។**

- គ្រូ : គ្រូលើកដៃម្ខាងឡើងលើថា **ប** លើកដៃម្ខាងទៀតថា **ក** រួច ផ្គុំបាតដៃទាំងពីរថា **បក** ។
- គ្រូ និងសិស្ស : លើកដៃម្ខាងឡើងលើថា **សា** លើកដៃម្ខាងទៀតថា **ក** រួចផ្គុំដៃទាំងពីរចូលគ្នាថា **សាក**។
- សិស្ស : គ្រូថាពាក្យ **ចូ និង ក ឆៃ និង ក ដេ និង ក** ម្តងមួយៗឱ្យសិស្សអនុវត្តផ្សំសូរដោយប្រើដៃដូចខាងលើ។

**គន្លឹះត្រូវចងចាំ**

★ គ្រូត្រូវបន្លឺសូរដែលត្រូវរៀនឱ្យបានឮៗ និងច្បាស់ៗ។

★ មានវិធីជាច្រើនយ៉ាង ក្នុងការបំផុសរកពាក្យថ្មី ក្នុងនោះរួមមាន ការលើកឧទាហរណ៍ ការពិពណ៌នា ការបង្ហាញវត្ថុជាក់ស្តែង ការបង្ហាញរូបភាព និងការធ្វើកាយវិការ។ល។ ការធ្វើកាយវិការត្រូវបានលើកទឹកចិត្តឱ្យគ្រូប្រើញឹកញាប់ ព្រោះវាអាចជួយឱ្យមានអន្តរកម្មរវាងគ្រូ និងសិស្ស សិស្សនិងសិស្ស ។

★ លើកទឹកចិត្តសិស្សឱ្យលើកដៃប្រកបព្យាង្គ និងពាក្យ ដូចដែលគ្រូបានធ្វើឱ្យមើល ដើម្បីឱ្យពួកគេធ្វើ ចលនាដៃគ្រប់គ្នា និងផ្តល់អារម្មណ៍ក្នុងសកម្មភាពរៀន។

✓ ពិនិត្យមើលពេលសិស្សប្រកប ដើម្បីដឹងថាសិស្សណាខ្លះបន្លឺសូរប្រកប និងអានពាក្យបានត្រឹមត្រូវ សិស្សណាខ្លះដែលត្រូវការជួយបន្ថែម។

✓ បង្រៀនទៅតាមពេលវេលាដែលបានកំណត់ ក្នុងសៀវភៅណែនាំគ្រូក្នុងសកម្មភាពណែនាំឱ្យសិស្សស្គាល់សូរអក្សរថ្មី។

☞ ត្រូវប្រាកដថា សិស្សអាចមើលឃើញគ្រូច្បាស់។ គ្រូទាញចំណាប់អារម្មណ៍សិស្សមើលគ្រូនិងចូលរួមអនុវត្តសកម្មភាព។ ខណៈពេលដែលគ្រូប្រកបសូរ និងអានពាក្យ។

## ២- ការស្គាល់តួអក្សរថ្មី ⏲ ៥នាទី

◎ ប្រកបព្យញ្ជនៈពួក « អ » ប្រកបនឹង ក ដើម្បីអានព្យាង្គ

🗐 ប័ណ្ណអក្សររូបភាព ឬប័ណ្ណអក្សរដែលសរសេរលើក្រដាស A4

⏲ ៥នាទី

ក- បក

**មុននេះយើងទើបនឹងបានឮសូរ បក ឥឡូវយើងនឹងរៀនពីរូបរាងរបស់វា។**

- គ្រូ : សរសេរ **បក** លើក្តារខៀន។ គ្រូអានដោយចង្អុលចំតួអក្សរហើយប្រកបឮៗ **ប នឹង ក បក**។
- សិស្ស និងគ្រូ : អាន **ប និងក បក**។
- សិស្ស : អាន **ប និងក បក**។

ខ- សាក

- គ្រូ : សរសេរ **សាក** លើក្តារខៀន។ គ្រូអានដោយចង្អុលចំតួអក្សរហើយប្រកបឮៗ **ស អា សា និង ក សាក**។
- សិស្ស និងគ្រូ : អាន **ស អា សា និងក សាក**។
- សិស្ស : អាន **ស អា សា និងក សាក**។

គ- គ្រូ ចង្អុល ៖

- **បក អានថា បក ។ សាក អានថា សាក**។
- **តើព្យាង្គ បក និងសាក មានអក្សរអ្វីនៅខាងចុង ?** (មាន ក)។ **ក នេះហើយជាតួដែលត្រូវ ប្រកប។ ការប្រកបគឺជាការផ្សំបញ្ចូលគ្នារវាងសូរព្យញ្ជនៈ ស្រៈ ព្យញ្ជនៈឱ្យទៅជាព្យាង្គ ឬពាក្យ ដែលមានសូរលោយចូលគ្នាតែមួយ។**

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

- គ្រូសរសេរចំណងជើងមេរៀនប្រកបនឹង ក លើក្ដារខៀន។

## ៣- ការអានព្យាង្គ និងពាក្យ ◷ ១៨នាទី

៣.១ - ការអានព្យាង្គ

៣.១.១- ការអានព្យាង្គ (ស្រៈកប់តួ)

◎ អានព្យាង្គប្រកបនឹង ក

🗐 សៀវភៅជំនួយសិស្ស

◷ ៨នាទី

- គ្រូ : សរសេរ **ខក** លើក្ដារខៀន។ គ្រូអាន **ខ និង ក ខក** ដោយចង្អុលចំតួអក្សរ និងព្យាង្គ។
- គ្រូ និងសិស្ស : គ្រូសរសេរ **ចក** លើក្ដារខៀន។ គ្រូ និងសិស្សអាន **ច និង ក ចក** ដោយចង្អុលចំតួអក្សរ និងព្យាង្គ។
- សិស្ស :
  - គ្រូសរសេរ **ជក** លើក្ដារខៀន។ គ្រូចង្អុល រួចសិស្សអាន **ជ និង ក ជក** ដោយចង្អុលចំតួអក្សរ និងព្យាង្គ។ ធ្វើដូចគ្នាចំពោះ **សក កក**។
  - អានព្យាង្គទាំងអស់ក្នុងតារាងទី១ជាដៃគូក្នុងសៀវភៅជំនួយសិស្ស ដោយចង្អុលចំតួអក្សរនីមួយៗ និងព្យាង្គ។

៣.១.២- ការអានព្យាង្គ (ស្រៈនិស្ស័យ)

- គ្រូ : សរសេរ **កាក** លើក្ដារខៀន។ គ្រូអាន **ក អា កា និង ក កាក** ដោយចង្អុលចំតួអក្សរនីមួយៗ និងព្យាង្គ។
- គ្រូ និងសិស្ស : គ្រូសរសេរ **ចូក** លើក្ដារខៀន។ គ្រូ និងសិស្សអាន **ច អូ ចូនិង ក ចូក** ដោយចង្អុលចំតួអក្សរ។
- សិស្ស :
  - គ្រូសរសេរ **ដែក** លើក្ដារខៀន។ គ្រូចង្អុល រួចសិស្សអាន **ដ អែ ដែ និង ក ដែក**។ ធ្វើដូចគ្នាចំពោះ **បើក ចុក**។
  - អានព្យាង្គទាំងអស់ក្នុងតារាងទី២ជាដៃគូក្នុងសៀវភៅជំនួយសិស្ស ដោយចង្អុលចំតួអក្សរនីមួយៗ និងព្យាង្គ។

៣.២- ការអានពាក្យ

◎ អានពាក្យដោយផ្សំប្រកប

🗐 សៀវភៅជំនួយសិស្ស

◷ ១០ នាទី

- គ្រូ : សរសេរ **ចចក** លើក្ដារខៀន។ គ្រូអាន **ច ច និងក ចក ចចក** ដោយចង្អុលឱ្យចំតួអក្សរនីមួយៗ និងចំពាក្យ។
- គ្រូ និងសិស្ស : គ្រូសរសេរ **របើក** លើក្ដារខៀន។ គ្រូ និងសិស្សអាន **រ ប អើ បើ និងក បើក របើក**។
- សិស្ស : គ្រូសរសេរ **អំបុក** លើក្ដារខៀន។ គ្រូចង្អុល រួចសិស្សអានដោយចង្អុល **អ អំ អំ ប អុ បុ និងក បុក អំបុក**។ អានពាក្យទាំងអស់ក្នុងតារាងទី៣ជាដៃគូក្នុងសៀវភៅជំនួយសិស្ស ដោយចង្អុលឱ្យចំតួអក្សរនីមួយៗ និងចំពាក្យ។

## ៤- វាក្យសព្ទ ◷ ៨នាទី

◎ យល់ន័យនៃពាក្យពិបាកតាមរយៈការបង្កើតល្បះដោយផ្ទាល់មាត់

🗐 សៀវភៅសិក្សាជំនួយសិស្ស

◷ ៨នាទី

- រាំឡក

▪ គ្រូ : សរសេរពាក្យ **រាំឡក** លើក្ដារខៀន រួចអាន និងពន្យល់ន័យ។ ក្នុងករណីពាក្យត្រូវពន្យល់មានសរសេរលើក្ដារខៀនម្ដងហើយ គ្រាន់តែគូសវង់លើពាក្យនោះក៏បាន។ **រាំឡក មានន័យថា រាំធ្វើមុខក្រមិចក្រមើម ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ រាំឡក។ ពូតេវចេះ រាំឡក គួរឱ្យចង់សើច។**
▪ គ្រូ និងសិស្ស : អានពាក្យ **រាំឡក** រួមគ្នា។ **ឥឡូវនេះយើងនឹងបង្កើតល្បះមួយ រួមគ្នាដោយប្រើពាក្យ រាំឡក ដោយគ្រូជាអ្នកផ្ដើម ហើយកូនៗជាអ្នកបំពេញ ពេលគ្រូបង្ហាក់បន្តិច។** គ្រូថា **សុភាចូលចិត្តមើលគេ ... ធៃយ៉ាំ។** សិស្សថា **រាំឡក ។ ឥឡូវនេះយើងថាល្បះឡើងវិញទាំងអស់គ្នា : សុភាចូលចិត្តមើលគេរាំឡកធៃយ៉ាំ។**
▪ **សិស្ស** : អានពាក្យ **រាំឡក** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **រាំឡក** ជាដៃគូ។

- ចំណែក
    ▪ គ្រូ : សរសេរពាក្យ **ចំណែក** លើក្ដារខៀន រួចអាន និងពន្យល់ន័យ។ **ចំណែក មានន័យថា ភាគដែលចែករួចហើយ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ចំណែក។ ឧ. ម៉ែពុះនំជាចំណែកស្មើៗគ្នា ចែកឱ្យកូនៗ។**
    ▪ គ្រូ និងសិស្ស :អានពាក្យ **ចំណែក** រួមគ្នា។ **ឥឡូវនេះយើងនឹងបង្កើតល្បះមួយ រួមគ្នាដោយប្រើពាក្យ ចំណែក ដោយគ្រូជាអ្នកផ្ដើម ហើយកូនៗជាអ្នកបំពេញ ពេលគ្រូបង្ហាក់បន្តិច។** គ្រូថា **សុភាចែកនំជា ...ដល់មិត្តភក្តិ។** សិស្សថា **ចំណែក។ ឥឡូវនេះយើងនឹងថាល្បះឡើងវិញទាំងអស់គ្នា : សុភាចែកនំជាចំណែកដល់មិត្តភក្តិ ។**
    ▪ **សិស្ស** : អានពាក្យ **ចំណែក** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ចំណែក** ជាដៃគូ។

**គន្លឹះត្រូវចងចាំ**

✓ សម្រាប់ការបង្រៀនវាក្យសព្ទ គ្រូត្រូវដើរតាមតុ ស្ដាប់សិស្សបង្កើតល្បះជាមួយដៃគូ។
✓ សកម្មភាពនេះទាមទារឱ្យសិស្សស្គាល់សូរ ចេះអានពាក្យយល់ន័យពាក្យ ចេះប្រើប្រាស់ពាក្យបានត្រឹមត្រូវ។ គ្រូ និងសិស្សបង្កើតល្បះដោយផ្ទាល់មាត់ ពុំមានការសរសេរទេ។
✓ ពេលសិស្សបង្កើតល្បះ គ្រូស្ដាប់ហើយសួរបញ្ជាក់ បើល្បះនោះមិនទាន់មានន័យគ្រប់គ្រាន់។
✓ គ្រូត្រូវដើរទៅជិតសិស្ស នៅពេលគ្រូពន្យល់ និងបង្កើតល្បះជាឧទាហរណ៍ដល់សិស្ស។

## ៥- ការអានល្បះ ⏱ ៥ នាទី

◎ អានស្ទាត់ និងយល់អត្ថន័យល្បះ
▤ សៀវភៅសិក្សាគោល
⏱ ៥ នាទី

ក -គ្រូបង្ហាញរូបភាពទាក់ទងនឹងល្បះ ប្រសិនបើមាន។

ខ -គ្រូសរសេរល្បះ **សេកចឹកចេកទុំស៊ីលើសំបុក។** លើក្ដារខៀន។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ ?** ពេលសិស្សឆ្លើយ គ្រូគូសសញ្ញា ( / ) លើល្បះដើម្បីញែកពាក្យ **សេក/ចឹក/ចេក/ទុំ/ស៊ី/លើ/សំបុក។**

គ- គ្រូនាំសិស្សហ្វឹកហាត់អាន៖

▪ គ្រូ : អានល្បះ **សេកចឹកចេកទុំស៊ីលើសំបុក។**
▪ គ្រូ និងសិស្ស : អានល្បះរួមគ្នា **សេកចឹកចេកទុំស៊ីលើសំបុក។**
▪ សិស្ស : អានល្បះទាំងអស់គ្នា **សេកចឹកចេកទុំស៊ីលើសំបុក។**

ឃ- គ្រូសួរសំណួរដែលផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់សិស្ស ដើម្បីឱ្យសិស្សយល់ពីអត្ថន័យនៃល្បះ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

ចំណាំ : សម្រាប់មេរៀនប្រកប ដែលមានបន្តក់ គ្រូឱ្យសិស្សអានល្បះនៅលើក្តារខៀន។ បន្ទាប់មក អានល្បះទាំងអស់ក្នុងសៀវភៅសិក្សាគោល។

**គន្លឹះត្រូវចងចាំ**

- ✓ គ្រូស្រង់ល្បះមួយ ពីក្នុងសៀវភៅសិក្សាគោល។ ប្រសិនបើមានរូបភាពក្នុងសៀវភៅនោះ គ្រូលើករូបភាពបង្ហាញ ដើម្បីបំផុសសំណួរដែលទាក់ទងនឹងល្បះដែលត្រូវរៀន។
- ✓ គ្រូឱ្យសិស្សប្រាប់ពាក្យពិបាក (បើមាន) ។

## ៦- ការអានអត្ថបទខ្លី ⏱ ១២ នាទី

◎ អានស្ទាត់និងយល់អត្ថន័យនៃអត្ថបទទាំងមូល

📄 សៀវភៅជំនួយសិស្ស អត្ថបទខ្លី អំបុក (មេរៀន **ប្រកបនឹង ក**)

⏱ ១២ នាទី

ក- គ្រូសួរសំណួរទាក់ទងនឹងរូបភាព។ រួចប្រាប់ចំណងជើងអត្ថបទ។

ខ- គ្រូឱ្យសិស្សទស្សន៍ទាយសាច់រឿងថា : **តើរឿងនេះនិយាយអំពីអ្វី ?**

គ- អានអត្ថបទខ្លី

- គ្រូ : អានរឿងយឺតៗ ដោយលើកដាក់សំឡេងគោរពតាមឃ្លា ល្បះ ក្នុងសាច់រឿង។
- គ្រូនិងសិស្ស : អានរួមគ្នា។ គ្រូណែនាំសិស្សយកចង្អុលដៃអូសពីក្រោមពាក្យនៅពេលអាន។
- សិស្ស : ហ្វឹកហាត់អានជាដៃគូ ដោយប្តូរវេនគ្នា ម្នាក់ជាអ្នកចង្អុល ម្នាក់ទៀតជាអ្នកអាន រួចអានជាបុគ្គល។ ប្រសិនបើមានពេល ឱ្យសិស្សអានឱ្យបានច្រើនដង។

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរម្តងមួយៗ ដោយទុកពេលឱ្យសិស្សគិត (បើរកចម្លើយមិនឃើញ គ្រូ និងសិស្សអានអត្ថបទរឿងឡើងវិញ)។

**១- តើចចកនាំកុកធ្វើអ្វី ?**

**២- តើសេកចឹកចេកទុំនៅឯណា ?**

**៣- តើកូនគិតថា សត្វទាំងអស់ក្នុងរឿងរីករាយឬទេ ?ព្រោះអ្វី ?**

**៤- ក្រៅពីសត្វក្នុងរឿងនេះ តើកូនស្គាល់សត្វអ្វីខ្លះ ?**

**គន្លឹះត្រូវចងចាំ**

- ★ សកម្មភាពគ្រូធ្វើ គ្រូត្រូវអានស្ទាត់ជាគំរូដល់សិស្ស។
- ✓ សកម្មភាពគ្រូនិងសិស្សធ្វើ គ្រូនិងសិស្សត្រូវអានរួមគ្នា (មិនមែនសិស្សអានតាមគ្រូទេ)។
- ✓ សម្រាប់សំណួរ ដែលមានចម្លើយលើសពីមួយទុកពេលសមល្មមឱ្យសិស្សប្រើបទពិសោធ ឬគំនិតផ្ទាល់ខ្លួនពិភាក្សាជាដៃគូ។
- ✓ ប្តូរសំណួរតែរក្សាន័យដដែល ពេលដែលសិស្សស្តាប់សំណួរគ្រូមិនយល់។
- ✓ ជួយសិស្ស ដោយប្រើសំណួរប្រដេញ ប្រសិនបើពួកគេនៅតែមិនទាន់យល់សំណួរ។

## ៧- ការសរសេរ ◷ ១៦នាទី

៧.១- ការសរសេរពាក្យ

◎ សរសេរព្យាង្គ និងពាក្យ

🗐 ក្ដារឆ្នួន សៀវភៅកិច្ចការសិស្ស និងសៀវភៅសិក្សាគោល (**មេរៀនទី៤២ ប្រកបនឹង ក ក់**)

◷ ១១ នាទី

- គ្រូ : គ្រូបន្លឺពាក្យ **ចំណែក** ។ គ្រូគិត និងថាឮៗ **ចំណែក មាន ច ស្រះ ំ ណ ស្រះ ែ និង ក**។ គ្រូសរសេរ **ចំណែក** លើក្ដារខៀន។
- គ្រូ និងសិស្ស : គ្រូបន្លឺពាក្យ **ដំណេក** ។ គ្រូ និងសិស្សគិត និងថាឮៗ **ដំណេក មាន ដ ស្រះ ំ ណ ស្រះ េ និង ក** រួចសរសេរ **ដំណេក** លើក្ដារខៀន ចំណែកសិស្សសរសេរលើក្ដារឆ្នួន។
- សិស្ស : គ្រូបន្លឺពាក្យ **អំបុក** ។ សិស្សគិត និងថាឮៗ **អំបុក មាន អ ស្រះ ំ ប ស្រះ ុ និង ក** រួចសរសេរពាក្យ **អំបុក** លើក្ដារឆ្នួន។ សិស្សលើកបង្ហាញគ្រូ។ គ្រូសរសេរ **អំបុក** លើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ គ្រូធ្វើដូចគ្នានឹងពាក្យ **អំបុក** ដែរ ចំពោះពាក្យ **បំបែក សំបុក** ។

៧.២- ការសរសេរឃ្លា

◎ សរសេរឃ្លាក្នុងសៀវភៅកិច្ចការបានត្រឹមត្រូវ

🗐 ប័ណ្ណពាក្យ

◷ ៥ នាទី

គ្រូប្រាប់សិស្សថា **ពេលនេះយើងនឹងហ្វឹកហាត់សរសេរឃ្លា។ គ្រូនឹងហៅឃ្លាយឺតៗចំនួន៣ដងឱ្យសិស្សសរសេរ។**

ក- គ្រូហៅឃ្លា **ចែកជាចំណែក** គ្រូហៅឃ្លាយឺតៗ ច្បាស់ៗ ចំនួន៣ដង។

ខ- សិស្សសរសេរឃ្លាខាងលើចូលក្នុងសៀវភៅកិច្ចការ។

គ- គ្រូសរសេរឃ្លាលើក្ដារខៀន ឱ្យសិស្សផ្ទៀងផ្ទាត់ និងកែតម្រូវ។

**គន្លឹះត្រូវចងចាំ**

✓ គ្រូថាពាក្យយឺតៗ ច្បាស់ៗ និងសរសេរធំៗ លើក្ដារខៀន ( ឧ. ចំណែក ) ។

✓ នៅពេលគ្រូហៅឱ្យសិស្សសរសេរ គ្រូគួរហៅពាក្យនីមួយៗពី ២-៣ដង ហើយប្រមាណ៣វិនាទីហៅម្ដង។

✓ គ្រូដើរពិនិត្យពេលសិស្សសរសេរ ហើយជួយកែតម្រូវនៅពេលដែលកំពុងសរសេរ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

- គ្រូពង្រឹង ឬពង្រីកចំណេះដឹងរបស់សិស្សលើការអាន និងការសរសេរ៖
  - ការអាន៖ ឧទាហរណ៍: គ្រូប្រើប័ណ្ណអក្សរ ឬប័ណ្ណពាក្យដែលសិស្សបានរៀន ឱ្យសិស្សអាន ឬឱ្យក្រុមសិស្សរៀបតួអក្សរឱ្យបានជាពាក្យ ឬលេងល្បែងសិក្សានានា...ដែលសំដៅដល់ការពង្រឹង ឬពង្រីកចំណេះដឹងដល់សិស្ស។
  - ការសរសេរ៖ ឧទាហរណ៍: គ្រូអាចហៅពាក្យដែលរៀនរួច ឱ្យសិស្សសរសេរលើក្ដារឆ្នួន ឬសៀវភៅកិច្ចការ...។
- គ្រូដាក់កិច្ចការឱ្យសិស្សធ្វើ៖
  - ឱ្យសិស្សចម្លងស្រៈ ព្យញ្ជនៈ ពាក្យ ឃ្លា ឬល្បះ... ដាក់ក្នុងសៀវភៅសរសេរ។ ( ឱ្យសិស្សចម្លងនៅផ្ទះបើគ្មានពេល ) ដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៤២ក | ប្រកបនឹង □ក (ព្យញ្ជនៈពួកអ) | ⌚ ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបាន រៀនរួច **អ៊ូអរ អេ៊្វ ហ៊ោ តៅហ៊ូ ភាស៊ី** ។

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **បក** ។ គ្រូបន្លឺ **បក** ។ គ្រូនិងសិស្សថា **បក** ។សិស្សថា **បក** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ប** លើកដៃម្ខាងទៀតថា **ក** រួចផ្ដុំបាតដៃទាំងពីរថា **បក** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **សា** លើកដៃម្ខាងទៀតថា **ក** រួចផ្ដុំបាតដៃទាំងពីរថា **សាក**។ |
| សិស្ស | - គ្រូថា **ចូ និង ក ឆៃ និង ក ដេ និង ក** ម្ដងមួយៗឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ។ |

## ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

ក- បក

| | |
|---|---|
| គ្រូ | - សរសេរ **បក** លើក្ដារខៀនរួចចង្អុលនិងអាន **ប និង ក បក**។ |
| គ្រូនិងសិស្ស | - អាន **បក** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **បក** ដោយផ្សំប្រកប។ |

ខ- សាក

| | |
|---|---|
| គ្រូ | - សរសេរ **សាក** លើក្ដារខៀនរួចចង្អុលនិងអាន **ស អា សា និង ក សាក** ។ |
| គ្រូនិងសិស្ស | - អាន **សាក** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **សាក** ដោយផ្សំប្រកប។ |

គ-គ្រូ : **បក អានថា** បក **សាក អានថា** សាក **នៅខាងចុងមាន** ក ។ **ក ជាតួប្រកប នេះជាមេរៀនប្រកបនឹង** ក ។ គ្រូសរសេរចំណងជើងមេរៀនលើក្ដារខៀន ។

## ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **ខក** លើក្ដារខៀនរួចចង្អុលនិងអាន **ខ និង ក ខក** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចក** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ជក សក កក** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **កាក** លើក្ដារខៀនរួចចង្អុលនិងអាន **ក អា កា និង ក កាក** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចូក** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ដែក បើក ចុក** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ចចក** លើក្ដារខៀនរួចចង្អុលនិងអាន **ច ច និង ក ចក ចចក** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **របើក** លើក្ដារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **អំបុក** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- រាំឡក

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ **រាំឡក មានន័យថា រាំធ្វើមុខក្រមិចក្រមើម** ។**គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ រាំឡក**។ **ពូតេវចេះ រាំឡក គួរឱ្យចង់សើច** ។ |
| គ្រូនិងសិស្ស | - អានពាក្យ **រាំឡក** រួមគ្នា។ គ្រូផ្ដើម **សុភាចូលចិត្តមើលគេ** ... **ឆៃយ៉ាំ**។ សិស្សថា **រាំឡក** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **រាំឡក** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **រាំឡក** ជាដៃគូ។ |

ខ-ចំណែក បង្រៀនដូចពាក្យខាងលើ។ **ចំណែក មានន័យថា ភាគដែលចែករួចហើយ។ឧ. ម៉ែពុះនំជាចំណែកស្មើៗគ្នាចែកឱ្យកូនៗ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **សេកចឹកចេកទុំស៊ីលើសំបុក**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **សេក/ចឹក/ចេក/ទុំ/ស៊ី/លើ/សំបុក**។

| | |
|---|---|
| គ្រូ | - គ្រូអាន **សេកចឹកចេកទុំស៊ីលើសំបុក** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **សេកចឹកចេកទុំស៊ីលើសំបុក**។ |
| សិស្ស | - សិស្សអានល្បះ **សេកចឹកចេកទុំស៊ីលើសំបុក**។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើចចកនាំកុកធ្វើអ្វី?**

**២- តើសេកចឹកចេកទុំនៅឯណា?**

**៣- តើកូនគិតថា សត្វទាំងអស់ក្នុងរឿងរីករាយឬទេ?ព្រោះអ្វី?**

**៤- ក្រៅពីសត្វក្នុងរឿងនេះ តើកូនស្គាល់សត្វអ្វីខ្លះ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ចំណែក ច ំ ណ ែ ក** រួចសរសេរ **ចំណែក** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ដំណេក ដ ំ ណ េ ក** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **អំបុក បំបែក សំបុក** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ចែកជាចំណែក** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៤២ខ | ប្រកបនឹង □ក់ (ព្យញ្ជនៈពួកអ) | ⌚ ៨០នាទី |
|---|---|---|

**រំលឹកថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ចចក អំបុក ភាស៊ី តៅហ៊ូ តវ៉ា** ។

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **បក់**។ គ្រូបន្លឺ **បក់**។ គ្រូនិងសិស្សថា **បក់** ។ សិស្សថា **បក់** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ប** លើកដៃម្ខាងទៀតថា **ក បក បន្តក់មួយ** រួចផ្ទុំបាតដៃទាំងពីរថា **បក់** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ដា** លើកដៃម្ខាងទៀតថា **ក ដាក បន្តក់មួយ** រួចផ្ទុំបាតដៃទាំងពីរថា **ដាក់**។ |
| សិស្ស | - គ្រូថា **ចា និង ក ចាក បន្តក់មួយ បា និង ក បាក បន្តក់មួយ កា និង ក កាក បន្តក់មួយ** ម្តងមួយៗ ឱ្យសិស្សផ្ទុំសូរដោយប្រើដៃដូចខាងលើ។ |

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

ក- បក់

| | |
|---|---|
| គ្រូ | - សរសេរ **បក់** លើក្តារខៀនរួចចង្អុលនិងអាន **ប និង ក បក បន្តក់មួយ បក់**។ |
| គ្រូនិងសិស្ស | - អាន **បក់** រួមគ្នាដោយផ្ទុំប្រកប។ |
| សិស្ស | - អាន **បក់** ដោយផ្ទុំប្រកប។ |

ខ- ដាក់

| | |
|---|---|
| គ្រូ | - សរសេរ **ដាក់** លើក្តារខៀនរួចចង្អុលនិងអាន **ដ អា ដា និង ក ដាក បន្តក់មួយ ដាក់**។ |
| គ្រូនិងសិស្ស | - អាន **ដាក់** រួមគ្នាដោយផ្ទុំប្រកប។ |
| សិស្ស | - អាន **ដាក់** ដោយផ្ទុំប្រកប។ |

គ- **សញ្ញា ( ់ ) សម្រាប់កាត់សូរវែងឱ្យខ្លី។ នេះជាមេរៀនប្រកបនឹងក់**។ គ្រូសរសេរចំណងជើងមេរៀនលើក្តារខៀន ។

**៣- ការអានព្យាង្គនិងពាក្យ** ⌚ ១៨នាទី

**៣.១ - ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **ដក់** លើក្តារខៀនរួចចង្អុលនិងអាន **ដ និង ក ដក បន្តក់មួយ ដក់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **សក់** រួចចង្អុលនិងអានរួមគ្នាដោយផ្ទុំប្រកប។ |
| សិស្ស | - អាន **ខក់ តក់ កក់** ដោយផ្ទុំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **ចាក់** លើក្តារខៀនរួចចង្អុលនិងអាន **ច អា ចា និង ក ចាក បន្តក់មួយ ចាក់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **កាក់** រួចចង្អុលនិងអានរួមគ្នាដោយផ្ទុំប្រកប។ |
| សិស្ស | - អាន **ដាក់ សាក់ ចាក់** ដោយផ្ទុំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ឡុកឡាក់** លើក្តារខៀនរួចចង្អុលនិងអាន **ឡ អុ ឡុ និង ក ឡុក ឡ អា ឡា និង ក ឡាក បន្តក់មួយ ឡាក់ ឡុកឡាក់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **បោកបក់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្ទុំប្រកប។ |

| | |
|---|---|
| សិស្ស | - អាន **សំណាក់** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- ដំអក់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ដំអក់ មានន័យថា អែអង់ អេង់។ គ្រូបង្កើតល្បះ សុផាត ដេកដំអក់យូរ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ដំអក់** រួមគ្នា។ គ្រូផ្ដើម **សំណាងអង្គុយ ... លើផ្ទះ**។ សិស្សថា **ដំអក់** រួចថាល្បះពេញលេញរួមគ្នា |
| សិស្ស | - អានពាក្យ **ដំអក់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ដំអក់** ជាដៃគូ។ |

ខ- ដក់ បង្រៀនដូចពាក្យខាងលើ។ **ដក់ មានន័យថា មាននៅ តាំងនៅ។ ឧ. ភ្លៀងធ្លាក់ មានទឹកដក់** ។

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **នារីកក់សក់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **នារី/កក់/សក់**។

| | |
|---|---|
| គ្រូ | - គ្រូអាន **នារីកក់សក់**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **នារីកក់សក់**។ |
| សិស្ស | - សិស្សអាន **នារីកក់សក់**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើចៅណាក់កំពុងចាំនរណា?**

**២- តើចៅចក់កក់សក់ដូចម្ដេច?**

**៣- ហេតុអ្វីបានជាចៅណាក់ប្រាប់ថា កុំកក់សក់ដំអក់យូរពេក?**

**៤ -ហេតុអ្វីបានជាយើងត្រូវកក់សក់?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ឡិកឡក់ ឡ ិ ក ឡ ក ់** រួចសរសេរ **ឡិកឡក់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **បែកបាក់ ប ែ ក ប ា ក ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **កំបាក់ ប៉ាក់ប៉ើក ដំណាក់** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ដេកដំអក់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## មេរៀនទី ៤៣ក ប្រកបនឹង □ក (ព្យញ្ជនៈពួក អ៊ី) ⌚ ៨០នាទី

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបាន រៀនរួច **ដំណាក់ ឡិកឡក់ ដំណេក អំបុក កៅស៊ូ** ។

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **មក**។ គ្រូបន្លឺ **មក**។ គ្រូនិងសិស្សថា **មក** ។ សិស្សថា **មក** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ម** លើកដៃម្ខាងទៀតថា **ក** រួច ផ្គុំបាតដៃទាំងពីរថា **មក** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ជី** លើកដៃម្ខាងទៀតថា **ក** រួច ផ្គុំបាតដៃទាំងពីរថា **ជីក**។ |
| សិស្ស | - គ្រូថា **រា និង ក ទូ និង ក វ៉េ និង ក** ម្តងមួយៗ ឱ្យសិស្សផ្ទំសូរដោយប្រើដៃដូចខាងលើ។ |

## ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

ក- មក

| | |
|---|---|
| គ្រូ | - សរសេរ **មក** លើក្តារខៀនរួចចង្អុលនិងអាន **ម និង ក មក**។ |
| គ្រូនិងសិស្ស | - អាន **មក** រួមគ្នាដោយផ្ទំប្រកប។ |
| សិស្ស | - អាន **មក** ដោយផ្ទំប្រកប។ |

ខ- ទូក

| | |
|---|---|
| គ្រូ | - សរសេរ **ទូក** លើក្តារខៀនរួចចង្អុលនិងអាន **ទ អ៊ូ ទូ និង ក ទូក** ។ |
| គ្រូនិងសិស្ស | - អាន **ទូក** រួមគ្នាដោយផ្ទំប្រកប។ |
| សិស្ស | - អាន **ទូក** ដោយផ្ទំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **រក** លើក្តារខៀនរួចចង្អុលនិងអាន **រ និង ក រក** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ស៊ក** រួចចង្អុលនិងអានរួមគ្នាដោយផ្ទំប្រកប។ |
| សិស្ស | - អាន **លក គក ពក** ដោយផ្ទំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **រាក** លើក្តារខៀនរួចចង្អុលនិងអាន **រ អ៊ា រា និង ក រាក** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **លើក** រួចចង្អុលនិងអានរួមគ្នាដោយផ្ទំប្រកប។ |
| សិស្ស | - អាន **វ៉ែក ងាក គោក** ដោយផ្ទំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **រលាក** លើក្តារខៀនរួចចង្អុលនិងអាន **រ ល អ៊ា លា និងក លាក រលាក** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ទទឹក** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្ទំប្រកប។ |
| សិស្ស | - អាន **លលក** ដោយផ្ទំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- លែលក

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **លែលក មានន័យថា ស្ទង់មើល តាមប្រមាណ**។ **គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ លែលក**។ **សុភាពចេះលែលក ពេលវេលាធ្វើលំហាត់**។ |
| គ្រូនិងសិស្ស | - អានពាក្យ **លែលក** រួមគ្នា។ គ្រូផ្ដើម **សុភីចេះ ... ជួយការងារផ្ទះ**។ សិស្សថា **លែលក** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **លែលក** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **លែលក** ជាដៃគូ។ |

ខ- ជជែក បង្រៀនដូចពាក្យខាងលើ។ **ជជែក មានន័យថា និយាយ ពិគ្រោះគ្នា** ។ **ឧ. វាសនាជជែកជាមួយសុភី** ។

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពូហ៊ាកវែកទឹក**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពូហ៊ាក/វែក/ទឹក**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ពូហ៊ាកវែកទឹក** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពូហ៊ាកវែកទឹក**។ |
| សិស្ស | - សិស្សអានល្បះ **ពូហ៊ាកវែកទឹក**។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូពែកជីកដីធ្វើអ្វី?**

**២- តើពូពែកបានរបស់អ្វីចែកដល់ពុកម៉ែ?**

**៣- តើកូនគិតថា ពូពែកជាមនុស្សដូចម្ដេច?**

**៤- តើកូនធ្លាប់បានធ្វើអ្វីខ្លះ ដែលពុកម៉ែកូនសរសើរ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **គគោក គ គ ោ ក** រួចសរសេរ **គគោក** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **រលក រ ល ក** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **មែកឈើ ទទឹក លលក** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗរួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **រលកទឹក** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៤៣ខ | ប្រកបនឹង □ក់ (ព្យញ្ជនៈពួក អ៊) | ⌚ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **គគោក រលោក ឡិកឡក់ បែកបាក់ សំបុក** ។

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **លក់**។ គ្រូបន្លឺ **លក់**។ គ្រូនិងសិស្សថា **លក់** ។ សិស្សថា **លក់** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថាល លើកដៃម្ខាងទៀតថា **ក លក បន្តក់មួយ** រួច ផ្ដុំបាតដៃទាំងពីរថា **លក់**។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **រ** លើកដៃម្ខាងទៀតថា **ក រាបន្តក់មួយ** រួច ផ្ដុំបាតដៃទាំងពីរថា **រាក់**។ |
| សិស្ស | - គ្រូថា **៣ និង ក ពាក បន្តក់មួយ ទា និង ក ទាក បន្តក់មួយ លា និង ក លាក បន្តក់មួយ** ម្ដងមួយៗ ឱ្យសិស្សផ្ទុំសូរដោយប្រើដៃដូចខាងលើ។ |

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

ក- លក់

| | |
|---|---|
| គ្រូ | - សរសេរ **លក់** លើក្ដារខៀនរួចចង្អុលនិងអាន **ល និង ក លក បន្តក់មួយ លក់**។ |
| គ្រូនិងសិស្ស | - អាន **លក់** រួមគ្នាដោយផ្ទុំប្រកប។ |
| សិស្ស | - អាន **លក់** ដោយផ្ទុំប្រកប។ |

ខ- ទាក់

| | |
|---|---|
| គ្រូ | - សរសេរ **ទាក់** លើក្ដារខៀនរួចចង្អុលនិងអាន **ទ អា ទា និង ក ទាក បន្តក់មួយ ទាក់**។ |
| គ្រូនិងសិស្ស | - អាន **ទាក់** រួមគ្នាដោយផ្ទុំប្រកប។ |
| សិស្ស | - អាន **ទាក់** ដោយផ្ទុំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និង សួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្ដារខៀន។

**៣- ការអានព្យាង្គនិងពាក្យ** ⌚ ១៨នាទី

**៣.១ - ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **ជក់** លើក្ដារខៀនរួចចង្អុលនិងអាន **ជ និង ក ជក បន្តក់មួយ ជក់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **គក់** រួចចង្អុលនិងអានរួមគ្នាដោយផ្ទុំប្រកប។ |
| សិស្ស | - អាន **ភក់ ពក់ ងក់** ដោយផ្ទុំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **រាក់** លើក្ដារខៀនរួចចង្អុលនិងអាន **រ អ៊ា រា និង ក រាក បន្តក់មួយ រាក់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **លាក់** រួចចង្អុលនិងអានរួមគ្នាដោយផ្ទុំប្រកប។ |
| សិស្ស | - អាន **នាក់ ពាក់ ជាក់** ដោយផ្ទុំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **រាក់ទាក់** លើក្ដារខៀនរួចចង្អុលនិងអាន **រ អ៊ា រា និង ក រាក បន្តក់មួយ រាក់ ទ អ៊ា ទា និងក ទាក បន្តក់មួយ ទាក់ រាក់ទាក់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ជាក់លាក់** លើក្ដារខៀនរួចចង្អុលនាំសិស្សអានដោយផ្ទុំប្រកប។ |

| | |
|---|---|
| សិស្ស | - អាន **ទឹករាក់** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៧នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- រាក់ទាក់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **រាក់ទាក់ មានន័យថា និយាយគួរសម ទទួលដោយត្រេកអរ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ រាក់ទាក់។ ម្ចាស់ផ្ទះ រាក់ទាក់ភ្ញៀវ។** |
| គ្រូនិងសិស្ស | - អានពាក្យ **រាក់ទាក់** រួមគ្នា។ គ្រូផ្ដើម **សុភី** ... **មិត្តភក្តិ**។ សិស្សថា **រាក់ទាក់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **រាក់ទាក់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **រាក់ទាក់** ជាដៃគូ។ |

ខ- ភក់ បង្រៀនដូចពាក្យខាងលើ។ **ភក់ មានន័យថា ដីជ្រាយ ឬខាប់** ។ **ឧ. ម៉ូតូប្រឡាក់ភក់** ។

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពុកពាក់មួកទៅជីកដីភក់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពុក/ពាក់/មួក/ទៅ/ជីក/ដី/ភក់**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ពុកពាក់មួកទៅជីកដីភក់**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពុកពាក់មួកទៅជីកដីភក់**។ |
| សិស្ស | - សិស្សអានល្បះ **ពុកពាក់មួកទៅជីកដីភក់**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនរណាកើតជំងឺរាក?**

**២- តើពូគក់ប្រាប់ពូលាក់ ថាដូចម្ដេច?**

**៣- តើកូនគិតថា ហេតុអ្វីបានជាពូលាក់កើតជំងឺរាក?**

**៤- តើកូនត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីបង្ការ និងព្យាបាលជំងឺរាក?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ញីញក់** ញ ី ញ ក ់ រួចសរសេរ **ញីញក់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **បំពាក់** ប ំ ព ា ក ់ រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **រីក់ លក់ដូរ រាក់ទាក់** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗរួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ជីកដីភក់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៤៤ក | ប្រកបនឹង □ង (ព្យញ្ជនៈពួក អ) | ⌚ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ជាក់លាក់ រីក់ រលក មែកឈើ ដំអក់** ។

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **កង** ។ គ្រូបន្លឺ **កង** ។ គ្រូនិងសិស្សថា **កង** ។ សិស្សថា **កង** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ក** លើកដៃម្ខាងទៀតថា **ង** រួច ផ្គុំបាតដៃទាំងពីរថា **កង** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **សា** លើកដៃម្ខាងទៀតថា **ក** រួច ផ្គុំបាតដៃទាំងពីរថា **សាក**។ |
| សិស្ស | - គ្រូថា **ចែ និង ង សា និង ង ធី និង ង** ម្តងមួយៗឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ។ |

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

ក- កង

| | |
|---|---|
| គ្រូ | - សរសេរ **កង** លើក្តារខៀនរួចចង្អុលនិងអាន **ក និង ង កង**។ |
| គ្រូនិងសិស្ស | - អាន **កង** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **កង** ដោយផ្សំប្រកប។ |

ខ- បែង

| | |
|---|---|
| គ្រូ | - សរសេរ **បែង** លើក្តារខៀនរួចចង្អុលនិងអាន **ប អែ បែ និង ង បែង** ។ |
| គ្រូនិងសិស្ស | - អាន **បែង** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **បែង** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

**៣- ការអានព្យាង្គនិងពាក្យ** ⌚ ១៨នាទី

**៣.១ - ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **ចង** លើក្តារខៀនរួចចង្អុលនិងអាន **ច និង ង ចង** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **បង** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **សង ថង ផង** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **បាំង** លើក្តារខៀនរួចចង្អុលនិងអាន **ប អាំ បាំ និង ង បាំង** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ខឹង** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **កែង ចុង ជឹង** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **បំណង** លើក្តារខៀនរួចចង្អុលនិងអាន **ប អំ បំ ណ និង ង ណង បំណង** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ដំណឹង** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **កំប៉ោង** ដោយផ្សំប្រកប។ អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- ធឹង

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ធឹង មានន័យថា វែងាស់ជាមួយនឹងស្មារឱ្យស្មូត។** គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ **ធឹង។ ម្ដាយខ្ញុំធឹងជំឡូង។** |
| គ្រូនិងសិស្ស | - អានពាក្យ **ធឹង** រួមគ្នា។ គ្រូផ្ដើម **បងស្រីខ្ញុំ .....ចេក។** សិស្សថា **ធឹង** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ធឹង** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ធឹង** ជាដៃគូ។ |

ខ- បំណង បង្រៀនដូចពាក្យខាងលើ។ **បំណង មានន័យថា សេចក្ដីប៉ង។ ឧ. តារាមានបំណងក្លាយជាគ្រូពេទ្យ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **បងស្ងួងឡើងបេះដូង។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **បងស្ងួង/ឡើង/បេះ/ដូង។**

| | |
|---|---|
| - គ្រូ | - គ្រូអាន **បងស្ងួងឡើងបេះដូង ។** |
| - គ្រូនិងសិស្ស | - អានរួមគ្នា **បងស្ងួងឡើងបេះដូង។** |
| - សិស្ស | - សិស្សអានល្បះ **បងស្ងួងឡើងបេះដូង។** |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើបងកេង ទៅយកអ្វីខ្លះនៅចុងបឹង?**

**២- តើបងលំអងយកដូងទុំទុកធ្វើអ្វី?**

**៣- តើកូនគិតថា បងលំអងបានចេក និងដូងទុំមកពីណា ដើម្បីធឹង?**

**៤- តើកូនធ្លាប់ស្គាល់ជំឡូងអ្វីខ្លះទៀត ក្រៅពីជំឡូងដូង?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **តឹងតែង ត ឹ ង ត ែ ង** រួចសរសេរ **តឹងតែង** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **អំបែង អ ំ ប ែ ង** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ចេកធឹង ចុងដូង ដំណឹង** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ចងជាចំណង** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៤៤ខ | ប្រកបនឹង ◻ង់ (ព្យញ្ជនៈពួក អ) | ⌚ ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **តឹងតែង អំបែង ទឹកភក់ ដីភក់ ៣ពក**។

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **កង់** ។ គ្រូបន្លឺ **កង់** ។ គ្រូនិងសិស្សថា **កង់** ។ សិស្សថា **កង់** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ក** លើកដៃម្ខាងទៀតថា **ង កង បន្តក់មួយ** រួចផ្គុំបាតដៃទាំងពីរថា **កង់** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ច** លើកដៃម្ខាងទៀតថា **ង ចង បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **កង់**។ |
| សិស្ស | - គ្រូថា **ស និង ង បន្តក់មួយ ប និង ង បន្តក់មួយ ថ និង ង បន្តក់មួយ** ម្តងមួយៗ<br>- សិស្សផ្សំសូរដោយប្រើដៃ **ស និង ង បន្តក់មួយ សង់**......។ |

## ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

ក- កង់

| | |
|---|---|
| គ្រូ | - សរសេរ **កង់** លើក្តារខៀនរួចចង្អុលនិងអាន **ក និង ង បន្តក់មួយ កង់**។ |
| គ្រូនិងសិស្ស | - អាន **កង់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **កង់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និង សួរសំណួរទាក់ទងមុននឹងសរសេរចំណាងជើងលើក្តារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **ចង់** លើក្តារខៀនរួចចង្អុលនិងអាន **ច និង ង ចង បន្តក់មួយ ចង់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **បង់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **សង់ ថង់ ដង់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **សំណង់** លើក្តារខៀនរួចចង្អុលនិងអាន **ស អំ សំ ណ និង ង ណង បន្តក់មួយ ណង់ សំណង់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **លំចង់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ចំណង់** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- សំណង់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **សំណង់ មានន័យថា ការសង់ ការផ្សំគ្រឿងឱ្យកើតជាលំនៅឋាន**។ គ្រូនឹងបង្កើតល្បះមួយ **ដោយប្រើពាក្យ សំណង់**។ **ពូសំជាកម្មករសំណង់**។ |
| គ្រូនិងសិស្ស | - អានពាក្យ **សំណង់** រួមគ្នា។ គ្រូផ្តើម **ទីក្រុងភ្នំពេញមាន .....ខ្ពស់ៗជាច្រើន**។ សិស្សថា **សំណង់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **សំណង់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **សំណង់** ជាដៃគូ។ |

ខ- អែអង់ បង្រៀនដូចពាក្យខាងលើ។ **អែអង់ មានន័យថា រេរង់ បង្អែបង្អង់**។ ឱ. **សំណាងឈរអែអង់ចាំនិមល។**

## ៥- ការអានល្បះ

🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **កុំតោងកង់បងតុង**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **កុំ/តោង/កង់/បងតុង**។

| | |
|---|---|
| គ្រូ | - គ្រូអាន **កុំតោងកង់បងតុង** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **កុំតោងកង់បងតុង**។ |
| សិស្ស | - សិស្សអានល្បះ **កុំតោងកង់បងតុង**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី

🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនរណាលក់ដូង?**

**២- តើចៅប៉ង់យកអ្វីដឹកដូងលក់?**

**៣- កូនគិតថា តើចៅប៉ង់ជាក្មេងដូចម្ដេច?**

**៤- តើកូនធ្លាប់ញ៉ាំដូងឬទេ? វាមានរសជាតិដូចម្ដេច?**

## ៧- ការសរសេរ

🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **លំចង់ ល ំ ច ង ់** រួចសរសេរ **លំចង់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **សំណង់ ស ំ ណ ង ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ចំណង់ អែអង់ ចែចង់** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **កង់បងប៉ង់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ

🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

sala.moeys.gov.kh
t.me/moeysnews
youtube.com/moeyscambodia

## មេរៀនទី ៤៥ក ប្រកបនឹង □ង (ព្យញ្ជនៈពួក អ៊ី) ⌚ ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **សំណង់ លំចង់ តឹងតែង អំបែង ញីញក់** ។

### ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **ទង** ។ គ្រូបន្លឺ **ទង** ។ គ្រូនិងសិស្សថា **ទង** ។សិស្សថា **ទង** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ទ** លើកដៃម្ខាងទៀតថា **ង** រួចផ្គុំបាតដៃទាំងពីរថា **ទង** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ដើ** លើកដៃម្ខាងទៀតថា **ង** រួច ផ្គុំបាតដៃទាំងពីរថា **ដើង**។ |
| សិស្ស | - គ្រូថា **លា និង ង មុ និង ង រឺ និង ង** ម្តងមួយៗឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ។ |

### ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

ក- ទង

| | |
|---|---|
| គ្រូ | - សរសេរ **ទង** លើក្តារខៀនរួចចង្អុលនិងអាន **ទ និង ង ទង**។ |
| គ្រូនិងសិស្ស | - អាន **ទង** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ទង** ដោយផ្សំប្រកប។ |

ខ- មុង

| | |
|---|---|
| គ្រូ | - សរសេរ **មុង** លើក្តារខៀន រួចចង្អុលនិងអាន **ម អ៊ុ មុ និង ង មុង** ។ |
| គ្រូនិងសិស្ស | - អាន **មុង** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **មុង** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

### ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

#### ៣.១ - ការអានព្យាង្គ

#### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **ទង** លើក្តារខៀនរួចចង្អុលនិងអាន **ទ និង ង ទង** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **មង** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **គង វង លង** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

#### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ធុង** លើក្តារខៀនរួចចង្អុលនិងអាន **ធ អ៊ុ ធុ និង ង ធុង** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ល្ងង** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ពាង លឹង រឿង** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

#### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **សំពោង** លើក្តារខៀនរួចចង្អុលនិងអាន **ស អំ សំ ព អោ ពោ និង ង ពោង សំពោង**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រនាំង** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **លំពែង** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- គង

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **គង មានន័យថា គ្រឿងភ្លេងម្យ៉ាងធ្វើពីលោហធាតុ។ គ្រូនឹងបង្កើតល្បះ មួយដោយប្រើពាក្យ គង។ លោកសង្ឃវាយគង ប្រជុំ។** |
| គ្រូនិងសិស្ស | - អានពាក្យ **គង** រួមគ្នា។ គ្រូផ្ដើម **ពូហ៊ឹងវាយ** .....**ប្រគំបទភ្លេង**។ សិស្សថា **គង** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **គង** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **គង** ជាដៃគូ។ |

ខ- ធេងធោង បង្រៀនដូចពាក្យខាងលើ។ **ធេងធោង មានន័យថា ឃ្លេងឃ្លោង ថយកម្លាំង។ ឧ. ពូពាងដើរធេងធោង។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **យើងកុំចុះលេងទឹកបឹង**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **យើង/កុំ/ចុះ/លេង/ទឹក/បឹង**។

| | |
|---|---|
| គ្រូ | - គ្រូអាន **យើងកុំចុះលេងទឹកបឹង** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **យើងកុំចុះលេងទឹកបឹង**។ |
| សិស្ស | - សិស្សអានល្បះ **យើងកុំចុះលេងទឹកបឹង** ។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូទៀងធ្វើអ្វី នៅឯណា?**

**២- តើពូទៀង និងចៅហ៊ាងយកគងទៅគរនៅឯណា?**

**៣- តើកូនគិតថា ពូទៀងមានមុខរបរជាអ្វី?**

**៤- តើកូនធ្លាប់ដឹងថា គេយកគងទៅធ្វើអ្វីខ្លះ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ទំនង ទ ំ ន ង** រួចសរសេរ **ទំនង** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **រលោង រ ល ោ ង** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ពឹងពាង ននោង រនាំង** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **រោងដាក់ពាង** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៥៥២ | ប្រកបនឹង □ង់ (ព្យញ្ជនៈពួក អ៊ី) | ⌚ ៤០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ឆេងឆោង នទោង លំចង់ សំណង់ ចុងដូង** ។

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **ទង់**។ គ្រូបន្លឺ **ទង់**។ គ្រូនិងសិស្សថា **ទង់** ។សិស្សថា **ទង់** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ទ** លើកដៃម្ខាងទៀតថា **ង ទង បន្តក់មួយ** រួច ផ្ទុំបាតដៃទាំងពីរថា **ទង់** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ជ** លើកដៃម្ខាងទៀតថា **ង ជង បន្តក់មួយ** រួច ផ្ទុំបាតដៃទាំងពីរថា **ជង់**។ |
| សិស្ស | - គ្រូថា **វ និង ង បន្តក់មួយ គ និង ង បន្តក់មួយ វ និង ង បន្តក់មួយ** ម្តងមួយៗ<br>- សិស្សផ្សំសូរដោយប្រើដៃ **វ និង ង បន្តក់មួយ វង់ ...**។ |

## ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

ក- ទង់

| | |
|---|---|
| គ្រូ | - សរសេរ **ទង់** លើក្តារខៀនរួចចង្អុលនិងអាន **ទ និង ង ទង បន្តក់មួយ ទង់**។ |
| គ្រូនិងសិស្ស | - អាន **ទង់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ទង់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និង សួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **គង់** លើក្តារខៀនរួចចង្អុលនិងអាន **គ នឹង ង គង បន្តក់មួយ គង់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **វង់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **វង់ លង់ ញង់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **មមង់** លើក្តារខៀនរួចចង្អុលនិងអាន **ម ម និង ង មង បន្តក់មួយ មង់ មមង់។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រាំវង់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ញុះញង់** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- រង់ចាំ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **រង់ចាំ មានន័យថា បង្អង់ចាំ ឈប់បង្អង់**។គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ **រង់ចាំ**។<br>**សុខា រង់ចាំប្អូននៅខ្លោងទ្វារ**។ |
| គ្រូនិងសិស្ស | - អានពាក្យ **រង់ចាំ** រួមគ្នា។ គ្រូផ្តើម **សុភាក់ .... មិត្តភក្តិនៅផ្ទះ**។ សិស្សថា **រង់ចាំ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **រង់ចាំ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **រង់ចាំ** ជាដៃគូ។ |

ខ- លង់ បង្រៀនដូចពាក្យខាងលើ។ **លង់ មានន័យថា ជ្រុល ហួស លិច។ ឧ. ក្មេងៗកុំលេងទឹកព្រោះបណ្តាលឱ្យលង់** ។

## ៥- ការអានល្បះ

🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **មីងគង់លាងពាងនិងធុងទឹក។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **មីងគង់/លាង/ពាង/និង/ធុង/ទឹក។**

| | |
|---|---|
| គ្រូ | - គ្រូអាន **មីងគង់លាងពាងនិងធុងទឹក។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **មីងគង់លាងពាងនិងធុងទឹក។** |
| សិស្ស | - សិស្សអានល្បះ **មីងគង់លាងពាងនិងធុងទឹក។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី

🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូគង់ទៅណា? នៅឯណា?**

**២- ហេតុអ្វី បានជាមីងពង់ខឹងពូគង់?**

**៣- តើកូនគិតថាពូគង់ជាមនុស្សដូចម្ដេច?**

**៤- តើកូនដឹងថាគេលេងរាំវង់ក្នុងពិធីអ្វីខ្លះ?**

## ៧- ការសរសេរ

🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **រាំវង់** **រ ាំ វ ង ់** រួចសរសេរ **រាំវង់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **រាំងនន** **រ ាំ ង ន ន** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ទំពាំង ជំទង់ បំពង់** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ទៅរាំវង់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ

🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| មេរៀនទី ៤៦ក | ប្រកបនឹង ◻ច (ព្យញ្ជនៈពួក អ) | ◷ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ◷ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **រាំវង់ ជំទង់ ទំនង រលោង រាក់ទាក់** ។

**១- ការស្គាល់សូរអក្សរថ្មី** ◷ ៥នាទី

- គ្រូបំផុសរកពាក្យ **ហួច** ។ គ្រូបន្លឺ **ហួច**។ គ្រូនិងសិស្សថា **ហួច** ។សិស្សថា **ហួច** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ហួ** លើកដៃម្ខាងទៀតថា **ច** រួចផ្ដុំបាតដៃទាំងពីរថា **ហួច** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **សើ** លើកដៃម្ខាងទៀតថា **ច** រួច ផ្ដុំបាតដៃទាំងពីរថា **សើច**។ |
| សិស្ស | - គ្រូថា **ច និង ច បា និង ច ត និង ច** ម្ដងមួយៗឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ។ |

**២- ការស្គាល់តួអក្សរថ្មី** ◷ ៥នាទី

ក- តច

| | |
|---|---|
| គ្រូ | - សរសេរ **តច** លើក្ដារខៀន រួចចង្អុលនិងអាន **ត និង ច តច** ។ |
| គ្រូនិងសិស្ស | - អាន **តច** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **តច** ដោយផ្សំប្រកប។ |

ខ- ហួច

| | |
|---|---|
| គ្រូ | - សរសេរ **ហួច** លើក្ដារខៀន រួចចង្អុលនិងអាន **ហ អួ ហួ និង ច ហួច** ។ |
| គ្រូនិងសិស្ស | - អាន **ហួច** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ហួច** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្ដារខៀន។

**៣- ការអានព្យាង្គនិងពាក្យ** ◷ ១៨នាទី

**៣.១ - ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **ចច** លើក្ដារខៀន រួចចង្អុលនិងអាន **ច និង ច ចច** ។ |
| គ្រូនិងសិស្ស | - អាន **ប៉ច** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ឡូច ហច ដច** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **សើច** លើក្ដារខៀនរួចចង្អុលនិងអាន **ស អើ សើ និង ច សើច** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **កាច** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **តូច បាច ខើច** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **សំណើច** លើក្ដារខៀនរួចចង្អុលនិងអាន **ស អំ សំ ណ អើ ណើ និង ច ណើច សំណើច** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **តូចតាច** លើក្ដារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **កំហូច** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- បាចសាច

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **បាចសាច** មានន័យថា **លើកជះ សាច** ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ **បាចសាច**។ **ពុកខ្ញុំបាចសាចទឹកដាក់ផ្លូវ**។ |
| គ្រូនិងសិស្ស | - អានពាក្យ **បាចសាច** រួមគ្នា។ គ្រូផ្ដើម **លោកនាយក .....ទឹកដាក់ទីធ្លា**។ សិស្សថា **បាចសាច** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **បាចសាច** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **បាចសាច** ជាដៃគូ។ |

ខ- តូចតាច បង្រៀនដូចពាក្យខាងលើ។ **តូចតាច មានន័យថា ដែលតូចពេក ឧ. រឿងតូចតាចកុំបង្កឱ្យប្រកែកគ្នា** ។

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ចៅម៉ាចចេះហួចនិងសើចតិចៗ**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ចៅម៉ាច/ចេះ/ហួច/និង/សើច/តិចៗ**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ចៅម៉ាចចេះហួចនិងសើចតិចៗ** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ចៅម៉ាចចេះហួចនិងសើចតិចៗ**។ |
| សិស្ស | - សិស្សអានល្បះ **ចៅម៉ាចចេះហួចនិងសើចតិចៗ** ។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើចៅចូចចេះធ្វើអ្វី?**

**២- ហេតុអ្វីបានជាបងម៉ាចខឹងចៅចូច?**

**៣- តើកូនគិតថាបងម៉ាចជាមនុស្សដូចម្ដេច?**

**៤- តើកូនៗធ្លាប់ប្រឡែងលេងជាមួយអ្នកណាខ្លះ?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **តូចតាច ត ូ ច ត ា ច** រួចសរសេរ **តូចតាច** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **សំណើច ស ំ ណ េី ច** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **តិចតួច ចាក់ចុច កំហូច** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ចេះហួចតិចៗ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៤៦ខ | ប្រកបនឹង □ច់ (ព្យញ្ជនៈពួក អ) | ⌚ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **តូចតាច កំហូច រាំងរ៉ង់ រង់ចាំ ពីងពាង ។**

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **កាច់**។ គ្រូបន្លឺ **កាច់**។ គ្រូនិងសិស្សថា **កាច់** ។សិស្សថា **កាច់** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **កា** លើកដៃម្ខាងទៀតថាច **កាច បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **កាច់** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ដា** លើកដៃម្ខាងទៀតថា **ច ដាច បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **ដាច់**។ |
| សិស្ស | - គ្រូថា **សា និង ច បន្តក់មួយ ក និង ច បន្តក់មួយ បា និង ច បន្តក់មួយ** ម្តងមួយៗ<br>- សិស្សផ្សំសូរដោយប្រើដៃ **សា និង ច បន្តក់មួយ សាច់ ...**។ |

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

ក- កច់

| | |
|---|---|
| គ្រូ | - សរសេរ **កច់** លើក្តារខៀន រួចចង្អុលនិងអាន **ក និង ច កច បន្តក់មួយ កច់**។ |
| គ្រូនិងសិស្ស | - អាន **កច់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **កច់** ដោយផ្សំប្រកប។ |

ខ- កាច់

| | |
|---|---|
| គ្រូ | - សរសេរ **កាច់** លើក្តារខៀន រួចចង្អុលនិងអាន **ក អា កា និង ច កាច បន្តក់មួយ កាច់**។ |
| គ្រូនិងសិស្ស | - អាន **កាច់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **កាច់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

**៣- ការអានព្យាង្គនិងពាក្យ** ⌚ ១៨នាទី

**៣.១ - ការអានព្យាង្គ**

**៣.១.១- ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ឡច់** លើក្តារខៀនរួចចង្អុលនិងអាន **ឡ និង ច ឡច បន្តក់មួយ ឡច់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **សច់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **បច់ ប៉ច់ ណច់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **បាច់** លើក្តារខៀនរួចចង្អុលនិងអាន **ប អា បា និង ច បាច បន្តក់មួយ បាច់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **សាច់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ដាច់ ប៉ាច់ ណាច់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ចាំបាច់** លើក្តារខៀនរួចចង្អុលនិងអាន **ច ◌ាំ ចាំ ប ◌ា បា និង ច បាច បន្តក់មួយ បាច់ ចាំបាច់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **បីបាច់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ដាច់ខែ** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- បួរបាច់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **បួរបាច់ មានន័យថា និយាយរៀបរាប់ប្រាប់ឱ្យដឹង។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ បួរបាច់។ សុខានិយាយបួរបាច់ពីនេះពីនោះ ។** |
| គ្រូនិងសិស្ស | - អានពាក្យ **បួរបាច់** រួមគ្នា។ គ្រូផ្តើម **ណារីនិយាយ ... ពីការរៀនសូត្រ។** សិស្សថា **បួរបាច់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **បួរបាច់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **បួរបាច់** ជាដៃគូ។ |

ខ- ចាំបាច់ បង្រៀនដូចពាក្យខាងលើ។ **ចាំបាច់ មានន័យថា ដែលសំខាន់។ ឧ. បើចង់មានការងារល្អ ចាំបាច់ត្រូវខិតខំរៀន ។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពុកម៉ែបីបាច់កូនៗ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពុក/ម៉ែ/បីបាច់/កូនៗ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ពុកម៉ែបីបាច់កូនៗ ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពុកម៉ែបីបាច់កូនៗ។** |
| សិស្ស | - សិស្សអានល្បះ**ពុកម៉ែបីបាច់កូនៗ ។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងនឹងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើម៉ែកំពុងធ្វើអ្វី?**

**២- តើម៉ែហុចធាសាច់គោឱ្យអ្នកណា?**

**៣- ហេតុអ្វីបានជាម៉ែថាការចែករំលែកជាការចាំបាច់?**

**៤- តើកូនធ្លាប់ចែករំលែកអ្វីឱ្យនរណាដែរឬទេ? ចែកអ្វី?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ដាច់ខែ ដ ា ច ់ ខ ែ** រួចសរសេរ **ដាច់ខែ** លើក្តារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **បីបាច់ ប ី ប ា ច ់** រួចគ្រូសរសេរលើក្តារខៀន។ សិស្សសរសេរលើក្តារឆ្នួន។ |
| សិស្ស | - គ្រូថា **ដាច់ដោច សាច់ជូរ សាច់ជុំ** ម្តងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្តារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្តារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **កាច់ជាកំណាច់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| មេរៀនទី ៤៧ក | ប្រកបនឹង ◻ច (ព្យញ្ជនៈពួក អ៊ី) | ⏲ ៨០នាទី |
|---|---|---|

| លំនឹងថ្នាក់ និងរំឭកមេរៀន | ⏲ ៥នាទី |
|---|---|

- គ្រូរំឭកពាក្យដែលបានរៀនរួច **ប៊ីបាច់ ដាច់ខែ កំហូច តូចតាច ញុះញង់។**

| ១- ការស្គាល់សូរអក្សរថ្មី | ⏲ ៥នាទី |
|---|---|

- គ្រូបំផុសរកពាក្យ **ទោច** ។ គ្រូបន្លឺ **ទោច**។ គ្រូនិងសិស្សថា **ទោច** ។សិស្សថា **ទោច** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ទោ** លើកដៃម្ខាងទៀតថា **ច** រួចផ្គុំបាតដៃទាំងពីរថា **ទោច** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **រួ** លើកដៃម្ខាងទៀតថា **ច** រួច ផ្គុំបាតដៃទាំងពីរថា **រួច**។ |
| សិស្ស | - គ្រូថា **លិ និង ច ជ និង ច គេ និង ច** ម្តងមួយៗឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ។ |

| ២- ការស្គាល់តួអក្សរថ្មី | ⏲ ៥នាទី |
|---|---|

ក- ជច

| | |
|---|---|
| គ្រូ | - សរសេរ **ជច** លើក្តារខៀនរួចចង្អុលនិងអាន **ជ និង ច ជច**។ |
| គ្រូនិងសិស្ស | - អាន **ជច** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ជច** ដោយផ្សំប្រកប។ |

ខទោច -

| | |
|---|---|
| គ្រូ | - សរសេរ **ទោច** លើក្តារខៀន រួចចង្អុលនិងអាន **ទ អោ ទោ និង ច ទោច** ។ |
| គ្រូនិងសិស្ស | - អាន **ទោច** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ទោច** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណាងជើងលើក្តារខៀន។

| ៣- ការអានព្យាង្គនិងពាក្យ | ⏲ ១៨នាទី |
|---|---|

### ៣.១ - ការអានព្យាង្គ

### ៣.១.១- ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **យច** លើក្តារខៀន។ គ្រូចង្អុលនិងអា **យ និង ច យច** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រច** និងនាំសិស្សអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ជច ញច លច** សិស្សអានដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **គួច** លើក្តារខៀនរួចចង្អុលនិងអាន **គ អួ គួ និង ច គួច** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ពោច** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **លិច គិច វេច** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **រំពេច** លើក្តារខៀនរួចចង្អុលនិងអាន **រ អុំ រុំ ព អេ ពេ និង ច ពេច រំពេច** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ទោចញី** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **សំពោច** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⏲ ៨នាទី

ក- លិច

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **លិច មានន័យថា ចូលកប់បាត់**។ **គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ លិច ។ នាវាលិចក្នុងទឹក**។ |
| គ្រូនិងសិស្ស | - អានពាក្យ **លិច** រួមគ្នា។ គ្រូផ្ដើម **ព្រះអាទិត្យ .....នៅពេលល្ងាច**។ សិស្សថា **លិច** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **លិច** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **លិច** ជាដៃគូ។ |

ខ- ដុច បង្រៀនដូចពាក្យខាងលើ។ **ដុច មានន័យថា ប្រដាប់នេសាទត្រី។ ឧ. ត្រីធំមួយជាប់ដុច។**

## ៥- ការអានល្បះ ⏲ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **តាអ៊ុចចុះដងទឹកបឹងខាងលិច**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **តាអ៊ុច /ចុះ/ដង/ទឹក/បឹង/ខាង/លិច**។

| | |
|---|---|
| គ្រូ | - គ្រូអាន **តាអ៊ុចចុះដងទឹកបឹងខាងលិច**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **តាអ៊ុចចុះដងទឹកបឹងខាងលិច**។ |
| សិស្ស | - សិស្សអានល្បះ **តាអ៊ុចចុះដងទឹកបឹងខាងលិច**។ |

## ៦- ការអានអត្ថបទខ្លី ⏲ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើសត្វអ្វីលួចស៊ីដំណាំពូលុច?**

**២- តើពូលុចធ្វើដូចម្ដេចដើម្បីការពារដំណាំគាត់?**

**៣- ហេតុអ្វីបានជាពូលុចការពារដំណាំ?**

**៤-តើកូនត្រូវធ្វើដូចម្ដេចខ្លះក្នុងការថែទាំដំណាំឱ្យបានល្អ?**

## ៧- ការសរសេរ ⏲ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **រនោច រ ន ោ ច** រួចសរសេរ **រនោច** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **សំពោច ស ំ ព ោ ច** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ទិច រំពេច គេចកែ** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

គ្រូហៅឃ្លា **រនោចទោចយំ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⏲ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៤៧ខ | ប្រកបនឹង □ច់ (ព្យញ្ជនៈពួក អ) | ⌚ ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **សាច់ បីបាច់ រំពេច រនោច កំណាច** ។

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **ទច់**។ គ្រូបន្លឺ **ទច់**។ គ្រូនិងសិស្សថា **ទច់** ។សិស្សថា **ទច់** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ទ** លើកដៃម្ខាងទៀតថាច **ទច បន្តក់មួយ** រួច ផ្ទុំបាតដៃទាំងពីរថា **ទច់** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ជ** លើកដៃម្ខាងទៀតថា **ច ជច បន្តក់មួយ** រួច ផ្ទុំបាតដៃទាំងពីរថា **ជច់**។ |
| សិស្ស | - គ្រូថា **គ និង ច បន្តក់មួយ ម និង ច បន្តក់មួយ រ និង ច បន្តក់មួយ** ម្តងមួយៗ<br>- សិស្សផ្សំសូរដោយប្រើដៃ **គ និង ច បន្តក់មួយ គច់** ...។ |

## ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

ក- ជច់

| | |
|---|---|
| គ្រូ | - សរសេរ **ជច់** លើក្តារខៀន រួចចង្អុលនិងអាន **ជ និង ច ជច បន្តក់មួយ ជច់**។ |
| គ្រូនិងសិស្ស | - អាន **ជច់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ជច់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និង សួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រះកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **គច់** លើក្តារខៀន រួចចង្អុលនិងអាន **គ និង ច គច បន្តក់មួយ គច់** |
| គ្រូនិងសិស្ស | - អាន **លច់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ហ៊ច់ ញច់ មច់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣-១-២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ញច់** លើក្តារខៀន រួចចង្អុលនិងអាន **ញ និង ច ញច បន្តក់ មួយ ញច់ ។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ទច់** លើក្តារខៀន នាំសិស្សអានដោយផ្សំប្រកប ។ |
| សិស្ស | - គ្រូសរសេរ **ជំនច់** សិស្សអានដោយផ្សំប្រកប។<br>- អានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- ទច់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ទច់ មានន័យថា ឈប់ង៉ក់។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ទច់។ សុផាតដើរទច់ង៉ក់។** |
| គ្រូនិងសិស្ស | - អានពាក្យ **ទច់** រួមគ្នា។ គ្រូផ្តើម **ដារាជិះកង់ចាប់ហ្វ្រាំង ... ង៉ក់**។ សិស្សថា **ទច់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ទច់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ទច់** ជាដៃគូ។ |

ខ- ជច់ បង្រៀនដូចពាក្យខាងលើ។ **ជច់ មានន័យថា ត្រេចឬស្រុញ។ ឧ. សំជិះកង់ធ្លាក់ត្រហុកជច់ខ្នង។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពូសំដើរៗ ទច់ង៉ក់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពូសំ/ ដើរៗ/ ទច់ង៉ក់**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ពូសំដើរៗ ទច់ង៉ក់**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពូសំដើរៗ ទច់ង៉ក់**។ |
| សិស្ស | - សិស្សអានល្បះ **ពូសំដើរៗ ទច់ង៉ក់** ។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើសត្វអ្វីលួចចេកតាអ៊ិច?**

**២- តើសត្វសំពោចរត់គេចពីអ្វី?**

**៣- តើកូនយល់ថាសំពោចជាសត្វដូចម្ដេច?**

**៤- តើកូនស្គាល់សត្វទោចឬទេ? វាមានរូបរាងស្រដៀងសត្វអ្វី?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ទច់** ទ ច ់ រួចសរសេរ **ទច់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ជច់** ជ ច ់ រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ជំនច់ ញច់ ពូអ៊ិច** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **កង់ទច់ង៉ក់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៤៨ក | ប្រកបនឹង ◻ញ (ព្យញ្ជនៈពួក អ) | ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន (៥នាទី)

- គ្រូរំឭកពាក្យដែលបានរៀនរួច **រនោច រំពេច ជច់ ទច់ សាច់**។

## ១- ការស្គាល់សូរអក្សរថ្មី (៥នាទី)

- គ្រូបំផុសរកពាក្យ **ដេញ** ។ គ្រូបន្លឺ **ដេញ** ។ គ្រូនិងសិស្សថា **ដេញ**។ សិស្សថា **ដេញ**។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ដេ** លើកដៃម្ខាងទៀតថា **ញ** រួច ផ្គុំបាតដៃទាំងពីរថា **ដេញ** ។ |
| គ្រូនិងសិស្ស | -លើកដៃម្ខាងឡើងលើថា **ចេ** លើកដៃម្ខាងទៀតថា **ញ** រួច ផ្គុំបាតដៃទាំងពីរថា **ចេញ**។ |
| សិស្ស | -គ្រូថា **ស និង ញ ឡ និង ញ ក និង ញ** ម្តងមួយៗឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ។ |

## ២- ការស្គាល់តួអក្សរថ្មី (៥នាទី)

ក- កញ

| | |
|---|---|
| គ្រូ | - សរសេរ **កញ** លើក្តារខៀនរួចចង្អុលនិងអាន **ក និង ញ កញ**។ |
| គ្រូនិងសិស្ស | - អាន **កញ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **កញ** ដោយផ្សំប្រកប។ |

ខ- ចេញ

| | |
|---|---|
| គ្រូ | - សរសេរ **ចេញ** លើក្តារខៀន រួចចង្អុលនិងអាន **ច អេ ចេ និង ញ ចេញ** ។ |
| គ្រូនិងសិស្ស | - អាន **ចេញ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ចេញ** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណាងជើងលើក្តារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ (១៨នាទី)

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រះកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **ចញ** លើក្តារខៀន។ គ្រូចង្អុលនិងអាន **ច និង ញ ចញ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **សញ** និងនាំសិស្សអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ខញ ជញ បញ** សិស្សអានដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រះនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **ចេញ** លើក្តារខៀនរួចចង្អុលនិងអាន **ច អេ ចេ និង ញ ចេញ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ខួញ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **សាញ តុញ ខើញ** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ចំណេញ** លើក្តារខៀនរួចចង្អុលនិងអាន **ច អំ ចំ ណ អេ ណេ និង ញ ណេញ ចំណេញ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រំដេញ** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ចាកចេញ** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- សុញ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **សុញ មានន័យថា ទាល់គំនិត។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ សុញ ។ ពូសាតសុញគំនិត។** |
| គ្រូនិងសិស្ស | - អានពាក្យ **សុញ** រួមគ្នា។ គ្រូផ្ដើម **នារី ... គំនិតពេលធ្វើលំហាត់។** សិស្សថា **សុញ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **សុញ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **សុញ** ជាដៃគូ។ |

ខ- ចំណេញ បង្រៀនដូចពាក្យខាងលើ។ **ចំណេញ មានន័យថា ដែលបានច្រើនជាងដើម។ឧ. មីងសានចំណេញប្រាក់ពីការលក់នំ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពូសាញ ចេញទៅបេះរំដេញ**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពូសាញ/ចេញ/ទៅ/បេះ/រំដេញ**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ពូសាញ ចេញទៅបេះរំដេញ** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពូសាញ ចេញទៅបេះរំដេញ**។ |
| សិស្ស | - សិស្សអានល្បះ **ពូសាញ ចេញទៅបេះរំដេញ** ។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនរណាខ្លះជាចៅតាម៉ាញ?**

**២- ពេលទំនេរ តើតាម៉ាញនាំចៅធ្វើអ្វី?**

**៣- ហេតុអ្វីបានជាតាម៉ាញនាំចៅៗដេញចាប៊ី?**

**៤- តើពេលទំនេរកូនចូលចិត្តធ្វើអ្វីខ្លះ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាព្យាង្គៗ **តិញតុញ ត ិ ញ ត ុ ញ** រួចសរសេរ **តិញតុញ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាព្យាង្គៗ **សុញសាញ ស ុ ញ ស ា ញ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **កកកុញ រំដេញ របុញ** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាព្យាង្គៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **លក់ចំណេញ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៤៨ខ | ប្រកបនឹង □ញ់ (ព្យញ្ជនៈពួក អ) | ៤០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ជច់ ទច់ លិចលង់ គេចកែ បីបាច់** ។

## ១- ការស្គាល់សូរអក្សរថ្មី ៥នាទី

- គ្រូបំផុសរកពាក្យ **បាញ់**។ គ្រូបន្លឺ **បាញ់**។ គ្រូនិងសិស្សថា **បាញ់** ។ សិស្សថា **បាញ់** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **បា** លើកដៃម្ខាងទៀតថា **ញ បាញ បន្តក់មួយ** រួច ផ្តុំបាតដៃទាំងពីរថា **បាញ់**។ |
| គ្រូនិងសិស្ស | -លើកដៃម្ខាងឡើងលើថា **ខ** លើកដៃម្ខាងទៀតថា **ញ ខញ បន្តក់មួយ** រួច ផ្តុំបាតដៃទាំងពីរថា **ខញ់**។ |
| សិស្ស | - គ្រូថា **ក និង ញ បន្តក់មួយ សានិង ញ បន្តក់មួយ ម៉ា និង ញ បន្តក់មួយ** ម្តងមួយៗ។<br>- សិស្សអនុវត្តផ្ទាំសូរដោយប្រើដៃ **ក និង ញ បន្តក់មួយ កញ់** ...។ |

## ២- ការស្គាល់តួអក្សរថ្មី ៥នាទី

ក- កញ់

| | |
|---|---|
| គ្រូ | - សរសេរ **កញ់** លើក្តារខៀន រួចចង្អុលនិងអាន **ក និង ញ កញ បន្តក់មួយ កញ់**។ |
| គ្រូនិងសិស្ស | - អាន **កញ់** រួមគ្នាដោយផ្ទាំប្រកប។ |
| សិស្ស | - អាន **កញ់** ដោយផ្ទាំប្រកប។ |

ខ- ចាញ់

| | |
|---|---|
| គ្រូ | - សរសេរ **ចាញ់** លើក្តារខៀន រួចចង្អុលនិងអាន **ច អា ចា និង ញ ចាញ បន្តក់មួយ ចាញ់**។ |
| គ្រូនិងសិស្ស | - អាន **ចាញ់** រួមគ្នាដោយផ្ទាំប្រកប។ |
| សិស្ស | - អាន **ចាញ់** ដោយផ្ទាំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ ១៨នាទី

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **តញ់** លើក្តារខៀន រួចចង្អុលនិងអាន **ត និង ញ តញ បន្តក់មួយ តញ់**។ |
| គ្រូនិងសិស្ស | - អាន **ជញ់** រួមគ្នាដោយផ្ទាំប្រកប។ |
| សិស្ស | - អាន **ប៉ញ់ ចញ់ សញ់** ដោយផ្ទាំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **កាញ់** លើក្តារខៀន រួចចង្អុលនិងអាន **ក អា កា និងញ កាញ បន្តក់មួយ កាញ់**។ |
| គ្រូនិងសិស្ស | - អាន **ញ៉ាញ់** រួមគ្នាដោយផ្ទាំប្រកប។ |
| សិស្ស | - អាន **ប៉ាញ់ សាញ់ ណាញ់** ដោយផ្ទាំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **កំណាញ់** លើក្តារខៀន រួចចង្អុលនិង **ក អំ កំ ណ អា ណា និង ញ ណាញ បន្តក់មួយ ណាញ់ កំណាញ់**។ |

| | |
|---|---|
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចុះចាញ់** លើក្ដារខៀន នាំសិស្សអានដោយផ្សំប្រកប ។ |
| សិស្ស | - គ្រូសរសេរ **សំណាញ់** សិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- កំណាញ់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **កំណាញ់ មានន័យថា មិនចែករំលែក ឬមិនចាយវាយ**។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ កំណាញ់។ **សុផាត ជាមនុស្ស កំណាញ់**។ |
| គ្រូនិងសិស្ស | - អានពាក្យ **កំណាញ់**។ គ្រូផ្ដើម **សំណាងជាមនុស្ស ...**។ សិស្សថា **កំណាញ់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **កំណាញ់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **កំណាញ់** ជាដៃគូ។ |

ខ- ចាញ់ បង្រៀនដូចពាក្យខាងលើ។ **ចាញ់ មានន័យថា មិនឈ្នះ**។ **ឧ. ក្រុមកុមារលេងបាល់ចាញ់ក្រុមកុមារី។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពូសាញ់បង់សំណាញ់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពូសាញ់/ បង់/ សំណាញ់**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ពូសាញ់បង់សំណាញ់**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពូសាញ់បង់សំណាញ់**។ |
| សិស្ស | - សិស្សអានល្បះ **ពូសាញ់បង់សំណាញ់**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើមីងសាញ់លក់អ្វី?**

**២- តើការលក់រំដេញរបស់មីងសាញ់ដូចម្ដេច?**

**៣- តើមីងសាញ់មានមុខរបរអ្វី?គាត់ជាមនុស្សដូចម្ដេច?**

**៤- តើកូនធ្លាប់ញ៉ាំរំដេញឬទេ?វាមានរសជាតិដូចម្ដេច?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **បរបាញ់ ប រ ប ា ញ ់** រួចសរសេរ **បរបាញ់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ចុះចាញ់ ច ុ ះ ច ា ញ ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **កំណាញ់ សំណាញ់ ជំងឺចាញ់** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

គ្រូហៅឃ្លា **បង់សំណាញ់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៤៩ក | ប្រកបនឹង ◻ញ (ព្យញ្ជនៈពួក អ) | 🕒 ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន 🕒 ៥នាទី

- គ្រូរំឭកពាក្យដែលបាន រៀនរួច **ចេញ ចាំបាច់ ចំណេញ សំណាញ់ បរបាញ់។**

## ១- ការស្គាល់សូរអក្សរថ្មី 🕒 ៥នាទី

- គ្រូបំផុសរកពាក្យ **ទាញ** ។ គ្រូបន្លឺ **ទាញ**។ គ្រូនិងសិស្សថា **ទាញ** ។ សិស្សថា **ទាញ** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ទា** លើកដៃម្ខាងទៀតថា **ញ** រួច ផ្ដុំបាតដៃទាំងពីរថា **ទាញ**។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **រួ** លើកដៃម្ខាងទៀតថា **ញ** រួច ផ្ដុំបាតដៃទាំងពីរថា **រួញ។** |
| សិស្ស | - គ្រូថា **ទ និង ញ រុ និង ញ វ និង ញ** ម្ដងមួយៗឱ្យសិស្សអនុវត្តផ្សំសូរដោយប្រើដៃដូចខាងលើ។ |

## ២- ការស្គាល់តួអក្សរថ្មី 🕒 ៥នាទី

ក- ទញ

| | |
|---|---|
| គ្រូ | - សរសេរ **ទញ** លើក្ដារខៀនរួចចង្អុលនិងអាន **ទ និង ញ ទញ**។ |
| គ្រូនិងសិស្ស | - អាន **ទញ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ទញ** ដោយផ្សំប្រកប។ |

ខ- ទាញ

| | |
|---|---|
| គ្រូ | - សរសេរ **ទាញ** លើក្ដារខៀនរួចចង្អុលនិងអាន **ទ អា ទា និង ញ ទាញ** ។ |
| គ្រូនិងសិស្ស | - អាន **ទាញ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ទាញ** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្ដារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ 🕒 ១៨នាទី

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **ជញ** លើក្ដារខៀនរួចចង្អុលនិងអាន **ជ និង ញ ជញ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **លញ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ធញ គញ ឌញ** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **ជួញ** លើក្ដារខៀនរួចចង្អុលនិងអាន **ជ អួ ជួ និង ញ ជួញ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ពេញ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **រួញ គិញ លៀញ** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ជំនាញ** លើក្ដារខៀនរួចចង្អុលនិងអានជ **អំ ជំ ន អា នា និង ញ នាញ ជំនាញ។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **បំពេញ** លើក្ដារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ពេញលេញ** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- ទំនិញ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ទំនិញ** មានន័យថា **អ្វីៗ ដែលសម្រាប់ឱ្យគេទិញ។** គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ **ទំនិញ ។ មីងសុខទៅទិញទំនិញនៅផ្សារទំនើប។** |
| គ្រូនិងសិស្ស | - អានពាក្យ **ទំនិញ** រួមគ្នា។ គ្រូផ្ដើម **គេលក់...នៅផ្សារ។** សិស្សថា **ទំនិញ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ទំនិញ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ទំនិញ** ជាដៃគូ។ |

ខ- ជំនាញ បង្រៀនដូចពាក្យខាងលើ។ **ជំនាញ** មានន័យថា **ដែលប៉ិនប្រសប់។** ឧ. **ពូបូមានជំនាញឡើងដើមដូង។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **មីងសាញ់ជំនាញខាងលក់ទំនិញ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **មីងសាញ់/ជំនាញ/ខាង/លក់/ទំនិញ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **មីងសាញ់ជំនាញខាងលក់ទំនិញ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **មីងសាញ់ជំនាញខាងលក់ទំនិញ។** |
| សិស្ស | - សិស្សអានល្បះ **មីងសាញ់ជំនាញខាងលក់ទំនិញ។** |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូមិញព្រលទេះទៅណា?**

**២- តើពូមិញទិញទំនិញពីអ្នកណា?**

**៣- តើកូនគិតថា រទេះពូមិញដឹកទំនិញអ្វីខ្លះ?**

**៤- តើឪពុកម្ដាយកូនធ្លាប់នាំកូនទៅទិញទំនិញនៅឯណា? ទិញអ្វីខ្លះ?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **បំពេញ** **ប ◌ំ ព េ◌ ញ** រួចសរសេរ **បំពេញ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ជំនាញ** **ជ ◌ំ ន ◌ា ញ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ជំនួញ ពេញលេញ ទំនិញ** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ជំនាញលក់ទំនិញ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

**មេរៀនទី៤៩២ ប្រកបនឹង □ញ់ (ព្យញ្ជនៈពួក អ៊ី) ⌚ ៨០នាទី**

**លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី**

- គ្រូរំឭកពាក្យដែលបាន រៀនរួច **លិចលង់ សំពោច បំពេញ ចំណោញ ចុះចាញ់។**

**១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី**

- គ្រូបំផុសរកពាក្យ **លញ់** ។ គ្រូបន្លឺ **លញ់**។ គ្រូនិងសិស្សថា **លញ់** ។ សិស្សថា **លញ់** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ល** លើកដៃម្ខាងទៀតថា **ញ លញ បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **លញ់**។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ទ** លើកដៃម្ខាងទៀតថា **ញ ទញ បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **ទញ់**។ |
| សិស្ស | - គ្រូថា **ជ និង ញ បន្តក់មួយ ង និង ញ បន្តក់មួយ ទ និង ញ បន្តក់មួយ** ម្តងមួយៗ<br>- សិស្សផ្សំសូរដោយប្រើដៃ **ជ និង ញ ជញ បន្តក់មួយ ជញ់ ...**។ |

**២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី**

ក- លញ់

| | |
|---|---|
| គ្រូ | - សរសេរ **លញ់** លើក្តារខៀនរួចចង្អុលនិងអាន **ល និង ញ លញ បន្តក់មួយ លញ់**។ |
| គ្រូនិងសិស្ស | - អាន **លញ់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **លញ់** ដោយផ្សំប្រកប។ |

ខ- ជញ់

| | |
|---|---|
| គ្រូ | - សរសេរ **ជញ់** លើក្តារខៀនរួចចង្អុលនិងអាន **ជ និង ញ ជញ បន្តក់មួយ ជញ់**។ |
| គ្រូនិងសិស្ស | - អាន **ជញ់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ជញ់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

**៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី**

**៣.១ - ការអានព្យាង្គ**

**៣.១ - ការអានព្យាង្គ (ស្រះកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **ញញ់** លើក្តារខៀនរួចចង្អុលនិងអាន **ញ និង ញ ញញ បន្តក់មួយ ញញ់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ងញ់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ធញ់ គញ់ ឌញ់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| សិស្ស | - អាន **លញ់** ដោយផ្សំប្រកប។ អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៤- វាក្យសព្ទ ⌚ ៨នាទី**

ក- លញ់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **លញ់ មានន័យថា ធ្វើវត្ថុជ្រាយឱ្យមូល ដោយប្រើបាតដៃ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើ ពាក្យ លញ់ ។ មីងសុខលញ់ម្សៅធ្វើនំផ្លែអាយ។** |
| គ្រូនិងសិស្ស | - អានពាក្យ **លញ់** រួមគ្នា។ គ្រូផ្តើម **ម្តាយខ្ញុំ ... ទៀន**។ សិស្សថា **លញ់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **លញ់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **លញ់** ជាដៃគូ។ |

ខ- ទញ់ បង្រៀនដូចពាក្យខាងលើ។ **ទញ់ មានន័យថា ដែលទើរ កើល ឬទាល់។ ឧ. ពុកទញ់គំនិតដោះស្រាយមិនចេញ។**

## ៥- ការអានល្បះ 🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ប្អូនខ្ញុំចូលចិត្តលញ់ជីលេង**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ប្អូន/ខ្ញុំ/ចូលចិត្ត/លញ់/ជី/លេង**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ប្អូនខ្ញុំចូលចិត្តលញ់ជីលេង** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ប្អូនខ្ញុំចូលចិត្តលញ់ជីលេង**។ |
| សិស្ស | - សិស្សអានល្បះ **ប្អូនខ្ញុំចូលចិត្តលញ់ជីលេង**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី 🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនរណាខ្លះមានជំនាញលក់ទំនិញ?**

**២- តើបងទញ់ទាញទំនិញចេញពីអ្វី?**

**៣- តើកូនគិតថា ហេតុអ្វីបានជាពួកគាត់លក់ទំនិញដាច់?**

**៤- តើកូនធ្លាប់ស្គាល់នរណាលក់ទំនិញ ដែរឬទេ?**
**តើគាត់លក់អ្វីខ្លះ?**

## ៧- ការសរសេរ 🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **លញ់** **ល ញ ់** រួចសរសេរ **លញ់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **លញ់** **ល ញ ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **លញ់ ទញ់ រញ់** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **លញ់នំ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ 🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៥០ ក | ប្រកបនឹង □ត (ព្យញ្ជនៈពួក អ) | ◷ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ◷ ៥នាទី

- គ្រូរំឭកពាក្យដែលបាន រៀនរួច **ជ្ជាញ ឃើញ សាញ សុញ ទច់។**

**១- ការស្គាល់សូរអក្សរថ្មី** ◷ ៥នាទី

- គ្រូបំផុសរកពាក្យ **ថត** ។ គ្រូបន្លឺ **ថត** ។ គ្រូនិងសិស្សថា **ថត** ។ សិស្សថា **ថត** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ថ** លើកដៃម្ខាងទៀតថា **ត** រួច ផ្គុំបាតដៃទាំងពីរថា **ថត**។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ខា** លើកដៃម្ខាងទៀតថា **ត** រួច ផ្គុំបាតដៃទាំងពីរថា **ខាត**។ |
| សិស្ស | - គ្រូថា **ច និង ត ផ និង ត ហ និង ត** រួចឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ។ |

**២- ការស្គាល់តួអក្សរថ្មី** ◷ ៥នាទី

ក- ថត

| | |
|---|---|
| គ្រូ | - សរសេរ **ថត** លើក្តារខៀនរួចចង្អុលនិងអាន **ថ និង ត ថត**។ |
| គ្រូនិងសិស្ស | - អាន **ថត** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ថត** ដោយផ្សំប្រកប។ |

ខ- ខាត

| | |
|---|---|
| គ្រូ | - សរសេរ **ខាត** លើក្តារខៀនរួចចង្អុលនិងអាន **ខ អា ខា និង ត ខាត** ។ |
| គ្រូនិងសិស្ស | - អាន **ខាត** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ខាត** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

**៣- ការអានព្យាង្គនិងពាក្យ** ◷ ១៨នាទី

**៣.១- ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **ចត** លើក្តារខៀនរួចចង្អុលនិងអាន **ច និង ត ចត** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ឡត** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **អត ប៉ត ហត** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **កើត** លើក្តារខៀនរួចចង្អុលនិងអាន **ក អើ កើ និង ត កើត**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ហូត** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **បូត ហឿត ឡើត** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ចំណិត** លើក្តារខៀនរួចចង្អុលនិងអាន **ច អំ ចំ ណ អិ ណិ និង ត ណិត ចំណិត**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **កំណើត** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **កាំបិត** ដោយផ្សំប្រកប។ អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- កាំបិត

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **កាំបិត មានន័យថា ប្រដាប់ធ្វើដោយដែក មានមុខម្ខាង និងដងម្ខាង សម្រាប់ចិតអ្វីមួយ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ** កាំបិត ។ **មីងណៃតកាន់កាំបិតចិតបន្លែ** ។ |
| គ្រូនិងសិស្ស | - អានពាក្យ **កាំបិត** រួមគ្នា។ គ្រូផ្ដើម **ពូសនយក...កាប់មែកឈើ**។ សិស្សថា **កាំបិត** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **កាំបិត** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **កាំបិត** ជាដៃគូ។ |

ខ- ចំណោត បង្រៀនដូចពាក្យខាងលើ។ **ចំណោត មានន័យថា ទី ឬកន្លែងដែលចោត**។ ឧ. **អ៊ំស៊ានរុញរទេះឡើងចំណោតក្បែរភូមិ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពូសុតអួតតាំងពីកំណើត**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពូសុត/អួត/តាំង/ពី/កំណើត**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ពូសុតអួតតាំងពីកំណើត**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពូសុតអួតតាំងពីកំណើត**។ |
| សិស្ស | - សិស្សអានល្បះ **ពូសុតអួតតាំងពីកំណើត**។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើតាសាតកើតនៅឃុំណា ហើយមានមុខរបរអ្វី?**

**២- តើគាត់យកអ្វីដំធ្វើកាំបិត?**

**៣- តើកូនគិតថា ហេតុអ្វីបានជាចៅធើតអួតពីកាំបិតតាសាត?**

**៤- តើម្ដាយឪពុកកូនយកកាំបិតធ្វើអ្វីខ្លះ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាព្យាង្គៗ **ខិតខំ ខ ិ ត ខ ំ** រួចសរសេរ **ខិតខំ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាព្យាង្គៗ **កំណើត ក ំ ណ េ ើ ត** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **សួត ចំណិត រំហួត** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាព្យាង្គៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ខិតខំរៀន** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៥០ ខ | ប្រកបនឹង □ត់ (ព្យញ្ជនៈពួក អ) | 🕒 ៨០នាទី |
|---|---|---|

| លំនឹងថ្នាក់ និងរំឭកមេរៀន | 🕒 ៥នាទី |
|---|---|

- គ្រូរំឭកពាក្យដែលបាន រៀនរួច **លញ់ សួត បាត ចុះចាញ់ បំពេញ។**

| ១- ការស្គាល់សូរអក្សរថ្មី | 🕒 ៥នាទី |
|---|---|

- គ្រូបំផុសរកពាក្យ **បត់** ។ គ្រូបន្លឺ **បត់**។ គ្រូនិងសិស្សថា **បត់**។ សិស្សថា **បត់**។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ប** លើកដៃម្ខាងទៀតថា **ត បន្តក់មួយ** រួចផ្គុំបាតដៃទាំងពីរថា **បត់**។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ហ** លើកដៃម្ខាងទៀតថា **ត បន្តក់មួយ** រួចផ្គុំបាតដៃទាំងពីរថា ហត់។ |
| សិស្ស | - គ្រូថា **កា និង ត បន្តក់មួយ ច និង ត បន្តក់មួយ ហា និង ត បន្តក់មួយ ម្តងមួយៗ**<br>- សិស្សអនុវត្តផ្សំសូរដោយប្រើដៃ **កា និង ត បន្តក់មួយ កាត់** ...។ |

| ២- ការស្គាល់តួអក្សរថ្មី | 🕒 ៥នាទី |
|---|---|

ក- បត់

| | |
|---|---|
| គ្រូ | - សរសេរ **បត់** លើក្តារខៀនរួចចង្អុលនិងអាន **ប និង ត បត បន្តក់មួយ បត់**។ |
| គ្រូនិងសិស្ស | - អាន **បត់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **បត់** ដោយផ្សំប្រកប។ |

ខ- កាត់

| | |
|---|---|
| គ្រូ | - សរសេរ **កាត់** លើក្តារខៀនរួចចង្អុលនិងអាន **ក អា កា និង ត កាត បន្តក់មួយ កាត់**។ |
| គ្រូនិងសិស្ស | - អាន **កាត់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **កាត់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

| ៣- ការអានព្យាង្គនិងពាក្យ | 🕒 ១៨នាទី |
|---|---|

**៣.១ -ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **ចត់** លើក្តារខៀនរួចចង្អុលនិងអាន **ច និង ត ចត បន្តក់មួយ ចត់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **សត់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ប៉ត់ សត់ អត់** ដោយផ្សំប្រកប។ អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **ចាត់** លើក្តារខៀនរួចចង្អុលនិងអាន **ច អា ចា និង ត ចាត បន្តក់មួយ ចាត់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **បាត់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ដាត់ ឡាត់ ប៉ាត់** ដោយផ្សំប្រកប។ អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **កំណាត់** លើក្តារខៀនរួចចង្អុលនិងអាន **ក អំ កំ ណ អា ណា និង ត ណាត បន្តក់មួយ ណាត់ កំណាត់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ម៉ត់ចត់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **បត់បែន** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- រសាត់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **រសាត់ មានន័យថា ហើរ ឬអណ្ដែតតាមខ្យល់ និងតាមទឹក។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ រសាត់ ។ កំណាត់ឈើរសាត់តាមទឹក ។** |
| គ្រូនិងសិស្ស | - អានពាក្យ **រសាត់** រួមគ្នា។ គ្រូផ្ដើម **កំទេចចំបើង...ទៅមក**។ សិស្សថា **រសាត់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **រសាត់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **រសាត់** ជាដៃគូ។ |

ខ- ម៉ត់ចត់ បង្រៀនដូចពាក្យខាងលើ។ **ម៉ត់ចត់ មានន័យថា ដែលយកចិត្តទុកដាក់ ឬដោយច្បាស់លាស់។**

គ្រូថា **មីងជាតិបំពេញការងារដោយម៉ត់ចត់ និងជាក់លាក់។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **កាំបិតបាក់ជាពីរកំណាត់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **កាំបិត/បាក់/ជា/ពីរ/កំណាត់**។

| | |
|---|---|
| គ្រូ | - គ្រូអាន **កាំបិតបាក់ជាពីរកំណាត់**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **កាំបិតបាក់ជាពីរកំណាត់**។ |
| សិស្ស | - សិស្សអានល្បះ **កាំបិតបាក់ជាពីរកំណាត់**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូផាត់លក់អ្វី? ហើយគាត់ជាមនុស្សដូចម្ដេច?**

**២- តើកូនគិតថា ហេតុអ្វីតាខាត់ទិញកាំបិតពូផាត់?**

**៣- តើនឹងមានរឿងអ្វីកើតឡើង ពេលចៅម៉ាត់យកកាំបិតកាត់ឈើលេង?**

**៤- តើកូនគិតថាគួរលេងកាំបិតដូចម៉ាត់ដែរឬទេ? ហេតុអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **កំណាត់ ក ◌ំ ណ ◌ា ត ◌់** រួចសរសេរ **កំណាត់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **រសាត់ រ ស ◌ា ត ◌់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ខាត់ ម៉ត់ចត់ កំសត់** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ឈើពីរកំណាត់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| មេរៀនទី៥១ ក | ប្រកបនឹង ☐ត (ព្យញ្ជនៈពួក អ៊ី) | ⌚ ៨០នាទី |
|---|---|---|

| លំនឹងថ្នាក់ និងរំឭកមេរៀន | ⌚ ៥នាទី |
|---|---|

- គ្រូរំឭកពាក្យដែលបាន រៀនរួច **ទំនិញ កាំបិត ចំណិត ម៉ត់ចត់ កំណាត់ ។**

| ១- ការស្គាល់សូរអក្សរថ្មី | ⌚ ៥នាទី |
|---|---|

- គ្រូបំផុសរកពាក្យ **លត**។ គ្រូបន្លឺ **លត** ។ គ្រូនិងសិស្សថា **លត** ។ សិស្សថា **លត** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ល** លើកដៃម្ខាងទៀតថា **ត** រួច ផ្គុំបាតដៃទាំងពីរថា **លត**។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ពោ** លើកដៃម្ខាងទៀតថា **ត** រួច ផ្គុំបាតដៃទាំងពីរថា **ពោត**។ |
| សិស្ស | - គ្រូថា **ទ និង ត ជូ និង ត រួ និង ត** រួចឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ។ |

| ២- ការស្គាល់តួអក្សរថ្មី | ⌚ ៥នាទី |
|---|---|

ក- លត

| | |
|---|---|
| គ្រូ | - សរសេរ **លត** លើក្តារខៀនរួចចង្អុលនិងអាន **ល និង ត លត**។ |
| គ្រូនិងសិស្ស | - អាន **លត** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **លត** ដោយផ្សំប្រកប។ |

ខ- ជូត

| | |
|---|---|
| គ្រូ | - សរសេរ **ជូត** លើក្តារខៀនរួចចង្អុលនិងអាន **ជ អ៊ូ ជូ និង ត ជូត** ។ |
| គ្រូនិងសិស្ស | - អាន **ជូត** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ជូត** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

| ៣- ការអានព្យាង្គនិងពាក្យ | ⌚ ១៨នាទី |
|---|---|

**៣.១ -ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **មត** លើក្តារខៀនរួចចង្អុលនិងអាន **ម និង ត មត** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **គត** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **អ៊ិត ងត យត** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **លូត** លើក្តារខៀនរួចចង្អុលនិងអាន **ល អ៊ូ លូ និង ត លូត**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ទើត** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **វៀត ឈុត ពើត** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **គំនិត** លើក្តារខៀនរួចចង្អុលនិងអាន **គ អុំ គំ ន អ៊ិ និ និង ត និត គំនិត។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ងងឹត** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ដូតទឹក** ដោយផ្សំប្រកប។ អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- លោត

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **លោត មានន័យថា ស្ទុះឡើងផុតពីដី ឬអ្វីមួយ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ លោត ។ នារីលេងលោតអន្ទាក់ ។** |
| គ្រូនិងសិស្ស | - អានពាក្យ **លោត** រួមគ្នា។ គ្រូផ្ដើម **បងធី...រំលងទឹកថ្លុក។** សិស្សថា **លោត** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **លោត** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **លោត** ជាដៃគូ។ |

ខ- រូតរះ បង្រៀនដូចពាក្យខាងលើ។ **រូតរះ មានន័យថា ប្រញាប់ប្រញាល់ ឧ. ធីតារូតរះទៅសាលារៀន។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **បូណាង្វូតទឹកពាង។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **បូណា/ង្វូត/ទឹក/ពាង។**

| | |
|---|---|
| គ្រូ | - គ្រូអាន **បូណាង្វូតទឹកពាង។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **បូណាង្វូតទឹកពាង។** |
| សិស្ស | - សិស្សអានល្បះ **បូណាង្វូតទឹកពាង។** |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូឈឿតចង់បើកហាងអ្វី?**

**២- តើហាងលតធា និងពោតដុតនៅឯណា?**

**៣- ហេតុអ្វីបានជាមីងលួត និងពូឈឿតគិតចង់បើកហាង?**

**៤- តើកូនចង់ប្រកបមុខរបរអ្វីពេលធំឡើង? ហេតុអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាព្យួ **ងងឹត ង ង ឹ ត** រួចសរសេរ **ងងឹត** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាព្យួ **រលួត រ ល ួ ត** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ញញើត គំនិត ស៊ុតទា** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាព្យួ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ហាងបោកអ៊ុត** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| មេរៀនទី៥១ ខ | ប្រកបនឹង ☐ត់ (ព្យញ្ជនៈពួក អ៊ី) | ◷ ៨០នាទី |
|---|---|---|

| លំនឹងថ្នាក់ និងរំឭកមេរៀន | ◷ ៥នាទី |
|---|---|

- គ្រូរំឭកពាក្យដែលបានរៀនរួច **លោត ពោត សួត បាត់ ជួញ។**

| ១- ការស្គាល់សូរអក្សរថ្មី | ◷ ៥នាទី |
|---|---|

- គ្រូបំផុសរកពាក្យ **ពត់** ។ គ្រូបន្លឺ **ពត់**។ គ្រូនិងសិស្សថា **ពត់**។ សិស្សថា **ពត់**។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ព** លើកដៃម្ខាងទៀតថា **ត បន្តក់មួយ** រួចផ្តុំបាតដៃទាំងពីរថា **ពត់**។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ល** លើកដៃម្ខាងទៀតថា **ត បន្តក់មួយ** រួចផ្តុំបាតដៃទាំងពីរថា **លត់**។ |
| សិស្ស | - គ្រូថា **មា និង ត បន្តក់មួយ គានិង ត បន្តក់មួយ ទា និង ត បន្តក់មួយ** ម្តងមួយៗ។<br>- សិស្សផ្សំសូរដោយប្រើដៃ **មា និងត បន្តក់មួយ មាត់** ....។ |

| ២- ការស្គាល់តួអក្សរថ្មី | ◷ ៥នាទី |
|---|---|

ក- ពត់

| | |
|---|---|
| គ្រូ | - សរសេរ **ពត់** លើក្តារខៀនរួចចង្អុលនិងអាន **ព និង ត ពត បន្តក់មួយ ពត់**។ |
| គ្រូនិងសិស្ស | - អាន **ពត់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ពត់** ដោយផ្សំប្រកប។ |

ខ- ទាត់

| | |
|---|---|
| គ្រូ | - សរសេរ **ទាត់** លើក្តារខៀនរួចចង្អុលនិងអាន **ទ អា ទា និង ត ទាត បន្តក់មួយ ទាត់**។ |
| គ្រូនិងសិស្ស | - អាន **ទាត់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ទាត់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

| ៣- ការអានព្យាង្គនិងពាក្យ | ◷ ១៨នាទី |
|---|---|

**៣.១ - ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **រត់** លើក្តារខៀនរួចចង្អុលនិងអាន **រ និង ត រត បន្តក់មួយ រត់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **គត់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ហ៊ត់ លត់ ជត់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **ជាត់** លើក្តារខៀនរួចចង្អុលនិងអាន **ជ អា ជា និង ត ជាត បន្តក់មួយ ជាត់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **មាត់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **លាត់ វាត់ គាត់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **សំពត់** លើក្តារខៀនរួចចង្អុលនិងអាន **ស អំ សំ ព និង ត ពត បន្តក់មួយ ពត់ សំពត់។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រលត់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ធំធាត់** ដោយផ្សំប្រកប។ អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- សំពត់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **សំពត់ មានន័យថា របស់ដែលកើតពីការត្បាញ ដែលប្រើសម្រាប់ស្លៀក គ្រប ឬដណ្ដប់។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ** សំពត់ ។ **ដានីទិញសំពត់បត់មួយ។** |
| គ្រូនិងសិស្ស | - អានពាក្យ **សំពត់** រួមគ្នា។ គ្រូផ្ដើម **ទីណាយក...ចែកពូមីង។** សិស្សថា **សំពត់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **សំពត់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **សំពត់** ជាដៃគូ។ |

ខ- ពត់ បង្រៀនដូចពាក្យខាងលើ។ **ពត់ មានន័យថា តម្រង់ឱ្យត្រង់ ឬកោងតាមចិត្តចង់បាន។ ឧ. អ្នករបាំខំពត់ម្រាមដៃឱ្យង។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **មីងស៊ត់បោកអ៊ុតទៀងទាត់។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **មីងស៊ត់/បោក/អ៊ុត/ទៀងទាត់។**

| | |
|---|---|
| គ្រូ | - គ្រូអាន **មីងស៊ត់បោកអ៊ុតទៀងទាត់។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **មីងស៊ត់បោកអ៊ុតទៀងទាត់។** |
| សិស្ស | - សិស្សអានល្បះ **មីងស៊ត់បោកអ៊ុតទៀងទាត់។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើបងហ៊ាត់លេងទាត់អ្វី?**

**២- តើបងហ៊ាត់មានរូបរាងដូចម្ដេច?**

**៣- ហេតុអ្វីបានជាបងហ៊ាត់មានរូបរាងរឹងមាំ?**

**៤- តើកូនគិតថាការទាត់សីមានផលប្រយោជន៍អ្វីខ្លះ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **រលោត់ រ ល ោ ត ់** រួចសរសេរ **រលោត់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮ **រំពាត់ រ ំ ព ា ត ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **គត់មត់ ធំធាត់ បាល់ទាត់** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ងូតទឹកទៀងទាត់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៥២ ក | ប្រកបនឹង □ន (ព្យញ្ជនៈពួក អ) | ⌚ ៨០នាទី |
|---|---|---|

| លំនឹងថ្នាក់ និងរំឭកមេរៀន | ⌚ ៥នាទី |
|---|---|

- គ្រូរំឭកពាក្យដែលបានរៀនរួច **សំពត់ រលាត់ ងងឹត រលូត អំនួត** ។

| ១- ការស្គាល់សូរអក្សរថ្មី | ⌚ ៥នាទី |
|---|---|

- គ្រូធ្វើកាយវិការពត់ខ្លួនបំផុសរកពាក្យ **អែនអន។** គ្រូបន្លឺ **អន** ។ គ្រូនិងសិស្សថា **អន។** សិស្សថា **អន។**

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **អ** លើកដៃម្ខាងទៀតថា **ន** រួច ផ្គុំបាតដៃទាំងពីរថា **អន** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ចា** លើកដៃម្ខាងទៀតថា **ន** រួច ផ្គុំបាតដៃទាំងពីរថា **ចាន។** |
| សិស្ស | - គ្រូថា **កូ និងន ប៊ុ និង ន ណៃ និង ន** ម្តងមួយៗឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ។ |

| ២- ការស្គាល់តួអក្សរថ្មី | ⌚ ៥នាទី |
|---|---|

ក- អន

| | |
|---|---|
| គ្រូ | - សរសេរ **អន** លើក្តារខៀនរួចចង្អុលនិងអាន **អ និង ន អន។** |
| គ្រូនិងសិស្ស | - អាន **អន** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **អន** ដោយផ្សំប្រកប។ |

ខ- ចាន

| | |
|---|---|
| គ្រូ | - សរសេរ **ចាន** លើក្តារខៀនរួចចង្អុលនិងអាន **ច អា ចា និង ន ចាន។** |
| គ្រូនិងសិស្ស | - អាន **ចាន** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ចាន** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

| ៣- ការអានព្យញ្ជនៈនិងពាក្យ | ⌚ ១៨នាទី |
|---|---|

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **ខន** លើក្តារខៀនរួចចង្អុលនិងអាន **ខ និង ន ខន** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចន** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ប៉ន រ៉ន សន** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **បាន** លើក្តារខៀនរួចចង្អុលនិងអាន **ប អា បា និង ន បាន។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **កើន** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ហួន អៀន សោន** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **អំណាន** លើក្តារខៀនរួចចង្អុលនិងអាន **អ អំ អំ ណ អា ណា និង ន ណាន អំណាន។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចេកចៀន** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ថៃថ្មួន** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- តឿន

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **តឿន មានន័យថា និយាយបង្ខំឱ្យធ្វើអ្វីមួយឱ្យបានឆាប់។ គ្រូនឹងបង្កើតល្បះមួយដោយប្រើ** ពាក្យ **តឿន** ។ **ពុកតឿនកូនៗឱ្យធ្វើកិច្ចការផ្ទះ មុនចូលគេង។** |
| គ្រូនិងសិស្ស | - អានពាក្យ **តឿន** រួមគ្នា។ គ្រូផ្ដើម **ម៉ែ......ខ្ញុំឱ្យឆាប់ងូតទឹក។** សិស្សថា **តឿន** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **តឿន** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **តឿន** ជាដៃគូ។ |

ខ- ប៉ិន បង្រៀនដូចពាក្យខាងលើ។ **ប៉ិន មានន័យថា ពូកែ ស្ទាត់ ប្រសប់** ។ ឧ. **ពុកប៉ិនតឿនកូនអានរឿង។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **បងណាន និងកូនពូកែថៃសួន។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **បងណាន/ និង/កូន/ពូកែ/ថៃ/សួន។**

| | |
|---|---|
| គ្រូ | - គ្រូអាន **បងណាន និងកូនពូកែថៃសួន។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **បងណាន និងកូនពូកែថៃសួន។** |
| សិស្ស | - សិស្សអានល្បះ **បងណាន និងកូនពូកែថៃសួន។** |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើសាខន និងសានម្នាក់ៗពូកែធ្វើអ្វី?**

**២- តើសាននាំសាខនធ្វើអ្វី?**

**៣- តើកូនគិតថា ហេតុអ្វីម៉ែថាកូននឹងកើនចំណេះ?**

**៤- តើកូនធ្លាប់អានរឿង និងគូរគំនូរអ្វីខ្លះ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ចំណាន ច ំ ណ ា ន** រួចសរសេរ **ចំណាន** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **អំណាន អ ំ ណ ា ន** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ខែខាន សំណែន កង់ឡាន** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **តឿនកូនអាន** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៥២ ខ | ប្រកបនឹង □ន់ (ព្យញ្ជនៈពួក អ) | ⏲ ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ⏲ ៥នាទី

- គ្រូរំឭកពាក្យដែលបាន រៀនរួច **ចេកចៀន ថៃថ្ងូន ធំធាត់ ចំណត ទំនិញ**។

## ១- ការស្គាល់សូរអក្សរថ្មី ⏲ ៥នាទី

- គ្រូបំផុសរកពាក្យ **បន់**។ គ្រូបន្លឺ **បន់**។ គ្រូនិងសិស្សថា **បន់**។ សិស្សថា **បន់**។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ប** លើកដៃម្ខាងទៀតថា **ន បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **បន់** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ចា** លើកដៃម្ខាងទៀតថា **ន បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **ចាន់**។ |
| សិស្ស | - គ្រូថា **កា និង ន បន្តក់មួយ ឆា និង ន បន្តក់មួយ ខា និង ន បន្តក់មួយ** ម្តងមួយៗ។<br>- សិស្សផ្សំសូរដោយប្រើដៃ **កា និងន កាន បន្តក់មួយ កាន់ ...**។ |

## ២- ការស្គាល់តួអក្សរថ្មី ⏲ ៥នាទី

ក- បន់

| | |
|---|---|
| គ្រូ | - សរសេរ **បន់** លើក្តារខៀនរួចចង្អុលនិងអាន **ប និង ន បន បន្តក់មួយ បន់**។ |
| គ្រូនិងសិស្ស | - អាន **បន់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **បន់** ដោយផ្សំប្រកប។ |

ខ- ឆាន់

| | |
|---|---|
| គ្រូ | - សរសេរ **ឆាន់** លើក្តារខៀនរួចចង្អុលនិងអាន **ឆ អា ឆា និង ន ឆាន បន្តក់មួយ ឆាន់**។ |
| គ្រូនិងសិស្ស | - អាន **ឆាន់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ឆាន់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ ⏲ ១៨នាទី

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **អន់** លើក្តារខៀនរួចចង្អុលនិងអាន **អ និង ន អន បន្តក់មួយ អន់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ប៉ន់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **រ៉ន់ កន់ ហន់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **ហាន់**លើក្តារខៀនរួចចង្អុលនិងអាន **ហ អា ហា និង ន ហាន បន្តក់មួយ ហាន់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចាន់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ដាន់ ប៉ាន់ ណាន់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **សំខាន់** លើក្តារខៀនរួចចង្អុលនិងអាន **ស អំ សំ ខ អា ខា និង ន ខាន បន្តក់មួយ ខាន់ សំខាន់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ណែនណាន់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ប៉ាន់តៃ** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- កាន់ជើង

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **កាន់ជើង មានន័យថា លម្អៀងទៅម្ខាង។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ កាន់ជើង។ ពុកម៉ែថាគាត់មិនកាន់ជើងកូនណាមួយឡើយ។** |
| គ្រូនិងសិស្ស | - អានពាក្យ **កាន់ជើង** រួមគ្នា។ គ្រូផ្ដើម **ពូសាន...កូនពៅជាងគេ។** សិស្សថា **កាន់ជើង** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **កាន់ជើង** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **កាន់ជើង** ជាដៃគូ។ |

ខ- ណែនណាន់ បង្រៀនដូចពាក្យខាងលើ។ **ណែនណាន់ មានន័យថា កុះករ ជុំជិត ។ ឧ. មនុស្សច្រើនណែនណាន់នៅពេលបុណ្យអុំទូក។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **អំសាន់ចំអន់ម៉ែថាកាន់ជើងកូន។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **អំសាន់/ចំអន់/ម៉ែ/ថា/កាន់ជើង/កូន។**

| | |
|---|---|
| គ្រូ | - គ្រូអាន **អំសាន់ចំអន់ម៉ែថាកាន់ជើងកូន។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **អំសាន់ចំអន់ម៉ែថាកាន់ជើងកូន។** |
| សិស្ស | - សិស្សអានល្បះ **អំសាន់ចំអន់ម៉ែថាកាន់ជើងកូន ។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើមីងចាន់នាំតន់ធ្វើអ្វី?**

**២- តើរឿងដែលមីងចាន់ និងតន់អាននិយាយពីអ្វី?**

**៣- តើកូនគិតថា ហេតុអ្វីបានជាចៅណាន់ចេះហោះ?**

**៤- តើកូនគិតថារឿងចៅណាន់ជារឿងពិតដែរឬទេ? ព្រោះអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាព្យា **ដុកដាន់ ដ ុ ក ដ ា ន ់** រួចសរសេរ **ដុកដាន់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាព្យា **សំខាន់ ស ំ ខ ា ន ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ណែនណាន់ បែបន់ ខាន់ខៅ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាព្យាៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ចំអែចំអន់លេង** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៥៣ ក | ប្រកបនឹង ◻ន (ព្យញ្ជនៈពួក អ៊ី) | ⌚ ៨០នាទី |
|---|---|---|

| លំនឹងថ្នាក់ និងរំឭកមេរៀន | ⌚ ៥នាទី |
|---|---|

- គ្រូរំឭកពាក្យដែលបាន រៀនរួច **សំខាន់ ដុកដាន់ រំខាន ចំណាន សំពត់** ។

| ១- ការស្គាល់សូរអក្សរថ្មី | ⌚ ៥នាទី |
|---|---|

- គ្រូបំផុសរកពាក្យ **មន។** គ្រូបន្លឺ **មន** ។ គ្រូនិងសិស្សថា**មន។** សិស្សថា **មន**។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ម** លើកដៃម្ខាងទៀតថា **ន** រួច ផ្គុំបាតដៃទាំងពីរថា **មន** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **មា** លើកដៃម្ខាងទៀតថា **ន** រួច ផ្គុំបាតដៃទាំងពីរថា **មាន**។ |
| សិស្ស | - គ្រូថា **ពួ និងន លឿ និង ន តែ និង ន** ម្តងមួយៗឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ |

| ២- ការស្គាល់តួអក្សរថ្មី | ⌚ ៥នាទី |
|---|---|

ក- មន

| | |
|---|---|
| គ្រូ | - សរសេរ **មន** លើក្តារខៀនរួចចង្អុលនិងអាន **ម និង ន មន**។ |
| គ្រូនិងសិស្ស | - អាន **មន** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **មន** ដោយផ្សំប្រកប។ |

ខ- ពួន

| | |
|---|---|
| គ្រូ | - សរសេរ **ពួន** លើក្តារខៀនរួចចង្អុលនិងអាន **ព អួ ពួ និង ន ពួន**។ |
| គ្រូនិងសិស្ស | - អាន **ពួន** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ពួន** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

| ៣- ការអានព្យាង្គនិងពាក្យ | ⌚ ១៨នាទី |
|---|---|

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **លន** លើក្តារខៀនរួចចង្អុលនិងអាន **ល និង ន លន** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ភន** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ងន នន ពន** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **លឿន** លើក្តារខៀនរួចចង្អុលនិងអាន **ល អឿ លឿ និង ន លឿន**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **លុន** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ពិន ជោន វៀន** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ចំនួន** លើក្តារខៀនរួចចង្អុលនិងអាន**ច អំ ចំ ន អួ នួ និង ន នួន ចំនួន។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ទំពួន** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ជឿនលឿន** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- ជឿនលឿន

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ជឿនលឿន មានន័យថា រីកចម្រើន ល្អជាងមុន។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ជឿនលឿន។ ការសិក្សារបស់សិស្សជឿនលឿនជាងមុន។** |
| គ្រូនិងសិស្ស | - អានពាក្យ **ជឿនលឿន** រួមគ្នា។ គ្រូផ្ដើម **មុខរបរគ្រួសារខ្ញុំ......ច្រើនជាងមុន។** សិស្សថា **ជឿនលឿន** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ជឿនលឿន** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ជឿនលឿន** ជាដៃគូ។ |

ខ- មាំមួន បង្រៀនដូចពាក្យខាងលើ។ **មាំមួន មានន័យថា រឹងប៉ឹង មាំទាំ** ។ ឧ. **ជីតាខ្ញុំមានសុខភាពមាំមួនណាស់។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **មីងអ៊ុនទិញមៀន និងទុរេនជូនតារឿន។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **មីងអ៊ុន/ទិញ/មៀន/ និង/ទុរេន/ជូន/តារឿន។**

| | |
|---|---|
| គ្រូ | - គ្រូអាន **មីងអ៊ុនទិញមៀន និងទុរេនជូនតារឿន។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **មីងអ៊ុនទិញមៀន និងទុរេនជូនតារឿន។** |
| សិស្ស | - សិស្សអានល្បះ **មីងអ៊ុនទិញមៀន និងទុរេនជូនតារឿន ។** |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូប៊ុនជឿន និងប៊ុនហ៊ុនត្រូវជាអ្វីនឹងគ្នា?**

**២- តើពូប៊ុនជឿនជាមនុស្សដូចម្ដេច?**

**៣- ហេតុអ្វីពូប៊ុនជឿនតឿនប៊ុនហ៊ុនឱ្យខំរៀនរហូតបានពាន?**

**៤- តើកូនត្រូវធ្វើដូចម្ដេច ដើម្បីក្លាយជាសិស្សពូកែដូចប៊ុនហ៊ុន?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **គំគួន គ ◌ំ គ ◌ួ ន** រួចសរសេរ **គំគួន** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **មែនទែន ម ◌ែ ន ទ ◌ែ ន** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **និទាន មាំមួន ជឿនលឿន** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **អានរឿងនិទាន** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៥៣ ខ | ប្រកបនឹង ◻ន់ (ព្យញ្ជនៈពួក អ៊ី) | 🕒 ៨០នាទី |
|---|---|---|

| លំនឹងថ្នាក់ និងរំឭកមេរៀន | 🕒 ៥នាទី |
|---|---|

- គ្រូរំឭកពាក្យដែលបាន រៀនរួច **ជីដូន និទាន រួសរាន់ ដើមចាន់ រលាត់**។

| ១- ការស្គាល់សូរអក្សរថ្មី | 🕒 ៥នាទី |
|---|---|

- គ្រូបំផុសរកពាក្យ **ទន់** ។ គ្រូបំផុសរកពាក្យ **ទន់**។ គ្រូបន្លឺ **ទន់**។ គ្រូនិងសិស្សថា **ទន់**។ សិស្សថា **ទន់**។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ទ** លើកដៃម្ខាងទៀតថា **ន បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **ទន់** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **មា** លើកដៃម្ខាងទៀតថា **ន បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **មាន់**។ |
| សិស្ស | - គ្រូថា **ទា និងន បន្តក់មួយ លា** និង **ន បន្តក់មួយ រា** និង **ន បន្តក់មួយ** ម្តងមួយៗ<br>- សិស្សផ្សំសូរដោយប្រើដៃ **ទា និង ន បន្តក់មួយ ទាន់ ...** ។ |

| ២- ការស្គាល់តួអក្សរថ្មី | 🕒 ៥នាទី |
|---|---|

ក- ទន់

| | |
|---|---|
| គ្រូ | - សរសេរ **ទន់** លើក្តារខៀនរួចចង្អុលនិងអាន **ទ និង ន ទន បន្តក់មួយ ទន់**។ |
| គ្រូនិងសិស្ស | - អាន **ទន់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ទន់** ដោយផ្សំប្រកប។ |

ខ- ទាន់

| | |
|---|---|
| គ្រូ | - សរសេរ **ទាន់** លើក្តារខៀនរួចចង្អុលនិងអាន **ទ អា ទា និង ន ទាន បន្តក់មួយ ទាន់**។ |
| គ្រូនិងសិស្ស | - អាន **ទាន់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ទាន់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

| ៣- ការអានព្យាង្គនិងពាក្យ | 🕒 ១៨នាទី |
|---|---|

### ៣.១- ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **ពន់** លើក្តារខៀនរួចចង្អុលនិងអាន **ព និង ន ពន បន្តក់មួយ ពន់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ធន់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **វន់ លន់ នន់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **ពាន់** លើក្តារខៀនរួចចង្អុលនិងអាន **ព អា ពា និង ន ពាន បន្តក់មួយ ពាន់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រាន់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ជាន់ លាន់ ញាន់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ជំនាន់** លើក្តារខៀនរួចចង្អុលនិងអាន **ជ អំ ជំ ន អា នា និង ន នាន បន្តក់មួយ នាន់ ជំនាន់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ពេកពន់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **អត់ធន់** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- រាន់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **រាន់ មានន័យថា បន្ទាន់ទប់មិនឈ្នះ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ រាន់។ មេមាន់រាន់ពង។** |
| គ្រូនិងសិស្ស | - អានពាក្យ **រាន់** រួមគ្នា។ គ្រូផ្ដើម **ខ្ញុំឈឺពោះ......ចូលបន្ទប់ទឹក។** សិស្សថា **រាន់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **រាន់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **រាន់** ជាដៃគូ។ |

ខ- អត់ធន់ បង្រៀនដូចពាក្យខាងលើ។ **អត់ធន់ មានន័យថា ទ្រាំ អត់ធ្មត់ ស៊ូ ។ ឧ. គាត់ប្រើខ្ញុំឱ្យធ្វើការច្រើនយ៉ាង តែខ្ញុំអាចអត់ធន់បាន។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **មេមាន់ពូគាន់ជាន់មែកមៀនឡើងទន់។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **មេ/មាន់/ពូគាន់/ជាន់/មែក/មៀន/ឡើង/ទន់។**

| | |
|---|---|
| គ្រូ | - គ្រូអាន **មេមាន់ពូគាន់ជាន់មែកមៀនឡើងទន់។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **មេមាន់ពូគាន់ជាន់មែកមៀនឡើងទន់។** |
| សិស្ស | - សិស្សអានល្បះ **មេមាន់ពូគាន់ជាន់មែកមៀនឡើងទន់។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើមេមាន់កើតអ្វី បានជាវារត់លាន់សូរអឹងកង ?**

**២- តើវារត់ជាន់មែកអ្វី?**

**៣- តើកូនគិតថា ហេតុអ្វីពូគាន់ខំថែមាន់គាត់?**

**៤- តើមាន់ផ្ដល់ផលអ្វីខ្លះដល់យើង?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ទោរទន់ ទ ោ រ ទ ន ់** រួចសរសេរ **ទោរទន់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮ **គយគន់ គ យ គ ន ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **អត់ធន់ ជំនន់ លន់តួ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **មិនទាន់មានជំនន់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| មេរៀនទី៥៤ក | ប្រកបនឹង ◻ប (ព្យញ្ជនៈពួក អ) | ⌚ ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **សំពត់ ចេកចៀន ណែនណាន់ ពត់ពេន មេមាន់** ។

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **ដប** ។ គ្រូបន្លឺ **ដប** ។ គ្រូនិងសិស្សថា **ដប** ។ សិស្សថា **ដប** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ដ** លើកដៃម្ខាងទៀតថា **ប** រួច ផ្គុំបាតដៃទាំងពីរថា **ដប** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ចា** លើកដៃម្ខាងទៀតថា **ប** រួច ផ្គុំបាតដៃទាំងពីរថា **ចាប**។ |
| សិស្ស | - គ្រូថា **កឺ និង ប ឆៃ និង ប តូ និង ប** ម្តងមួយៗឱ្យសិស្សអនុវត្តផ្សំសូរដោយប្រើដៃដូចខាងលើ។ |

## ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

ក- ដប

| | |
|---|---|
| គ្រូ | - សរសេរ **ដប** លើក្តារខៀនរួចចង្អុលនិងអាន **ដ និង ប ដប**។ |
| គ្រូនិងសិស្ស | - អាន **ដប** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ដប** ដោយផ្សំប្រកប។ |

ខ- ចាប

| | |
|---|---|
| គ្រូ | - សរសេរ **ចាប** លើក្តារខៀនរួចចង្អុលនិងអាន **ច អា ចា និង ប ចាប** ។ |
| គ្រូនិងសិស្ស | - អាន **ចាប** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ចាប** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **តប** លើក្តារខៀនរួចចង្អុលនិងអាន **ត និង ប តប** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចប** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **អប កប សប** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **ឆៃប** លើក្តារខៀនរួចចង្អុលនិងអាន **ឆ អៃ ឆៃ និង ប ឆៃប** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ដាប** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **បែប ហូប ចើប** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **សំណាប** លើក្តារខៀនរួចចង្អុលនិងអាន **ស អំ សំ ណ អា ណា និង ប ណាប សំណាប**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រសើប** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ដងចប** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- ឆាប

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ឆាប មានន័យថា ហើរហក់ចុះទាប ដើម្បីចាប់អ្វីមួយ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ឆាប។ ខ្លែងឆាបកូនមាន់។** |
| គ្រូនិងសិស្ស | - អានពាក្យ **ឆាប** រួមគ្នា។ គ្រូផ្ដើម **ស្ទាំង..........ត្រីក្នុងត្រពាំង។** សិស្សថា **ឆាប** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ឆាប** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ឆាប** ជាដៃគូ។ |

ខ- តប បង្រៀនដូចពាក្យខាងលើ។ **តប មានន័យថា ឆ្លើយវិញ សងវិញ។ ឧ. សុខាឆ្លើយតបនឹងសំណួរគ្រូ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ចាបយំចេបៗលើមែកចាន់។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ចាប/យំ/ចេបៗ/លើ/មែកចាន់/។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ចាបយំចេបៗលើមែកចាន់។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ចាបយំចេបៗលើមែកចាន់។** |
| សិស្ស | - សិស្សអានល្បះ **ចាបយំចេបៗលើមែកចាន់។** |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១ -តើកូនចាបយំនៅឯណា?**

**២- តើចៅកូបលើកអ្វីដេញទាកាប?**

**៣- តើកូនគិតថា ហេតុអ្វីបានជាចៅកូបជួយកូនចាប?**

**៤- តើកូនចូលចិត្តសត្វអ្វីខ្លះ? ព្រោះអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **សំណាប** ស ំ ណ ា ប រួចសរសេរ **សំណាប** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **រសើប រ ស ើ ប** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ដែកថៃប របៀប រណប** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ដកសំណាប** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៥៤៩ | ប្រកបនឹង □ប់ (ព្យញ្ជនៈពួក អ) | ◷ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ◷ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ណែនណាន់ ពត់ពេន មេមាន់ សំណាប ណេប** ។

**១- ការស្គាល់សូរអក្សរថ្មី** ◷ ៥នាទី

- គ្រូបំផុសរកពាក្យ **ដប់** ។ គ្រូបន្លឺ **ដប់** ។ គ្រូនិងសិស្សថា **ដប់** ។ សិស្សថា **ដប់** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ដ** លើកដៃម្ខាងទៀតថា **ប បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **ដប់** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ចា** លើកដៃម្ខាងទៀតថា **ប បន្តក់មួយ** រួច ផ្គុំបាតដៃទាំងពីរថា **ចាប់**។ |
| សិស្ស | - គ្រូថា **ក និង ប បន្តក់មួយ អ និង ប បន្តក់មួយ ឡ និង ប បន្តក់មួយ** ម្តងមួយៗ<br>- សិស្សអនុវត្តផ្សំសូរដោយប្រើដៃ **ក និង ប បន្តក់មួយ កប់** ...។ |

**២- ការស្គាល់តួអក្សរថ្មី** ◷ ៥នាទី

ក- ដប់

| | |
|---|---|
| គ្រូ | - សរសេរ **ដប់** លើក្តារខៀនរួចចង្អុលនិងអាន **ដ និង ប ដប បន្តក់មួយ ដប់**។ |
| គ្រូនិងសិស្ស | - អាន **ដប់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ដប់** ដោយផ្សំប្រកប។ |

ខ- ចាប់

| | |
|---|---|
| គ្រូ | - សរសេរ **ចាប់** លើក្តារខៀនរួចចង្អុលនិងអាន **ច អា ចា និង ប ចាប បន្តក់មួយ ចាប់**។ |
| គ្រូនិងសិស្ស | - អាន **ចាប់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ចាប់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និង សួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

**៣- ការអានព្យាង្គនិងពាក្យ** ◷ ១៨នាទី

**៣.១ - ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **តប់** លើក្តារខៀនរួចចង្អុលនិងអាន **ត និង ប តប បន្តក់មួយ តប់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **សប់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **កប់ ចប់ ហប់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **កាប់** លើក្តារខៀនរួចចង្អុល និងអាន **ក អា កា និង ប កាប បន្តក់មួយ កាប់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ដាប់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ហាប់ សាប់ ឆាប់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ចំណាប់** លើក្តារខៀនរួចចង្អុល និងអាន **ច អំ ចំ ណ អា ណា និង ប ណាប បន្តក់មួយ ណាប់ ចំណាប់** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចបកាប់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **ចំបាប់** ដោយផ្សំប្រកប។ អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- កុកសាប់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **កុកសាប់ មានន័យថា ជាសត្វកុកមួយប្រភេទដែលមានរោមស្លាបខាងក្រៅពណ៌ប្រផេះ និងរោមស្លាបខាងក្នុងពណ៌ស។** គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ កុកសាប់។ **ខ្ញុំឃើញកុកសាប់ចុះក្នុងស្រែ។** |
| គ្រូនិងសិស្ស | - អានពាក្យ **កុកសាប់**រួមគ្នា។ គ្រូផ្ដើម **សុខឃើញ ...............ចឹកត្រីក្នុងត្រពាំង។** សិស្សថា **កុកសាប់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **កុកសាប់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **កុកសាប់** ជាដៃគូ។ |

ខ- ចំណាប់ បង្រៀនដូចពាក្យខាងលើ។ **ចំណាប់ មានន័យថា ដែលពូកែ។ ឧ. សុខាជាសិស្សចំណាប់ខាងគិតលេខ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **កុកសាប់ចាប់ចំណី**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **កុកសាប់/ចាប់/ចំណី**។

| | |
|---|---|
| គ្រូ | - គ្រូអាន **កុកសាប់ចាប់ចំណី**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **កុកសាប់ចាប់ចំណី**។ |
| សិស្ស | - សិស្សអានល្បះ **កុកសាប់ចាប់ចំណី**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើប៉ប់លីចបទៅណា?**

**២- តើប៉ប់ទុកចបរួចគាត់ទៅណា?**

**៣- តើកូនគិតថា ចៅប៉ប់កាប់ដីធ្វើអ្វី?**

**៤- តើកូនធ្លាប់ឃើញគេកាប់ដីឬទេ? គេកាប់ធ្វើអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ចបកាប់** **ច ប ក ា ប ់** រួចសរសេរ **ចបកាប់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ចំបាប់** **ច ំ ប ា ប ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
- គ្រូសរសេរល្បះ **តាលារពរងារនៅបឹង**។គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**

- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **តាលាវ/រាវ/ងាវ/នៅ/បឹង។**

| | |
|---|---|
| គ្រូ | - គ្រូអាន **តាលាវរាវងាវនៅបឹង។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **តាលាវរាវងាវនៅបឹង។** |
| សិស្ស | - សិស្សអានល្បះ **តាលាវរាវងាវនៅបឹង។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយសិស្ស។

**១- តើពូលាវចែវទូកទៅណា? ជាមួយនរណា?**

**២- តើពួកគេរាវងាវយកទៅធ្វើអ្វី?**

**៣- តើកូនគិតថាតើពួកគេលក់ងាវជាច់ដែរឬទេ?ព្រោះអ្វី?**

**៤- តើកូនដឹងថា គេយកងាវទៅធ្វើម្ហូបអ្វីខ្លះ?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ការដូង** គ ា រ ដ ូ ង រួចសរសេរ **ការដូង** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **អំពាវនាវ** អ ំ ព ា វ ន ា វ រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ជំទាវ វងាវ គុយទាវ** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ឆាគុយទាវ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| មេរៀនទី ៦៣ ក | ប្រកបនឹង □ស (ព្យញ្ជនៈពួក អ) | ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន (៥នាទី)

- គ្រូរំឭកពាក្យដែលបាន រៀនរួច **រាវ អំពាវនាវ សៀវភៅ ឡេវអាវ យល់** ។

## ១- ការស្គាល់សូរអក្សរថ្មី (៥នាទី)

- គ្រូបំផុសរកពាក្យ **ចាស**។ គ្រូបន្លឺ **ចាស**។ គ្រូនិងសិស្សថា **ចាស**។ សិស្សថា **ចាស**។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ចា** លើកដៃម្ខាងទៀតថា **ស** រួច ផ្គុំបាតដៃទាំងពីរថា **ចាស** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **ប** លើកដៃម្ខាងទៀតថា **ស** រួច ផ្គុំបាតដៃទាំងពីរថា **បស** ។ |
| សិស្ស | - គ្រូថា **ខ** និង **ស ក** និង **ស ឡ** និង **ស** ម្តងមួយៗឱ្យសិស្សអនុវត្តផ្សំសូរដោយប្រើដៃដូចខាងលើ។ |

## ២- ការស្គាល់តួអក្សរថ្មី (៥ នាទី)

ក-បស

| | |
|---|---|
| គ្រូ | - សរសេរ **បស** លើក្តារខៀនរួចចង្អុលនិងអាន **ប និង ស បស**។ |
| គ្រូនិងសិស្ស | - អាន **បស** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **បស** ដោយផ្សំប្រកប។ |

ខ- ចាស

| | |
|---|---|
| គ្រូ | - សរសេរ **ចាស** លើក្តារខៀនរួចចង្អុលនិងអាន **ច អា ចា និង ស ចាស** ។ |
| គ្រូនិងសិស្ស | - អាន **ចាស** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ចាស** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

## ៣- ការអានព្យាង្គនិងពាក្យ (១៨នាទី)

### ៣.១- ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រះកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **ចស** លើក្តារខៀនរួចចង្អុលនិងអាន **ច និង ស ចស**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ឡស** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ថស សស កស** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រះនិស្ស័យ)

| | |
|---|---|
| គ្រូ | - សរសេរ **កោស** លើក្តារខៀនរួចចង្អុលនិងអាន **ក អោ កោ និង ស កោស** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **បូស** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ដុស សែស សួស** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **កំហុស** លើក្តារខៀនរួចចង្អុលនិងអាន **ក អំ កំ ហ អុ ហុ និង ស ហុស កំហុស**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **បំបួស** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **របួស** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- កៀស

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **កៀស** **មានន័យថា ឆ្កឹះ ឆ្កៀសដោយខ្សៀស។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ កៀស។ ជីតាខ្ញុំកំពុងកៀសដីនៅក្រោយផ្ទះ។** |
| គ្រូនិងសិស្ស | - អានពាក្យ **កៀស**រួមគ្នា។ គ្រូផ្ដើម **ជាងកំបោរកំពុងតែ......ស៊ីម៉ង់ត៍ជញ្ជាំងផ្ទះ។** សិស្សថា **កៀស** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **កៀស** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **កៀស** ជាដៃគូ។ |

ខ- កោស បង្រៀនដូចពាក្យខាងលើ។ **កោស មានន័យថា រូសលើង។ ឧ. បងស្រីខ្ញុំកំពុងកោសដូងឱ្យម្ដាយខ្ញុំធ្វើបង្អែម។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **យើងបោសសំរាម។**គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **យើង/បោស/សំរាម។**

| | |
|---|---|
| គ្រូ | - គ្រូអាន **យើងបោសសំរាម។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **យើងបោសសំរាម។** |
| សិស្ស | - សិស្សអានល្បះ **យើងបោសសំរាម។** |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយសិស្ស។

**១- តើសួស និងសុសនាំគ្នាធ្វើអ្វី?**

**២- តើនរណាធ្វើឱ្យជើងសុសរបួស?**

**៣- តើសួសធ្វើដូចម្ដេចក្នុងការលាងរបួសឱ្យសុស?**

**៤- តើកូនត្រូវធ្វើដូចម្ដេច បើកូនធ្វើខុសចំពោះអ្នកដទៃ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **អំបោស អ ំ ប ោ ស** រួចសរសេរ **អំបោស** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ចចេស ច ច េ ស** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **កំហុស របួស ដេរដាស** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ចៀសវាងកំហុស** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៦៣ ខ | ប្រកបនឹង □ស់ (ព្យញ្ជនៈពួក អ) | ⌚ ៤០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបាន រៀនរួច **អំបោស របួស សារម៉ាវ អំពាវនាវ វល់** ។

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូបំផុសរកពាក្យ **ចាស់**។ គ្រូបន្លឺ **ចាស់**។ គ្រូនិងសិស្សថា **ចាស់**។ សិស្សថា **ចាស់**។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ចា** លើកដៃម្ខាងទៀតថា **ស ចាស បន្តក់មួយ** រួច ផ្តុំបាតដៃទាំងពីរថា **ចាស់**។ |
| គ្រូនិងសិស្ស | -លើកដៃម្ខាងឡើងលើថា **អ** លើកដៃម្ខាងទៀតថា **ស អស បន្តក់មួយ** រួចផ្តុំបាត ដៃទាំងពីរថា **អស់**។ |
| សិស្ស | -គ្រូថា **ប** និង **ស បន្តក់មួយ ណា** និង **ស បន្តក់មួយ ឡា** និង **ស បន្តក់មួយ** ម្តងមួយៗ<br>-សិស្សអនុវត្តផ្សំសូរដោយប្រើដៃ **ប** និង **ស បន្តក់មួយ បស់ ...**។ |

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥ នាទី

ក- អស់

| | |
|---|---|
| គ្រូ | - សរសេរ **អស់** លើក្តារខៀនរួចចង្អុលនិងអាន **អ និង ស អស បន្តក់មួយ អស់**។ |
| គ្រូនិងសិស្ស | - អាន **អស់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **អស់** ដោយផ្សំប្រកប។ |

ខ- ចាស់

| | |
|---|---|
| គ្រូ | - សរសេរ **ចាស់** លើក្តារខៀនរួចចង្អុលនិងអាន **ច អា ចា និង ស ចាស បន្តក់មួយ ចាស់**។ |
| គ្រូនិងសិស្ស | - អាន **ចាស់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ចាស់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

**៣- ការអានព្យាង្គនិងពាក្យ** ⌚ ១៨នាទី

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **បស់** លើក្តារខៀនរួចចង្អុលនិងអាន **ប និង ស បស បន្តក់មួយ បស់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **សស់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **តស់ ចស់ ឡស់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **ជាស់** លើក្តារខៀនរួចចង្អុលនិងអាន **ជ អា ជា និងស ជាស បន្តក់មួយ ជាស់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **បាស់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ម៉ាស់ ង៉ាស់ តាស់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **របស់** លើក្តារខៀនរួចចង្អុលនិងអាន **រ ប និង ស បស បន្តក់មួយ បស់ របស់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ចំណាស់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **បំបាស់** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- ចំណាស់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ចំណាស់ មានន័យថា ចាស់។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ចំណាស់។ បងស្រីខ្ញុំមានវ័យចំណាស់ជាងខ្ញុំ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ចំណាស់** រួមគ្នា។ គ្រូផ្ដើម **តាសុខមានវ័យ....ជាងយាយចាន់ ។** សិស្សថា **ចំណាស់**រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ចំណាស់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ចំណាស់** ជាដៃគូ។ |

ខ- ដាស់ បង្រៀនដូចពាក្យខាងលើ។ **ដាស់ មានន័យថា ធ្វើឱ្យភ្ញាក់ពីដេក។ ឧ. ម្ដាយខ្ញុំដាស់ខ្ញុំពីដំណេក ។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **អំបោសនេះចាស់ណាស់។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **អំបោស/នេះ/ចាស់/ណាស់។**

| | |
|---|---|
| គ្រូ | - គ្រូអាន **អំបោសនេះចាស់ណាស់។** |
| គ្រូនិងសិស្ស | - អានព្រម **អំបោសនេះចាស់ណាស់។** |
| សិស្ស | - សិស្សអានល្បះ **អំបោសនេះចាស់ណាស់។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយសិស្ស។

**១- តើដាស់ និងយ៉ាស់ជាចៅរបស់នរណា?**

**២- តើដាស់ និងយ៉ាស់បានធ្វើអ្វីខ្លះជូនជីតា?**

**៣- តើកូនគិតថា ដាស់ និងយ៉ាស់ជាកុមារដូចម្ដេច?**

**៤- តើកូនបានធ្វើអ្វីខ្លះជូនជីតារបស់កូន?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ចំណាស់ ច ◌ំ ណ ◌ា ស ◌់** រួចសរសេរ **ចំណាស់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ចាស់ទុំ ច ◌ា ស ◌់ ទ ◌ុំ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **របស់ ណាស់ ដាស់**ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **អំបោសចាស់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៦៤ ក | ប្រកបនឹង □ស (ព្យញ្ជនៈពួក អ៊ី) | ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ៥នាទី

- គ្រូរំឭកពាក្យដែលបាន រៀនរួច **ចាស់ ណាស់ បំបួស កំហុស អំពាវនាវ** ។

**១- ការស្គាល់សូរអក្សរថ្មី** ៥នាទី

- គ្រូបំផុសរកពាក្យ **មាស**។ គ្រូបន្លឺ **មាស**។ គ្រូនិងសិស្សថា **មាស**។ សិស្សថា **មាស**។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **មា** លើកដៃម្ខាងទៀតថា **ស** រួច ផ្គុំបាតដៃទាំងពីរថា **មាស** ។ |
| គ្រូនិងសិស្ស | - លើកដៃម្ខាងឡើងលើថា **រ** លើកដៃម្ខាងទៀតថា **ស** រួច ផ្គុំបាតដៃទាំងពីរថា **រស** ។ |
| សិស្ស | - គ្រូថា **ពា** និង **ស លួ** និង **ស គួ** និង **ស** ម្តងមួយៗឱ្យសិស្សអនុវត្តផ្សំសូរដោយប្រើដៃដូចខាងលើ។ |

**២- ការស្គាល់តួអក្សរថ្មី** ៥ នាទី

ក-រស

| | |
|---|---|
| គ្រូ | - សរសេរ **រស** លើក្តារខៀនរួចចង្អុលនិងអាន **រ និង ស រស**។ |
| គ្រូនិងសិស្ស | - អាន **រស** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **រស** ដោយផ្សំប្រកប។ |

ខ- មាស

| | |
|---|---|
| គ្រូ | - សរសេរ **មាស** លើក្តារខៀនរួចចង្អុលនិងអាន **ម អា មា និង ស មាស** ។ |
| គ្រូនិងសិស្ស | - អាន **មាស** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **មាស** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និងសួរសំណួរទាក់ទងមុននឹងសរសេរចំណងជើងលើក្តារខៀន។

**៣- ការអានព្យាង្គនិងពាក្យ** ១៨នាទី

**៣.១ - ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **ហ៊ស** លើក្តារខៀនរួចចង្អុលនិងអាន **ហ៊ និង ស ហ៊ស**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ជស** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ងស ធស ឌស** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **ពាស** លើក្តារខៀនរួចចង្អុលនិងអាន **ព អា ពា និង ស ពាស** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **គូស** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **រួស ញើស ទោស** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ជួសជុល** លើក្តារខៀនរួចចង្អុលនិងអាន **ជ អួ ជួ និង ស ជួស ជ អ៊ុ ជុ និង ល ជុល ជួសជុល**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ឈើគូស** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **រមាស** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក -ញើស

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ញើស មានន័យថា ទឹកដែលចេញពីខ្លួន។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ញើស។ ពូសុខដើរទាល់តែបែកញើស។** |
| គ្រូនិងសិស្ស | - អានពាក្យ **ញើស** រួមគ្នា។ គ្រូផ្ដើម **ខ្ញុំទាត់សីទាល់តែបែក** ...... ។ សិស្សថា **ញើស** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ញើស** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ញើស** ជាដៃគូ។ |

ខ- លើសលប់ បង្រៀនដូចពាក្យខាងលើ។ **លើសលប់ មានន័យថា លើសហួសកំណត់។ ឧ .គេរកត្រីបានច្រើនលើសលប់។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ចៅសួសហ៊ានសុំទោសពេលមានកំហុស។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ចៅសួស/ហ៊ាន/សុំ/ទោស/ពេល/មាន/កំហុស។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ចៅសួសហ៊ានសុំទោសពេលមានកំហុស។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ចៅសួសហ៊ានសុំទោសពេលមានកំហុស។** |
| សិស្ស | - សិស្សអានល្បះ **ចៅសួសហ៊ានសុំទោសពេលមានកំហុស។** |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយសិស្ស។

**១- តើពូលួស និងមីងភាសប្រកបរបរអ្វី?**

**២- តើពួកគាត់ដឹកលៀសយកទៅលក់នៅឯណា?**

**៣- ហេតុអ្វីបានជាគាត់យកលុយទៅទិញមាស?**

**៤- តើការបរិភោគលៀសល្អសម្រាប់សុខភាពដែរឬទេ? ព្រោះអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ជួសជុល ជ ួ ស ជ ុ ល** រួចសរសេរ **ជួសជុល** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **រួសរាយ រ ួ ស រ ា យ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **រលួស ញញើស ឈើគូស** ម្ដងមួយពាក្យៗ ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ជួសជុលរទេះ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី ៦៤ ខ | ប្រកបនឹង □ស់ (ព្យញ្ជនៈពួក អ៊ី) | ⏲ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⏲ ៥នាទី

- គ្រូរំឭកពាក្យដែលបាន រៀនរួច **ឈើគូស ជួសជុល អំបោស បំបួស ចាស់** ។

**១- ការស្គាល់សូរអក្សរថ្មី** ⏲ ៥នាទី

- គ្រូបំផុសរកពាក្យ **ពស់**។ គ្រូបន្លឺ **ពស់**។ គ្រូនិងសិស្សថា **ពស់**។ សិស្សថា **ពស់**។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើថា **ព** លើកដៃម្ខាងទៀតថា **ស បន្តក់មួយ** រួច ផ្ទុំបាតដៃទាំងពីរថា **ពស់** ។ |
| គ្រូនិងសិស្ស | -លើកដៃម្ខាងឡើងលើថា **គា** លើកដៃម្ខាងទៀតថា **ស បន្តក់មួយ** រួច ផ្ទុំបាតដៃទាំងពីរថា **គាស់**។ |
| សិស្ស | -គ្រូថា **ទា** និង **ស បន្តក់មួយ មា** និង **ស បន្តក់មួយ រ** និង **ស បន្តក់មួយ** ម្តងមួយៗ។<br>-សិស្សអនុវត្តផ្សំសូរដោយប្រើដៃ **ទា** និង **ស បន្តក់មួយ ទាស់** ....។ |

**២- ការស្គាល់តួអក្សរថ្មី** ⏲ ៥ នាទី

ក- ពស់

| | |
|---|---|
| គ្រូ | - សរសេរ **ពស់** លើក្តារខៀនរួចចង្អុលនិងអាន **ព និង ស ពស បន្តក់មួយ ពស់**។ |
| គ្រូនិងសិស្ស | - អាន **ពស់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ពស់** ដោយផ្សំប្រកប។ |

ខ- គាស់

| | |
|---|---|
| គ្រូ | - សរសេរ **គាស់** លើក្តារខៀន រួចចង្អុលនិងអាន **គ អ៊ា គា និង ស គាស បន្តក់មួយ គាស់**។ |
| គ្រូនិងសិស្ស | - អាន **គាស់** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **គាស់** ដោយផ្សំប្រកប។ |

គ- គ្រូពន្យល់ពីរបៀបអាន និង សួរសំណួរទាក់ទងមុននឹងសរសេរចំណាងជើងលើក្តារខៀន។

**៣- ការអានព្យាង្គនិងពាក្យ** ⏲ ១៨នាទី

**៣.១- ការអានព្យាង្គ**

**៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)**

| | |
|---|---|
| គ្រូ | - សរសេរ **ទស់** លើក្តារខៀនរួចចង្អុលនិងអាន **ទ និង ស ទស បន្តក់មួយ ទស់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **លស់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ធស់ រស់ ស៊ស់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.១.២ - ការអានព្យាង្គ (ស្រៈនិស្ស័យ)**

| | |
|---|---|
| គ្រូ | - សរសេរ **វាស់** លើក្តារខៀនរួចចង្អុលនិងអាន **វ អ៊ា វា និង ស វាស បន្តក់មួយ វាស់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រាស់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ទាស់ លាស់ ញាស់** ដោយផ្សំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ម្ចាស់** លើក្តារខៀនរួចចង្អុលនិងអាន **រ ម អ៊ា មា និង ស មាស បន្តក់មួយ មាស់ ម្ចាស់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ទំនាស់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **រំលស់** ដោយផ្សំប្រកប។អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- រលស់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **រលស់ មានន័យថា ថយចំនួន ឬ មានចំនួនតិចជាងចំនួនដើម។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ** រលស់។ **ពូសុខចាយលុយរលស់ពីហោប៉ៅ។** |
| គ្រូនិងសិស្ស | - អានពាក្យ **រលស់** រួមគ្នា។ គ្រូផ្ដើម **បងខ្ញុំចែកអំបុកឱ្យមិត្តភក្តិឡើង......ពីចង្អេរ។** សិស្សថា **រលស់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **រលស់** បង្កើតល្បះដោយប្រើប្រាស់ពាក្យ **រលស់** ជាដៃគូ។ |

ខ- រាស់ បង្រៀនដូចពាក្យខាងលើ។ **រាស់ មានន័យថា កាយការដោយរនាស់ដៃ ឬបររនាស់ធំបង្កួសកិនលើផ្ទៃដី។**

ឧ. **ឪពុកខ្ញុំកំពុងរាស់ដីស្រែ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពូរស់លីរនាស់ទៅរាស់ដី។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពូរស់/លី/រនាស់/ទៅ/រាស់/ដី។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ពូរស់លីរនាស់ទៅរាស់ដី។** |
| គ្រូនិងសិស្ស | - អានព្រម**ពូរស់លីរនាស់ទៅរាស់ដី។** |
| សិស្ស | - សិស្សអានល្បះ **ពូរស់លីរនាស់ទៅរាស់ដី។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរនិងសម្របសម្រួលចម្លើយសិស្ស។

**១- តើពូរស់លីរនាស់ទៅណា?**

**២- តើពូរស់ឃើញសត្វអ្វីនៅជិតរនាស់?**

**៣ -ហេតុអ្វីបានជាពូរស់រត់គេចចេញពីពស់?**

**៤- តើកូនធ្វើដូចម្ដេចនៅពេលឃើញពស់?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **រនាស់ រ ន ា ស ់** រួចសរសេរ **រនាស់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **រលស់ រ ំ ល ស ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **រមាស់ ពស់វែក ទាស់ទែង** ម្ដងមួយពាក្យៗ។ សិស្សគិត និងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **រនាស់រាស់ដី** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# លំនាំបង្រៀន

# មេរៀនស្រៈពេញតួ

**គន្លឹះត្រូវចងចាំ**

- ✓ គ្រប់សកម្មភាពត្រូវអនុវត្តទៅតាមលំនាំក្នុងសៀវភៅណែនាំគ្រូនិងប្រើប្រាស់ពាក្យពេចន៍ជាអក្សរដិត។
- ✓ ក្នុងពេលអាន សិស្សត្រូវប្រើភ្នែក និងចង្អុលដៃរេតាមតួអក្សរ។
- ✓ គ្រូត្រូវដើរតាមតុសិស្ស ស្តាប់សិស្សអានជាដៃគូ និងជួយកែតម្រូវសិស្សណាអានមិនទាន់ត្រឹមត្រូវ។
- ✓ ប្រសិនបើសិស្សណាមានលំបាក គ្រូត្រូវជួយសិស្សនោះ។ គ្រូអាចអានពាក្យជាគំរូ អានពាក្យនោះម្តងទៀតជាមួយសិស្ស និងឱ្យសិស្សអានពាក្យនោះខ្លួនឯងម្តងទៀត។
- ✓ ប្រសិនបើសិស្សភាគច្រើនមានការលំបាក គ្រូត្រូវណែនាំឡើងវិញដោយប្រើ វិធីគ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើជាមួយសិស្សទាំងអស់ក្នុងថ្នាក់។
- ✓ សម្រាប់ការបង្រៀនតួអក្សរថ្មី គ្រូត្រូវសរសេរតួអក្សរដែលត្រូវរៀនធំៗលើក្តារខៀន។
- ✓ អនុវត្ត គ្រូធ្វើ គ្រូ និងសិស្សធ្វើ សិស្សធ្វើ ដូចដែលបានលម្អិតក្នុងសៀវភៅណែនាំគ្រូ។
- ✓ ដើរជុំវិញថ្នាក់នៅពេល គ្រូនិងសិស្សធ្វើ សិស្សធ្វើ ក្នុងគ្រប់សកម្មភាពអាន និងសរសេរ។
- ✓ សម្រាប់សកម្មភាពអាន ឱ្យសិស្សអានលើសពីម្តង។

៙ ប្រសិនបើក្នុងថ្នាក់មានសិស្សខ្សោយគំហើញ និងខ្សោយស្តាប់ រាល់ការបង្ហាញ និងការណែនាំរបស់គ្រូត្រូវប្រាកដថាសិស្សទាំងនោះស្តាប់ឮ និងឃើញច្បាស់។

៙ គ្រូប្រើប័ណ្ណពាក្យ ល្បះសម្រាប់សិស្សខ្សោយស្តាប់ និងខ្សោយគំហើញ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## លំនឹងថ្នាក់ និង រំឭកមេរៀន ៥ នាទី

◎ រំឭកពាក្យដែលបានរៀន

▤ ប័ណ្ណពាក្យ ក្តារឆ្នួន

◷ ៥ នាទី

គ្រូសរសេរពាក្យ **ជួសជុល អំពាវនាវ នោស់ ឈើគូស ចៀសវាង** មួយម្តងៗឱ្យសិស្សអាន ឬហៅឱ្យសិស្សសរសេរលើក្តារឆ្នួនហើយអាន។ គ្រូកែតម្រូវសិស្ស ដែលអាន ឬសរសេរមិនបានត្រឹមត្រូវ។

## ១- ការស្គាល់សូរអក្សរថ្មី ៥ នាទី

ល្បែងទស្សន៍ទាយ

◎ កំណត់សូរពាក្យ ដែលផ្តើមដោយសូរ ស្រៈពេញតួ

▤ សកម្មភាព វត្ថុជាក់ស្តែង រូបភាព

◷ ៥ នាទី

គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬ បំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

ក- សូរ អគារ

-គ្រូបង្ហាញរូបភាព ឬចង្អុលទៅរក អគារ រួចសួរសិស្សថា **តើនេះជាអ្វី? (អគារ)**។ គ្រូប្រាប់សិស្ស ថា **អគារ មានពីរព្យាង្គគឺ អៈ គា**។ គ្រូសួរសិស្សថា **តើព្យាង្គទី១មានសូរដូចម្តេច? អៈ(អាក់)**។

- គ្រូ : បន្លឺសូរ **អះ (អាក់)**។
- គ្រូ និងសិស្ស : **បន្លឺសូរ អះ (អាក់) រួមគ្នា**។
- សិស្ស : **បន្លឺសូរ អះ (អាក់)**។

ខ- សូរ អាកាស

- គ្រូនិយាយថា **យើងនៅកន្លែងដែលមាន វាលធំ មានខ្យល់ គេហៅថាអ្វី? (អាកាស)**។ គ្រូថាពាក្យ **អាកាស មានពីរព្យាង្គគឺ អា កាស**។ រួចសួរសិស្សថា **តើព្យាង្គទី១ មានសូរដូចម្ដេច? (អា)** ។
  - គ្រូ : គ្រូបន្លឺសូរ **អា**។
  - គ្រូ និងសិស្ស : បន្លឺសូរ **អា** រួមគ្នា។
  - សិស្ស : បន្លឺសូរ **អា**។

គ- សូរ ឥ

- គ្រូបង្ហាញរូបភាព ដុំឥដ្ឋ រួចសួរសិស្សថា**តើនេះជារូបអ្វី?** (**ដុំឥដ្ឋ**)។ គ្រូថាពាក្យ **ឥដ្ឋ**។ សួរសិស្សថា **តើពាក្យ ឥដ្ឋ មានសូរដើមអ្វី**? **ឥ(អិ)**។
  - គ្រូ : គ្រូបន្លឺសូរ **ឥ(អិ)**។
  - គ្រូ និងសិស្ស : បន្លឺសូរ **ឥ(អិ)** រួមគ្នា។
  - សិស្ស : បន្លឺសូរ **ឥ(អិ)**។

ឃ- សូរ ឦ

- គ្រូចង្អុលទៅទិសឦសាន និង**សួរ**ថា **តើទិសនេះជាទិសអ្វី? (ឦសាន)**។ គ្រូថាពាក្យ **ឦសាន មានពីរព្យាង្គគឺ ឦសាន**។ គ្រូសួរសិស្សថា **តើព្យាង្គទី១ មានសូរដូចម្ដេច**? **ឦ(អុី)**។
  - គ្រូ : គ្រូបន្លឺសូរ **ឦ(អុី)**។
  - គ្រូ និងសិស្ស : បន្លឺសូរ **ឦ(អុី)** រួមគ្នា។
  - សិស្ស : បន្លឺសូរ **ឦ(អុី)**។

ង- សូរ ឧ

- គ្រូ**សួរសិស្សថា តើខែទី៥ឈ្មោះខែអ្វី?** (**ឧសភា**)។ គ្រូថាពាក្យ **ឧសភា មានបីព្យាង្គគឺ ឧ សះ ភា**។ គ្រូសួរសិស្សថា **តើព្យាង្គទី១មានសូរដូចម្ដេច**? **ឧ(អុ)**។
  - គ្រូ : បន្លឺសូរ **ឧ(អុ)**។
  - គ្រូ និងសិស្ស : បន្លឺសូរ **ឧ(អុ)** រួមគ្នា។
  - សិស្ស : បន្លឺសូរ **ឧ(អុ)**។

**គន្លឹះត្រូវចងចាំ**

★ គ្រូត្រូវបន្លឺសូរដែលត្រូវរៀនឱ្យបានឮ និងច្បាស់ៗ។
★ មានវិធីជាច្រើនយ៉ាង ក្នុងការបំផុសរកពាក្យថ្មី។ ក្នុងនោះរួមមាន ការលើកឧទាហរណ៍ ការពិពណ៌នា ការបង្ហាញវត្ថុជាក់ស្តែង ការបង្ហាញរូបភាព និងការធ្វើកាយវិការ។ល។ ការធ្វើកាយវិការត្រូវបានលើកទឹកចិត្តឱ្យគ្រូប្រើឱ្យបានញឹកញាប់ ព្រោះវាអាចជួយឱ្យមានអន្តរកម្មរវាងគ្រូ និងសិស្ស សិស្សនិងសិស្ស ។
★ លើកទឹកចិត្តសិស្សឱ្យលើកដៃប្រកបព្យាង្គ និងពាក្យ ដូចដែលគ្រូបានធ្វើឱ្យមើល ដើម្បីឱ្យពួកគេធ្វើ ចលនាដៃគ្រប់គ្នា និងផ្តល់អារម្មណ៍ក្នុងសកម្មភាពរៀន។
✓ ពិនិត្យមើលពេលសិស្សប្រកប ដើម្បីដឹងថាសិស្សណាខ្លះបន្លឺសូរប្រកប និងអានពាក្យបានត្រឹមត្រូវ សិស្សណាខ្លះដែលត្រូវការជួយបន្ថែម។
✓ បង្រៀនទៅតាមពេលវេលាដែលបានកំណត់ ក្នុងសៀវភៅណែនាំគ្រូ ក្នុងសកម្មភាពណែនាំឱ្យសិស្សស្គាល់សូរអក្សរថ្មី។
៚ ត្រូវប្រាកដថា សិស្សអាចមើលឃើញគ្រូច្បាស់។ គ្រូទាញចំណាប់អារម្មណ៍ឱ្យសិស្សមើលគ្រូ ខណៈពេលដែលគ្រូប្រកបសូរ និងអានពាក្យ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## ២- ការស្គាល់តួអក្សរថ្មី ◷ ៥ នាទី

◎ ស្គាល់តួស្រៈពេញតួ អ អា ឥ ឦ ឧ

🗐 គ្មានសម្ភារៈ

◷ ៥នាទី

ក- ស្រៈពេញតួ អ (អាក់)
- គ្រូ : សរសេរអក្សរ **អ** លើក្តារខៀន រួចអាន **អះ អាក់** ។
- គ្រូ និងសិស្ស : អានរួមគ្នា **អះ (អាក់)**។
- សិស្ស : អានទាំងអស់គ្នា **អះ (អាក់)**។

ខ- ស្រៈពេញតួ អា (អា)
- គ្រូ : សរសេរអក្សរ អា លើក្តារខៀន រួចអាន អា ។
- គ្រូ និងសិស្ស : អានរួមគ្នា **អា**។
- សិស្ស : អានទាំងអស់គ្នា **អា**។

គ- ស្រៈពេញតួ ឥ(អិ)
- គ្រូ : សរសេរអក្សរ **ឥ** លើក្តារខៀន រួចអាន **ឥ(អិ)**។
- គ្រូ និងសិស្ស : អានរួមគ្នា **ឥ(អិ)**។
- សិស្ស : អានទាំងអស់គ្នា **ឥ (អិ)**។

ឃ- ស្រៈពេញតួ ឦ (អ៊ី)
- គ្រូ : សរសេរអក្សរ **ឦ** លើក្តារខៀន រួចអាន **ឦ (អ៊ី)**។
- គ្រូ និងសិស្ស : អានរួមគ្នា **ឦ (អ៊ី)**។
- សិស្ស : អានទាំងអស់គ្នា **ឦ (អ៊ី)**។

ង- ស្រះពេញតួ ឱ

- គ្រូ : សរសេរអក្សរ **ឱ** លើក្ដារខៀន រួចអាន **ឱ (អ៊ុ)**។
- គ្រូ និងសិស្ស : អានរួមគ្នា **ឱ (អ៊ុ)** ។
- សិស្ស : អានទាំងអស់គ្នា **ឱ (អ៊ុ)**។

សរសេរចំណងជើងមេរៀនស្រះពេញតួ អ អា ឥ ឰ ឱ

- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្ដារខៀន ស្រះពេញតួ អ អា ឥ ឰ ឱ ។
- គ្រូចង្អុល ហើយសិស្សអានចំណងជើងម្ដងមួយៗ។

## ៣- ការអានស្រះពេញតួ និងពាក្យ ◷ ១៨នាទី

៣.១- ការអានស្រះពេញតួ

◎ អានស្រះពេញតួ អ អា ឥ ឰ ឱ

▤ សៀវភៅជំនួយសិស្ស

◷ ៨នាទី

- គ្រូ : សរសេរ **អ** លើក្ដារខៀន។ គ្រូអាន **អះ (អាក់)** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរ។
- គ្រូ និងសិស្ស : គ្រូសរសេរ **អា** លើក្ដារខៀន។ គ្រូនិងសិស្សអាន **អា** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរ។
- សិស្ស :

- គ្រូសរសេរ **ឥ** លើក្ដារខៀន។ គ្រូចង្អុល រួចសិស្សអាន **ឥ (អិ)** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរ។ ធ្វើដូចគ្នាចំពោះ **ឰ ឱ ។**
- អានស្រះពេញតួជាដៃគូក្នុងសៀវភៅជំនួយសិស្ស ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ។

៣.២ -ការអានពាក្យ

◎ អានពាក្យឱ្យបានត្រឹមត្រូវ

▤ សៀវភៅជំនួយសិស្ស

◷ ១០ នាទី

- គ្រូ : សរសេរពាក្យ **អគារ** លើក្ដារខៀន។ គ្រូអានពាក្យ និងយកដៃចង្អុល ក្រោមពាក្យដោយបង្អូសពីក្រោមពាក្យ **អាក់ គ អ៊ា គា និង រ គា អគារ**។
- គ្រូ និងសិស្ស : គ្រូសរសេរពាក្យ **ឥឡូវ** លើក្ដារខៀន។ គ្រូ និងសិស្សអានរួមគ្នាដោយផ្សំប្រកប **អិ ឡ អូ ឡូ និង វ ឡូវ ឥឡូវ**។
- សិស្ស :
  - គ្រូសរសេរពាក្យ **អាកាស** លើក្ដារខៀន រួចចង្អុល។ សិស្សអានពាក្យ **អាកាស** ដោយផ្សំប្រកប ។
  - សិស្សអានពាក្យទាំងអស់ក្នុងតារាងក្នុងសៀវភៅជំនួយសិស្សជាដៃគូ។

## ៤- វាក្យសព្ទ

🕒 ៨នាទី

◎ យល់ន័យ និងប្រើប្រាស់ពាក្យ

🗐 តាមជាក់ស្ដែង

🕒 ៨នាទី

**ក- ឥឡូវ**

- គ្រូ : សរសេរពាក្យ **ឥឡូវ** លើក្ដារខៀន រួចអាន និងពន្យល់ន័យ។ ក្នុងករណីពាក្យត្រូវពន្យល់មានសរសេរលើក្ដារខៀនម្ដងហើយ គ្រាន់តែគូសវង់លើពាក្យនោះក៏បាន។ **ឥឡូវ មានន័យថា ពេលនេះ វេលានេះ។ ឥឡូវនេះគ្រូនឹងបង្កើតល្បះមួយ ដោយប្រើពាក្យ ឥឡូវ។ យើងនឹងចេញលេងឥឡូវនេះ ។**
- គ្រូ និងសិស្ស : អានពាក្យ **ឥឡូវ** រួមគ្នា។ **ឥឡូវនេះយើងបង្កើតល្បះរួមគ្នា។** គ្រូចាប់ផ្ដើម **យើងនឹងលេងបាល់ទាត់....នេះ។** សិស្សថា**ឥឡូវ** ។ ថាល្បះឡើងវិញទាំងអស់គ្នា **យើងនឹងលេងបាល់ទាត់ឥឡូវនេះ។**
- សិស្ស : អានពាក្យ **ឥឡូវ** ដោយខ្លួនឯង និងបង្កើតល្បះដោយប្រើពាក្យ **ឥឡូវ** ជាដៃគូ។

**ខ- ឦសាន**

- គ្រូ : សរសេរពាក្យ **ឦសាន** លើក្ដារខៀន រួចអាន និងពន្យល់ន័យ។ **ពាក្យ ឦសាន មានន័យថា ទិសដែលនៅចន្លោះទិសខាងកើត និងទិសខាងជើង។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ឦសាន ។ ផ្ទះខ្ញុំនៅទិសឦសាន។**
- គ្រូ និងសិស្ស : អានពាក្យ **ឦសាន** រួមគ្នា។ **ឥឡូវនេះយើងបង្កើតល្បះរួមគ្នា។** គ្រូចាប់ផ្ដើម **ដើមស្វាយនោះនៅទិស...?** សិស្សថា **ឦសាន** ។ ថាល្បះឡើងវិញទាំងអស់គ្នា **ដើមស្វាយនោះនៅទិសឦសាន។**
- សិស្ស : អានពាក្យ **ឦសាន** ដោយខ្លួនឯង និងបង្កើតល្បះដោយប្រើពាក្យ **ឦសាន** ជាដៃគូ។

**គន្លឹះត្រូវចងចាំ**

✓ សម្រាប់ការបង្រៀនវាក្យសព្ទ គ្រូត្រូវដើរតាមតុ ស្ដាប់សិស្សបង្កើតល្បះជាមួយដៃគូ។
✓ សកម្មភាពនេះទាមទារឱ្យសិស្សស្គាល់សូរ ចេះអានពាក្យ យល់ន័យនៃពាក្យ ចេះប្រើប្រាស់ពាក្យបានត្រឹមត្រូវ។ គ្រូ និងសិស្សបង្កើតល្បះដោយផ្ទាល់មាត់ ពុំមានការសរសេរទេ។
✓ ពេលសិស្សបង្កើតល្បះ គ្រូស្ដាប់ហើយសួរបញ្ជាក់ បើល្បះនោះមិនទាន់មានន័យគ្រប់គ្រាន់។
✓ គ្រូត្រូវដើរទៅជិតសិស្ស នៅពេលគ្រូពន្យល់ និងបង្កើតល្បះជាឧទាហរណ៍ដល់សិស្ស។

## ៥- ការអានល្បះ

🕒 ៥ នាទី

◎ អានល្បះដោយមិនផ្សំប្រកប

🗐 សៀវភៅជំនួយសិស្ស

🕒 ៥ នាទី

ក-គ្រូបង្ហាញរូបភាពទាក់ទងនឹងល្បះប្រសិនបើមាន។

ខ -គ្រូសរសេរល្បះ **ឥឡូវនេះជំនោរបក់មកពីទិសឦសាន។** លើក្ដារខៀន។ គ្រូសួរសិស្សថា **តើក្នុងល្បះមាន ពាក្យអ្វីខ្លះ ?** ពេលសិស្សឆ្លើយ គ្រូប្រើសញ្ញា ( / )លើល្បះ ដើម្បីញែកពាក្យ ឥឡូវ/នេះ/ជំនោរ/បក់/មក/ពី/ទិស/ឦសាន ។

គ -គ្រូនាំសិស្សហ្វឹកហាត់អាន៖

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

- គ្រូ : អានល្បះ **ឥឡូវនេះជំនោរបក់មកពីទិសឦសាន។**
- គ្រូ និងសិស្ស : អានល្បះរួមគ្នា **ឥឡូវនេះជំនោរបក់មកពីទិសឦសាន។**
- សិស្ស : អានល្បះទាំងអស់គ្នា **ឥឡូវនេះជំនោរបក់មកពីទិសឦសាន។**

ឃ- គ្រូសួរសំណួរដែលផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់សិស្ស ដើម្បីឱ្យសិស្សយល់ពីអត្ថន័យនៃល្បះ។ **ឧ. តើខ្យល់បក់មកពីទិសណា? តើអ្នកណាអាចចង្អុលទិសឦសានបាន?**

| គន្លឹះត្រូវចងចាំ |
|---|
| ✓ គ្រូស្រង់ល្បះមួយពីក្នុងសៀវភៅសិក្សាគោល។ ប្រសិនបើមានរូបភាពក្នុងសៀវភៅនោះ គ្រូលើករូបភាពបង្ហាញ ដើម្បីបំផុសសំណួរដែលទាក់ទងនឹងល្បះដែលត្រូវរៀន។ |
| ✓ គ្រូឱ្យសិស្សប្រាប់ពាក្យពិបាក (បើមាន) ។ |

## ៦- ការអានអត្ថបទខ្លី

🕒 ១២នាទី

◎ ហាត់អានស្ទាត់ និងយល់ន័យខ្លឹមសារអត្ថបទ

🗐 សៀវភៅជំនួយសិស្ស

🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងនឹងរូបភាព (ឧទាហរណ៍ **តើកូនបានឃើញអ្វីខ្លះក្នុងរូបភាពនេះ?** ) រួចអានចំណងជើងអត្ថបទ។

ខ- គ្រូឱ្យសិស្សទស្សន៍ទាយសាច់រឿង : **តើរឿងនេះនិយាយអំពីអ្វី?**

គ- អានអត្ថបទខ្លី

- គ្រូ : អានរឿងយឺតៗ ដោយលើកដាក់សំឡេងគោរពតាមឃ្លា ល្បះ ក្នុងសាច់រឿង។
- គ្រូ និងសិស្ស : អានរួមគ្នា។ គ្រូណែនាំសិស្សឱ្យយកចង្អុលដៃអូសពីក្រោមពាក្យនៅពេលអាន។
- សិស្ស: អានជាដៃគូ ដោយប្តូរវេនគ្នា ម្នាក់ជាអ្នកចង្អុលម្នាក់ទៀតជាអ្នកអាន រួចអានជាបុគ្គល។ ប្រសិនបើមានពេល ឱ្យសិស្សអានឱ្យបានច្រើនដង។ ។

ឃ -គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង -គ្រូសួរសំណួរម្តងមួយៗ ដោយទុកពេលឱ្យសិស្សគិត (បើរកចម្លើយមិនឃើញ គ្រូ និងសិស្ស អានអត្ថបទរឿងឡើងវិញ)។

**១- តើឧសភាអានរឿងអ្វី?**

**២- តើឥសី និងឥសូរហោះទៅទីណា?**

**៣-ហេតុអ្វីបានជាឧសភាចង់ចេះហោះហើរដូចឥសី និងឥសូរ ?**

**៤- តើកូនយល់ថាឥសី និងឥសូរជាអ្វី?**

**គន្លឹះត្រូវចងចាំ**

★ ក្នុងពេលគ្រូធ្វើ គ្រូត្រូវអានស្ទាត់ជាគំរូដល់សិស្ស។
✓ ក្នុងពេលគ្រូនិងសិស្សធ្វើ គ្រូនិងសិស្សត្រូវអានរួមគ្នា (មិនមែនសិស្សអានតាមគ្រូទេ)។
✓ សម្រាប់សំណួរ ដែលមានចម្លើយលើសពីមួយទុកពេលសមល្មមឱ្យសិស្សប្រើបទពិសោធ ឬគំនិតផ្ទាល់ខ្លួនពិភាក្សាជាដៃគូ។
✓ ប្តូរសំណួរតែរក្សាន័យដដែល ពេលដែលសិស្សស្តាប់សំណួរគ្រូមិនយល់។
✓ ជួយសិស្ស ដោយប្រើសំណួរប្រដេញ ប្រសិនបើពួកគេនៅតែមិនទាន់យល់សំណួរ។

## ៧- ការសរសេរ ◷ ១៦នាទី

៧.១ -ការសរសេរពាក្យ

◎ សរសេរពាក្យបានត្រឹមត្រូវ

▤ បណ្ណពាក្យ ក្តារខៀន

◷ ១១នាទី

- គ្រូ : បន្លឺពាក្យ **ឧទាន** ។ គ្រូគិត និងថាឮៗ **ឧទាន មាន ស្រះពេញតួ ឧ ទ ស្រះ ា និង ន** រួចសរសេរពាក្យ **ឧទាន** លើក្តារខៀន។
- គ្រូ និងសិស្ស : គ្រូបន្លឺពាក្យ **អាកាស** ។ គ្រូ និងសិស្សគិត និងថាឮៗ **អាកាស មាន ស្រះពេញតួ អា ក ា និង ស** ។ គ្រូសរសេរ **អាកាស** លើក្តារខៀន ចំណែកសិស្សសរសេរ **អាកាស** លើក្តារឆ្នួន។
- សិស្ស : គ្រូបន្លឺពាក្យ **អគារ** ។ សិស្សគិត និងថាឮៗ **អគារ មាន អ គ ស្រះ ា និង រ** រួចសរសេរពាក្យ **អគារ** លើក្តារឆ្នួន។ សិស្សលើកបង្ហាញគ្រូ។ គ្រូសរសេរ **អគារ** លើក្តារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ គ្រូធ្វើដូចគ្នានឹងពាក្យ **អគារ** ដែរ ចំពោះពាក្យ **ឥឡូវ ឧសភា**។

៧.២ -ការសរសេរឃ្លា

◎ សរសេរឃ្លាក្នុងសៀវភៅកិច្ចការបានត្រឹមត្រូវ

▤ បណ្ណពាក្យ

◷ ៥ នាទី

គ្រូប្រាប់សិស្សថា **ពេលនេះយើងនឹងហ្វឹកហាត់សរសេរឃ្លា។ គ្រូនឹងហៅឃ្លាយឺតៗចំនួនបីដងឱ្យកូនសរសេរ។**

ក- គ្រូហៅឃ្លា **អគារចាស់** យឺតៗចំនួនបីដង។

ខ- សិស្សសរសេរឃ្លា **អគារចាស់** ចូលក្នុងសៀវភៅកិច្ចការ។

គ- គ្រូសរសេរឃ្លាលើក្តារខៀន ឱ្យសិស្សផ្ទៀងផ្ទាត់ និងកែតម្រូវ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

**គន្លឹះត្រូវចងចាំ**

- ✓ គ្រូថាពាក្យយឺតៗ ច្បាស់ៗ និងសរសេរធំៗ លើក្ដារខៀន ខ .(ចំណែក) ។
- ✓ នៅពេលគ្រូហៅឱ្យសិស្សសរសេរ គ្រូគួរហៅពាក្យនីមួយៗពី ២-៣ដង ហើយប្រមាណ៣វិនាទីហៅម្ដង។
- ✓ គ្រូដើរពិនិត្យពេលសិស្សសរសេរ ហើយជួយកែតម្រូវនៅពេលដែលកំពុងសរសេរ។

**ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ** ◷ ៦នាទី

- ➢ គ្រូពង្រឹង ឬពង្រីកចំណេះដឹងរបស់សិស្សលើការអាន និងការសរសេរ៖
  - ○ ការអាន៖ ឧទាហរណ៍ៈ គ្រូប្រើប័ណ្ណអក្សរ ឬប័ណ្ណពាក្យដែលសិស្សបានរៀន ឱ្យសិស្សអាន ឬឱ្យក្រុមសិស្សរៀបតួអក្សរឱ្យបានជាពាក្យ ឬលេងល្បែងសិក្សានានា...ដែលសំដៅដល់ការពង្រឹង ឬពង្រីកចំណេះដឹងដល់សិស្ស។
  - ○ ការសរសេរ៖ ឧទាហរណ៍ៈ គ្រូអាចហៅពាក្យដែលរៀនរួច ឱ្យសិស្សសរសេរលើក្ដារឆ្នួន ឬសៀវភៅកិច្ចការ...។
- ➢ គ្រូដាក់កិច្ចការឱ្យសិស្សធ្វើ៖
  - ○ ឱ្យសិស្សចម្លងស្រៈ ព្យញ្ជនៈ ពាក្យ ឃ្លា ឬល្បះ... ដាក់ក្នុងសៀវភៅសរសេរ។ ។ (ឱ្យសិស្សចម្លងនៅផ្ទះបើគ្មានពេល) ដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ។

**ចំណាំ : របៀបអានស្រៈពេញតួ**

| ល.រ | សំណេរ ( សញ្ញា ) | អាន ( សូរ ) | ឧទាហរណ៍ |
|---|---|---|---|
| ១ | អ | [អៈ] | អគារ [អៈគា] អវយវៈ [អៈវ៉ៈយៈវ៉ៈ] |
| ២ | អា | [អា] | អាកាស [អាកាស] អាឃាត [អាឃាត] |
| ៣ | ឥ | [អិ] | ឥដ្ឋ [អិត] ឥន្ទ [អិន] ឥឡូវ [អិឡូវ] ឥសី [អិសី] |
| | | [អី] | ឥឡូវ [អីឡូវ] |
| | | [អ៊ិ] | ឥច្ឆា [អ៊ិចឆា] |
| ៤ | ឦ | [អី] | ឦសូរ [អីសូ] |
| | | [អ៊ី] | ឦសាន [អ៊ីសាន] ឦសូរ [អ៊ីសូ] |
| ៥ | ឧ | [អុ] | ឧស [ អុស] |
| | | [អ៊ុ] | ឧសភា [អ៊ុសៈភា] ឧទាន [អ៊ុទាន]<br>ឧទាហរណ៍ [អ៊ុទា-ហ] ឧណ្ហ [អ៊ុន] |
| ៦ | ឩ | [អូ] | ឩដ្ឋ [អូដ្ឋ] ឩន [អូន] |
| | | [អ៊ូ] | ឩរុ [អ៊ូរុ] |
| ៧ | ឪ | [អូវ] | ឪពុក [អូវពុក] ឪម៉ាល់ [អូវម៉ាល់] ឪឡឹក [អូវឡឹក] |
| ៨ | ឫ | [រឹ] | ឫក [រឹក] ឫកពា [រឹកពា] ឫស្សី [រឹស-សី] |
| ៩ | ឬ | [រឺ] | ឬ [រឺ] |
| ១០ | ឭ | [លឹ] | រឭក [រលឹក] |
| ១១ | ឮ | [លឺ] | ឮ [លឺ] |
| ១២ | ឯ | [អែ] | ឯង [អែង] ឯណា [អែណា] |
| ១៣ | ឰ | [អៃ] | ឰដ៏ [អៃ-ដ] |
| ១៤ | ឱ | [អោ] | ឱកាស [អោកាស] ឱសថ [អោសត់]<br>ឱភាទ[អោភ៉ាត] ឱប៉ាល់ [អោប៉ាល់] ឱ្យ [អោយ] |
| ១៥ | ឳ | [អៅ] | ក្រឳឈូក [ក្រអៅឈូក] |

យើងគួរអានស្រៈពេញតួនីមួយៗតាមទម្លាប់ដូចខាងក្រោម៖

| អក្សរ | អ | អា | ឥ | ឦ | ឧ | ឩ | ឪ | ឫ | ឬ | ឭ | ឮ | ឯ | ឰ | ឱ | ឳ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សូរ | អៈ ( អាក់ ) | អា | អិ | អី | អុ | អូ | អូវ | រឹ | រឺ | លឹ | លឺ | អែ | អៃ | អោ | អៅ |

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## មេរៀនទី៦៥ ស្រៈពេញតួ អ អា ឥ ឦ ឱ ⏲ ៨០នាទី

## លំនឹងថ្នាក់ និងរំឭកមេរៀន ⏲ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ជួសជុល អំពាវនាវ នោស់ ឈើគូស ចៀសវាង។**

## ១- ការស្គាល់សូរអក្សរថ្មី ⏲ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញ វត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **អគារ**។ គ្រូបន្លឺ **អគារ**។ **តើព្យាង្គទី១មានសូរអ្វី? អៈ (អាក់)**។ គ្រូបន្លឺ **អាក់** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **អៈ (អាក់) រួមគ្នា**។ |
| សិស្ស | - បន្លឺសូរ **អៈ (អាក់) រួមគ្នា**។ |

គ្រូអនុវត្តលំនាំដូចខាងលើចំពោះស្រៈពេញតួ: អា(អាកាស) ឥ(ឥដ្ឋ) ឦ(ឦសាន) ឱ(ឱសភា)

## ២- ការស្គាល់តួអក្សរថ្មី ⏲ ៥នាទី

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **អ** ធំៗ លើក្តារខៀន រួចចង្អុលនិងអានជាគំរូ **អៈ(អាក់)** ។ |
| គ្រូនិងសិស្ស | - អាន **អៈ (អាក់)** រួមគ្នា។ |
| សិស្ស | - អាន **អៈ (អាក់)** ដោយខ្លួនឯង។ |

- គ្រូអនុវត្តលំនាំដូចខាងលើចំពោះស្រៈពេញតួ : អា (អា) ឥ (អិ) ឦ (អ៊ី) ឱ (អ៊ុ)។
- គ្រូសរសេរចំណាងជើងរួចចង្អុលឱ្យសិស្សអាន។

## ៣- ការអានស្រៈពេញតួនិងពាក្យ ⏲ ១៨នាទី

### ៣ ១.- ការអានស្រៈពេញតួ

| | |
|---|---|
| គ្រូ | - អាន **អ** លើក្តារខៀនរួចចង្អុលនិងអាន **អៈ (អាក់)** ។ |
| គ្រូនិងសិស្ស | - អាន **អា** រួចចង្អុលនិងអានរួមគ្នា។ |
| សិស្ស | - អាន **អិ ឦ ឱ** ម្តងមួយៗ រួចចង្អុលឱ្យសិស្សអាន។<br>- អានស្រៈពេញតួជាដៃគូក្នុងសៀវភៅជំនួយសិស្ស។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **អគារ** លើក្តារខៀនរួចចង្អុលនិងអាន **អាក់ គ អ៊ា គា និង រ គា អគារ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ឥឡូវ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **អាកាស** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⏲ ៨នាទី

ក- ឥឡូវ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ឥឡូវ មានន័យថា ពេលនេះ វេលានេះ**។ **គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ឥឡូវ ។ យើងនឹងចេញលេងឥឡូវនេះ** ។ |
| គ្រូនិងសិស្ស | - អានពាក្យ **ឥឡូវ** រួមគ្នា។ គ្រូផ្តើម **យើងនឹងលេងបាល់ទាត់ ... នេះ** ។ សិស្សថា **ឥឡូវ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ឥឡូវ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ឥឡូវ** ជាដៃគូ។ |

ខ- ឦសាន បង្រៀនដូចពាក្យខាងលើឥឡូវ។ **ឦសាន មានន័យថា ចន្លោះទិសពីខាងកើត និងខាងជើង។ឧ.ផ្ទះខ្ញុំនៅទិសឦសាន។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ឥឡូវនេះជំនោរបក់មកពីទិសឦសាន។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ឥឡូវ/នេះ/ជំនោរ/បក់/មក/ពី/ទិស/ឦសាន។**

| | |
|---|---|
| - គ្រូ | - គ្រូអាន **ឥឡូវនេះជំនោរបក់មកពីទិសឦសាន។** |
| - គ្រូនិងសិស្ស | - អានរួមគ្នា **ឥឡូវនេះជំនោរបក់មកពីទិសឦសាន។** |
| - សិស្ស | - សិស្សអានល្បះ **ឥឡូវនេះជំនោរបក់មកពីទិសឦសាន។** |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើឧសភាអានរឿងអ្វី?**

**២- តើឥសី និងឥសូរហោះទៅទីណា?**

**៣-ហេតុអ្វីបានជាឧសភាចង់ចេះហោះហើរដូចឥសី និងឥសូរ ?**

**៤- តើកូនយល់ថាឥសី និងឥសូរជាអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ឧទាន ឧ ទ ា ន** រួចសរសេរ **ឧទាន** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **អាកាស អ ា ក ា ស** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **អគារ ឥឡូវ ឧសភា** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **អគារចាស់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៦៦ក | ស្រះពេញតួ ឩ ឪ ឫ ឬ ឭ | ⌚ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **អគារ ឥស្សរ រនាស់ ឈើគូស ចៀសវាង**។

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ឩដ្ឋ** ។ គ្រូបន្លឺ **ឩដ្ឋ។ តើពាក្យ ឩដ្ឋ មានសូរដើមអ្វី? ឩ (អូ)។ គ្រូបន្លឺ ឩ(អូ)** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ឩ (អូ) រួមគ្នា**។ |
| សិស្ស | - បន្លឺសូរ **ឩ (អូ) រួមគ្នា**។ |

- គ្រូអនុវត្តលំនាំដូចខាងលើចំពោះស្រះពេញតួ : ឪ (ឪឡឹក) ឫ (ឫសឈើ) ឬ ( ឬទេ?) ឭ (រំឭក) ។

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **ឩ** ធំៗ លើក្តារខៀន រួចចង្អុលនិងអានជាគំរូ **ឩ (អ៊ូ)** ។ |
| គ្រូនិងសិស្ស | - អាន **ឩ(អ៊ូ)** រួមគ្នា។ |
| សិស្ស | - អាន **ឩ(អ៊ូ)** ដោយខ្លួនឯង។ |

- គ្រូអនុវត្តលំនាំដូចខាងលើចំពោះស្រះពេញតួ : ឪ ឫ ឬ ឭ ។
- គ្រូសរសេរចំណងជើងរួចចង្អុលឱ្យសិស្សអាន។

**៣- ការអានស្រះពេញតួនិងពាក្យ** ⌚ ១៨នាទី

**៣ ១.- ការអានស្រះពេញតួ**

| | |
|---|---|
| គ្រូ | - អាន **ឩ** លើក្តារខៀនរួចចង្អុលនិងអាន **អ៊ូ** ។ |
| គ្រូនិងសិស្ស | - អាន **ឪ** រួចចង្អុលនិងអានរួមគ្នា។ |
| សិស្ស | - អាន **ឫ ឬ ឭ** ម្តងមួយៗ រួចចង្អុលឱ្យសិស្សអាន។<br>- អានស្រះពេញតួជាដៃគូក្នុងសៀវភៅជំនួយសិស្ស។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ឪឡឹក** លើក្តារខៀនរួចចង្អុលនិងអាន **ស្រះពេញតួ ឪ ឡ អឹ ឡឹ និង ក ឡឹក ឪឡឹក**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **រំឭក** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ឫស** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៤- វាក្យសព្ទ** ⌚ ៨នាទី

ក- រំឭក

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **រំឭក មានន័យថា ធ្វើឱ្យនឹកឃើញឡើងវិញ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ រំឭក** ។ **សុខារំឭកមេរៀនមុនមកសាលា** ។ |
| គ្រូនិងសិស្ស | - អានពាក្យ **រំឭក** រួមគ្នា។ គ្រូផ្តើម **សិស្សទាំងអស់ត្រូវ** ... **មេរៀនជាប្រចាំ**។ សិស្សថា **រំឭក** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **រំឭក** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **រំឭក** ជាដៃគូ។ |

ខ -ឪម៉ាល់ បង្រៀនដូចពាក្យខាងលើឥឡូវ។ **ឪម៉ាល់ មានន័យថា គឺសត្វល្អិតមួយប្រភេទមានពិសរស់នៅជាសំបុកជារន្ធ តូចៗនៅរួមគ្នា។ ឱ.ឪម៉ាល់ដេញទិចពូសាន។**

## ៥- ការអានល្បះ

🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ឪពុកដាំឪឡឹកនៅដើមខែឧសភា។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ឪពុក/ដាំ/ឪឡឹក/នៅ/ដើម/ខែ/ឧសភា។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ឪពុកដាំឪឡឹកនៅដើមខែឧសភា។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ឪពុកដាំឪឡឹកនៅដើមខែឧសភា។** |
| សិស្ស | - សិស្សអានល្បះ **ឪពុកដាំឪឡឹកនៅដើមខែឧសភា។** |

## ៦- ការអានអត្ថបទខ្លី

🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូឧមដាំឪឡឹកនៅឯណា?**

**២- តើសត្វអ្វីដេញទិចពូឧម?**

**៣- តើកូនគិតថាហេតុអ្វីឪម៉ាល់ទិចពូឧម?**

**៤- តើកូនស្គាល់សត្វល្អិតណាខ្លះដែលទិចឈឺដូចឪម៉ាល់?**

## ៧- ការសរសេរ

🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ឪឡឹក ឪ ឡ ឹ ក** រួចសរសេរ **ឪឡឹក** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ឫកពា ឫ ក ព ា** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ឧដ្ឋ រំពុក ឫស** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ដាំឪឡឹក** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ារពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ

🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| មេរៀនទី៦២ | ស្រៈពេញតួ ឮ ឯ ឰ ឱ ឪ | ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ឧទាន អាកាស ឱពុក ឳដ្ឋ ឦសាន ។**

## ១- ការស្គាល់សូរអក្សរថ្មី ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរដើមនៃពាក្យ។

| | |
|---|---|
| គ្រូ | - គ្រូថា **ឮឬទេ? តើឮ ឮឬទេ មានសូរពាក្យអ្វីដំបូង? ឮ**។ គ្រូបន្លឺ **ឮ** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ឮ** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ឮ** រួមគ្នា។ |

គ្រូអនុវត្តលំនាំដូចខាងលើចំពោះស្រៈពេញតួ : ឯ(ឯណា?) ឰ(ឰដ៏អាកាស) ឱ(ឱសថ) ឪ(ក្រឪឈូក : ក្រឪ- សូរចុង)។

## ២- ការស្គាល់តួអក្សរថ្មី ៥នាទី

| | |
|---|---|
| គ្រូ | - សរសេរព្យញ្ជនៈ **ឮ** ធំៗ លើក្តារខៀន រួចចង្អុលនិងអានជាគំរូ **ឮ** ។ |
| គ្រូនិងសិស្ស | - អាន **ឮ** រួមគ្នា។ |
| សិស្ស | - អាន **ឮ** ដោយខ្លួនឯង។ |

- គ្រូអនុវត្តលំនាំដូចខាងលើចំពោះស្រៈពេញតួ : ឯ ឰ ឱ ឪ។
- គ្រូសរសេរចំណងជើងរួចចង្អុលឱ្យសិស្សអាន។

## ៣- ការអានស្រៈពេញតួនិងពាក្យ ១៨នាទី

### ៣ ១.- ការអានស្រៈពេញតួ

| | |
|---|---|
| គ្រូ | - អាន **ឮ** លើក្តារខៀនរួចចង្អុលនិងអាន **លឺ** ។ |
| គ្រូនិងសិស្ស | - អាន **ឯ** រួចចង្អុលនិងអានរួមគ្នា។ |
| សិស្ស | - អាន **ឰ ឱ ឪ** ម្តងមួយៗ រួចចង្អុលឱ្យសិស្សអាន។<br>- អានស្រៈពេញតួជាដៃគូក្នុងសៀវភៅជំនួយសិស្ស។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ឰដ៏** លើក្តារខៀនរួចចង្អុលនិងអាន **ស្រៈពេញតួ ឰ ដ លេខអស្តា ឰដ៏** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ឱសថ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **ឱកាស** ដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ⏱ ៨នាទី

ក- ឱវាទ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ឱវាទ មានន័យថា ដំបូន្មាន ពាក្យសម្រាប់ណែនាំទៅអ្នកណាម្នាក់ឱ្យធ្វើអ្វីមួយ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ឱវាទ ។ សុភាពស្ដាប់ឱវាទឪពុកម្ដាយ ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ឱវាទ** រួមគ្នា។ គ្រូផ្ដើម **កុមារគ្រប់រូប ត្រូវស្ដាប់ ........... លោកគ្រូ អ្នកគ្រូ**។ សិស្សថា **ឱវាទ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ឱវាទ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ឱវាទ** ជាដៃគូ។ |

ខ- ឮដំ បង្រៀនដូចពាក្យខាងលើឥឡូវ។ **ឮដំ មានន័យថា នៅឯ នៅទី។ ឧ.សត្វហើរឮដំអាកាស។**

## ៥- ការអានល្បះ ⏱ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពពករសាត់ឮដំអាកាស។**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពពក/រសាត់/ឮដំ/អាកាស។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ពពករសាត់ឮដំអាកាស។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពពករសាត់ឮដំអាកាស។** |
| សិស្ស | - សិស្សអានល្បះ **ពពករសាត់ឮដំអាកាស។**។ |

## ៦- ការអានអត្ថបទខ្លី ⏱ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើតាឪឮសូរសំឡេងនរណាយំ?**

**២- តើចៅឯមជាសះពីជំងឺដោយសារអ្វី?**

**៣ - តើកូនគិតថា ចៅឯមឈឺអ្វី?**

**៤- នៅពេលកូនមានជំងឺតើកូនធ្វើដូចម្ដេច?**

## ៧- ការសរសេរ ⏱ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ឮដំ ឮ ដ ំ** រួចសរសេរ **ឮដំ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ឯណា ឯ ណ ា** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ឱសថ ឱកាស ឮ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ឱសថព្យាបាលជំងឺ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⏱ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# លំនាំបង្រៀន

# មេរៀន

# ព្យញ្ជនៈ និងជើងព្យញ្ជនៈ

## មេរៀនទី ៦៧ក ព្យញ្ជនៈ និងជើងព្យញ្ជនៈ ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ ◷ ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន ◷ ៥នាទី

- គ្រូរំឭកជើងព្យញ្ជនៈដែលបានរៀនរួច **ក ខ គ ឃ ង ច ឆ ជ ឈ ញ**។

### ១- ការស្គាល់តួអក្សរថ្មី ◷ ២៨ នាទី

- គ្រូប្រាប់ថា **យើងបានស្គាល់ស្រៈនិងព្យញ្ជនៈរួចហើយ ថ្ងៃនេះយើងនឹងរៀនអំពីជើងព្យញ្ជនៈ។ គ្រប់ជើងព្យញ្ជនៈទាំងអស់មានសូរសំឡេងដូចតួរបស់វាដែរ។**

ក- ក្ក

| | |
|---|---|
| គ្រូ | - សរសេរអក្សរ ក ឱ្យធំនៅផ្នែកខាងលើក្ដារខៀនរួចអានថា ក។ បន្ទាប់មកគ្រូសរសេរជើង ្ក រួចចង្អុលនិងអានជាគំរូ **ក ជើង** ្ក (ក្ក)។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ក ជើង** ្ក រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ក ជើង** ្ក រួមគ្នា។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ក្ក ខាងលើចំពោះ **ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ** ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្ដារខៀន ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ ( ឧ. **ក ជើង** ្ក ... )។

### ២- ការអានព្យញ្ជនៈ និងជើងព្យញ្ជនៈ ◷ ២៥នាទី

#### ២.១ - ការអានព្យញ្ជនៈ និងជើងព្យញ្ជនៈ

| | |
|---|---|
| សិស្ស | - គ្រូណែនាំសិស្សឱ្យអាន ព្យញ្ជនៈ និងជើងព្យញ្ជនៈ ក្នុងសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានព្យញ្ជនៈ និងជើងព្យញ្ជនៈ ក្នុងសៀវភៅជំនួយសិស្សជាដៃគូ។ |

#### ២.២- ការភ្ជាប់ ព្យញ្ជនៈ និងជើងព្យញ្ជនៈ

| | |
|---|---|
| គ្រូ | - បើកសៀវភៅជំនួយសិស្ស រួចយកចង្អុលដៃគូសភ្ជាប់ព្យញ្ជនៈ **គ** ទៅនឹងជើងរបស់វា ្គ ជាគំរូ។ |
| គ្រូនិងសិស្ស | - បើកសៀវភៅជំនួយសិស្ស រួចយកចង្អុលដៃគូសភ្ជាប់ព្យញ្ជនៈ **ក** ទៅនឹងជើងរបស់វា ្ក រួមគ្នា។ |
| សិស្ស | - សិស្សគូសភ្ជាប់ព្យញ្ជនៈនិងជើងព្យញ្ជនៈ ជាដៃគូ។ |

### ៣- ការសរសេរ ◷ ១៦នាទី

#### ៣.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ក្ក** ក ្ក រួចសរសេរ **ក្ក** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ខ្ខ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរអក្សរទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## មេរៀនទី ៦៧ខ ព្យញ្ជនៈ និងជើងព្យញ្ជនៈ **ង្គ ឞ្ឞ ខ្ខ ឈ្ឈ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន** ⌚ ៨០នាទី

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកជើងព្យញ្ជនៈដែលបានរៀនរួច ្ក ្ខ ្គ ្ឃ ្ច ្ឆ ្ជ ្ឈ ្ឈ ្ញ **ញ**។

## ១- ការស្គាល់តួអក្សរថ្មី ⌚ ២៨ នាទី

- គ្រូប្រាប់ថា **យើងបានស្គាល់ស្រៈនិងព្យញ្ជនៈរួចហើយ ថ្ងៃនេះយើងនឹងរៀនអំពីជើងព្យញ្ជនៈ។ គ្រប់ជើងព្យញ្ជនៈ ទាំងអស់ មានសូរសំឡេងដូចតួរបស់វាដែរ។**

ក- ង្គ

| | |
|---|---|
| គ្រូ | - សរសេរអក្សរ ង ឱ្យធំនៅផ្នែកខាងលើក្ដារខៀនរួចអានថា **ង**។ បន្ទាប់មកគ្រូសរសេរជើង ្គ រួចចង្អុលនិងអានជាគំរូ **ង ជើង** ្គ (**ង្គ**)។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ង ជើង** ្គ រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ង ជើង** ្គ រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀន **ង្គ** ខាងលើចំពោះ **ឞ្ឞ ខ្ខ ឈ្ឈ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន**។

គ-គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្ដារខៀន ង្គ ឞ្ឞ ខ្ខ ឈ្ឈ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ (ឧ. **ង ជើង** ្គ ... )។

## ២- ការអានព្យញ្ជនៈ និងជើងព្យញ្ជនៈ ⌚ ២៥នាទី

### ២.១ - ការអានព្យញ្ជនៈ និងជើងព្យញ្ជនៈ

| | |
|---|---|
| សិស្ស | - គ្រូណែនាំសិស្សឱ្យអាន ព្យញ្ជនៈ និងជើងព្យញ្ជនៈ ក្នុងសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានព្យញ្ជនៈ និងជើងព្យញ្ជនៈ ក្នុងសៀវភៅជំនួយសិស្សជាដៃគូ។ |

### ២.២- ការភ្ជាប់ ព្យញ្ជនៈ និងជើងព្យញ្ជនៈ

| | |
|---|---|
| គ្រូ | - បើកសៀវភៅជំនួយសិស្ស រួចយកចង្អុលដៃគូសភ្ជាប់ព្យញ្ជនៈ **ណ** ទៅនឹងជើងរបស់វា ្ណ ជាគំរូ។ |
| គ្រូនិងសិស្ស | - បើកសៀវភៅជំនួយសិស្ស រួចយកចង្អុលដៃគូសភ្ជាប់ព្យញ្ជនៈ **ឈ** ទៅនឹងជើងរបស់វា ្ឈ រួមគ្នា។ |
| សិស្ស | - សិស្សគូសភ្ជាប់ព្យញ្ជនៈនិងជើងព្យញ្ជនៈ ជាដៃគូ។ |

## ៣- ការសរសេរ ⌚ ១៦នាទី

### ៣.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ណ្ណ** ណ ្ណ រួចសរសេរ **ណ្ណ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ឞ្ឞ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ខ្ខ ឈ្ឈ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរអក្សរទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

| មេរៀនទី ៦៧គ | ព្យញ្ជនៈ និងជើងព្យញ្ជនៈ ឞ ផ្ន ព្ព ភ្ភ ម្ម យ្យ ប្រ ល្ល វ្វ ស្ស ហ្ហ ឡ្ល អ្អ | ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ៥នាទី

- គ្រូរំឭកជើងព្យញ្ជនៈដែលបានរៀនរួច ្ត ្ថ ្ទ ្ឋ ្ណ ្ត ្ថ ្ទ ្ធ ្ន។

**១- ការស្គាល់តួអក្សរថ្មី** ២៨ នាទី

- គ្រូប្រាប់ថា **យើងបានស្គាល់ស្រៈនិងព្យញ្ជនៈរួចហើយ ថ្ងៃនេះយើងនឹងរៀនអំពីជើងព្យញ្ជនៈ។ គ្រប់ជើងព្យញ្ជនៈទាំងអស់មានសូរសំឡេងដូចតួរបស់វាដែរ។**

ក- ឞ

| | |
|---|---|
| គ្រូ | - សរសេរអក្សរ **ប** ឱ្យធំនៅផ្នែកខាងលើក្ដារខៀនរួចអានថា **ប**។ បន្ទាប់មកគ្រូសរសេរជើង ្ឞ រួចចង្អុលនិងអានជាគំរូ **ប ជើង** ្ឞ (**ឞ**)។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ប ជើង** ្ឞ រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ប ជើង** ្ឞ រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀន **ឞ** ខាងលើចំពោះ **ផ្ន ព្ព ភ្ភ ម្ម យ្យ ប្រ ល្ល វ្វ ស្ស ហ្ហ ឡ្ល អ្អ** ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្ដារខៀន ឞ ផ្ន ព្ព ភ្ភ ម្ម យ្យ ប្រ ល្ល វ្វ ស្ស ហ្ហ ឡ្ល អ្អ រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ ( ឧ. **ប ជើង** ្ឞ ... ) ។

**២- ការអានព្យញ្ជនៈ និងជើងព្យញ្ជនៈ** ២៥នាទី

**២.១ - ការអានព្យញ្ជនៈ និងជើងព្យញ្ជនៈ**

| | |
|---|---|
| សិស្ស | - គ្រូណែនាំសិស្សឱ្យអាន ព្យញ្ជនៈ និងជើងព្យញ្ជនៈ ក្នុងសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានព្យញ្ជនៈ និងជើងព្យញ្ជនៈ ក្នុងសៀវភៅជំនួយសិស្សជាដៃគូ។ |

**២.២- ការភ្ជាប់ ព្យញ្ជនៈ និងជើងព្យញ្ជនៈ**

| | |
|---|---|
| គ្រូ | - បើកសៀវភៅជំនួយសិស្ស រួចយកចង្អុលដៃគូសភ្ជាប់ព្យញ្ជនៈ **ប** ទៅនឹងជើងរបស់វា ្ឞ ជាគំរូ។ |
| គ្រូនិងសិស្ស | - បើកសៀវភៅជំនួយសិស្ស រួចយកចង្អុលដៃគូសភ្ជាប់ព្យញ្ជនៈ **ព** ទៅនឹងជើងរបស់វា ្ព រួមគ្នា។ |
| សិស្ស | - សិស្សគូសភ្ជាប់ព្យញ្ជនៈនិងជើងព្យញ្ជនៈ ជាដៃគូ។ |

**៣- ការសរសេរ** ១៦នាទី

**៣.១- ការសរសេរពាក្យ**

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ឞ ប** ្ឞ រួចសរសេរ **ឞ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ផ្ន** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា**ភ្ភ ម្ម យ្យ ប្រ ល្ល វ្វ ស្ស ហ្ហ ឡ្ល អ្អ** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរអក្សរទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

**ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ** ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# លំនាំបង្រៀន
# មេរៀនធ្វើជើង

**គន្លឹះត្រូវចងចាំ**

- ✓ គ្រប់សកម្មភាពត្រូវអនុវត្តទៅតាមលំនាំក្នុងសៀវភៅណែនាំគ្រូនិងប្រើប្រាស់ពាក្យពេចន៍ជាអក្សរដិត។
- ✓ ក្នុងពេលអាន សិស្សត្រូវប្រើភ្នែក និងចង្អុលដៃទៅតាមតួអក្សរ។
- ✓ គ្រូត្រូវដើរតាមតុសិស្ស ស្តាប់សិស្សអានជាដៃគូ និងជួយកែតម្រូវសិស្សណាអានមិនទាន់ត្រឹមត្រូវ។
- ✓ ប្រសិនបើសិស្សណាលំបាកអាន គ្រូត្រូវជួយសិស្សនោះ។ គ្រូអាចអានពាក្យជាគំរូ អានពាក្យនោះម្តងទៀតជាមួយសិស្ស និងឱ្យសិស្សអានពាក្យនោះខ្លួនឯងម្តងទៀត។
- ✓ ប្រសិនបើសិស្សភាគច្រើនមានការលំបាក គ្រូត្រូវណែនាំឡើងវិញដោយប្រើ វិធីគ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើជាមួយសិស្សទាំងអស់ក្នុងថ្នាក់។
- ✓ សម្រាប់ការបង្រៀនតួអក្សរថ្មី គ្រូត្រូវសរសេរតួអក្សរដែលត្រូវរៀនធំៗលើក្តារខៀន។
- ✓ អនុវត្ត គ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើ ដូចដែលបានលម្អិតក្នុងសៀវភៅណែនាំគ្រូ។
- ✓ គ្រូដើរតាមតុក្នុងថ្នាក់ ពេលគ្រូនិងសិស្សធ្វើ សិស្សធ្វើ ក្នុងគ្រប់សកម្មភាពអាន និងសរសេរដើម្បីជួយសិស្ស។
- ✓ សម្រាប់សកម្មភាពអាន ឱ្យសិស្សអានលើសពីម្តង។
- ប្រសិនបើមានសិស្សខ្សោយគំហើញ និងខ្សោយស្តាប់ រាល់ការបង្ហាញ និងការណែនាំរបស់គ្រូត្រូវប្រាកដថាសិស្សទាំងនោះស្តាប់ឮ និងឃើញច្បាស់។
- គ្រូប្រើប័ណ្ណពាក្យ ល្បះសម្រាប់សិស្សខ្សោយស្តាប់ និងខ្សោយគំហើញ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## លំនឹងថ្នាក់ និងរំឭកមេរៀន ⏲ ៥ នាទី

- ◎ រំឭកពាក្យដែលបានរៀន
- សម្ភារៈ
- ⏲ ៥ នាទី

គ្រូសរសេរពាក្យ **ក្អម ក្អាត់ ក្បោះក្បាយ ក្សេមក្សាន្ត** មួយម្តងៗ ឱ្យសិស្សអាន ឬហៅឱ្យសិស្សសរសេរលើក្តារឆ្នួន ហើយអាន។ គ្រូកែតម្រូវសិស្ស ដែលអាន ឬសរសេរមិនបានត្រឹមត្រូវ។

## ១- ការស្គាល់សូរអក្សរថ្មី ⏲ ៥ នាទី

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៧៨ | ផ្ញើជើង ជ្រ ជ្វ | ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ឆ្អិនឆ្អៅ ប្របូកប្របល់ ឆ្លងឆ្លើយ ក្លារឆ្នួន ឆ្នាំឆ្លូវ។**

**១- ការស្គាល់សូរអក្សរថ្មី** ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ជ្រ

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ជ្រូក**។ បន្លឺថា **ជ្រូក ។ តើពាក្យ ជ្រូកមានសូរដើមអ្វី? ជ្រ**។ គ្រូបន្លឺ **ជ្រ** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ជ្រ** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ជ្រ** រួមគ្នា។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ជ្រ ខាងលើចំពោះសូរ ជ្វ (ជំឡូងជ្វា)។

**២- ការស្គាល់តួអក្សរថ្មី** ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ជ្រ

| | |
|---|---|
| គ្រូ | - សរសេរ **ជ្រ** លើក្ដារខៀនរួចចង្អុលនិងអាន **ជ ជើង ្រ ជ្រ**។ |
| គ្រូនិងសិស្ស | - អាន **ជ្រ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ជ្រ** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ជ្រ ខាងលើចំពោះ ជ្វ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃជាក់លើក្ដារខៀន ផ្ញើជើង ជ្រ ជ្វ រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ ដោយផ្សំប្រកប **(ឧ. ជ ជើង ្រ ជ្រ )** រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ជ្រ ជ្វ**។

**៣- ការអានព្យាង្គនិងពាក្យ** ១៨នាទី

**៣.១ - ការអានព្យាង្គ**

| | |
|---|---|
| គ្រូ | - សរសេរ **ជ្រូ** លើក្ដារខៀនរួចចង្អុលនិងអាន **ជ្រ អ៊ូ ជ្រូ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ជ្វា** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ជ្រឺ ជ្រា ជ្វើ** ម្ដងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ជ្រុលជ្រួស** លើក្ដារខៀនរួចចង្អុលនិងអាន **ជ្រ អ៊ុ ជ្រុ និង ល ជ្រុល ជ្រ អួ ជ្រួ និង ស ជ្រួស ជ្រុលជ្រួស**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ទន់ជ្រាយ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ទុំជ្រុះ** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- ជ្រោមជ្រែង

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ជ្រោមជ្រែង មានន័យថា ទំនុកបម្រុងដោយជួយគាំពារ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ជ្រោមជ្រែង។ ពុកម៉ែជួយជ្រោមជ្រែងកូនរៀនសូត្រ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ជ្រោមជ្រែង** រួមគ្នា។ គ្រូផ្ដើម **មេភូមិជួយ.....នាយកដើម្បីធ្វើខ្លោងទ្វារសាលារៀន។** សិស្សថា **ជ្រោមជ្រែង** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | អានពាក្យ **ជ្រោមជ្រែង** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ជ្រោមជ្រែង** ជាដៃគូ។ |

ខ- ជ្រួយ បង្រៀនដូចពាក្យខាងលើ។ **ជ្រួយ មានន័យថា ធ្វើឱ្យផុស ឱ្យធូរ ចាក់គាស់។ ឧ.កុមារជ្រួយដីជាំផ្កាមុខថ្នាក់រៀន។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ជ្រឹងជាច្រើនទំលើមែកជ្រៃ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ជ្រឹង/ជា/ច្រើន/ទំ/លើ/មែក/ជ្រៃ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ជ្រឹងជាច្រើនទំលើមែកជ្រៃ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ជ្រឹងជាច្រើនទំលើមែកជ្រៃ។** |
| សិស្ស | - សិស្សអានល្បះ **ជ្រឹងជាច្រើនទំលើមែកជ្រៃ ។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើជ្រឹងទំនៅឯណា?**

**២- តើជ្រឹងឃើញជ្រូកធ្វើអ្វីខ្លះ?**

**៣- ហេតុអ្វីបានជាជ្រូកជ្រមុជក្បាលចូលក្នុងជ្រាំ?**

**៤- តើកូនៗគិតថាជ្រូកជាសត្វដូចម្ដេច?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ជ្រើសរើស ជ ្រ ើ ស រ ើ ស** រួចសរសេរ **ជ្រើសរើស** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ជ្រោមជ្រែង ជ ្រ ោ ម ជ ្រ ែ ង** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ជ្រលក់ ជ្រូក ជំឡូងជ្វា** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **បបរបាយជ្រូក** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៧៩ | ផ្ញើជើង ឈ្វ ឈ្ន ឈ្ម ឈ្ល ឈ្វ | ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ដំឡូងជ្វា ជ្រើសរើស ឆ្អិនឆ្អៅ ឆ្អល់ពោះ ឆ្អែតឆ្អត ។**

**១- ការស្គាល់សូរអក្សរថ្មី** ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ឈ្វ

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ឈ្វោក**។ បន្លឺថា **ឈ្វោក ។ តើពាក្យ ឈ្វោកមានសូរដើមអ្វី? ឈ្វ**។ គ្រូបន្លឺ **ឈ្វ** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ឈ្វ** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ឈ្វ** រួមគ្នា។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀនសូរ **ឈ្វ** ខាងលើចំពោះសូរ **ឈ្ន**(**ឈ្នាង**) **ឈ្ម**(**ឈ្មោល**) **ឈ្ល**(**ឈ្លូស**) **ឈ្វ**(**ត្រីឈ្វាត**)។

**២- ការស្គាល់តួអក្សរថ្មី** ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ឈ្វ

| | |
|---|---|
| គ្រូ | - សរសេរ **ឈ្វ** លើក្តារខៀនរួចចង្អុលនិងអាន **ឈ ជើង ្វ ឈ្វ**។ |
| គ្រូនិងសិស្ស | - អាន **ឈ្វ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ឈ្វ** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ឈ្វ ខាងលើចំពោះ ឈ្ន ឈ្ម ឈ្ល ឈ្វ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្តារខៀន ផ្ញើជើង ឈ្ន ឈ្ម ឈ្ល ឈ្វ រួចចង្អុលឱ្យសិស្សអានម្តងមួយៗ ដោយផ្សំប្រកប ( **ឧ. ឈ ជើង ្វ ឈ្វ** ) រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ឈ្ន ឈ្ម ឈ្ល ឈ្វ**។

**៣- ការអានព្យាង្គនិងពាក្យ** ១៨នាទី

**៣ ១.- ការអានព្យាង្គ**

| | |
|---|---|
| គ្រូ | - សរសេរ **ឈ្វោ** លើក្តារខៀនរួចចង្អុលនិងអាន **ឈ្វ អោ ឈ្វោ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ឈ្នា** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ឈ្លុ ឈ្មោ ឈ្វា** ម្តងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ឈ្មុសឈ្មុល** លើក្តារខៀនរួចចង្អុលនិងអាន **ឈ្ម អ៊ុ ឈ្មុ និង ស ឈ្មុស ឈ្ម អ៊ុ ឈ្មុ និង ល ឈ្មុល ឈ្មុសឈ្មុល ។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ឈ្លានពាន** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ឈ្លាសវៃ** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- ឈ្ងុយឈ្ងប់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ឈ្ងុយឈ្ងប់** **មានន័យថា ដែលមានក្លិនក្រអូបងំឆ្ងិត។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ឈ្ងុយឈ្ងប់។ ផ្កាម្លិះមានក្លិនក្រអូបឈ្ងុយឈ្ងប់។** |
| គ្រូនិងសិស្ស | - អានពាក្យ **ឈ្ងុយឈ្ងប់** រួមគ្នា។ គ្រូផ្ដើម **ផ្ការំដួលជះក្លិនក្រអូប...។** សិស្សថា **ឈ្ងុយឈ្ងប់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ឈ្ងុយឈ្ងប់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ឈ្ងុយឈ្ងប់** ជាដៃគូ។ |

ខ- ឈ្ងុស បង្រៀនដូចពាក្យខាងលើ។ **ឈ្ងុស មានន័យថា ឈូសគាស់ដីដោយច្រមុះ។ ឧ.ជ្រូកឈ្ងុសដំណាំក្នុងចម្ការ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **កូនឈ្លូសឈ្មោលបោលរកមេវា។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **កូន/ឈ្លូស/ឈ្មោល/បោល/រក/មេ/វា។**

| | |
|---|---|
| គ្រូ | - គ្រូអាន **កូនឈ្លូសឈ្មោលបោលរកមេវា។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **កូនឈ្លូសឈ្មោលបោលរកមេវា។** |
| សិស្ស | - សិស្សអានល្បះ **កូនឈ្លូសឈ្មោលបោលរកមេវា។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើឈ្លូសរាប់អាននរណាជាមិត្ត?**

**២- តើឈ្លើងទាមឈ្លូសនៅពេលណា?**

**៣- ហេតុអ្វីបានជាឈ្មាតឈ្លោះជាមួយឈ្លើង?**

**៤- តើកូនគិតថា ឈ្លើងជាសត្វដូចម្ដេច?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ឈ្លានពាន ឈ ◌្ល ◌ា ន ព ◌ា ន** រួចសរសេរ **ឈ្លានពាន** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ឈ្លាសវៃ ឈ ◌្ល ◌ា ស វ ◌ៃ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ឈ្មោះ ឈ្ងុយឈ្ងប់ ឈ្នាន់** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ឈ្លូសឈ្មោលឈ្ងុស** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| មេរៀនទី៨០ | ផ្ញើជើង ត្ឋ ត្ន ត្រ | ⏲ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⏲ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ឈ្លានពាន ឈ្លាសវៃ ជ្រមុជ ជ្រលក់ ជើងធ្វេង។**

**១- ការស្គាល់សូរអក្សរថ្មី** ⏲ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ត្ឋ

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ត្បូង**។ បន្លឺថា **ត្បូង។ តើពាក្យ ត្បូងមានសូរដើមអ្វី? ត្ប**។ គ្រូបន្លឺ **ត្ប** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ត្ប** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ត្ប** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ **ត្ប** ខាងលើចំពោះសូរ **ត្ន (ត្នាត) ត្រ(ត្រាវ)**។

**២- ការស្គាល់តួអក្សរថ្មី** ⏲ ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ត្ប

| | |
|---|---|
| គ្រូ | - សរសេរ **ត្ប** លើក្ដារខៀនរួចចង្អុលនិងអាន **ត ជើង ប ត្ប**។ |
| គ្រូនិងសិស្ស | - អាន **ត្ប** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ត្ប** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ត្ប ខាងលើចំពោះ ត្ន ត្រ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃជាក់លើក្ដារខៀន ផ្ញើជើង ត្ប ត្ន ត្រ រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ ដោយផ្សំប្រកប (ឧ. **ត ជើង ប ត្ប** ) រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ត្ប ត្ន ត្រ**។

**៣- ការអានព្យាង្គនិងពាក្យ** ⏲ ១៨នាទី

**៣.១ - ការអានព្យាង្គ**

| | |
|---|---|
| គ្រូ | - សរសេរ **ត្បូ** លើក្ដារខៀនរួចចង្អុលនិងអាន **ត្ប អូ ត្បូ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ត្នា** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ត្រា ត្បា ត្នោ** ម្ដងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ត្រឹមត្រូវ** លើក្ដារខៀនរួចចង្អុលនិងអាន **ត្រ អឹ ត្រឹ និង ម ត្រឹម ត្រ អូ ត្រូ និង វ ត្រូវ ត្រឹមត្រូវ។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ត្បាល់កិន** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ត្នាតភ្លើង** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- ត្បូរ

| | |
|---|---|
| គ្រូ | គ្រូពន្យល់ពាក្យ **ត្បូរ** មានន័យថា សសុលចូល មមុលចូល ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ត្បូរ។ **កណ្ដុរត្បូរគំនរចំបើង។** |
| គ្រូនិងសិស្ស | - អានពាក្យ **ត្បូរ** រួមគ្នា។ គ្រូផ្ដើម **ជ្រូក.....ដីភក់។** សិស្សថា **ត្បូរ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ត្បូរ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ត្បូរ** ជាដៃគូ។ |

ខ- ត្រួតត្រា បង្រៀនដូចពាក្យខាងលើ។ **ត្រួតត្រា** មានន័យថា **ត្រួតមើលឱ្យដឹងខុសឬត្រូវ បើខុសបញ្ជាឱ្យធ្វើឱ្យត្រូវ។**

**ឧ.មេជាងផ្ទះត្រួតត្រាកម្មករ ។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ត្មាតរត់ក្បែរដើមត្រែង។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ត្មាត/រត់/ក្បែរ/ដើមត្រែង។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ត្មាតរត់ក្បែរដើមត្រែង។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ត្មាតរត់ក្បែរដើមត្រែង ។** |
| សិស្ស | - សិស្សអានល្បះ **ត្មាតរត់ក្បែរដើមត្រែង។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើមីងត្រប់ធ្វើអ្វីនៅឯណា?**

**២- តើត្រុំធ្វើអ្វីនៅឯណា?**

**៣- ហេតុអ្វីបានត្មាតត្បូរក្បែរទ្រើងត្រឡាច ពេលវាឃើញខ្មោចត្រី?**

**៤- តើកូនធ្លាប់ដាំ ឬឃើញគេដាំត្រកួនដែរឬទេ? តើគេដាំ និងថែទាំវាដូចម្ដេច?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ត្មាតភ្លើង** ត ្ម ា ត ភ ្ល េ ី ង រួចសរសេរ **ត្មាតភ្លើង** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ត្រឡាច** ត ្រ ឡ ា ច រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ត្រួតត្រា ត្បាល់ត្បៀង ត្បូង** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ត្បាញហូលផាមួង** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៨១ | ផ្ញើជើង ថ្ក ថ្ង ថ្ន ថ្ម ថ្ល ថ្វ | ⌚ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ជ្រោមជ្រែង ដំឡូងជ្វា ឈ្មុយឈ្មប់ ត្បាល់ត្បឿង ត្រឡាច។**

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ថ្ក

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ថ្កូវ**។ បន្លឺថា **ថ្កូវ** ។ **តើពាក្យ ថ្កូវមានសូរដើមអ្វី? ថ្ក** ។ គ្រូបន្លឺ **ថ្ក** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ថ្ក** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ថ្ក** រួមគ្នា។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ថ្ក ខាងលើចំពោះសូរ **ថ្ង(ថ្ងាស) ថ្ន(ថ្នាក់) ថ្ម(ថ្មី) ថ្ល(ថ្លង់) ថ្វ(ថ្វាយ)**។

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ថ្ក

| | |
|---|---|
| គ្រូ | - សរសេរ **ថ្ក** លើក្តារខៀនរួចចង្អុលនិងអាន **ថ ជើង ្ក ថ្ក**។ |
| គ្រូនិងសិស្ស | - អាន **ថ្ក** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ថ្ក** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ថ្ក ខាងលើចំពោះ ថ្ង ថ្ន ថ្ម ថ្ល ថ្វ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្តារខៀន ផ្ញើជើង ថ្ក ថ្ង ថ្ន ថ្ម ថ្ល ថ្វ រួចចង្អុលឱ្យសិស្សអានម្តងមួយៗ ដោយផ្សំប្រកប **( ឧ. ថ ជើង ្ក ថ្ក )** រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ថ្ក ថ្ង ថ្ន ថ្ម ថ្ល ថ្វ**។

**៣- ការអានព្យាង្គនិងពាក្យ** ⌚ ១៨នាទី

**៣ ១.- ការអានព្យាង្គ**

| | |
|---|---|
| គ្រូ | - សរសេរ **ថ្កូ** លើក្តារខៀនរួចចង្អុលនិងអាន **ថ្ក អូ ថ្កូ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ថ្ងៃ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ថ្នា ថ្មើ ថ្លោះ ថ្វី** ម្តងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ថ្កើងថ្កាន** លើក្តារខៀនរួចចង្អុលនិងអាន **ថ្ក អើ ថ្កើ និង ង ថ្កើង ថ្ក អា ថ្កា និង ន ថ្កាន ថ្កើងថ្កាន** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ថ្នាក់ថ្នម** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ថ្មោងថ្មី** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- ថ្នាក់ថ្នម

| | |
|---|---|
| គ្រូ | គ្រូពន្យល់ពាក្យ **ថ្នាក់ថ្នម មានន័យថា បីបាច់ក្សាមិនឱ្យហ្មង បីបាច់រក្សាដោយប្រយ័ត្ន ថ្នមមិនឱ្យអាក់ចិត្ត។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ថ្នាក់ថ្នម។ ពុកម៉ែថ្នាក់ថ្នមកូនៗ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ថ្នាក់ថ្នម** រួមគ្នា។ គ្រូផ្ដើម **មីងសួនបីកូនដោយ...**។ សិស្សថា **ថ្នាក់ថ្នម** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ថ្នាក់ថ្នម** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ថ្នាក់ថ្នម** ជាដៃគូ។ |

ខ- ថ្លៃថ្នូរ បង្រៀនដូចពាក្យខាងលើ។ **ថ្លៃថ្នូរ មានន័យថា មានតម្លៃគួរលើកសរសើរ គួររាប់អាន។ ឧ.ពូសំមានឫកពាថ្លៃថ្នូរ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ម៉ែថ្នាក់ថ្នមកូនដោយចិត្តថ្លៃថ្លា**។គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ម៉ែ/ថ្នាក់ថ្នម/កូន/ដោយ/ចិត្ត/ថ្លៃថ្លា**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ម៉ែថ្នាក់ថ្នមកូនដោយចិត្តថ្លៃថ្លា**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ម៉ែថ្នាក់ថ្នមកូនដោយចិត្តថ្លៃថ្លា**។ |
| សិស្ស | - សិស្សអានល្បះ **ម៉ែថ្នាក់ថ្នមកូនដោយចិត្តថ្លៃថ្លា**។<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពស់ថ្លាន់ធ្វើអ្វីកូនថ្លែន?**

**២- តើកូនថ្លែនរត់បុកអ្វី ត្រូវចំកន្លែងណា?**

**៣- តើកូនគិតថា ហេតុអ្វីបានជាពស់ថ្លាន់ដេញកូនថ្លែន?**

**៤- បើកូនឃើញនរណាម្នាក់ជួបនឹងគ្រោះថ្នាក់ តើកូនធ្វើដូចម្ដេច?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ថ្នោងថ្មី ថ ្ន េា ង ថ ្ម ី** រួចសរសេរ **ថ្នោងថ្មី** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ថ្នាក់ថ្នម ថ ្ន ា ក ់ ថ ្ន ម** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ថ្កើងថ្កាន ថ្មី ថ្លៃថ្លា** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ឫកពាថ្លៃថ្នូរ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៨២ | ផ្ញើជើង ទ្រ ទ្វ | ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ថ្ងួចថ្ងូរ ថ្កើងថ្កាន ត្រួតត្រា ត្រកួន ឈ្លានពាន។**

## ១- ការស្គាល់សូរអក្សរថ្មី ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ទ្វ

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ទ្វារ**។ បន្លឺថា **ទ្វារ**។ **តើពាក្យ ទ្វារមានសូរដើមអ្វី? ទ្វ** ។គ្រូបន្លឺ **ទ្វ** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ទ្វ** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ទ្វ** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ទ្វ ខាងលើចំពោះសូរ ទ្រ(ទ្រុង)។

## ២- ការស្គាល់តួអក្សរថ្មី ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ទ្វ

| | |
|---|---|
| គ្រូ | - សរសេរ **ទ្វ** លើក្តារខៀនរួចចង្អុលនិងអាន **ទ ជើង ្វ ទ្វ**។ |
| គ្រូនិងសិស្ស | - អាន **ទ្វ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ទ្វ** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ទ្វ ខាងលើចំពោះ ទ្រ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្តារខៀន ផ្ញើជើង ទ្វ ទ្រ រួចចង្អុលឱ្យសិស្សអានម្តងមួយៗ ដោយផ្សំប្រកប **(ឧ. ទ ជើង ្វ ទ្វ )** រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ទ្វ ទ្រ**។

## ៣- ការអានព្យាង្គនិងពាក្យ ១៨នាទី

### ៣.១ - ការអានព្យាង្គ

| | |
|---|---|
| គ្រូ | - សរសេរ **ទ្វា** លើក្តារខៀនរួចចង្អុលនិងអាន **ទ្វ អា ទ្វា**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ទ្រើ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ទ្រុ ទ្វី ទ្រេ** ម្តងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ទ្រាំទ្រ** លើក្តារខៀនរួចចង្អុលនិងអាន **ទ្រ អាំ ទ្រាំ ទ្រ ទ្រាំទ្រ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ទ្វីបលោក** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ទ្រុឌទ្រោម** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ៨នាទី

ក- ទ្រេតទ្រោត

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ **ទ្រេតទ្រោត មានន័យថា ងេកងោក ដែលទេរងោកទៅខាងនេះម្តង ទៅខាងនោះម្តង។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ទ្រេតទ្រោត។ អ្នកស្រវឹងស្រាដើរទ្រេតទ្រោត។** |

| | |
|---|---|
| គ្រូនិងសិស្ស | - អានពាក្យ **ទ្រេតទ្រោត** រួមគ្នា។ គ្រូផ្ដើម **ពូទ្រីនឈឺចង្កេះដើរ.....**។ សិស្សថា **ទ្រេតទ្រោត** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ទ្រេតទ្រោត** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ទ្រេតទ្រោត** ជាដៃគូ។ |

ខ -ទ្រុឌទ្រោម បង្រៀនដូចពាក្យខាងលើ។ **ទ្រុឌទ្រោម មានន័យថា ស្រុតចុះ លិចចុះ ផតខ្ទូងចុះ។**

**ឧ. អគារនេះចាស់ទ្រុឌទ្រោម។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **អ៊ំសឿនជួសជុលទ្រុងជ្រូក។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **អ៊ំសឿន/ជួសជុល/ទ្រុង/ជ្រូក។**

| | |
|---|---|
| គ្រូ | - គ្រូអាន **អ៊ំសឿនជួសជុលទ្រុងជ្រូក។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **អ៊ំសឿនជួសជុលទ្រុងជ្រូក។** |
| សិស្ស | - សិស្សអានល្បះ **អ៊ំសឿនជួសជុលទ្រុងជ្រូក។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- ពូទ្រីដាក់ទ្រូនៅឯណា?**

**២- តើទ្រុងជ្រូកពូទ្រីកើតអ្វី?**

**៣- ហេតុអ្វីបានជាពូទ្រីធ្វើទ្រុងជ្រូកថ្មី?**

**៤- បើគេចិញ្ចឹមជ្រូកមិនដាក់ទ្រុង តើកូនយល់ដូចម្ដេច?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ទ្វីបលោក ទ ្វ ី ប ល ោ ក** រួចសរសេរ **ទ្វីបលោក** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ទ្រេតទ្រោត ទ ្រ េ ត ទ ្រ ោ ត** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ទ្រុង ទ្រុឌទ្រោម ទ្រាំទ្រ** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ដើរទ្រេតទ្រោត** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| មេរៀនទី៨៣ | **ផ្ញើជើង ធ្ង ធ្ន ធ្ម** | 🕒 ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** 🕒 ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ទ្រាំទ្រ ទ្រុឌទ្រោម ថ្កើងថ្កាន ថ្លៃថ្នូរ ត្រក្លួន ។**

**១- ការស្គាល់សូរអក្សរថ្មី** 🕒 ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ធ្ង

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ធ្ងន់**។ បន្លឺថា **ធ្ងន់**។ **តើពាក្យ ធ្ងារមានសូរដើមអ្វី? ធ្ង** ។គ្រូបន្លឺ **ធ្ង** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ធ្ង** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ធ្ង** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ធ្ង ខាងលើចំពោះសូរ ធ្ន( ធ្នើរ ) ធ្ម( ធ្មេញ )។

**២- ការស្គាល់តួអក្សរថ្មី** 🕒 ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ធ្ង

| | |
|---|---|
| គ្រូ | - សរសេរ **ធ្ង** លើក្តារខៀនរួចចង្អុលនិងអាន **ធ ជើង ្ង ធ្ង**។ |
| គ្រូនិងសិស្ស | - អាន **ធ្ង** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ធ្ង** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ធ្ង ខាងលើចំពោះ ធ្ន ធ្ម។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្តារខៀន ផ្ញើជើង ធ្ង ធ្ន ធ្ម រួចចង្អុលឱ្យសិស្សអានម្តងមួយៗ ដោយផ្សំប្រកប ( **ឧ. ធ ជើង ្ង ធ្ង** ) រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ធ្ង ធ្ន ធ្ម**។

**៣- ការអានព្យាង្គនិងពាក្យ** 🕒 ១៨នាទី

**៣.១ - ការអានព្យាង្គ**

| | |
|---|---|
| គ្រូ | - សរសេរ **ធ្ងី** លើក្តារខៀនរួចចង្អុលនិងអាន **ធ្ង អ៊ី ធ្ងី**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ធ្នើ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ធ្មេ ធ្ងួ ធ្នុ** ម្តងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ធ្មេញឈើ** លើក្តារខៀនរួចចង្អុលនិងអាន **ធ្ម អេ ធ្មេ និងញ ធ្មេញ ឈ អ៊ី ឈើ ធ្មេញឈើ។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **គ្រូធ្មប់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ធ្ងន់ធ្ងរ** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ 🕒 ៨នាទី

ក- ធូន់ធ្ងរ

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ **ធ្ងន់ធ្ងរ** **មានន័យថា ធ្ងន់ធ្ងរ ជ្រុលជាបខ្លាំង។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ធ្ងន់ធ្ងរ។ ច្រើបឈឺធ្មេញធ្ងន់ធ្ងរ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ធ្ងន់ធ្ងរ** រួមគ្នា។ គ្រូផ្ដើម **មីងហួនឈឺក្រពះ.....**។ សិស្សថា **ធ្ងន់ធ្ងរ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ធ្ងន់ធ្ងរ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ធ្ងន់ធ្ងរ** ជាដៃគូ។ |

ខ- ធ្មឹង បង្រៀនដូចពាក្យខាងលើ។ **ធ្មឹង មានន័យថា នៅស្ងៀមមិនស្ដី។ ឧ.នារីឈរធ្មឹងពេលឃើញច្រើបយំ។**

## ៥- ការអានល្បះ 🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ការងារដាំធ្មេមិនធ្ងន់ធ្ងរទេ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ការងារ/ដាំ/ធ្មេ/មិន/ធ្ងន់ធ្ងរ/ទេ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ការងារដាំធ្មេមិនធ្ងន់ធ្ងរទេ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ការងារដាំធ្មេមិនធ្ងន់ធ្ងរទេ។** |
| សិស្ស | - សិស្សអានល្បះ **ការងារដាំធ្មេមិនធ្ងន់ធ្ងរទេ។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី 🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើឃ្មៀចសកសម្បុកអ្វី?**

**២- ឃ្មៀចឱ្យច្រើបធ្វើអ្វី?**

**៣- ច្រើបហើមធ្មេញ តើច្រឹមត្រូវធ្វើដូចម្ដេចកុំឱ្យធ្មេញឈឺ?**

**៤- តើកូនត្រូវធ្វើដូចម្ដេចដើម្បីថែរក្សាធ្មេញឱ្យបានល្អ?**

## ៧- ការសរសេរ 🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ធ្នុងត្រី ធ ◌្ន ◌ុ ង ត ◌្រ ◌ី** រួចសរសេរ **ធ្នុងត្រី** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **គ្រូធ្នប់ គ ◌្រ ◌ូ ធ ◌្ន ប ◌់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ធ្ងន់ធ្ងរ ធ្មេញឈើ ធ្នូ** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ធ្នុងត្រីធ្លាំង** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ 🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## មេរៀនទី៨៤ ផ្ញើជើង ប្ត ប្រ ប្ល ប្អ ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ថ្លៃថ្លា ទីបលោក ទ្រេតទ្រោត ផ្ទុងត្រី ធ្ងន់ធ្ងរ។**

### ១- ការស្គាល់សូរអក្សរថ្មី ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ប្ត

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ប្តី**។ បន្លឺថា **ប្តី**។ **តើពាក្យ ប្តីមានសូរដើមអ្វី? ប្ត** ។គ្រូបន្លឺ **ប្ត** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ប្ត** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ប្ត** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ប្ត ខាងលើចំពោះសូរ ប្រ(ប្រុស) ប្ល(ប្លែក) ប្អ(ប្អូន)។

### ២- ការស្គាល់តួអក្សរថ្មី ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ប្ត

| | |
|---|---|
| គ្រូ | - សរសេរ **ប្ត** លើក្តារខៀនរួចចង្អុលនិងអាន **ប ជើង ◌្ត ប្ត**។ |
| គ្រូនិងសិស្ស | - អាន **ប្ត** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ប្ត** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ប្ត ខាងលើចំពោះ ប្រ ប្ល ប្អ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្តារខៀន ផ្ញើជើង ប្ត ប្រ ប្ល ប្អ រួចចង្អុលឱ្យសិស្សអានម្តងមួយៗ ដោយផ្សំប្រកប **( ឧ. ប ជើង ◌្ត ប្ត )** រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ប្ត ប្រ ប្ល ប្អ**។

### ៣- ការអានព្យាង្គនិងពាក្យ ១៨នាទី

**៣.១ - ការអានព្យាង្គ**

| | |
|---|---|
| គ្រូ | - សរសេរ **ប្តឹ** លើក្តារខៀនរួចចង្អុលនិងអាន **ប្ត អឹ ប្តឹ។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ប្រុ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ប្លែ ប្អូ ប្តេ** ម្តងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ប្តូរប្រាក់** លើក្តារខៀនរួចចង្អុលនិងអាន **ប្ត អូ ប្តូ និង រ ប្តូរ ប្រ អា ប្រា និង ក ប្រាក បន្តក់មួយ ប្រាក់ ប្តូរប្រាក់។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ប្រែប្រួល** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **បងប្អូន** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- ប្លេះប្លោះ

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យប្លេះប្លោះ មានន័យថា ដែលឡេះឡោះ ក្រមាច់ ក្រមើម។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ប្លេះប្លោះ។ នាយក្រឹមនិយាយប្លេះប្លោះ។ |
| គ្រូនិងសិស្ស | - អានពាក្យ **ប្លេះប្លោះ** រួមគ្នា។ **គ្រូផ្ដើម ពូញ៉ាញ់និយាយ.....**។ សិស្សថា **ប្លេះប្លោះ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ប្លេះប្លោះ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ប្លេះប្លោះ** ជាដៃគូ។ |

ខ- ប្រកួត បង្រៀនដូចពាក្យខាងលើ។ **ប្រកួត មានន័យថា ប្រឡងគ្នា ប្រណាំងប្រជែងគ្នា**។

**ឱ.សុភី និងសំណាងប្រកួតគំនូរ។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **កុមារប្រកួតគូរគំនូរ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **កុមារ/ប្រកួត/គូរ/គំនូរ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **កុមារប្រកួតគូរគំនូរ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **កុមារប្រកួតគូរគំនូរ។** |
| សិស្ស | - សិស្សអានល្បះ **កុមារប្រកួតគូរគំនូរ។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើប្ដីមីងប្រុកឈ្មោះអ្វី?**

**២- តើពូប្រឹមនិយាយដូចម្ដេច?**

**៣- ហេតុអ្វីបានជាប្អូនៗស្រឡាញ់ពូប្រឹម?**

**៤- តើប្អូនចូលចិត្តមើល និងស្ដាប់រឿងកំប្លែងឬទេ? ព្រោះអ្វី?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ប្រកួត ប ្រ ក ្ួ ត** រួចសរសេរ **ប្រកួត** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ**ប្រើប្រាស់ ប ្រ ើ ប ្រ ា ស ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារ ឆ្នួន។ |
| សិស្ស | - គ្រូថា **កំប្រុក ប្រែប្រួល ប្លេះប្លោះ** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **កូនកំប្រុកប្រាំ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| មេរៀនទី៨៥ | ផ្ញើជើង ផ្ក ផ្ង ផ្ទ ផ្វ | ⌚ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ទីបលោក ធ្ងន់ធ្ងរ ធ្មុងត្រី កំប្រុក ប្រែប្រួល។**

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ផ្ក

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ផ្កាយ**។ បន្លឺថា **ផ្កាយ**។ **តើពាក្យ ផ្កាយមានសូរដើមអ្វី? ផ្ក** ។ គ្រូបន្លឺ **ផ្ក** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ផ្ក** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ផ្ក** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ផ្ក ខាងលើចំពោះសូរ ផ្ទ(ផ្ទារ) ផ្ង(ផ្ងិត) ផ្ញ(ផ្ញើ)។

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ផ្ក

| | |
|---|---|
| គ្រូ | - សរសេរ **ផ្ក** លើក្ដារខៀនរួចចង្អុលនិងអាន **ផ ជើង ្ក ផ្ក**។ |
| គ្រូនិងសិស្ស | - អាន **ផ្ក** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ផ្ក** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ផ្ក ខាងលើចំពោះ ផ្ទ ផ្ង ផ្ញ ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្ដារខៀន ផ្ញើជើង ផ្ក ផ្ទ ផ្ង ផ្ញ រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ ដោយផ្សំប្រកប (**ឧ. ផ ជើង ្ក ផ្ក** ) រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ផ្ក ផ្ទ ផ្ង ផ្ញ**។

**៣- ការអានព្យាង្គនិងពាក្យ** ⌚ ១៨នាទី

**៣.១ - ការអានព្យាង្គ**

| | |
|---|---|
| គ្រូ | - សរសេរ **ផ្កា** លើក្ដារខៀនរួចចង្អុលនិងអាន **ផ្ក អា ផ្កា**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ផ្ងា** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ផ្ទិ ផ្ញើ ផ្ទូ** ម្ដងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ផ្កាត្រែង** លើក្ដារខៀនរួចចង្អុលនិងអាន **ផ្ក អា ផ្កា ត្រ អែ ត្រែ និង ង ត្រែង ផ្កាត្រែង។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ផ្ងិតផ្ងង់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ផ្ញៀវ** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- ផ្ចិតផ្ចង់

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ**ផ្ចិតផ្ចង់ មានន័យថា ធ្វើដោយផ្ចង់អស់ពីចិត្តអស់ពីចំណង់។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ផ្ចិតផ្ចង់។ សុខាគូររូបដោយផ្ចិតផ្ចង់។** |
| គ្រូនិងសិស្ស | - អានពាក្យ **ផ្ចិតផ្ចង់** រួមគ្នា។ គ្រូផ្ដើម **តារាសរសេរដោយ.....**។ សិស្សថា **ផ្ចិតផ្ចង់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ផ្ចិតផ្ចង់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ផ្ចិតផ្ចង់** ជាដៃគូ។ |

ខ- ផ្ចាញ់ផ្ចាល បង្រៀនដូចពាក្យខាងលើ។ **ផ្ចាញ់ផ្ចាល មានន័យថា ធ្វើឱ្យចាញ់ ឱ្យរាងចាលលែងហ៊ានតទៅទៀត។ឧ.បូផាមិនចូលចិត្តអ្នកដែលផ្ចាញ់ផ្ចាលឡើយ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពេលយប់ផ្កាយរះគ្រប់ទិសទី។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពេល/យប់/ផ្កាយ/រះ/គ្រប់/ទិសទី។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ពេលយប់ផ្កាយរះគ្រប់ទិសទី។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពេលយប់ផ្កាយរះគ្រប់ទិសទី។** |
| សិស្ស | - សិស្សអានល្បះ **ពេលយប់ផ្កាយរះគ្រប់ទិសទី។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើចៅផ្កាយធ្វើអ្វី?**

**២- តើអ្នកណាផ្ចាញ់ផ្ចាលចៅផ្កាយ?**

**៣- តើកូនគិតថា ចៅផ្កានិងចៅផ្កាយត្រូវជាអ្វីនឹងគ្នា?**

**៤- តើការផ្ចាញ់ផ្ចាលជាអំពើល្អឬទេ? ហេតុអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ផ្កាត្រែង ផ ្ក ា ត ្រ ែ ង** រួចសរសេរ **ផ្កាត្រែង** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ផ្ចិតផ្ចង់ ផ ្ច ិ ត ផ ្ច ង ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ផ្កាឈូក ផ្ទារ ផ្ទៀរ** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ផ្ចិតផ្ចង់គួរគំនូរ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៨៦ | ផ្ញើជើង ផ្ដ ផ្ត ផ្ទ ផ្ល ផ្ស ផ្អ | ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ធ្មេញឈើ កំប្រុក ប្រែប្រួល ផ្កាត្រែង ផ្កាឈូក។**

## ១- ការស្គាល់សូរអក្សរថ្មី ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ផ្ដ

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ផ្ដើម**។ បន្លឺថា **ផ្ដើម។តើពាក្យ ផ្ដើមមានសូរដើមអ្វី? ផ្ដ** ។គ្រូបន្លឺ **ផ្ដ** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ផ្ដ** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ផ្ដ** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ផ្ដ ខាងលើចំពោះសូរ ផ្ត(ផ្តិល) ផ្ទ(ផ្ទត់) ផ្ល(ផ្លិត) ផ្ស(ផ្សិត) ផ្អ(ផ្អែម)

## ២- ការស្គាល់តួអក្សរថ្មី ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ផ្ដ

| | |
|---|---|
| គ្រូ | - សរសេរ **ផ្ដ** លើក្ដារខៀនរួចចង្អុលនិងអាន **ផ ជើងដ ្ដ ផ្ដ**។ |
| គ្រូនិងសិស្ស | - អាន **ផ្ដ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ផ្ដ** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ផ្ដ ខាងលើចំពោះ ផ្ត ផ្ទ ផ្ល ផ្ស ផ្អ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្ដារខៀន ផ្ញើជើង ផ្ដ ផ្ត ផ្ទ ផ្ល ផ្ស ផ្អ រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ ដោយផ្សំប្រកប (**ឧ. ផ ជើងដ ្ដ ផ្ដ** ) រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ផ្ដ ផ្ត ផ្ទ ផ្ល ផ្ស ផ្អ**។

## ៣- ការអានព្យាង្គនិងពាក្យ ១៨នាទី

### ៣.១ - ការអានព្យាង្គ

| | |
|---|---|
| គ្រូ | - សរសេរ **ផ្ដើ** លើក្ដារខៀនរួចចង្អុលនិងអាន **ផ្ដ អើ ផ្ដើ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ផ្តិ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប (**អានជើង ត**)។ |
| សិស្ស | - គ្រូសរសេរ **ផ្ទូ ផ្លិ ផ្សិ ផ្អែ** ម្ដងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ផ្ដាំផ្ញើ** លើក្ដារខៀនរួចចង្អុលនិងអាន **ផ្ដ អាំ ផ្ដាំ ផ្ញ អើ ផ្ញើ ផ្ដាំផ្ញើ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ផ្ដួចផ្ដើម** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ផ្សែផ្សំ** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ៨នាទី

ក- ផ្ដាំផ្ញើ

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ **ផ្ដាំផ្ញើ មានន័យថា ផ្ញើពាក្យ ផ្ញើសំដី។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ផ្ដាំផ្ញើ។ អ្នកគ្រូផ្ដាំផ្ញើកូនៗឱ្យថែរក្សាសៀវភៅកុំឱ្យរហែក ឬប្រឡាក់។** |
| គ្រូនិងសិស្ស | - អានពាក្យ **ផ្ដាំផ្ញើ** រួមគ្នា។ គ្រូផ្ដើម **ជីតាខ្ញុំ.....ឱ្យជួយមើលបងប្អូន**។ សិស្សថា **ផ្ដាំផ្ញើ** រួចថាល្បះពេញលេញរួមគ្នា។ |

| | |
|---|---|
| សិស្ស | - អានពាក្យ **ផ្កាំផ្ញើ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ផ្កាំផ្ញើ** ជាដៃគូ។ |

ខ- ផ្សៀផ្សំ បង្រៀនដូចពាក្យខាងលើ។ **ផ្សៀផ្សំ មានន័យថា សន្សំ ផ្សំនេះខ្លះនោះខ្លះ។**

ឱ. **បូណាផ្សៀផ្សំលុយដើម្បីទិញកាតាប។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **តាលាំផ្កាំចៅកែឱ្យចេះថៃផ្សេត។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **តាលាំ/ផ្កាំ/ចៅកែ/ឱ្យ/ចេះ/ថៃ/ផ្សេត។**

| | |
|---|---|
| គ្រូ | - គ្រូអាន **តាលាំផ្កាំចៅកែឱ្យចេះថៃផ្សេត។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **តាលាំផ្កាំចៅកែឱ្យចេះថៃផ្សេត។** |
| សិស្ស | - សិស្សអានល្បះ **តាលាំផ្កាំចៅកែឱ្យចេះថៃផ្សេត។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើមីងផ្លយកាច់ផ្កាឈូកដាក់ក្នុងអ្វី?**

**២- តើគាត់យកផ្កាឈូក និងផ្អកជូននរណា?**

**៣- ហេតុអ្វីបានជាគាត់យកផ្កាឈូក និងផ្អកជូនជីដូន?**

**៤- តើគេយកផ្កាឈូកសម្រាប់ធ្វើអ្វីខ្លះ?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ផ្កាំផ្ញើ ផ ្ត ា ំ ផ ្ញ ើ** រួចសរសេរ **ផ្កាំផ្ញើ** លើក្តារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ផ្តួចផ្តើម ផ ្ត ួ ច ផ ្ត ើ ម** រួចគ្រូសរសេរលើក្តារខៀន។ សិស្សសរសេរលើក្តារឆ្នួន។ |
| សិស្ស | - គ្រូថា **ផ្សៀផ្សំ ផ្ទះ ផ្លូវ** ម្តងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្តារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្តារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ផ្តួចផ្តើមគំនិតថ្មី** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ារពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| មេរៀនទី៨៧ | ផ្ញើជើង ញ្ញ ញ្យ ញ្រ ញ្ល | ◷ ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ◷ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ប្រើប្រាស់ ផ្កាត្រែង ផ្ចិតផ្ចង់ ផ្កាំផ្ទើ ផ្សែផ្សំ។**

## ១- ការស្គាល់សូរអក្សរថ្មី ◷ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ញ្ញ

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ញ្ញៅ**។ បន្លឺថា **ញ្ញៅ**។ **តើពាក្យ ញ្ញៅមានសូរដើមអ្វី? ញ្ញ** ។គ្រូបន្លឺ **ញ្ញ** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ញ្ញ** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ញ្ញ** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ញ្ញ ខាងលើចំពោះសូរ ញ្យ(ញ្យូរ) ញ្រ(ញ្រាប) ញ្ល(ញ្លុក)។

## ២- ការស្គាល់តួអក្សរថ្មី ◷ ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ញ្ញ

| | |
|---|---|
| គ្រូ | - សរសេរ **ញ្ញ** លើក្តារខៀនរួចចង្អុលនិងអាន **ញ ជើង ្ញ ញ្ញ**។ |
| គ្រូនិងសិស្ស | - អាន **ញ្ញ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ញ្ញ** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ញ្ញ ខាងលើចំពោះ ញ្យ ញ្រ ញ្ល។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្តារខៀន ផ្ញើជើង ញ្ញ ញ្យ ញ្រ ញ្ល រួចចង្អុលឱ្យសិស្សអានម្តងមួយៗ ដោយផ្សំប្រកប **(ឧ. ញ ជើង ្ញ ញ្ញ )** រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ញ្ញ ញ្យ ញ្រ ញ្ល**។

## ៣- ការអានព្យាង្គនិងពាក្យ ◷ ១៨នាទី

### ៣.១ - ការអានព្យាង្គ

| | |
|---|---|
| គ្រូ | - សរសេរ **ញ្ញៅ** លើក្តារខៀនរួចចង្អុលនិងអាន **ញ្ញ អៅ ញ្ញៅ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ញ្យូ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ញ្រា ញ្លុ ញ្យុះ** ម្តងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ព្យាយាម** លើក្តារខៀនរួចចង្អុលនិងអាន **ព្យ អា ព្យា យ អា និង ម យាម ព្យាយាម។** |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ព្រលឹម** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ព្រោងព្រាត** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក -ព្យាយាម

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ **ព្យាយាម មានន័យថា ខំប្រឹង ឬ ប្រឹងប្រែង។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ព្យាយាម។ ពូព្រំព្យាយាមរកថ្នាំទំលាក់ព្រូន។** |
| គ្រូនិងសិស្ស | - អានពាក្យ **ព្យាយាម** រួមគ្នា។ គ្រូផ្តើម **ជីតាខ្ញុំ.....ធ្វើស្រែចំការ**។ សិស្សថា **ព្យាយាម** រួចថាល្បះពេញលេញរួមគ្នា។ |

| | |
|---|---|
| សិស្ស | - អានពាក្យ **ព្យាយាម** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ព្យាយាម** ជាដៃគូ។ |

ខ -ព្យាបាល បង្រៀនដូចពាក្យខាងលើ។ **ព្យាបាល មានន័យថា ថែទាំ ឬថែរក្សាអ្នកជំងឺ ធ្វើឱ្យជាសះស្បើយ។**

ឧ. **គ្រូពេទ្យព្យាបាលអ្នកជំងឺ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **កូនព្រាបហើរព្រោងព្រាត។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **កូន/ព្រាប/ហើរ/ព្រោងព្រាត។**

| | |
|---|---|
| គ្រូ | - គ្រូអាន **កូនព្រាបហើរព្រោងព្រាត។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **កូនព្រាបហើរព្រោងព្រាត។** |
| សិស្ស | - សិស្សអានល្បះ **កូនព្រាបហើរព្រោងព្រាត។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើកូនព្រីលមានជំងឺអ្វី?**

**២- តើពូព្រំបេះផ្លែអ្វីខ្លះធ្វើថ្នាំ?**

**៣- តើកូនគិតថា ហេតុអ្វីបានជាពូព្រំទៅព្រៃ?**

**៤- ដើម្បីព្យាបាលជំងឺអ្វីមួយតើកូនត្រូវធ្វើដូចម្តេច?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ព្យាយាម ព ◌្យ ◌ា យ ◌ា ម** រួចសរសេរ **ព្យាយាម** លើក្តារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ព្រលឹម ព ◌្រ ល ◌ឹ ម** រួចគ្រូសរសេរលើក្តារខៀន។ សិស្សសរសេរលើក្តារឆ្នួន។ |
| សិស្ស | - គ្រូថា **ព្រោងព្រាត ព្យាបាល ផ្លែឈ្លៅ** ម្តងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្តារឆ្នួន។<br>គ្រូសរសេរពាក្យទាំងនេះលើក្តារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ក្រោកពីព្រលឹម**ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ារពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៨៨ | ផ្ញើជើង ភ្យ ភ្ជ ភ្ញ ភ្ន ភ្ល | ◷ ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ◷ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ប្រែប្រួល ផ្គួចផ្គើម ផ្សែផ្សុំ ព្យាបាល ព្រោងព្រាត។**

## ១- ការស្គាល់សូរអក្សរថ្មី ◷ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ភ្យ

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ភ្យើយ**។ បន្លឺថា **ភ្យើយ**។ **តើពាក្យ ភ្យើយមានសូរដើមអ្វី? ភ្យ** ។ គ្រូបន្លឺ **ភ្យ** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ភ្យ** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ភ្យ** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ភ្យ ខាងលើចំពោះសូរ ភ្ជ(ភ្ជាប់) ភ្ញ(ភ្ញៀវ) ភ្ន(ភ្នែក) ភ្ល(ភ្លៅ)។

## ២- ការស្គាល់តួអក្សរថ្មី ◷ ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ភ្យ

| | |
|---|---|
| គ្រូ | - សរសេរ **ភ្យ** លើក្តារខៀនរួចចង្អុលនិងអាន **ភ ជើង ្យ ភ្យ**។ |
| គ្រូនិងសិស្ស | - អាន **ភ្យ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ភ្យ** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ភ្យ ខាងលើចំពោះ ភ្ជ ភ្ញ ភ្ន ភ្ល។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្តារខៀន ផ្ញើជើង ភ្យ ភ្ជ ភ្ញ ភ្ន ភ្ល រួចចង្អុលឱ្យសិស្សអានម្តងមួយៗ ដោយផ្សំប្រកប (**ឧ. ភ ជើង ្យ ភ្យ** ) រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ភ្យ ភ្ជ ភ្ញ ភ្ន ភ្ល**។

## ៣- ការអានព្យាង្គនិងពាក្យ ◷ ១៨នាទី

### ៣.១ - ការអានព្យាង្គ

| | |
|---|---|
| គ្រូ | - សរសេរ **ភ្យើ** លើក្តារខៀនរួចចង្អុលនិងអាន **ភ្យ អ៊ើ ភ្យើ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ភ្ជា** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ភ្ញៀ ភ្នែ ភ្លើ** ម្តងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ភ្ញាក់ផ្អើល** លើក្តារខៀនរួចចង្អុលនិងអាន **ភ្ញ អា ភ្ញា និង ក ភ្ញាក បន្តក់មួយ ភ្ញាក់ ផ្អ អើ ផ្អើ និង ល ផ្អើល ភ្ញាក់ផ្អើល** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ភ្នំពេញ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ភ្លេចភ្លាំង** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- ភ្លើតភ្លើន

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ភ្លើតភ្លើន** មានន័យថា **រីករាយសប្បាយហួសពេក។** **គ្រូនឹងបង្កើតឃ្លាមួយដោយប្រើពាក្យ ភ្លើតភ្លើន។ ឧ.ក្មេងៗមិនត្រូវភ្លើតភ្លើននឹងល្បែង។** |

| | |
|---|---|
| គ្រូនិងសិស្ស | - អានពាក្យ **ភ្លើតភ្លើន** រួមគ្នា។ គ្រូផ្ដើម **កុំសប្បាយ....ភ្លេចការសិក្សា**។ សិស្សថា **ភ្លើតភ្លើន** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ភ្លើតភ្លើន** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ភ្លើតភ្លើន** ជាដៃគូ។ |

ខ- ភ្លេចភ្លាំង បង្រៀនដូចពាក្យខាងលើ។ **ភ្លេចភ្លាំង មានន័យថា ចាំមិនបាន នឹកមិនឃើញ**។

ឌ. **ឈុំភ្លេចភ្លាំងពេលគ្រូសួរមេរៀន**។

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពូសុខភ្ញាក់ពីព្រលឹមទៅភ្ជួរស្រែក្បែរជើងភ្នំ**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពូសុខ/ភ្ញាក់/ពី/ព្រលឹម/ទៅ/ភ្ជួរ/ស្រែ/ក្បែរ/ជើងភ្នំ**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ពូសុខភ្ញាក់ពីព្រលឹមទៅភ្ជួរស្រែក្បែរជើងភ្នំ**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពូសុខភ្ញាក់ពីព្រលឹមទៅភ្ជួរស្រែក្បែរជើងភ្នំ**។ |
| សិស្ស | - សិស្សអានល្បះ **ពូសុខភ្ញាក់ពីព្រលឹមទៅភ្ជួរស្រែក្បែរជើងភ្នំ**។<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើភ្លុកនឹកភ្លុកចង់ទៅណា?**

**២- ហេតុអ្វីភ្លុកចង់ទៅភ្នំពេញ?**

**៣- តើកូនគិតថា ហេតុអ្វីភ្លុកភ្លើងឆាបឆេះ?**

**៤- តើការភ្លើតភ្លើននាំឱ្យសិស្សជួបបញ្ហាអ្វីខ្លះ?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ភ្ញាក់ផ្អើល ភ ◌្ញ ◌ា ក ◌់ ផ ◌្អ ◌ើ ល** រួចសរសេរ **ភ្ញាក់ផ្អើល** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ផ្កាភ្ញី ផ ◌្ក ◌ា ភ ◌្ញ ◌ី** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ភ្ជួរ ភ្ញៀវ ភ្លេចភ្លាំង** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ភ្លើតភ្លើនភ្លេចខ្លួន** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| មេរៀនទី៨៩ | ផ្ញើជើង ម្ក ម្ខ ម្ទ ម្ត | ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ផ្ដួចផ្ដើម ព្យាបាល ព្រលឹម ភ្នំដូនពេញ ភ្លេចភ្លាំង។**

## ១- ការស្គាល់សូរអក្សរថ្មី ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ម្ក

| | |
|---|---|
| គ្រូ | - បំផុសរកពាក្យ **ម្កាក់**។ បន្លឺថា **ម្កាក់**។ **តើពាក្យ ម្កាក់មានសូរដើមអ្វី? ម្ក** ។ គ្រូបន្លឺ **ម្ក** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ម្ក** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ម្ក** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ម្ក ខាងលើចំពោះសូរ ម្ខ(ម្ខាង) ម្ទ(ម្ចាស់) ម្ត(ម្ដាយ)។

## ២- ការស្គាល់តួអក្សរថ្មី ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ម្ក

| | |
|---|---|
| គ្រូ | - សរសេរ **ម្ក** លើក្ដារខៀនរួចចង្អុលនិងអាន **ម ជើង ្ក ម្ក**។ |
| គ្រូនិងសិស្ស | - អាន **ម្ក** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ម្ក** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ម្ក ខាងលើចំពោះ ម្ខ ម្ទ ម្ត។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្ដារខៀន ផ្ញើជើង ម្ក ម្ខ ម្ទ ម្ត រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ ដោយផ្សំប្រកប **(ឧ. ម ជើង ្ក ម្ក )** រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ម្ក ម្ខ ម្ទ ម្ត**។

## ៣- ការអានព្យាង្គនិងពាក្យ ១៨នាទី

### ៣.១ - ការអានព្យាង្គ

| | |
|---|---|
| គ្រូ | - សរសេរ **ម្កា** លើក្ដារខៀនរួចចង្អុលនិងអាន **ម្ក អា ម្កា**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ម្ខា** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ម្ទា ម្តា ម្ទុ** ម្ដងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ផ្លែម្កាក់** លើក្ដារខៀនរួចចង្អុលនិងអាន **ផ្ល អែ ផ្លែ ម្ក អា ម្កា និង ក ម្កាក បន្តក់មួយ ម្កាក់ ផ្លែម្កាក់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ម្ទាស់ដី** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ម្តងម្កាល** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ៨នាទី

ក- ម្តុំ

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ **ម្តុំ មានន័យថា មួយជុំ ជុំវិញកន្លែងណាមួយ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ម្តុំ។ ខ្ញុំរស់នៅម្តុំផ្សារថ្មី។** |
| គ្រូនិងសិស្ស | - អានពាក្យ **ម្តុំ** រួមគ្នា។ គ្រូផ្ដើម **ផ្ទះសុខានៅ....សាលាឃុំ**។ សិស្សថា **ម្តុំ** រួចថាល្បះពេញលេញរួមគ្នា។ |

| | |
|---|---|
| សិស្ស | - អានពាក្យ **ម្ដុំ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ម្ដុំ** ជាដៃគូ។ |

ខ- ម្តងម្កាល បង្រៀនដូចពាក្យខាងលើ។ **ម្តងម្កាល មានន័យថា មួយកាល យូរៗម្តង មិនញឹកញាប់។ ឧ. ខ្ញុំធ្លាប់ទៅលេងភ្នំពេញម្តងម្កាល។**

## ៥- ការអានល្បះ: ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ម្ដាយខ្ញុំទិញផ្លែម្នាក់មកផ្ញើក្មេងៗ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ម្ដាយខ្ញុំ/ទិញ/ផ្លែម្នាក់/មក/ផ្ញើ/ក្មេងៗ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ម្ដាយខ្ញុំទិញផ្លែម្នាក់មកផ្ញើក្មេងៗ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ម្ដាយខ្ញុំទិញផ្លែម្នាក់មកផ្ញើក្មេងៗ។** |
| សិស្ស | - សិស្សអានល្បះ **ម្ដាយខ្ញុំទិញផ្លែម្នាក់មកផ្ញើក្មេងៗ។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូព្រាំទៅលេងផ្ទះនរណា?**

**២- តើម្តាយរបស់ពូព្រាំរស់នៅម្តុំណា?**

**៣- កូនគិតថា ម្ដាយពូព្រាំគាត់មានមុខរបរជាអ្វី?**

**៤- តើកូនចូលចិត្តដាំដំណាំហូបផ្លែអ្វីខ្លះ? ព្រោះអ្វី?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ម្ចាស់ដី ម ◌្ច ា ស ◌់ ដ ◌ី** រួចសរសេរ **ម្ចាស់ដី** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ផ្លែម្នាក់ ផ ◌្ល ែ◌ ម ◌្ន ា ក ◌់** ផរួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ម្ចាស់ ម្ដាយ ម្ដងម្កាល** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **លើកម្តងម្ខាង** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ារពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ: ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៩០ | ផ្ញើជើង ម្ញ ម្ជ ម្ភ ម្ទ | ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ផ្ចិតផ្ចង់ ព្យាបាល ភ្នំដូនពេញ ផ្លែម្កាក់ ម្ចាស់ដី។**

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃព្យាង្គ ពាក្យដែលត្រូវរៀន។

ក-សូរ ម្ញ

| | |
|---|---|
| គ្រូ | - ប្រាប់សិស្សថា **នៅម្តុំផ្ទះគ្រូមានមីងម្នាក់ឈ្មោះ ម្ញី**។ បន្លឺថា **ម្ញី**។ **តើពាក្យ ម្ញីមានសូរដើមអ្វី?** ម្ញ។ គ្រូបន្លឺ ម្ញ ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ម្ញ** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ម្ញ** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ម្ញ ខាងលើចំពោះសូរ ម្ជ(ម្ជុល) ម្ភ(ម្ភា) ម្ទ(ម្ទេស)។

## ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ម្ញ

| | |
|---|---|
| គ្រូ | - សរសេរ **ម្ញ** លើក្តារខៀនរួចចង្អុលនិងអាន **ម ជើង ្ញ ម្ញ**។ |
| គ្រូនិងសិស្ស | - អាន **ម្ញ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ម្ញ** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ម្ញ ខាងលើចំពោះ ម្ជ ម្ភ ម្ទ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្តារខៀន ផ្ញើជើង ម្ញ ម្ជ ម្ភ ម្ទ រួចចង្អុលឱ្យសិស្សអានម្តងមួយៗ ដោយផ្សំប្រកប **( ឧ. ម ជើង ្ញ ម្ញ )** រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ម្ញ ម្ជ ម្ភ ម្ទ**។

## ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

### ៣.១ - ការអានព្យាង្គ

| | |
|---|---|
| គ្រូ | - សរសេរ **ម្ញី** លើក្តារខៀនរួចចង្អុលនិងអាន **ម្ញ អ៊ី ម្ញី**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ម្ជុ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ម្ទេ ម្ភិ ម្ជូ** ម្តងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ម្ញិកម្ញ៉ក់** លើក្តារខៀនរួចចង្អុលនិងអាន **ម្ញ សម្លាប់ពីរ ម៉្ញ ម៉្ញ អិ ម្ញិ និង ក ម្ញិក ម៉្ញ និង ក ម៉្ញក បន្តក់មួយ ម៉្ញក់ ម្ញិកម្ញ៉ក់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ម្ជុលខ្ទាស់** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ម្ទេសឆ្អើរ** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- ម្ញិកម្ញ៉ក់

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ម្ញិកម្ញ៉ក់ មានន័យថា ដែលធ្វើឫក ឬអាការញ៉ិកញ៉ក់។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ញ៉ិកម្ញ៉ក់ ។ ឧ.ក្មេងនេះ ធ្វើឫកពាម្ញិកម្ញ៉ក់**។ |

| | |
|---|---|
| គ្រូនិងសិស្ស | - អានពាក្យ **ម្ទិកម្ទ៉ក់** រួមគ្នា។ គ្រូផ្ដើម **កុសលធ្វើឫក....ពេលចង់បានអាវថ្មី**។ សិស្សថា **ម្ទិកម្ទ៉ក់** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ម្ទិកម្ទ៉ក់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ម្ទិកម្ទ៉ក់** ជាដៃគូ។ |

ខ- ម្ទេសឆ្អើរ បង្រៀនដូចពាក្យខាងលើ។ **ម្ទេសឆ្អើរ មានន័យថា ម្ទេសទុំដែលគេហាលថ្ងៃ ឬកម្ដៅភ្លើងឱ្យស្ងួត**។

គ. **មីងចិញ្ច្រាំម្ទេសឆ្អើរ**។

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **មីងចាន់ហាលម្ទេសឆ្អើរ**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **មីងចាន់/ហាល/ម្ទេសឆ្អើរ**។

| | |
|---|---|
| គ្រូ | - គ្រូអាន **មីងចាន់ហាលម្ទេសឆ្អើរ**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **មីងចាន់ហាលម្ទេសឆ្អើរ**។ |
| សិស្ស | - សិស្សអានល្បះ **មីងចាន់ហាលម្ទេសឆ្អើរ**។<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនរណាជាម្ចាស់ថ្នាលម្ទេស?**

**២- តើយាយស៊ុយជ្រុះបាត់អ្វី?**

**៣- តើកូនគិត ថាហេតុអ្វីបានជាគាត់ហាលម្ទេស?**

**៤- ក្រៅពីដាំម្ទេស តើអ្នកភូមិកូនដាំអ្វីខ្លះទៀត?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ម្ហូលខ្លាស់** ម ◌្ហ ◌ុ ល ខ ◌្ល ា ស ◌់ រួចសរសេរ **ម្ហូលខ្លាស់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ម្ទេសឆ្អើរ** ម ◌្ទ េ◌ ស ឆ ◌្អ េ◌ី រ រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ម្ហូរ ម្ហុល ម្ទេស** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ម្ចាស់ម្ទេសឆ្អើរ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៩១ | ផ្ញើជើង ម្ន ម្ក ម្យ ម្រ ម្ល | ⌚ ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ភ្លេចភ្លាំង ផ្លែម្កាក់ ម្ចាស់ដី ម្នុលខ្នាស់ ម្ទេសឆ្អើរ។**

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃព្យាង្គ ពាក្យដែលត្រូវរៀន។

ក-សូរ ម្ន

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ម្នាស់**។ បន្លឺថា **ម្នាស់**។ **តើពាក្យ ម្នាស់មានសូរដើមអ្វី? ម្ន**។ គ្រូបន្លឺ **ម្ន** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ម្ន** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ម្ន** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ម្ន ខាងលើចំពោះសូរ ម្ក(ម្កែ) ម្យ(ម្យប់) ម្រ(ម្រាម) ម្ល(ម្លិះ)។

## ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ម្ន

| | |
|---|---|
| គ្រូ | - សរសេរ **ម្ន** លើក្ដារខៀនរួចចង្អុលនិងអាន **ម ជើង ្ន ម្ន**។ |
| គ្រូនិងសិស្ស | - អាន **ម្ន** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ម្ន** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ម្ន ខាងលើចំពោះ ម្ក ម្យ ម្រ ម្ល។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃជាក់លើក្ដារខៀន ផ្ញើជើង ម្ន ម្ក ម្យ ម្រ ម្ល រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ ដោយផ្សំប្រកប **(ឧ. ម ជើង ្ន ម្ន )** រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ម្ន ម្ក ម្យ ម្រ ម្ល**។

## ៣- ការអានព្យាង្គនិងពាក្យ ⌚ ១៨នាទី

### ៣.១ - ការអានព្យាង្គ

| | |
|---|---|
| គ្រូ | - សរសេរ **ម្នា** លើក្ដារខៀនរួចចង្អុលនិងអាន **ម្ន អា ម្នា** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ម្កែ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ម្យា ម្រុំ ម្លិះ** ម្ដងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ម្ទីម្នា** លើក្ដារខៀនរួចចង្អុលនិងអាន **ម្ន អ៊ី ម្ទី ម្ន អា ម្នា ម្ទីម្នា** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ម្រាមដៃ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ម្រះព្រៅ** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- ម្លូ

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ **ម្លូ មានន័យថា វល្លិឡើងជន្លង់ម្យ៉ាង ដែលដើមនិងស្លឹកមានរសហាង ក្លិនប្រហើរឆ្ងួល បន្តិចៗ ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ម្លូ ។ ជីដូនខ្ញុំចូលចិត្តហូបម្លូ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ម្លូ** រួមគ្នា។ គ្រូផ្ដើម **ជីតាខ្ញុំហូប....ពេលគាត់ពិសារបាយរួច**។ សិស្សថា **ម្លូ** រួចថាល្បះពេញលេញរួមគ្នា។ |

| | |
|---|---|
| សិស្ស | - អានពាក្យ ម្ន និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ ម្ន ជាដៃគូ។ |

ខ- ម្ទីម្នា បង្រៀនដូចពាក្យខាងលើ។ **ម្ទីម្នា មានន័យថា រូតរះ ប្រញាប់ប្រញាល់។ ឧ. រាល់ព្រឹក សុខាម្ទីម្នាមកសាលារៀន។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **នាងណាតម្ទីម្នាទៅបេះផ្លែម្នាស់។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **នាងណាត/ម្ទីម្នា/ទៅ/បេះ/ផ្លែម្នាស់។**

| | |
|---|---|
| គ្រូ | - គ្រូអាន **នាងណាតម្ទីម្នាទៅបេះផ្លែម្នាស់។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **នាងណាតម្ទីម្នាទៅបេះផ្លែម្នាស់។** |
| សិស្ស | - សិស្សអានល្បះ **នាងណាតម្ទីម្នាទៅបេះផ្លែម្នាស់។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី ?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើមីងញុំាទៅបេះផ្លែអ្វី ?**

**២- ពេលដើរក្នុងព្រៃ តើគាត់ឃើញអ្វី ?**

**៣- ហេតុអ្វីបានជាគាត់ម្ទីម្នាទៅបេះផ្លែម្នាស់ ?**

**៤- តើកូនធ្លាប់ឃើញចម្ការម្នាស់ឬទេ ? នៅឯណា ?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ម្ទីម្នា ម ្ន ី ម ្ន ា** រួចសរសេរ **ម្ទីម្នា** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ម្រាមដៃ ម ្រ ា ម ដ ែ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ម្រះព្រៅ ម្លប់ជ្រៃ ផ្លែម្នាស់** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ម្ទីម្នាទៅបេះម្រះ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| មេរៀនទី៩២ | ផ្ញើជើង ល្វ ល្ប ល្ង ល្ម | ⌚ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៧នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ផ្លែម្កាក់ ម្ជុលខ្វាស់ ម្ទេសផ្លោរ ផ្លែម្នាស់ ម្រាមដៃ។**

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ល្វ

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ល្វោន**។ បន្លឺថា **ល្វោន**។ **តើពាក្យ ល្វោនមានសូរដើមអ្វី? ល្វ**។គ្រូបន្លឺ **ល្វ** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ល្វ** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ល្វ** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ល្វ ខាងលើចំពោះសូរ ល្ប(ល្បឿន) ល្ង(ល្ងង) ល្ម(ល្មិត)។

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ល្វ

| | |
|---|---|
| គ្រូ | - សរសេរ **ល្វ** លើក្តារខៀនរួចចង្អុលនិងអាន **ល ជើង ្វ ល្វ**។ |
| គ្រូនិងសិស្ស | - អាន **ល្វ** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ល្វ** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ល្វ ខាងលើចំពោះ ល្ប ល្ង ល្ម។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្តារខៀន ផ្ញើជើង ល្វ ល្ប ល្ង ល្ម រួចចង្អុលឱ្យសិស្សអានម្តងមួយៗ ដោយផ្សំប្រកប (**ឧ. ល ជើង ្វ ល្វ**) រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ល្វ ល្ប ល្ង ល្ម**។

**៣- ការអានព្យាង្គនិងពាក្យ** ⌚ ១៨នាទី

**៣.១ - ការអានព្យាង្គ**

| | |
|---|---|
| គ្រូ | - សរសេរ **ល្វោ** លើក្តារខៀនរួចចង្អុលនិងអាន **ល្វ អោ ល្វោ** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ល្បែ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ល្ងុ ល្មិ ល្បី** ម្តងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ល្វោនខោល** លើក្តារខៀនរួចចង្អុលនិងអាន **ល្វ អោ ល្វោ និង ន ល្វោន ខ អោ ខោ និង ល ខោល ល្វោនខោល** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ល្បីល្បាញ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ល្មិតល្មែ** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

**៤- វាក្យសព្ទ** ⌚ ៨នាទី

ក- ល្បីល្បាញ

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ **ល្បីល្បាញ មានន័យថា ការឮសុះសាយ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ល្បីល្បាញ។ ប្រាសាទអង្គរវត្តល្បីល្បាញលើពិភពលោក។** |

| | |
|---|---|
| គ្រូនិងសិស្ស | - អានពាក្យ **ល្បីល្បាញ** រួមគ្នា។ គ្រូផ្ដើម **ចំរើន....ខាងវត់ប្រណាំង**។ សិស្សថា **ល្បីល្បាញ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ល្បីល្បាញ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ល្បីល្បាញ** ជាដៃគូ។ |

ខ- ល្អិតល្អន់ បង្រៀនដូចពាក្យខាងលើ។ **ល្អិតល្អន់ មានន័យថា ហ្មត់ចត់ ប្រាកដប្រជា។ ឧ. អ្នកគ្រូពន្យល់មេរៀនបានល្អិតល្អន់។**

## ៥- ការអានល្បះ 🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **នារីប្រឹងប្រែងធ្វើការយ៉ាងល្អិតល្អន់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **នារី/ប្រឹងប្រែង/ធ្វើការ/យ៉ាង/ល្អិតល្អន់**។

| | |
|---|---|
| គ្រូ | - គ្រូអាន **នារីប្រឹងប្រែងធ្វើការយ៉ាងល្អិតល្អន់**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **នារីប្រឹងប្រែងធ្វើការយ៉ាងល្អិតល្អន់**។ |
| សិស្ស | - សិស្សអានល្បះ **នារីប្រឹងប្រែងធ្វើការយ៉ាងល្អិតល្អន់**។<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី 🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើពូប្រឹមចេះលេងអ្វី?**

**២- តើគាត់ល្បីល្បាញខាងសម្ដែងតួអ្វី?**

**៣- ហេតុអ្វីបានពូប្រឹមហាត់ល្អិតល្អៃ?**

**៤- តើកូនចូលចិត្តមើលការសម្ដែងល្ខោនឬទេ?ព្រោះអ្វី?**

## ៧- ការសរសេរ 🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាព្យាង្គ **ល្ខោនខោល ល ្ង េ ន ខ េ ល** រួចសរសេរ **ល្ខោនខោល** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាព្យាង្គ **ល្បីល្បាញ ល ្ប ី ល ្ប ា ញ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ល្អិតល្អៃ ល្បិចកល ល្អិតល្អន់** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាព្យាង្គ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **សាកល្បងជាំល្អុង** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ 🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៩៣ | ផ្ញើជើង ស្ក ស្គ ស្ល ស្ប ស្រ | ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ម្នេសឆ្នើរ ម្នីម្នា ផ្លែម្នាស់ ល្អិតល្អៃ ល្បិចកល។**

**១- ការស្គាល់សូរអក្សរថ្មី** ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ស្ក

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ស្កូវ**។ បន្លឺថា **ស្កូវ**។ **តើពាក្យ ស្កូវមានសូរដើមអ្វី? ស្ក**។គ្រូបន្លឺ **ស្ក** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ស្ក** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ស្ក** រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ស្ក ខាងលើចំពោះសូរ ស្គ(ស្គោះ) ស្ល(ស្លិត) ស្ប(ស្បែក ) ស្រ(ស្រូវ)។

**២- ការស្គាល់តួអក្សរថ្មី** ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ស្ក

| | |
|---|---|
| គ្រូ | - សរសេរ **ស្ក** លើក្ដារខៀនរួចចង្អុលនិងអាន **ស ជើង ្ក ស្ក**។ |
| គ្រូនិងសិស្ស | - អាន **ស្ក** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ស្ក** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ស្ក ខាងលើចំពោះ ស្គ ស្ល ស្ប ស្រ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃដាក់លើក្ដារខៀន ផ្ញើជើង ស្ក ស្គ ស្ល ស្ប ស្រ រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ ដោយផ្សំប្រកប (**ឧ. ស ជើង ្ក ស្ក** ) រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំប្រកប **ស្ក ស្គ ស្ល ស្ប ស្រ**។

**៣- ការអានព្យាង្គនិងពាក្យ** ១៨នាទី

**៣.១ - ការអានព្យាង្គ**

| | |
|---|---|
| គ្រូ | - សរសេរ **ស្កូ** លើក្ដារខៀនរួចចង្អុលនិងអាន **ស្ក អូ ស្កូ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ស្គា** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ស្លិ ស្បៃ ស្រូ** ម្ដងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

**៣.២- ការអានពាក្យ**

| | |
|---|---|
| គ្រូ | - សរសេរ **ស្កប់ស្កល់** លើក្ដារខៀនរួចចង្អុលនិងអាន **ស្ក និង ប ស្កប បន្តក់មួយ ស្កប់ ស្ក និង ល ស្កល បន្តក់មួយ ស្កល់ ស្កប់ស្កល់** ។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ស្លិតស្លោ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ស្រុកស្រែ** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

### ៤- វាក្យសព្ទ ◷ ៨នាទី

ក- ស្រស់ស្រាយ

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ **ស្រស់ស្រាយ មានន័យថា រាក់ទាក់រួសរាយ ស្រស់រីករាយ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ស្រស់ស្រាយ ។ ជីតាមានទឹកមុខស្រស់ស្រាយ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ស្រស់ស្រាយ** រួមគ្នា។ គ្រូផ្ដើម **ថ្ងៃនេះខ្ញុំមានអារម្មណ៍....ណាស់។** សិស្សថា **ស្រស់ស្រាយ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ស្រស់ស្រាយ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ស្រស់ស្រាយ** ជាដៃគូ។ |

ខ- ស្កឹមស្កៃ បង្រៀនដូចពាក្យខាងលើ។ **ស្កឹមស្កៃ មានន័យថា ធំខ្ពស់សម្បើម ធំធេងល្វឹងល្វើយ ធំល្វល្វេវ ។**

**ឧ.នៅទីក្រុងមានអគារធំស្កឹមស្កៃជាច្រើន។**

### ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ស្រីៗស្រុកស្រែពូកែញាំស្ដៅ។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ស្រីៗ/ស្រុកស្រែ/ពូកែ/ញាំ/ស្ដៅ។**

| | |
|---|---|
| គ្រូ | - គ្រូអាន **ស្រីៗស្រុកស្រែពូកែញាំស្ដៅ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ស្រីៗស្រុកស្រែពូកែញាំស្ដៅ។** |
| សិស្ស | - សិស្សអានល្បះ **ស្រីៗស្រុកស្រែពូកែញាំស្ដៅ។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

### ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី ?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើគ្រួសារពួកគេរស់នៅឯណា ?**

**២- តើមានអ្វីដុះជុំវិញស្រះ ?**

**៣- ហេតុអ្វីបានជាគេដាំផ្កាស្បៃរឿង ?**

**៤- តើពេលទំនេរ កូនធ្វើអ្វីខ្លះនៅផ្ទះរបស់កូន ?**

### ៧- ការសរសេរ ◷ ១៦នាទី

#### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ស្កប់ស្កល់ ស ◌្ក ប ◌់ ស ◌្ក ល ◌់** រួចសរសេរ **ស្កប់ស្កល់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ស្លិតស្លេរ ស ◌្ល ◌ិ ត ស ◌្ល េ◌ រ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា**ស្កឹមស្កៃ ស្រុកស្រែ ស្បែកជើង** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

#### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ស្ទកពេញស្រែ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

### ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## មេរៀនទី៩៤ ផ្ញើជើង ស្វ ស្ន ស្ម ស្ល ស្វ ស្អ ⏲ ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន ⏲ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ម្រាមដៃ ល្បីល្បាញ ល្អិតល្អៃ ស្រុកស្រែ ស្បែកជើង។**

### ១- ការស្គាល់សូរអក្សរថ្មី ⏲ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងប្រាប់សូរដើមនៃពាក្យដែលត្រូវរៀន។

ក-សូរ ស្វ

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ស្ងួត**។ បន្លឺថា **ស្ងួត**។ **តើពាក្យ ស្ងួតមានសូរដើមអ្វី?** **ស្ង**។ គ្រូបន្លឺ **ស្ង** ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ស្ង** រួមគ្នា។ |
| សិស្ស | - បន្លឺសូរ **ស្ង** រួមគ្នា។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀនសូរ ស្ង ខាងលើចំពោះសូរ ស្ន(ស្និត) ស្ម(ស្មៅ) ស្ល(ស្លឹក) ស្វ(ស្វាយ) ស្អ(ស្អែក)។

### ២- ការស្គាល់តួអក្សរថ្មី ⏲ ៥នាទី

ក- ព្យញ្ជនៈផ្ញើជើង ស្ង

| | |
|---|---|
| គ្រូ | - សរសេរ **ស្ង** លើក្ដារខៀនរួចចង្អុលនិងអាន **ស ជើង** ្ង **ស្ង**។ |
| គ្រូនិងសិស្ស | - អាន **ស្ង** រួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - អាន **ស្ង** ដោយផ្សំប្រកប។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀន ស្ង ខាងលើចំពោះ ស្ន ស្ម ស្ល ស្វ ស្អ។

គ- គ្រូសរសេរចំណងជើងមេរៀនប្រចាំថ្ងៃជាក់លើក្ដារខៀន ផ្ញើជើង ស្ង ស្ន ស្ម ស្ល ស្វ ស្អ រួចចង្អុលឱ្យសិស្សអានម្ដងមួយៗ ដោយផ្សំប្រកប (ឧ. **ស ជើង** ្ង **ស្ង** រួចគ្រូចង្អុលឱ្យសិស្សអានដោយមិនផ្សំ (ប្រកប **ស្ង ស្ន ស្ម ស្ល ស្វ ស្អ**។

### ៣- ការអានព្យាង្គនិងពាក្យ ⏲ ១៨នាទី

#### ៣ ១.- ការអានព្យាង្គ

| | |
|---|---|
| គ្រូ | - សរសេរ **ស្ងួ** លើក្ដារខៀនរួចចង្អុលនិងអាន **ស្ង អួ ស្ងួ**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ស្និ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ស្មៅ ស្លឹ ស្វា ស្អែ** ម្ដងមួយៗរួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

#### ៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - សរសេរ **ស្ងៀមស្ងាត់** លើក្ដារខៀនរួចចង្អុលនិងអាន **ស្ង អៀ ស្ងៀ និង ម ស្ងៀម ស្ង អា ស្ងា និង ត ស្ងាត បន្តក់មួយ ស្ងាត់ ស្ងៀមស្ងាត់**។ |
| គ្រូនិងសិស្ស | - គ្រូសរសេរ **ស្នាដៃ** រួចចង្អុលនិងអានរួមគ្នាដោយផ្សំប្រកប។ |
| សិស្ស | - គ្រូសរសេរ **ស្លាបព្រា** រួចចង្អុលឱ្យសិស្សអានដោយផ្សំប្រកប។<br>- សិស្សអានពាក្យក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។<br>- សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។ |

### ៤- វាក្យសព្ទ ⏲ ៨នាទី

ក- ស្លូតបូត

| | |
|---|---|
| គ្រូ | - ពន្យល់ពាក្យ **ស្លូតបូត** មានន័យថា ដែលមិនកាច សុភាព។ គ្រូនឹងបង្កើតឈ្មោះមួយដោយប្រើពាក្យ ស្លូតបូត។ **ឧ.កញ្ញា ស្លូតបូតគួរឱ្យស្រឡាញ់**។ |

| | |
|---|---|
| គ្រូនិងសិស្ស | - អានពាក្យ **ស្លូតបូត** រួមគ្នា។ គ្រូផ្ដើម **សុភាព....ជាងគេក្នុងគ្រួសារ**។ សិស្សថា **ស្លូតបូត** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ស្លូតបូត** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ស្លូតបូត** ជាដៃគូ។ |

ខ- **ស្វិតស្វាញ** បង្រៀនដូចពាក្យខាងលើ។ **ស្វិតស្វាញ មានន័យថា ដែលមិនងាយលែង មិនងាយចុះចាញ់។**

**ង. ទោះបីលំបាកក្ដី នារីរៀនសូត្រយ៉ាងស្វិតស្វាញ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **មីងខុមបោចស្មៅក្នុងស្រែយ៉ាងស្ទៀមស្ទាត់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **មីងខុម/បោច/ស្មៅ/ក្នុង/ស្រែ/យ៉ាង/ស្ទៀមស្ទាត់។**

| | |
|---|---|
| គ្រូ | - គ្រូអាន **មីងខុមបោចស្មៅក្នុងស្រែយ៉ាងស្ទៀមស្ទាត់។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **មីងខុមបោចស្មៅក្នុងស្រែយ៉ាងស្ទៀមស្ទាត់។** |
| សិស្ស | - សិស្សអានល្បះ **មីងខុមបោចស្មៅក្នុងស្រែយ៉ាងស្ទៀមស្ទាត់។**<br>- សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើនារីស្វះស្វែងធ្វើអ្វី?**

**២- តើនរណាទិញស្បែកជើងឱ្យនារី?**

**៣- ហេតុអ្វីបានជាពូស្មៀនទិញស្បែកជើងថ្មីឱ្យនារី?**

**៤- នៅពេលដែលកូនទទួលបានអំណោយអ្វីមួយពីនរណាម្នាក់ តើកូនត្រូវធ្វើបែបណា?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ស្ទៀមស្ទាត់ ស ្ទ ៀ ម ស ្ទ ា ត ់** រួចសរសេរ **ស្ទៀមស្ទាត់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ស្នាដៃ ស ្ន ា ដ ៃ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ស្លូតបូត ស្លាបព្រា ស្វាហាប់** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ស្វះស្វែងរៀនសូត្រ** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# លំនាំបង្រៀន

# មេរៀន

# ព្យាង្គតម្រួត ង្ក ង្ខ ង្គ ង្ឃ ញ្ច ញ្ជ

**គន្លឹះត្រូវចងចាំ**

- ✓ គ្រប់សកម្មភាពត្រូវអនុវត្តទៅតាមលំនាំក្នុងសៀវភៅណែនាំគ្រូនិងប្រើប្រាស់ពាក្យពេចន៍ជាអក្សរជិត។
- ✓ ក្នុងពេលអាន សិស្សត្រូវប្រើភ្នែក និងចង្អុលដៃរេតាមតួអក្សរ។
- ✓ គ្រូត្រូវដើរតាមតុសិស្ស ស្ដាប់សិស្សអានជាដៃគូ និងជួយកែតម្រូវសិស្សណាអានមិនទាន់ត្រឹមត្រូវ។
- ✓ ប្រសិនបើសិស្សណាលំបាកអាន គ្រូត្រូវជួយសិស្សនោះ។ គ្រូអាចអានពាក្យជាគំរូ អានពាក្យនោះម្ដងទៀតជាមួយសិស្ស និងឱ្យសិស្សអានពាក្យនោះខ្លួនឯងម្ដងទៀត។
- ✓ ប្រសិនបើសិស្សភាគច្រើនមានការលំបាក គ្រូត្រូវណែនាំឡើងវិញដោយប្រើ វិធីគ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើជាមួយសិស្សទាំងអស់ក្នុងថ្នាក់។
- ✓ សម្រាប់ការបង្រៀនតួអក្សរថ្មី គ្រូត្រូវសរសេរតួអក្សរដែលត្រូវរៀនធំៗលើក្ដារខៀន។
- ✓ អនុវត្ត គ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើ ដូចដែលបានលម្អិតក្នុងសៀវភៅណែនាំគ្រូ។
- ✓ គ្រូដើរតាមតុក្នុងថ្នាក់ ពេលគ្រូនិងសិស្សធ្វើ សិស្សធ្វើ ក្នុងគ្រប់សកម្មភាពអាន និងសរសេរដើម្បីជួយសិស្ស។
- ✓ សម្រាប់សកម្មភាពអាន ឱ្យសិស្សអានលើសពីម្ដង។

☙ ៀ ប្រសិនបើមានសិស្សខ្សោយគំហើញ និងខ្សោយស្ដាប់ រាល់ការបង្ហាញ និងការណែនាំរបស់គ្រូត្រូវប្រាកដថាសិស្សទាំងនោះស្ដាប់ឮ និងឃើញច្បាស់។

☙ ៀ គ្រូប្រើប័ណ្ណពាក្យ ល្បះសម្រាប់សិស្សខ្សោយស្ដាប់ និងខ្សោយគំហើញ។

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

◎ **រំឭកពាក្យព្យញ្ជនៈផ្សំស្រៈ**

🗐 ប័ណ្ណពាក្យ និងក្ដារឆ្នួន

⌚ ៥ នាទី

គ្រូសរសេរពាក្យ : **ល្ខោនខោល ស្បែកជើង ស្ពឹមស្ពៃ ស្អាតបាត ស្លូតបូត** ម្ដងមួយពាក្យៗ រួចឱ្យសិស្សអាន ឬហៅឱ្យសិស្សសរសេរលើក្ដារឆ្នួន ហើយអាន។ គ្រូកែតម្រូវការអាន ឬការសរសេររបស់សិស្ស។

## ១- ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

◎ **ប្រាប់សូរពាក្យព្យាង្គតម្រួត**

🗐 កាយវិការ ពណ៌នា បង្ហាញរូបភាព វត្ថុជាក់ស្ដែង

⌚ ៥ នាទី

**១- ការស្គាល់សូរ** :

ក- គ្រូអាចធ្វើកាយវិការ ពណ៌នា បំផុសសំណួរ បង្ហាញរូបភាព ឬ វត្ថុជាក់ស្ដែងនៃពាក្យ កង្កែប បង្ខិត ង្ងាន់ អង្រ្គា បង្ហាញ បង្គួច។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

កង្កែប

- គ្រូ : បង្ហាញរូបភាព កង្កែប រួចសួរសិស្សថា តើនេះជាសត្វអ្វី? (**កង្កែប**)។
- គ្រូថា **កង្កែប** រួចទះដៃតាមសូរព្យាង្គ **[កង់-កែប]** ។
- គ្រូនិងសិស្ស : បន្លឺពាក្យ **កង្កែប** រួមគ្នាព្រមទាំងទះដៃតាមសូរព្យាង្គ **[កង់-កែប]** ។
- សិស្ស : បន្លឺពាក្យ **កង្កែប** ដោយទះដៃតាមសូរព្យាង្គ **[កង់-កែប]** ដោយខ្លួនឯង។

បង្ខិត

- គ្រូ : ធ្វើសកម្មភាព ដោយដាក់របស់អ្វីមួយឱ្យខិតរកគ្នា រួចគ្រូសួរសិស្សថា **តើគ្រូកំពុងធ្វើសកម្មភាពអ្វី?** (**បង្ខិត**)។ គ្រូថា **បង្ខិត** រួចទះដៃតាមសូរព្យាង្គ **[បង់-ខិត]** ។
- គ្រូនិងសិស្ស : បន្លឺពាក្យ **បង្ខិត** រួមគ្នាព្រមទាំងទះដៃតាមសូរព្យាង្គ **[បង់-ខិត]** ។
- សិស្ស : បន្លឺពាក្យ **បង្ខិត** ដោយទះដៃតាមសូរព្យាង្គ **[បង់-ខិត]** ដោយខ្លួនឯង។

រង្វាន់

- គ្រូ : សួរសិស្សថា **តើកីឡាករជាតិដែលប្រកួតឈ្នះគេ បានទទួលអ្វីពីគណៈកម្មការ?**(**ពានរង្វាន់ ឬ រង្វាន់**)។ គ្រូថា រង្វាន់ រួចទះដៃតាមសូរព្យាង្គ **[រង់-វ៉ាន់]** ។
- គ្រូនិងសិស្ស : បន្លឺពាក្យ **រង្វាន់** រួមគ្នាព្រមទាំងទះដៃតាមសូរព្យាង្គ **[រង់-វ៉ាន់]** ។
- សិស្ស : បន្លឺពាក្យ **រង្វាន់** ដោយទះដៃតាមសូរព្យាង្គ **[រង់-វ៉ាន់]** ដោយខ្លួនឯង។

អង្សា

- គ្រូ : ប្រាប់សិស្សថា ខ្នាតប្រវែងគេប្រើម៉ែត្រ។ រួចសួរសិស្សថា តើខ្នាតវាស់កំដៅគេប្រើអ្វី? (**អង្សា**)។ គ្រូថា **អង្សា** រួចទះដៃតាមសូរព្យាង្គ [អង់-សា] ។
- គ្រូនិងសិស្ស : បន្លឺពាក្យ អង្សា រួមគ្នាព្រមទាំងទះដៃតាមសូរព្យាង្គ **[អង់-សា]** ។
- សិស្ស : បន្លឺពាក្យ **អង្សា** ដោយទះដៃតាមសូរព្យាង្គ **[អង់-សា]** ដោយខ្លួនឯង។

បង្ហាញ

- គ្រូ : លើករបស់អ្វីមួយបង្ហាញសិស្ស ហើយសួរសិស្សថា **តើគ្រូកំពុងធ្វើអ្វី? (បង្ហាញ)**។ គ្រូថា **បង្ហាញ** រួចទះដៃតាមសូរព្យាង្គ **[បង់-ហាញ]** ។
- គ្រូនិងសិស្ស : បន្លឺពាក្យ **បង្ហាញ** រួមគ្នាព្រមទាំងទះដៃតាមសូរព្យាង្គ **[បង់-ហាញ]** ។
- សិស្ស : បន្លឺពាក្យ **បង្ហាញ** ដោយទះដៃតាមសូរព្យាង្គ **[បង់-ហាញ]** ដោយខ្លួនឯង។

បង្អួច

- គ្រូ : ចង្អុលទៅបង្អួច រួចសួរសិស្សថា **តើនេះជាអ្វី?** (**បង្អួច**)។ គ្រូថា **បង្អួច** រួចទះដៃតាមសូរព្យាង្គ **[បង់-អួច]** ។
- គ្រូនិងសិស្ស : បន្លឺពាក្យ **បង្អួច** រួមគ្នាព្រមទាំងទះដៃតាមសូរព្យាង្គ **[បង់-អួច]** ។
- សិស្ស : បន្លឺពាក្យ **បង្អួច** ដោយទះដៃតាមសូរព្យាង្គ **[បង់-អួច]** ដោយខ្លួនឯង។

## ២- ការស្គាល់តួអក្សរថ្មី ◷ ៥នាទី

◎ **ប្រាប់តួអក្សរ ព្យាង្គក្នុងពាក្យ**

🗐 មិនមាន

◷ ៥ នាទី

ក- គ្រូសរសេរពាក្យ **កង្កែប បង្ខិត វង្វាន់ អង្ស៊ា បង្ហាញ បង្អួច** លើក្ដារខៀន។ គ្រូសួរសិស្សថា **តើក្នុងពាក្យនីមួយៗ អក្សរណាដែលត្រួតលើគ្នា?** គ្រូសរសេរព្យាង្គតម្រួតក្នុងពាក្យនីមួយៗដូចខាងក្រោម៖

- **កង្កែប** [ ង្ក ] **បង្ខិត** [ ង្ខ ] **វង្វាន់** [ ង្វ ] **អង្ស៊ា** [ ង្ស ] **បង្ហាញ** [ ង្ហ ] **បង្អួច** [ ង្អ ]

ខ- គ្រូសរសេរចំណងជើងមេរៀន **"មេរៀនព្យាង្គតម្រួត ង្ក ង្ខ ង្វ ង្ស ង្ហ ង្អ"** លើក្ដារខៀន រួចនាំសិស្សអាន៖

- គ្រូ : អានម្ដងមួយៗ **[ង ជើង ក] [ង ជើង ខ] [ង ជើង វ] [ង ជើង ស] [ង ជើង ហ ] [ង ជើង អ] ង្ក ង្ខ ង្វ ង្ស ង្ហ ង្អ** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ។
- គ្រូ និងសិស្ស : អានរួមគ្នា **[ង ជើង ក] [ង ជើង ខ] [ង ជើង វ] [ង ជើង ស] [ង ជើង ហ ] [ង ជើង អ] ង្ក ង្ខ ង្វ ង្ស ង្ហ ង្អ** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ។
- សិស្ស : អានទាំងអស់គ្នា **[ង ជើង ក] [ង ជើង ខ] [ង ជើង វ] [ង ជើង ស] [ង ជើង ហ ] [ង ជើង អ] ង្ក ង្ខ ង្វ ង្ស ង្ហ ង្អ** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ។

**គន្លឹះត្រូវចងចាំ**

★ គ្រូត្រូវបន្លឺសូរដែលត្រូវរៀនឱ្យបានឮៗ និងច្បាស់ៗ។

★ គ្រូចង្អុលឱ្យសិស្សអានម្ដងមួយៗ ( ឧ.**ង្ក ង ជើង ក**...)។

★ មានវិធីជាច្រើនយ៉ាង ក្នុងការបំផុសរកពាក្យថ្មី ក្នុងនោះរួមមាន ការលើកឧទាហរណ៍ ការពិពណ៌នា ការបង្ហាញវត្ថុជាក់ស្ដែង ការបង្ហាញរូបភាព និងការធ្វើកាយវិការ។ល។ ការធ្វើកាយវិការត្រូវបានលើកទឹកចិត្តឱ្យគ្រូប្រើញឹកញាប់ ព្រោះវាអាចជួយឱ្យមានអន្តរកម្មរវាងគ្រូ និងសិស្ស សិស្សនិងសិស្ស។

★ លើកទឹកចិត្តសិស្សឱ្យលើកដៃប្រកបព្យាង្គ និងពាក្យ ដូចដែលគ្រូបានធ្វើឱ្យមើល ដើម្បីឱ្យពួកគេធ្វើ ចលនាដៃគ្រប់គ្នា និងផ្ដល់អារម្មណ៍ក្នុងសកម្មភាពរៀន។

✓ ពិនិត្យមើលពេលសិស្សប្រកប ដើម្បីដឹងថាសិស្សណាខ្លះបន្លឺសូរប្រកប និងអានពាក្យបានត្រឹមត្រូវ សិស្សណាខ្លះដែលត្រូវការជួយបន្ថែម។

✓ បង្រៀនទៅតាមពេលវេលាដែលបានកំណត់ក្នុងសៀវភៅណែនាំគ្រូ ក្នុងសកម្មភាពណែនាំឱ្យសិស្សស្គាល់សូរអក្សរថ្មី។

👁 ត្រូវប្រាកដថា សិស្សអាចមើលឃើញគ្រូច្បាស់។ គ្រូទាញចំណាប់អារម្មណ៍សិស្សមើលគ្រូ និងចូលរួមអនុវត្តសកម្មភាព។

## ៣- ការអានពាក្យ ◷ ១៨នាទី

◎ **អានពាក្យព្យាង្គតម្រួត**

🗐 សៀវភៅសិក្សាគោល

◷ ១៨នាទី

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

គ្រូប្រាប់សិស្សថាសម្រាប់ការអានព្យាង្គតម្រួត យើងត្រូវអានដោយប្រកបព្យញ្ជនៈទី១ និងព្យញ្ជនៈទី២ ហើយសូរអាន បន្លឺដូចមានបន្តក់ដែរ។ ចំណែកឯជើងព្យញ្ជនៈ ដែលស្ថិតនៅក្រោមព្យញ្ជនៈទី ២ ត្រូវផ្សំប្រកបអានដូចជាតួព្យញ្ជនៈដែរ។

**កង្កែប**

- គ្រូ : អាន **កង្កែប** លើក្តារខៀនដោយផ្សំប្រកបថា **ក និង ង អានថា កង់ ជើង ្ក អានដូច ក ដែរ ក អែ កែ និង ប កែប កង្កែប** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ និងពាក្យ។
- គ្រូ និងសិស្ស: អាន **កង្កែប** លើក្តារខៀនដោយផ្សំប្រកបថា **ក និង ង កង់ ក អែ កែ និង ប កែប កង្កែប។**
- សិស្ស : អាន **កង្កែប** លើក្តារខៀនដោយផ្សំប្រកបថា **ក និង ង កង់ ក អែ កែ និង ប កែប កង្កែប។**

**បង្ខិត**

- គ្រូ : អាន **បង្ខិត** លើក្តារខៀនដោយផ្សំប្រកបថា **ប និង ង បង់ ខ អិ ខិ និង ត ខិត បង្ខិត** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ និងពាក្យ។
- គ្រូ និងសិស្ស: អាន **បង្ខិត** លើក្តារខៀនដោយផ្សំប្រកបថា **ប និង ង បង់ ខ អិ ខិ និង ត ខិត បង្ខិត ។**
- សិស្ស : អាន **បង្ខិត** លើក្តារខៀនដោយផ្សំប្រកបថា **ប និង ង បង់ ខ អិ ខិ និង ត ខិត បង្ខិត ។**

**វង្វាន់**

- គ្រូ : អាន **វង្វាន់** លើក្តារខៀនដោយផ្សំប្រកបថា **វ និង ង វង់ វ អ៊ា វា និង ន វាន បន្តក់មួយ វាន់ វង្វាន់**ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ និងពាក្យ។
- គ្រូ និងសិស្ស: អាន **វង្វាន់** លើក្តារខៀនដោយផ្សំប្រកបថា **វ និង ង វង់ វ អ៊ា វា និង ន វាន បន្តក់មួយ វាន់ វង្វាន់។**
- សិស្ស : អាន **វង្វាន់** លើក្តារខៀនដោយផ្សំប្រកបថា **វ និង ង វង់ វ អ៊ា វា និង ន វាន បន្តក់មួយ វាន់ វង្វាន់។**

**អង្សា**

- គ្រូ : អាន **អង្សា** លើក្តារខៀនដោយផ្សំប្រកបថា **អ និង ង អង់ ស អា សា អង្សា** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ និងពាក្យ។
- គ្រូ និងសិស្ស: អាន **អង្សា** លើក្តារខៀនដោយផ្សំប្រកបថា **អ និង ង អង់ ស អា សា អង្សា។**
- សិស្ស : អាន **អង្សា** លើក្តារខៀនដោយផ្សំប្រកបថា **អ និង ង អង់ ស អា សា អង្សា។**

**បង្ហាញ**

- គ្រូ : អាន **បង្ហាញ** លើក្តារខៀនដោយផ្សំប្រកបថា **ប និង ង បង់ ហ អា ហា និង ញ ហាញ បង្ហាញ** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ និងពាក្យ។
- គ្រូ និងសិស្ស: អាន **បង្ហាញ** លើក្តារខៀនដោយផ្សំប្រកបថា **ប និង ង បង់ ហ អា ហា និង ញ ហាញ បង្ហាញ។**
- សិស្ស : អាន **បង្ហាញ** លើក្តារខៀនដោយផ្សំប្រកបថា **ប និង ង បង់ ហ អា ហា និង ញ ហាញ បង្ហាញ។**

**បង្អួច**

- គ្រូ : អាន **បង្អួច** លើក្តារខៀនដោយផ្សំប្រកបថា **ប និង ង បង់ អ អួ អួ និង ច អួច បង្អួច** ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ និងពាក្យ។
- គ្រូ និងសិស្ស: អាន **បង្អួច** លើក្តារខៀនដោយផ្សំប្រកបថា **ប និង ង បង់ អ អួ អួ និង ច អួច បង្អួច ។**
- សិស្ស : អាន **បង្អួច** លើក្តារខៀនដោយផ្សំប្រកបថា **ប និង ង បង់ អ អួ អួ និង ច អួច បង្អួច ។**

- គ្រូឱ្យសិស្សអានពាក្យទាំងអស់ក្នុងសៀវភៅសិក្សាគោលជាដៃគូ។ បើមានពេលអានជាបុគ្គល។

**៤ - វាក្យសព្ទ** ◷ ៨នាទី

**◎ យល់ន័យ និងប្រើប្រាស់ពាក្យ**

🗐 មិនត្រូវការ

◷ ៨នាទី

ក- បង្វិល

- គ្រូ : សរសេរពាក្យ **បង្វិល** លើក្ដារខៀន រួចអាន និងពន្យល់ន័យ។ ក្នុងករណីពាក្យត្រូវពន្យល់មានសរសេរលើក្ដារខៀនម្ដងហើយ គ្រាន់តែគូសវង់លើពាក្យនោះក៏បាន។ **ពាក្យ បង្វិល មានន័យថា ធ្វើឱ្យ វិល។ ឥឡូវនេះគ្រូនឹងបង្កើតល្បះមួយ ដោយប្រើពាក្យ បង្វិល។ តារាលេងបង្វិលសំបកកង់។**
- គ្រូ និងសិស្ស : អានពាក្យ **បង្វិល** រួមគ្នា។ ឥឡូវនេះយើងនឹងបង្កើតល្បះមួយ **រួមគ្នាដោយប្រើពាក្យ បង្វិល ដោយគ្រូជាអ្នកផ្ដើម ហើយកូនៗជាអ្នកបំពេញ** ពេលគ្រូបង្អាក់បន្តិច។ គ្រូថា **ខ្ញុំ...........ខ្លួនឈរផ្លុះកញ្ចក់** ពេល **ស្លៀកពាក់។ សិស្សថា បង្វិល។ ឥឡូវនេះយើង នឹងថា ល្បះឡើងវិញទាំងអស់គ្នា : ខ្ញុំបង្វិលខ្លួនឈរផ្លុះកញ្ចក់ពេលស្លៀកពាក់។**
- សិស្ស : អានពាក្យ **បង្វិល** ដោយខ្លួនឯង និងបង្កើតល្បះដោយប្រើពាក្យ **បង្វិល** ជាដៃគូ។

ខ- ចង្អើរ

- គ្រូ : សរសេរពាក្យ **ចង្អើរ** លើក្ដារខៀន រួចអាន និងពន្យល់ន័យ។ ពាក្យ **ចង្អើរ មានន័យថា រានសម្រាប់ផ្អើរត្រី ផ្អើរសាច់ ផ្អើរនំ ផ្អើរម្ទេស ជាដើម ។ ឧ. ម្ដាយខ្ញុំយកចង្អើរទៅផ្អើរត្រី។**
- គ្រូ និងសិស្ស :អានពាក្យ **ចង្អើរ** រួមគ្នា។ **ឥឡូវនេះ យើងនឹងបង្កើតល្បះមួយ រួមគ្នាដោយប្រើពាក្យ ចង្អើរ ដោយគ្រូជាអ្នកផ្ដើម ហើយកូនៗជាអ្នកបំពេញ** ពេលគ្រូបង្អាក់បន្តិច។ គ្រូថា **បងភីយកត្រីទៅដាក់លើ...នៅមុខផ្ទះ។** សិស្សថា ចង្អើរ ។ **ឥឡូវនេះ យើងនឹងថាល្បះ ឡើងវិញទាំងអស់គ្នា** : **បងភីយកត្រីទៅដាក់លើចង្អើរនៅមុខផ្ទះ។**
- សិស្ស : អានពាក្យ **ចង្អើរ** ដោយខ្លួនឯង និងបង្កើតល្បះដោយប្រើពាក្យ **ចង្អើរ** ជាដៃគូ។

**៥- ការអានល្បះ** ◷ ៥នាទី

**◎ អានល្បះដោយមិនផ្សំប្រកប**

🗐 សៀវភៅសិក្សាគោល

◷ ៥ នាទី

ក -គ្រូបង្ហាញរូបភាពទាក់ទងនឹងល្បះ ប្រសិនបើមាន។

ខ -គ្រូសរសេរល្បះ **សង្ហា សង្វាតសិក្សាមិនបង្អង់។** លើក្ដារខៀន។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?** ពេលសិស្សឆ្លើយ គ្រូគូសសញ្ញា ( / ) លើល្បះដើម្បីញែកពាក្យ **សង្ហា /សង្វាត/សិក្សា/មិន/បង្អង់។**

គ- គ្រូនាំសិស្សហ្វឹកហាត់អាន៖

- គ្រូ : អានល្បះ **សង្ហា សង្វាតសិក្សាមិនបង្អង់។**
- គ្រូ និងសិស្ស : អានល្បះរួមគ្នា **សង្ហា សង្វាតសិក្សាមិនបង្អង់។**
- សិស្ស :អានល្បះទាំងអស់គ្នា **សង្ហា សង្វាតសិក្សាមិនបង្អង់។**

ឃ- គ្រូសួរសំណួរដែលផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់សិស្ស ដើម្បីឱ្យសិស្សយល់ពីអត្ថន័យនៃល្បះ។

ង- គ្រូឱ្យសិស្សហ្វឹកហាត់អានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល ជាដៃគូ ដោយម្នាក់ចង្អុល ម្នាក់ទៀតអាន រួចប្ដូរវេនគ្នា។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

**គន្លឹះត្រូវចងចាំ**

- ✓ សម្រាប់ការបង្រៀនវាក្យសព្ទ គ្រូត្រូវដើរតាមតុ ស្តាប់សិស្សបង្កើតល្បះជាមួយដៃគូ។
- ✓ សកម្មភាពនេះទាមទារឱ្យសិស្សស្គាល់សូរ ចេះអានពាក្យយល់ន័យពាក្យ ចេះប្រើប្រាស់ពាក្យបានត្រឹមត្រូវ។ គ្រូ និងសិស្សបង្កើតល្បះដោយផ្ទាល់មាត់ ពុំមានការសរសេរទេ។
- ✓ ពេលសិស្សបង្កើតល្បះ គ្រូស្តាប់ហើយសួរបញ្ជាក់ បើល្បះនោះមិនទាន់មានន័យគ្រប់គ្រាន់។
- ✓ គ្រូត្រូវដើរទៅជិតសិស្ស នៅពេលគ្រូពន្យល់ និងបង្កើតល្បះជាឧទាហរណ៍ដល់សិស្ស។

## ៦- ការអានអត្ថបទខ្លី 12នាទី

◎ **ហាត់អានស្ទាត់ និងយល់ន័យខ្លឹមសារអត្ថបទ**

សៀវភៅជំនួយសិស្ស

១២នាទី

ក -គ្រូសួរសំណួរទាក់ទងនឹងរូបភាព និងប្រាប់ចំណងជើងអត្ថបទ។

ខ- ឱ្យសិស្សទស្សន៍ទាយសាច់រឿងថា **តើរឿងនេះនិយាយអំពីអ្វី?**

គ-អានអត្ថបទខ្លី

- គ្រូ : អានរឿងទាំងមូលយឺតៗដោយលើកដាក់សំឡេងគោរពតាមឃ្លា ល្បះក្នុងសាច់រឿង។
- គ្រូ និងសិស្ស : អានទាំងអស់គ្នា។
- សិស្ស : ហ្វឹកហាត់អានជាដៃគូដោយប្តូរវេនគ្នា ម្នាក់ជាអ្នកចង្អុលម្នាក់ទៀតជាអ្នកអាន រួចអានជាបុគ្គល។ ប្រសិនបើមានពេល ឱ្យសិស្សអានឱ្យបានច្រើនដង។

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង -គ្រូសួរសំណួរម្តងមួយៗ ដោយទុកពេលឱ្យសិស្សគិត (បើរកចម្លើយមិនឃើញ គ្រូ និងសិស្សអានអត្ថបទរឿងឡើងវិញ)។

**១. តើបង្កួយតោងអ្វី?ហើយ ធ្លាក់ចូលក្នុងអ្វី?**
**២. ពេលឃើញបង្កួយធ្លាក់លើចង្អេរ តើកង្កែបធ្វើដូចម្តេច?**
**៣. តើកូនគិតថា ហេតុអ្វីបានជាកង្កែបជួយបង្កួយ?**
**៤. តើកូនធ្លាប់បានជួយអ្នកណាខ្លះ? ការងារអ្វីខ្លះ? ពេលណា?**

**គន្លឹះត្រូវចងចាំ**

- ✓ គ្រូស្រង់ល្បះមួយ ពីក្នុងសៀវភៅសិក្សាគោល។ ប្រសិនបើមានរូបភាពក្នុងសៀវភៅនោះ គ្រូលើករូបភាពបង្ហាញ ដើម្បីបំផុសសំណួរដែលទាក់ទងនឹងល្បះដែលត្រូវរៀន។
- ✓ គ្រូឱ្យសិស្សប្រាប់ពាក្យពិបាក (បើមាន) ។

## ៧- ការសរសេរ ១៦នាទី

៧.១- ការសរសេរពាក្យ

◎ បន្លឺសូរ និងសរសេរពាក្យបានត្រឹមត្រូវ

🗐 ក្ដារឆ្នួន

🕒 ១១នាទី

- គ្រូ: បន្លឺពាក្យ សង្វារ ។ គ្រូគិត និងថាឮៗ **សង្វារ មាន ស ង ជើង ្វ ស្រៈា និង រ** រួចសរសេរ **សង្វារ** លើក្ដារខៀន។
- គ្រូនិងសិស្ស : គ្រូបន្លឺពាក្យ **ចង្អេរ** ។ គ្រូ និងសិស្សគិត និងថាឮៗ **ចង្អេរ មាន ច ង ជើង ្អ ស្រៈ េ និង រ** ។ គ្រូសរសេរ **ចង្អេរ** លើក្ដារខៀន។ សិស្សសរសេរ **ចង្អេរ** លើក្ដារឆ្នួន។
- សិស្ស : គ្រូបន្លឺពាក្យ **បង្កើត** ។ សិស្សគិត និងថាឮៗ បង្កើត មាន **ប ង ្ក ស្រៈ ើ និង ត** រួចសរសេរពាក្យ **បង្កើត** លើក្ដារឆ្នួន។ សិស្សលើកបង្ហាញគ្រូ។ គ្រូសរសេរ **បង្កើត** លើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់ ។ គ្រូធ្វើដូចគ្នានឹងពាក្យ **បង្កើត** ដែរ ចំពោះពាក្យ **បង្ខំ អង្រួ** ។

៧.២- ការសរសេរឃ្លា

◎ សរសេរឃ្លាបានត្រឹមត្រូវ

🗐 សៀវភៅកិច្ចការសិស្ស

🕒 ៥ នាទី

- គ្រូប្រាប់សិស្សថា **ពេលនេះយើងនឹងហ្វឹកហាត់សរសេរឃ្លា។ គ្រូនឹងហៅឃ្លាយឺតៗចំនួន៣ដងឱ្យកូនសរសេរ។**

ក- គ្រូហៅឃ្លា **ចង្អេរឫស្សី** យឺតៗចំនួនបីដង។

ខ- សិស្សសរសេរឃ្លា **ចង្អេរឫស្សី** ចូលក្នុងសៀវភៅកិច្ចការ។

គ- គ្រូសរសេរឃ្លាលើក្ដារខៀន ឱ្យសិស្សផ្ទៀងផ្ទាត់ និងកែតម្រូវ។

**គន្លឹះត្រូវចងចាំ**

★ សកម្មភាពគ្រូធ្វើ គ្រូត្រូវអានស្ទាត់ជាគំរូដល់សិស្ស។
✓ សកម្មភាពគ្រូនិងសិស្សធ្វើ គ្រូនិងសិស្សត្រូវអានរួមគ្នា (មិនមែនសិស្សអានតាមគ្រូទេ)។
✓ សម្រាប់សំណួរ ដែលមានចម្លើយលើសពីមួយទុកពេលសមល្មមឱ្យសិស្សប្រើបទពិសោធ ឬគំនិតផ្ទាល់ខ្លួនពិភាក្សាជាដៃគូ។
✓ ប្ដូរសំណួរតែរក្សាន័យដដែល ពេលដែលសិស្សស្ដាប់សំណួរគ្រូមិនយល់។
ជួយសិស្សដោយប្រើសំណួរប្រជេញ ប្រសិនបើពួកគេនៅតែមិនទាន់យល់សំណួរ។

**ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ** 🕒 ៦នាទី

➢ គ្រូពង្រឹង ឬពង្រីកចំណេះដឹងរបស់សិស្សលើការអាន និងការសរសេរ៖
  ○ ការអាន៖ ឧទាហរណ៍: គ្រូប្រើប័ណ្ណអក្សរ ឬប័ណ្ណពាក្យដែលសិស្សបានរៀន ឱ្យសិស្សអាន ឬឱ្យក្រុមសិស្សរៀបតួអក្សរឱ្យបានជាពាក្យ ឬលេងល្បែងសិក្សានានា...ដែលសំដៅដល់ការពង្រឹង ឬពង្រីកចំណេះដឹងដល់សិស្ស។
  ○ ការសរសេរ៖ ឧទាហរណ៍: គ្រូអាចហៅពាក្យដែលរៀនរួច ឱ្យសិស្សសរសេរលើក្ដារឆ្នួន ឬសៀវភៅកិច្ចការ...។
➢ គ្រូដាក់កិច្ចការឱ្យសិស្សធ្វើ៖
  ○ ឱ្យសិស្សចម្លងស្រៈ ព្យញ្ជនៈ ពាក្យ ឃ្លា ឬល្បះ... ដាក់ក្នុងសៀវភៅសរសេរ។ (ឱ្យសិស្សចម្លងនៅផ្ទះបើគ្មានពេល) ដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៩៥ | ព្យាង្គតម្រួត ង្ក ង្ខ ង្វ ង្ស ង្គ ង្អ | ៤០នាទី |
|---|---|---|

| លំនឹងថ្នាក់ និងរំឭកមេរៀន | ៥នាទី |
|---|---|

- គ្រូរំឭកពាក្យដែលបានរៀនរួច **ល្ងោនខោល ស្បែកជើង ស្ពឹមស្ពែ ស្អាតបាត ស្លូតបូត ។**

| ១- ការស្គាល់សូរអក្សរថ្មី | ៥នាទី |
|---|---|

- គ្រូអាចធ្វើកាយវិការ ពណ៌នា បំផុសសំណួរ បង្ហាញរូបភាព ឬ វត្ថុជាក់ស្តែងសម្រាប់ពាក្យ **កង្កែប បង្ខិត វង្វាន់ អង្សា បង្គាញ បង្អួច។**

ក- សូរពាក្យ កង្កែប

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **កង្កែប។ នេះជាសត្វអ្វី? កង្កែប។**<br>- គ្រូបន្លឺ និងទះដៃតាមព្យាង្គ **កង់** (ទះដៃ) **កែប** (ទះដៃ)។ |
| គ្រូនិងសិស្ស | - បន្លឺ និងទះដៃតាមព្យាង្គ **កង់** (ទះដៃ) **កែប** (ទះដៃ) រួមគ្នា។ |
| សិស្ស | - បន្លឺនិងទះដៃតាមព្យាង្គ **កង់** (ទះដៃ) **កែប** (ទះដៃ) រួមគ្នា។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀនសូរនៃពាក្យ កង្កែប ខាងលើ ចំពោះពាក្យ បង្ខិត វង្វាន់ អង្សា បង្គាញ បង្អួច។

| ២- ការស្គាល់តួអក្សរថ្មី | ៥នាទី |
|---|---|

- គ្រូសរសេរពាក្យ **កង្កែប បង្ខិត វង្វាន់ អង្សា បង្គាញ បង្អួច** នៅលើក្តារខៀន។ គ្រូសួរសិស្សថា នៅក្នុងពាក្យនីមួយៗ តើអក្សរណាដែលត្រួតលើគ្នា។ គ្រូសរសេរព្យាង្គតម្រួតនៅក្រោយពាក្យនីមួយៗ **កង្កែប [ ង្ក ] បង្ខិត [ ង្ខ ] វង្វាន់ [ ង្វ ] អង្សា [ ង្ស ] បង្គាញ [ ង្គ ] បង្អួច [ ង្អ ]។**

- គ្រូសរសេរ ចំណងជើងមេរៀន **ង្ក ង្ខ ង្វ ង្ស ង្គ ង្អ** លើក្តារខៀន រួចនាំសិស្សអនុវត្តតាម ៣ជំហាន៖

| | |
|---|---|
| គ្រូ | - អានម្តងមួយៗ **[ង ជើង ក] [ង ជើង ខ] [ង ជើង វ] [ង ជើង ស] [ង ជើង ហ ]<br>[ង ជើង អ] ង្ក ង្ខ ង្វ ង្ស ង្គ ង្អ។** |
| គ្រូ និងសិស្ស | - អានរួមគ្នាម្តងមួយៗ **[ង ជើង ក] [ង ជើង ខ] [ង ជើង វ] [ង ជើង ស] [ង ជើង ហ ]<br>[ង ជើង អ] ង្ក ង្ខ ង្វ ង្ស ង្គ ង្អ។** |
| សិស្ស | - អានម្តងមួយៗ **[ង ជើង ក] [ង ជើង ខ] [ង ជើង វ] [ង ជើង ស] [ង ជើង ហ ]<br>[ង ជើង អ] ង្ក ង្ខ ង្វ ង្ស ង្គ ង្អ។** |

| ៣- ការអានពាក្យ | ១៨នាទី |
|---|---|

គ្រូប្រាប់សិស្សថាសម្រាប់ការអានព្យាង្គតម្រួត យើងត្រូវអានដោយប្រកបព្យញ្ជនៈទី១ និងព្យញ្ជនៈទី២ ហើយសូរអាន បន្លឺដូចបន្តក់ដែរ។ ចំណែកឯជើងព្យញ្ជនៈ ដែលស្ថិតនៅក្រោមព្យញ្ជនៈទី ២ ត្រូវផ្សំប្រកបអានដូចជាតួព្យញ្ជនៈដែរ។

| | |
|---|---|
| គ្រូ | - អាន **កង្កែប** លើក្តារខៀនដោយផ្សំប្រកបថា **ក និង ង កង់ ក អែ កែ និង ប កែប កង្កែប**<br>ដោយយកម្រាមដៃចង្អុលពីក្រោមតួអក្សរនីមួយៗ និងពាក្យ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **កង្កែប** លើក្តារខៀនដោយផ្សំប្រកប។ |
| សិស្ស | - អាន **កង្កែប** លើក្តារខៀនដោយផ្សំប្រកប។ |

-អនុវត្តដូចពាក្យ កង្កែប ចំពោះពាក្យ បង្ខិត វង្វាន់ អង្សា បង្គាញ បង្អួច។

-សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។

## ៤- វាក្យសព្ទ ◷ ៨នាទី

ក- បង្វិល

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **បង្វិល មានន័យថា ធ្វើឱ្យវិល។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ បង្វិល** ។ **ជាវាលេងបង្វិលសំបកកង់** ។ |
| គ្រូនិងសិស្ស | - អានពាក្យ **បង្វិល** រួមគ្នា។ គ្រូផ្ដើម ខ្ញុំ... **ខ្លួនឈរឆ្លុះកញ្ចក់ ពេលស្លៀកពាក់។** សិស្សថា **បង្វិល** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **បង្វិល** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **បង្វិល** ជាដៃគូ។ |

ខ- ចង្កើរ បង្រៀនដូចពាក្យខាងលើ។ **ចង្កើរ មានន័យថា រានសម្រាប់ឆ្អើរត្រី ឆ្អើរសាច់ ឆ្អើរនំ ឆ្អើរម្ទេស ជាដើម។**

**ឧ.ម្ដាយខ្ញុំយកចង្កើរទៅឆ្អើរត្រី។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **សង្ហា សង្ខាតសិក្សាមិនបង្អង់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **សង្ហា/ សង្ខាត/សិក្សា/មិន/បង្អង់។**

| | |
|---|---|
| គ្រូ | - គ្រូអាន **សង្ហា សង្ខាតសិក្សាមិនបង្អង់** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **សង្ហា សង្ខាតសិក្សាមិនបង្អង់**។ |
| សិស្ស | - សិស្សអានល្បះ **សង្ហា សង្ខាតសិក្សាមិនបង្អង់**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១. តើបង្គួយតោងអ្វី? ហើយ ធ្លាក់ចូលក្នុងអ្វី?**

**២. ពេលឃើញបង្គួយធ្លាក់លើចង្អេរ តើកង្កែបធ្វើដូចម្ដេច?**

**៣. តើកូនគិតថា ហេតុអ្វីបានជាកង្កែបជួយបង្គួយ ពេលវាធ្លាក់ក្នុងចង្អេរ?**

**៤. តើកូនធ្លាប់បានជួយអ្នកណាខ្លះ? ការងារអ្វីខ្លះ? ពេលណា?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **សង្ខារ ស ង ្ខ ា រ** រួចសរសេរ **សង្ខារ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ចង្អេរ ច ង ្អ េ រ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **បង្កើត បង្ខំ អង្សា** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ចង្អេរឫស្សី** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៩៦ | ព្យាង្គតម្រួត ង្គ ង្ឃ ង្រ | ⌚ ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **បង្វែរ កង្ហារ ស្វះស្វែង ស្លាបព្រា ស្បែកជើង។**

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូអាចធ្វើកាយវិការ ពណ៌នា បំផុសសំណួរ បង្ហាញរូបភាព ឬ វត្ថុជាក់ស្ដែងសម្រាប់ពាក្យ **បង្គា មង្ឃុត ពង្រាយ ។**

ក- សូរពាក្យ គង្គា

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **បង្គា។ តើនេះជាអ្វី? (បង្គា)។ គ្រូបន្លឺ បង្គា។**<br>- គ្រូបន្លឺ និងទះដៃតាមព្យាង្គ **បង់** (ទះដៃ) **គា** (ទះដៃ)។ |
| គ្រូនិងសិស្ស | - បន្លឺ និងទះដៃតាមព្យាង្គ **បង់** ( ទះដៃ ) **គា** ( ទះដៃ ) រួមគ្នា។ |
| សិស្ស | - បន្លឺនិងទះដៃតាមព្យាង្គ **បង់** ( ទះដៃ ) **គា** ( ទះដៃ ) រួមគ្នា។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀនសូរនៃពាក្យ បង្គា ខាងលើ ចំពោះពាក្យ មង្ឃុត ពង្រាយ ។

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

- គ្រូសរសេរពាក្យ **បង្គា មង្ឃុត ពង្រាយ** នៅលើក្ដារខៀន។ គ្រូសួរសិស្សថា នៅក្នុងពាក្យនីមួយៗ តើអក្សរណាដែលត្រួតលើគ្នា។ គ្រូសរសេរព្យាង្គតម្រួតនៅក្រោយពាក្យនីមួយៗ **បង្គា [ ង្រ ] ពង្រាយ [ ង្ឃ ] មង្ឃុត [ ង្គ ]** ។

- គ្រូសរសេរ ចំណងជើងមេរៀន **ង្គ ង្ឃ ង្រ** លើក្ដារខៀន រួចនាំសិស្សអនុវត្តតាម ៣ជំហាន៖

| | |
|---|---|
| គ្រូ | - អានម្ដងមួយៗ **[ង ជើង គ] [ង ជើង ឃ] [ង ជើង រ] ង្គ ង្ឃ ង្រ។** |
| គ្រូ និងសិស្ស | - អានរួមគ្នាម្ដងមួយៗ **[ង ជើង គ] [ង ជើង ឃ] [ង ជើង រ] ង្គ ង្ឃ ង្រ។** |
| សិស្ស | - អានម្ដងមួយៗ **[ង ជើង គ] [ង ជើង ឃ] [ង ជើង រ] ង្គ ង្ឃ ង្រ។** |

**៣- ការអានពាក្យ** ⌚ ១៨នាទី

-គ្រូប្រាប់សិស្សថាសម្រាប់ការអានព្យាង្គតម្រួត យើងត្រូវអានដោយប្រកបព្យញ្ជនៈទី១ និងព្យញ្ជនៈទី២ ហើយសូរអាន បន្លឺដូចបន្តក់ដែរ។ ចំណែកឯជើងព្យញ្ជនៈ ដែលស្ថិតនៅក្រោមព្យញ្ជនៈទី ២ ត្រូវផ្សំប្រកបអានដូចជាតួព្យញ្ជនៈដែរ។

| | |
|---|---|
| គ្រូ | - អាន **បង្គា** លើក្ដារខៀនដោយផ្សំប្រកបថា **ប និង ង បង់ គអា គា បង្គា**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **បង្គា** លើក្ដារខៀនដោយផ្សំប្រកប។ |
| សិស្ស | - អាន **បង្គា** លើក្ដារខៀនដោយផ្សំប្រកប។ |

-អនុវត្តដូចពាក្យ បង្គា ចំពោះពាក្យ មង្ឃុត ពង្រាយ។

-សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។

**៤- វាក្យសព្ទ** ⌚ ៨នាទី

ក- បង្គី

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **បង្គី មានន័យថា កញ្ច្រែងមានដៃសម្រាប់រែកដី, កើបសំរាម ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ បង្គី។ ឧ. រាល់ព្រឹកពូសំយកបង្គីទៅកើបអាចម៍គោ។** |
| គ្រូនិងសិស្ស | - អានពាក្យ **បង្គី** រួមគ្នា។ គ្រូផ្ដើម **តារាយក ... ដាក់សំរាម។** សិស្សថា **បង្គី** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **បង្គី** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **បង្គី** ជាដៃគូ។ |

ខ- សង្ឃឹម បង្រៀនដូចពាក្យខាងលើ។ **សង្ឃឹម មានន័យថា គិតទុកថានឹងបានសម្រេចដូចបំណង។**

**ឧ.លោកគ្រូសង្ឃឹមថាកូនៗចេះអានអត្ថបទទាំងអស់គ្នា។**

## ៥- ការអានល្បះ ⏲ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **កឹមអង្គុយក្នុងអង្រឹង**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **កឹម/អង្គុយ/ក្នុង/អង្រឹង**។

| | |
|---|---|
| គ្រូ | - គ្រូអាន **កឹមអង្គុយក្នុងអង្រឹង** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **កឹមអង្គុយក្នុងអង្រឹង**។ |
| សិស្ស | - សិស្សអានល្បះ **កឹមអង្គុយក្នុងអង្រឹង**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⏲ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើចៅស្ទាញដើរទៅណា?**

**២- តើវាអើលជើងជាន់អ្វី?**

**៣- ហេតុអ្វីបានចៅស្ទាញអស់សំណើច?**

**៤- តើកូនត្រូវដើរដូចម្ដេចដើម្បីកុំឱ្យអើល?**

## ៧- ការសរសេរ ⏲ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **បង្គោល** **ប ង ្គ ោ ល** រួចសរសេរ **បង្គោល** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **ជង្គង់** **ជ ង ្គ ង** ់ រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **អង្គុយ មង្ឃុត ពង្រាយ** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **បង្គោលចងអង្រឹង** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⏲ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| មេរៀនទី៩៧ | ព្យាង្គតម្រួត ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ញ | ៨០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ស្វិតស្វាញ សង្ឃឹម ពង្រឹង ចង្អើរ សង្ស័យ** ។

**១- ការស្គាល់សូរអក្សរថ្មី** ៥នាទី

- គ្រូអាចធ្វើកាយវិការ ពណ៌នា បំផុសសំណួរ បង្ហាញរូបភាព ឬវត្ថុជាក់ស្តែងសម្រាប់ពាក្យ **ចិញ្ចៀន កញ្ឆែត ជញ្ជីង បញ្ឈរ កញ្ញា**។

ក- សូរពាក្យ ចិញ្ចៀន

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ចិញ្ចៀន**។ **តើនេះជាអ្វី? (ចិញ្ចៀន)** ។ គ្រូបន្លឺ **ចិញ្ចៀន**។<br>- គ្រូបន្លឺ និងទះដៃតាមព្យាង្គ **ចិញ** (ទះដៃ) **ចៀន** (ទះដៃ)។ |
| គ្រូនិងសិស្ស | - បន្លឺ និងទះដៃតាមព្យាង្គ **ចិញ** (ទះដៃ) **ចៀន** (ទះដៃ) រួមគ្នា។ |
| សិស្ស | - បន្លឺនិងទះដៃតាមព្យាង្គ **ចិញ** (ទះដៃ) **ចៀន** (ទះដៃ) រួមគ្នា។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀនសូរនៃពាក្យ ចិញ្ចៀន ខាងលើ ចំពោះពាក្យ កញ្ឆែត ជញ្ជីង បញ្ឈរ កញ្ញា(ក័ញ-ញ៉ា)។

**២- ការស្គាល់តួអក្សរថ្មី** ៥នាទី

- គ្រូសរសេរពាក្យ **ចិញ្ចៀន កញ្ឆែត ជញ្ជីង បញ្ឈរ កញ្ញា** នៅលើក្តារខៀន។ គ្រូសួរសិស្សថា នៅក្នុងពាក្យនីមួយៗ តើអក្សរណាដែលត្រួតលើគ្នា។ គ្រូសរសេរព្យាង្គតម្រួតនៅក្រោយពាក្យនីមួយៗ **ចិញ្ចៀន[ ញ្ច ] កញ្ឆែត [ ញ្ឆ ] ជញ្ជីង [ ញ្ជ ] បញ្ឈរ [ ញ្ឈ ] កញ្ញា [ ញ្ញ ]** ។

- គ្រូសរសេរ ចំណងជើងមេរៀន **ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ញ** លើក្តារខៀន រួចនាំសិស្សអនុវត្តតាម ៣ជំហាន៖

| | |
|---|---|
| គ្រូ | - អានម្តងមួយៗ **[ញ ជើង ច ] [ញ ជើង ឆ] [ញ ជើង ជ ] [ញ ជើង ឈ] [ញ ជើង ញ ]**<br>**ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ញ**។ |
| គ្រូ និងសិស្ស | - អានរួមគ្នាម្តងមួយៗ **[ញ ជើង ច ] [ញ ជើង ឆ] [ញ ជើង ជ ] [ញ ជើង ឈ] [ញ ជើង ញ ]**<br>**ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ញ**។ |
| សិស្ស | - អានម្តងមួយៗ **[ញ ជើង ច ] [ញ ជើង ឆ] [ញ ជើង ជ ] [ញ ជើង ឈ] [ញ ជើង ញ ]**<br>**ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ញ**។ |

**៣- ការអានពាក្យ** ១៨នាទី

គ្រូប្រាប់សិស្សថាសម្រាប់ការអានព្យាង្គតម្រួត យើងត្រូវអានដោយប្រកបព្យញ្ជនៈទី១ និងព្យញ្ជនៈទី២ ហើយសូរអាន បន្លឺដូចបន្តក់ដែរ។ ចំណែកឯជើងព្យញ្ជនៈ ដែលស្ថិតនៅក្រោមព្យញ្ជនៈទី ២ ត្រូវផ្សំប្រកបអានដូចជាតួព្យញ្ជនៈដែរ។

| | |
|---|---|
| គ្រូ | - អាន **ចិញ្ចៀន** លើក្តារខៀនដោយផ្សំប្រកបថា **ច អិ ចិ និង ញ ចិញ ច អៀ ចៀ និង ន ចៀន ចិញ្ចៀន** ។ |
| គ្រូនិងសិស្ស | -អានរួមគ្នា **ចិញ្ចៀន** ម្តងមួយៗលើក្តារខៀនដោយផ្សំប្រកប។ |
| សិស្ស | -អាន **ចិញ្ចៀន** លើក្តារខៀនដោយផ្សំប្រកប។ |

-អនុវត្តដូចពាក្យ ចិញ្ចៀន ចំពោះពាក្យ កញ្ឆែត ជញ្ជីង បញ្ឈរ កញ្ញា(ក័ញ-ញ៉ា)។

-សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- ជញ្ជូន

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ជញ្ជូន មានន័យថា នាំយកអ្វីពីកន្លែងមួយទៅកន្លែងមួយទៀត។ ឧ.ថ្ងៃនេះសិស្សថ្នាក់ទី៦នាំគ្នាជញ្ជូនកៅអីទៅបន្ទប់ប្រជុំ។** |
| គ្រូនិងសិស្ស | - អានពាក្យ **ជញ្ជូន** រួមគ្នា។ គ្រូផ្ដើម **ស្រមោច..........ចំណីទៅសម្បុកវា។** សិស្សថា **ជញ្ជូន** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ជញ្ជូន** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ជញ្ជូន** ជាដៃគូ។ |

ខ- បញ្ជី បង្រៀនដូចពាក្យខាងលើ។ **បញ្ជី មានន័យថា កំណត់ដែលកត់ឈ្មោះ។ ឧ. ក្រដាសនៅលើជញ្ជាំងនេះគឺជាបញ្ជីឈ្មោះសិស្សថ្នាក់ទី១ក។**

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **នំបញ្ចុកដាក់កញ្ឆែតមានរសជាតិឆ្ងាញ់។** គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **នំបញ្ចុក/ដាក់/កញ្ឆែត/មាន/រសជាតិ/ឆ្ងាញ់។**

| | |
|---|---|
| គ្រូ | - គ្រូអាន **នំបញ្ចុកដាក់កញ្ឆែតមានរសជាតិឆ្ងាញ់ ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **នំបញ្ចុកដាក់កញ្ឆែតមានរសជាតិឆ្ងាញ់។** |
| សិស្ស | - សិស្សអានល្បះ **នំបញ្ចុកដាក់កញ្ឆែតមានរសជាតិឆ្ងាញ់។** សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⌚ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើឪពុកកញ្ញាលក់អ្វីខ្លះ?**

**២- តើកញ្ញាជួយជញ្ជូនអ្វីខ្លះ?**

**៣- តើកញ្ញាជាកូនស្រីដូចម្ដេច?**

**៤- តើគេប្រើប្រាស់កញ្ឆើ សម្រាប់ធ្វើអ្វីខ្លះ?**

## ៧- ការសរសេរ ⌚ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ចិញ្ចឹម ច ិ ញ ្ច ឹ ម** រួចសរសេរ **ចិញ្ចឹម** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **បញ្ឆោត ប ញ ្ឆ ោ ត** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ជញ្ជីង បញ្ចេញ បញ្ឈប់** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **បញ្ឈរក្បែរជញ្ជាំង** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⌚ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី៩៨ | ព្យាង្គតម្រួត ណ្ដ ណ្ឋ ណ្ឌ | ៨០នាទី |
| --- | --- | --- |

## លំនឹងថ្នាក់ និងរំឭកមេរៀន (៥នាទី)

- គ្រូរំឭកពាក្យដែលបានរៀនរួច **បង្ហាញ អង្គុយ សង្ឃឹម បញ្ឈរ ជញ្ជីង ។**

## ១- ការស្គាល់សូរអក្សរថ្មី (៥នាទី)

- គ្រូអាចធ្វើកាយវិការ ពណ៌នា បំផុសសំណួរ បង្ហាញរូបភាព ឬវត្ថុជាក់ស្ដែងសម្រាប់ពាក្យ **អណ្ដាត បណ្ឋៃ សណ្ឌាន។**

ក- សូរពាក្យ អណ្ដាត

| | |
| --- | --- |
| គ្រូ | - គ្រូបំផុសរកពាក្យ **អណ្ដាត។ តើនេះជាអ្វី? (អណ្ដាត)។** គ្រូបន្លឺ **អណ្ដាត។**<br>- គ្រូបន្លឺ និងទះដៃតាមព្យាង្គ **អណ៌** (ទះដៃ) **ដាត** (ទះដៃ)។ |
| គ្រូនិងសិស្ស | - បន្លឺ និងទះដៃតាមព្យាង្គ **អណ៌** (ទះដៃ) **ដាត** (ទះដៃ) រួមគ្នា។ |
| សិស្ស | - បន្លឺនិងទះដៃតាមព្យាង្គ **អណ៌** (ទះដៃ) **ដាត** (ទះដៃ) រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរនៃពាក្យ អណ្ដាត ខាងលើ ចំពោះពាក្យ បណ្ឋៃ សណ្ឌាន។

## ២- ការស្គាល់តួអក្សរថ្មី (៥នាទី)

- គ្រូសរសេរពាក្យ **អណ្ដាត បណ្ឋៃ សណ្ឌាន** នៅលើក្ដារខៀន។ គ្រូសួរសិស្សថា នៅក្នុងពាក្យនីមួយៗ តើអក្សរណាដែលត្រួតលើគ្នា។ គ្រូសរសេរព្យាង្គតម្រួតនៅក្រោយពាក្យនីមួយៗ **អណ្ដាត[ ណ្ដ ] បណ្ឋៃ [ ណ្ឋ ] សណ្ឌាន [ ណ្ឌ ]**
- គ្រូសរសេរ ចំណងជើងមេរៀន **ណ្ដ ណ្ឋ ណ្ឌ** លើក្ដារខៀន រួចនាំសិស្សអនុវត្តតាម ៣ជំហាន៖

| | |
| --- | --- |
| គ្រូ | - អានម្ដងមួយៗ **[ណ ជើង ដ ] [ណ ជើង ឋ ] [ណ ជើង ឌ ] ណ្ដ ណ្ឋ ណ្ឌ។** |
| គ្រូ និងសិស្ស | - អានរួមគ្នាម្ដងមួយៗ **[ណ ជើង ដ ] [ណ ជើង ឋ ] [ណ ជើង ឌ ] ណ្ដ ណ្ឋ ណ្ឌ។** |
| សិស្ស | - អានម្ដងមួយៗ **[ណ ជើង ដ ] [ណ ជើង ឋ ] [ណ ជើង ឌ ] ណ្ដ ណ្ឋ ណ្ឌ។** |

## ៣- ការអានពាក្យ (១៨នាទី)

| | |
| --- | --- |
| គ្រូ | - អាន **អណ្ដាត** លើក្ដារខៀនដោយផ្សំប្រកបថា **អ និង ណ អណ៌ ដ អា ដា និង ត ដាត អណ្ដាត។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **អណ្ដាត** លើក្ដារខៀនដោយផ្សំប្រកប។ |
| សិស្ស | - អាន **អណ្ដាត** លើក្ដារខៀនដោយផ្សំប្រកប។ |

-អនុវត្តដូចពាក្យ អណ្ដាត ចំពោះពាក្យ បណ្ឋៃ សណ្ឌាន ។

-សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។

## ៤- វាក្យសព្ទ (៨នាទី)

ក- បណ្ណាល័យ

| | |
| --- | --- |
| គ្រូ | - ពន្យល់ពាក្យ **បណ្ណាល័យ**(ប៉ុន-ណា-ល៉ៃ) មានន័យថា **ផ្ទះ ឬទីកន្លែងសម្រាប់តម្កល់ទុកនូវសៀវភៅ គម្ពីរ ក្បួនច្បាប់ផ្សេងៗ។ ឧ : សិស្សទាំងអស់គួរខ្ចីសៀវភៅពីបណ្ណាល័យ ទៅអានឱ្យបានញឹកញាប់។** |
| គ្រូនិងសិស្ស | - អានពាក្យ **បណ្ណាល័យ** រួមគ្នា។ គ្រូផ្ដើម **ខ្ញុំចូលចិត្តអានសៀវភៅរឿងនៅ............។**<br>សិស្សថា **បណ្ណាល័យ** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **បណ្ណាល័យ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **បណ្ណាល័យ** ជាដៃគូ។ |

ខ- បណ្ណាគារ បង្រៀនដូចពាក្យខាងលើ។ **បណ្ណាគារ (ប៉ុន-ណា-គារ)** មានន័យថា **ផ្ទះឬទីកន្លែងសម្រាប់ដាក់លក់សៀវភៅ គម្ពីរ ក្បួនច្បាប់ផ្សេងៗ។ ឧ : បណ្ណាគារនៅក្បែរសាលារៀនយើង មានលក់សៀវភៅច្រើនប្រភេទ។**

## ៥- ការអានល្បះ 🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **យើងនាំគ្នាអានសៀវភៅនៅបណ្ណាល័យ**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **យើង/នាំ/គ្នា/អាន/សៀវភៅ/នៅ/បណ្ណាល័យ**។

| | |
|---|---|
| គ្រូ | - គ្រូអាន **យើងនាំគ្នាអានសៀវភៅនៅបណ្ណាល័យ ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **យើងនាំគ្នាអានសៀវភៅនៅបណ្ណាល័យ**។ |
| សិស្ស | - សិស្សអានល្បះ **យើងនាំគ្នាអានសៀវភៅនៅបណ្ណាល័យ**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី 🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើកណ្តូបបបួលសត្វអ្វីខ្លះទៅបណ្ណាល័យ?**

**២- តើអណ្តើករស់នៅឯណា?**

**៣- តើកូនគិតថា ជាពួកវាទៅបណ្ណាល័យដើម្បីធ្វើអ្វី?**

**៤- តើសៀវភៅអ្វីខ្លះដែលកូនចូលចិត្តអាននៅបណ្ណាល័យ និងនៅផ្ទះ? ហេតុអ្វី?**

## ៧- ការសរសេរ 🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **កណ្តូប ក ណ ◌្ត ◌ូ ប** រួចសរសេរ **កណ្តូប** លើក្តារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **កណ្តុរ ក ណ ◌្ត ◌ុ រ** រួចគ្រូសរសេរលើក្តារខៀន។ សិស្សសរសេរលើក្តារឆ្នួន។ |
| សិស្ស | - គ្រូថា **បណ្ណាល័យ អណ្តើក សណ្ឋាគារ** ម្តងមួយពាក្យៗ។ សិស្សគិតនិងថាឮៗរួចសរសេរលើក្តារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្តារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **បណ្ណាល័យថ្មី** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ 🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## មេរៀនទី៩៩ ព្យាង្គតម្រួត ន្យ ន្ធ ន្ល ន្ស ⌚ ៤០នាទី

## លំនឹងថ្នាក់ និងរំឭកមេរៀន ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **បង្គន់ កញ្ចែ កញ្ជើ អណ្ដូង កណ្ដឹង ។**

## ១-ការស្គាល់សូរអក្សរថ្មី ⌚ ៥នាទី

- គ្រូអាចធ្វើកាយវិការ ពណ៌នា បំផុសសំណួរ បង្ហាញរូបភាព ឬវត្ថុជាក់ស្ដែងសម្រាប់ពាក្យ **ពន្យារ បន្ធូរ បន្លែ ទន្សាយ។**

ក- សូរពាក្យ **បន្លែ**

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **ពន្យារ។ តើនេះជាអ្វី? (ពន្យារ)។** គ្រូបន្លឺ **ពន្យារ។**<br>- គ្រូបន្លឺ និងទះដៃតាមព្យាង្គ **ពន់** (ទះដៃ) **យា** (ទះដៃ)។ |
| គ្រូនិងសិស្ស | - បន្លឺ និងទះដៃតាមព្យាង្គ **ពន់** (ទះដៃ) **យា** (ទះដៃ) រួមគ្នា។ |
| សិស្ស | - បន្លឺនិងទះដៃតាមព្យាង្គ **ពន់** (ទះដៃ) **យា** (ទះដៃ) រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរនៃពាក្យ ពន្យារ ខាងលើ ចំពោះពាក្យ បន្ធូរ បន្លែ ទន្សាយ។

## ២- ការស្គាល់តួអក្សរថ្មី ⌚ ៥នាទី

- គ្រូសរសេរពាក្យ **ពន្យារ បន្ធូរ បន្លែ ទន្សាយ** នៅលើក្ដារខៀន។ គ្រូសួរសិស្សថា នៅក្នុងពាក្យនីមួយៗ តើអក្សរណាដែលត្រួតលើគ្នា។ គ្រូសរសេរព្យាង្គតម្រួតនៅក្រោយពាក្យនីមួយៗ **ពន្យារ [ ន្យ ] បន្ធូរ [ ន្ធ ] បន្លែ [ ន្ល ] ទន្សាយ [ ន្ស ]**

- គ្រូសរសេរ ចំណងជើងមេរៀន **ន្យ ន្ធ ន្ល ន្ស** លើក្ដារខៀន រួចនាំសិស្សអនុវត្តតាម ៣ជំហាន៖

| | |
|---|---|
| គ្រូ | - អានម្ដងមួយៗ **[ន ជើង យ ] [ន ជើង ធ ] [ន ជើង ល ] [ន ជើង ស ]** ន្យ ន្ធ ន្ល ន្ស។ |
| គ្រូ និងសិស្ស | - អានរួមគ្នាម្ដងមួយៗ **[ន ជើង យ ] [ន ជើង ធ ] [ន ជើង ល ] [ន ជើង ស ]** ន្យ ន្ធ ន្ល ន្ស។ |
| សិស្ស | - អានម្ដងមួយៗ **[ន ជើង យ ] [ន ជើង ធ ] [ន ជើង ល ] [ន ជើង ស ]** ន្យ ន្ធ ន្ល ន្ស។ |

## ៣- ការអានពាក្យ ⌚ ១៨នាទី

| | |
|---|---|
| គ្រូ | - អាន **ពន្យារ** ម្ដងមួយៗលើក្ដារខៀនដោយផ្សំប្រកបថា **ព និង ន ពន់ យ អា យា និង រ យារ ពន្យារ ។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពន្យារ** លើក្ដារខៀនដោយផ្សំប្រកប។ |
| សិស្ស | - អាន **ពន្យារ** លើក្ដារខៀនដោយផ្សំប្រកប។ |

-អនុវត្តដូចពាក្យ ពន្យារ ចំពោះពាក្យ បន្ធូរ បន្លែ ទន្សាយ ។

-សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។

## ៤- វាក្យសព្ទ ⌚ ៨នាទី

ក- សន្សើម

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **សន្សើម មានន័យថា តំណក់ទឹកជាល្អងដែលធ្លាក់ចុះពីផ្ទៃអាកាស។ ឧ. ពេលខែរងារមានសន្សើមធ្លាក់លើស្មៅ។** |
| គ្រូនិងសិស្ស | - អានពាក្យ **សន្សើម** រួមគ្នា។ គ្រូផ្ដើម **ខ្ញុំឃើញទឹក ... នៅលើស្លឹកចេកនៅពេលព្រឹក។** សិស្សថា **សន្សើម** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **សន្សើម** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **សន្សើម** ជាដៃគូ។ |

ខ- សន្យា បង្រៀនដូចពាក្យខាងលើ **សន្យា មានន័យថា សេចក្ដីប្ដេជ្ញានឹងធ្វើអ្វីមួយ។ ឧ. អ្នកគ្រូសន្យានឹងអានសៀវភៅរឿងមួយក្បាលឱ្យចប់ក្នុងរយៈពេល៣ខែ។**

## ៥- ការអានល្បះ 🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ទន្សាយស៊ីបន្លែនិងផឹកទឹកសន្សើម**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ទន្សាយ/ស៊ី/បន្លែ/និង/ផឹក/ទឹកសន្សើម**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ទន្សាយស៊ីបន្លែនិងផឹកទឹកសន្សើម** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ទន្សាយស៊ីបន្លែនិងផឹកទឹកសន្សើម**។ |
| សិស្ស | - សិស្សអានល្បះ **ទន្សាយស៊ីបន្លែនិងផឹកទឹកសន្សើម**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី 🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើទន្សាយផឹកទឹកអ្វី?**

**២- តើក្នុងរឿងនេះមានសត្វអ្វីខ្លះ?**

**៣- តើកូនគិតថា សត្វកន្ធាយទៅផឹកទឹកទន្លេតាមទន្សោង និងទន្សាយដែរឬទេ? ព្រោះអ្វី?**

**៤- បើមានគេបបួលកូនទៅទីណាមួយ កូនធ្វើដូចម្តេចមុននឹងសម្រេចចិត្តទៅ?**

## ៧- ការសរសេរ 🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ពន្លឺ** **ព ន ◌្ល ◌ឺ** រួចសរសេរ **ពន្លឺ** លើក្តារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **អន្សម** **អ ន ◌្ស ម** រួចគ្រូសរសេរលើក្តារខៀន។ សិស្សសរសេរលើក្តារឆ្នួន។ |
| សិស្ស | - គ្រូថា **ទន្សោង បន្ទរ សន្សា** ម្តងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្តារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្តារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ផឹកទឹកសន្សើម** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ 🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| មេរៀនទី១០០ | ព្យាង្គតម្រួត ម្ប ម្ព ម្ភ ម្ម ម្រ ម្ល | ៨០នាទី |
|---|---|---|

## លំនឹងថ្នាក់ និងរំឭកមេរៀន ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ជញ្ជាំង អណ្តើក បណ្ណាល័យ បន្ទូរ បន្លែ។**

## ១- ការស្គាល់សូរអក្សរថ្មី ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងទះដៃតាមចំនួនសូរព្យាង្គនៃពាក្យ។

ក- សូរពាក្យ សម្បក

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **សម្បក**។ **តើនេះជាអ្វី? (សម្បក)**។ គ្រូបន្លឺ **សម្បក។**<br>- គ្រូបន្លឺ និងទះដៃតាមព្យាង្គ **សម់** (ទះដៃ) **បក** (ទះដៃ)។ |
| គ្រូនិងសិស្ស | - បន្លឺ និងទះដៃតាមព្យាង្គ **សម់** (ទះដៃ) **បក** (ទះដៃ) រួមគ្នា។ |
| សិស្ស | - បន្លឺនិងទះដៃតាមព្យាង្គ **សម់** (ទះដៃ) **បក** (ទះដៃ) រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរនៃពាក្យ សម្បក ខាងលើ ចំពោះពាក្យ កុម្ភៈ កម្ពុជា ចម្រៀង ចម្លើយ កម្មករ(កាំ-មៈ-ករ)។

## ២- ការស្គាល់តួអក្សរថ្មី ៥នាទី

- គ្រូសរសេរពាក្យ **សម្បក កុម្ភៈ កម្ពុជា ចម្រៀង ចម្លើយ កម្មករ** នៅលើក្តារខៀន។ គ្រូសួរសិស្សថា នៅក្នុងពាក្យនីមួយៗ តើអក្សរណាដែលត្រួតលើគ្នា។ គ្រូសរសេរព្យាង្គតម្រួតនៅក្រោយពាក្យនីមួយៗ **សម្បក [ ម្ប ] កុម្ភៈ [ ម្ភ ] កម្ពុជា [ ម្ព ] ចម្រៀង [ ម្រ ]ចម្លើយ ] ម្ល [ កម្មករ [ ម្ម ]**។

- គ្រូសរសេរ ចំណងជើងមេរៀន **ម្ប ម្ព ម្ភ ម្ម ម្រ ម្ល** លើក្តារខៀន រួចនាំសិស្សអនុវត្តតាម ៣ជំហាន៖

| | |
|---|---|
| គ្រូ | - អានម្តងមួយៗ **[ម ជើង ប] [ម ជើង ព] [ម ជើង ភ] [ម ជើង ម] [ម ជើង រ ] [ម ជើង ល] ម្ប ម្ព ម្ភ ម្ម ម្រ ម្ល ។** |
| គ្រូ និងសិស្ស | - អានរួមគ្នាម្តងមួយៗ **[ម ជើង ប] [ម ជើង ព] [ម ជើង ភ] [ម ជើង ម] [ម ជើង រ ] [ម ជើង ល] ម្ប ម្ព ម្ភ ម្ម ម្រ ម្ល ។** |
| សិស្ស | - អានម្តងមួយៗ **[ម ជើង ប] [ម ជើង ព] [ម ជើង ភ] [ម ជើង ម] [ម ជើង រ ] [ម ជើង ល] ម្ប ម្ព ម្ភ ម្ម ម្រ ម្ល ។** |

## ៣- ការអានពាក្យ ១៨នាទី

គ្រូប្រាប់សិស្សថាសម្រាប់ការអានព្យាង្គតម្រួត យើងត្រូវអានដោយប្រកបព្យញ្ជនៈទី១ និងព្យញ្ជនៈទី២ ហើយសូរអាន បន្លឺដូចបន្តក់ដែរ។ ចំណែកឯជើងព្យញ្ជនៈ ដែលស្ថិតនៅក្រោមព្យញ្ជនៈទី ២ ត្រូវផ្សំប្រកបអានដូចជាតួព្យញ្ជនៈដែរ។

| | |
|---|---|
| គ្រូ | - អាន **សម្បក** លើក្តារខៀនដោយផ្សំប្រកបថា **ស និង ម សំ ប និង ក បក សម្បក**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **សម្បក** លើក្តារខៀនដោយផ្សំប្រកប។ |
| សិស្ស | - អាន **សម្បក** លើក្តារខៀនដោយផ្សំប្រកប។ |

-អនុវត្តដូចពាក្យ សម្បក ចំពោះពាក្យ កុម្ភៈ កម្ពុជា ចម្រៀង ចម្លើយ កម្មករ(កាំ-មៈ-ករ)។

-សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។

## ៤- វាក្យសព្ទ ⏲ ៨នាទី

ក- សម្បូរ

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **សម្បូរ មានន័យថា ពេញពាស គគោក។ ឧ. ស្រុកយើងឥឡូវសម្បូរម៉ូតូ និងឡាន។** |
| គ្រូនិងសិស្ស | - អានពាក្យ **សម្បូរ** រួមគ្នា។ គ្រូផ្ដើម**បណ្ណាល័យយើង.............. សៀវភៅរឿង**។ សិស្សថា **សម្បូរ** រួចថាល្បះ **ពេញលេញរួមគ្នា**។ |
| សិស្ស | - អានពាក្យ **សម្បូរ** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **សម្បូរ** ជាដៃគូ។ |

ខ- សម្បត្តិ បង្រៀនដូចពាក្យខាងលើ។ **សម្បត្តិ មានន័យថា : ទ្រព្យ ធនធាន។ ឧ: បូផាមានសម្បត្តិច្រើនដូចជា កង់ ម៉ូតូ ផ្ទះ ស្រែ ចម្ការ។ល។**

## ៥- ការអានល្បះ ⏲ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **សម្លៀកបំពាក់ខ្ញុំស្អាតណាស់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **សម្លៀកបំពាក់/ខ្ញុំ/ស្អាត/ណាស់**។

| | |
|---|---|
| គ្រូ | - គ្រូអាន **សម្លៀកបំពាក់ខ្ញុំស្អាតណាស់** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **សម្លៀកបំពាក់ខ្ញុំស្អាតណាស់**។ |
| សិស្ស | - សិស្សអានល្បះ **សម្លៀកបំពាក់ខ្ញុំស្អាតណាស់**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ⏲ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើប្រទេសកម្ពុជាយើងសម្បូរអ្វី?**

**២- តើប្រទេសកម្ពុជានាំអ្វីខ្លះទៅលក់នៅក្រៅប្រទេស?**

**៣- តើអ្វីខ្លះដែលជួយលើកកម្ពស់ជីវភាពប្រជាជនយើង?**

**៤- តើសមាជិកគ្រួសារកូនប្រកបមុខរបរអ្វីខ្លះ? ហើយកូនស្រឡាញ់មុខរបរអ្វីខ្លះ?**

## ៧- ការសរសេរ ⏲ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **កម្រិត ក ម ្រ ិ ត** រួចសរសេរ **កម្រិត** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **កម្លាំង ក ម ្ល ា ំ ង** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ជម្ងួ សម្បត្តិ សម្លាញ់** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **អ៊ុតសម្លៀកបំពាក់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ⏲ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## មេរៀនទី១០១ ព្យាង្គតម្រួត ង្រ ង្គ្រ ៨០នាទី

### លំនឹងថ្នាក់ និងរំឭកមេរៀន ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **អណ្ដើក សន្សំ ទន្សាយ កម្លាំង សម្លៀកបំពាក់** ។

### ១- ការស្គាល់សូរអក្សរថ្មី ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្ដែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងទះដៃតាមចំនួនសូរព្យាង្គនៃពាក្យ។

ក- សូរពាក្យ អង្រ្កង

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **អង្រ្កង។ នេះជាសត្វអ្វី? (អង្រ្កង)**។ គ្រូបន្លឺ **អង្រ្កង។**<br>- គ្រូបន្លឺ និងទះដៃតាមព្យាង្គ **អង់** (ទះដៃ) **ក្រង** (ទះដៃ)។ |
| គ្រូនិងសិស្ស | - បន្លឺ និងទះដៃតាមព្យាង្គ **អង់** (ទះដៃ) **ក្រង** (ទះដៃ) រួមគ្នា។ |
| សិស្ស | - បន្លឺនិងទះដៃតាមព្យាង្គ **អង់** (ទះដៃ) **ក្រង** (ទះដៃ) រួមគ្នា។ |

ខ-គ្រូអនុវត្តដូចលំនាំបង្រៀនសូរនៃពាក្យ អង្រ្កង ខាងលើ ចំពោះពាក្យ សង្រ្គោះ។

### ២- ការស្គាល់តួអក្សរថ្មី ៥នាទី

- គ្រូសរសេរពាក្យ **អង្រ្កង សង្រ្គោះ** នៅលើក្ដារខៀន។ គ្រូសួរសិស្សថា នៅក្នុងពាក្យនីមួយៗ តើអក្សរណាដែលត្រួតលើគ្នា។ គ្រូសរសេរព្យាង្គតម្រួតនៅក្រោយពាក្យនីមួយៗ **អង្រ្កង [ ង្រ្ក ] សង្រ្គោះ។ [ ង្រ្គ ]**
- គ្រូសរសេរ ចំណងជើងមេរៀន **ង្រ្ក ង្រ្គ** លើក្ដារខៀន រួចនាំសិស្សអនុវត្តតាម ៣ជំហាន៖

| | |
|---|---|
| គ្រូ | - អានម្ដងមួយៗ **[ង ជើង ក ជើង រ ] [ង ជើង គ ជើង រ] ង្រ្ក ង្រ្គ។** |
| គ្រូ និងសិស្ស | - អានរួមគ្នាម្ដងមួយៗ **[ង ជើង ក ជើង រ ] [ង ជើង គ ជើង រ] ង្រ្ក ង្រ្គ។** |
| សិស្ស | - អានម្ដងមួយៗ **[ង ជើង ក ជើង រ ] [ង ជើង គ ជើង រ ] ង្រ្ក ង្រ្គ។** |

### ៣- ការអានពាក្យ ១៨នាទី

| | |
|---|---|
| គ្រូ | - អាន **អង្រ្កង** ម្ដងមួយៗលើក្ដារខៀនដោយផ្សំប្រកបថា **អ និង ង អង់ ក ជើង ្រ ក្រ និង ង ក្រង អង្រ្កង។** |
| គ្រូនិងសិស្ស | - អានរួមគ្នា **អង្រ្កង** លើក្ដារខៀនដោយផ្សំប្រកប។ |
| សិស្ស | - អាន **អង្រ្កង** លើក្ដារខៀនដោយផ្សំប្រកប។ |

-អនុវត្តដូចពាក្យ អង្រ្កង ចំពោះពាក្យ សង្រ្គោះ។

-សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។

### ៤- វាក្យសព្ទ ៨នាទី

ក- បង្រ្កាប

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **បង្រ្កាប មានន័យថា ធ្វើឱ្យក្រាប, ឱ្យរាប, ឱ្យបាក់បប។ ឧ. ម្សិលមិញ កងនគរបាលបង្រ្កាបចោរឆក់។** |
| គ្រូនិងសិស្ស | - អានពាក្យ **បង្រ្កាប** រួមគ្នា។ គ្រូផ្ដើម **ប៉ូលិស ....ចោរលួច។** សិស្សថា **ប៉ូលិស** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **ប៉ូលិស** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ប៉ូលិស** ជាដៃគូ។ |

ខ- បង្រ្គប់ បង្រៀនដូចពាក្យខាងលើ។ **បង្រ្គប់ មានន័យថា ធ្វើឱ្យគ្រប់ បន្ថែមឱ្យគ្រប់។** ឧ : **ប្រាំបីដាក់ពីរថែមទៀតបង្រ្គប់ដប់។**

## ៥- ការអានល្បះ 🕒 ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ពូសុខដើរគោះអង្រ្កងក្នុងព្រៃអង្រ្កង**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ពូសុខ/ដើរ/គោះ/អង្រ្កង/ក្នុង/ព្រៃ/អង្រ្កង**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ពូសុខ ដើរគោះអង្រ្កងក្នុងព្រៃអង្រ្កង** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ពូសុខ ដើរគោះអង្រ្កងក្នុងព្រៃអង្រ្កង**។ |
| សិស្ស | - សិស្សអានល្បះ **ពូសុខ ដើរគោះអង្រ្កងក្នុងព្រៃអង្រ្កង**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី 🕒 ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើអង្រ្កងឈ្លោះគ្នានៅឯណា?**

**២- តើចាបចង្រ្កង់ចង់ធ្វើអ្វី?ព្រោះអ្វី?**

**៣- តើពូភ្លុកធ្វើដូចម្ដេចទើបយកអង្រ្កងធ្វើម្ហូបបាន?**

**៤- តើគេយកអង្រ្កងធ្វើម្ហូបអ្វីខ្លះ?**

## ៧- ការសរសេរ 🕒 ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **បង្រ្កាប ប ង** ្ក ្រ ា **ប** រួចសរសេរ **បង្រ្កាប** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **សង្រ្គោះ ស ង** ្គ ្រ **ោះ** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **សង្រ្កុប សង្រ្គាម ចង្រ្កាន** ម្ដងមួយពាក្យៗ ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **បញ្ឈប់សង្រ្គាម** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ 🕒 ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| មេរៀនទី១០២ | ព្យាង្គតម្រួត ញ្រ ញ្ជ្រ | ⌚ ៤០នាទី |
|---|---|---|

**លំនឹងថ្នាក់ និងរំឭកមេរៀន** ⌚ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **បន្លយ សម្លាញ់ កម្មករ សង្គ្រោះ ចង្ក្រាន។**

**១- ការស្គាល់សូរអក្សរថ្មី** ⌚ ៥នាទី

- គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ បន្លឺពាក្យ និងទះដៃតាមចំនួនសូរព្យាង្គនៃពាក្យ។

ក- សូរពាក្យ កញ្ច្រែង

| | |
|---|---|
| គ្រូ | - គ្រូបំផុសរកពាក្យ **កញ្ច្រែង។ តើនេះជាអ្វី? (កញ្ច្រែង)។** គ្រូបន្លឺ **កញ្ច្រែង។**<br>- គ្រូបន្លឺ និងទះដៃតាមព្យាង្គ **កញ់** (ទះដៃ) **ច្រែង** (ទះដៃ)។ |
| គ្រូនិងសិស្ស | - បន្លឺ និងទះដៃតាមព្យាង្គ **កញ់** (ទះដៃ) **ច្រែង** (ទះដៃ) រួមគ្នា។ |
| សិស្ស | - បន្លឺនិងទះដៃតាមព្យាង្គ **កញ់** (ទះដៃ) **ច្រែង** (ទះដៃ) រួមគ្នា។ |

ខ- គ្រូអនុវត្តដូចលំនាំបង្រៀនសូរនៃពាក្យ កញ្ច្រែង ខាងលើ ចំពោះពាក្យ កញ្ជ្រោង។

**២- ការស្គាល់តួអក្សរថ្មី** ⌚ ៥នាទី

- គ្រូសរសេរពាក្យ **កញ្ច្រែង កញ្ជ្រោង** នៅលើក្តារខៀន។ គ្រូសួរសិស្សថា នៅក្នុងពាក្យនីមួយៗ តើអក្សរណាដែលត្រួតលើគ្នា។ គ្រូសរសេរព្យាង្គតម្រួតនៅក្រោយពាក្យនីមួយៗ **កញ្ច្រែង [ ញ្ច្រ ] កញ្ជ្រោង។ [ ញ្ជ្រ ]**
- គ្រូសរសេរ ចំណងជើងមេរៀន **ញ្ច្រ ញ្ជ្រ** លើក្តារខៀន រួចនាំសិស្សអនុវត្តតាម ៣ជំហាន៖

| | |
|---|---|
| គ្រូ | - អានម្តងមួយៗ **[ញ ជើង ច ជើង រ] [ញ ជើង ជ ជើង រ] ញ្ច្រ ញ្ជ្រ។** |
| គ្រូ និងសិស្ស | - អានរួមគ្នាម្តងមួយៗ **[ញ ជើង ច ជើង រ] [ញ ជើង ជ ជើង រ] ញ្ច្រ ញ្ជ្រ។** |
| សិស្ស | - អានម្តងមួយៗ **[ញ ជើង ច ជើង រ] [ញ ជើង ជ ជើង រ] ញ្ច្រ ញ្ជ្រ។** |

**៣- ការអានពាក្យ** ⌚ ១៨នាទី

| | |
|---|---|
| គ្រូ | - អាន **កញ្ច្រែង** លើក្តារខៀនដោយផ្សំប្រកបថា **ក និង ញ កញ់ ច ជើង ្រ ច្រ ច្រ អែ ច្រែ ច្រែ និង ង ច្រែង កញ្ច្រែង** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **កញ្ច្រែង** លើក្តារខៀនដោយផ្សំប្រកប។ |
| សិស្ស | - អាន **កញ្ច្រែង** លើក្តារខៀនដោយផ្សំប្រកប។ |

-អនុវត្តដូចពាក្យ កញ្ច្រែង ចំពោះពាក្យ កញ្ជ្រោង។

-សិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ។

**៤- វាក្យសព្ទ** ⌚ ៨នាទី

ក- កញ្ច្រឹក

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **កញ្ច្រឹក មានន័យថា ដែលមានមាឌតូចទាប។ ឱ. អាគីផ្អែខ្ញុំតូចកញ្ច្រឹក។** |
| គ្រូនិងសិស្ស | - អានពាក្យ **កញ្ច្រឹក** រួមគ្នា។ គ្រូផ្តើម **ប្អូនខ្ញុំមានរាងតូច** ...។ សិស្សថា **កញ្ច្រឹក** រួចថាល្បះពេញលេញរួមគ្នា។ |
| សិស្ស | - អានពាក្យ **កញ្ច្រឹក** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **កញ្ច្រឹក** ជាដៃគូ។ |

ខ- កញ្ជ្រៀវ បង្រៀនដូចពាក្យខាងលើ។ **កញ្ជ្រៀវ មានន័យថា ស្រែកខ្សៀវខ្សារ។ ឱ : សេះកញ្ជ្រៀវ។**

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **ផ្អកត្រីកញ្ច្រកមានរសជាតិឆ្ងាញ់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **ផ្អក/ត្រីកញ្ច្រក/មាន/រសជាតិ/ឆ្ងាញ់**។

| | |
|---|---|
| គ្រូ | - គ្រូអាន **ផ្អកត្រីកញ្ច្រកមានរសជាតិឆ្ងាញ់** ។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **ផ្អកត្រីកញ្ច្រកមានរសជាតិឆ្ងាញ់**។ |
| សិស្ស | - សិស្សអានល្បះ **ផ្អកត្រីកញ្ច្រកមានរសជាតិឆ្ងាញ់**។ សិស្សអានល្បះនៅក្នុងសៀវភៅសិក្សាគោល។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង-គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើយាយស៊ុយទិញត្រីអ្វី?**

**២- ហេតុអ្វីបានជាយាយស៊ុយមិនឱ្យបូណាធ្វើការធ្ងន់?**

**៣- តើកូនគិតថា យាយស៊ុយយកត្រីកញ្ច្រកធ្វើអ្វីខ្លះ?**

**៤- តើកូនស្គាល់ត្រីអ្វីខ្លះ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ចិញ្ច្រាំ** ច ◌ិ ញ ◌្ច ◌្រ ◌ាំ រួចសរសេរ **ចិញ្ច្រាំ** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **កញ្ច្រឹល ក ញ ◌្ច ◌្រ ◌ឹ ល** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **ជញ្ជ្រាំង កញ្ជ្រៀវ បញ្ជ្រាស** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **យួរកញ្ច្រែងដើរកាត់ជញ្ជ្រាំង** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# បំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរថ្នាក់ទី១ ប្រចាំឆ្នាំ

| សប្តាហ៍ | ចន្ទ | អង្គារ | ពុធ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|
| ១ | ១រៀនគូសបន្ទាត់. | ១រៀនគូសបន្ទាត់. | ២.ចម្រៀងនិង ៣.ស្រៈ | ២.ចម្រៀងនិង ៣.ស្រៈ | ២.ចម្រៀងនិង ៣.ស្រៈ |
| ២ | ៤ចម្រៀងព្យញ្ជនៈ. | ព្យក ខ . | ព្យច ឆ . | ព្យកខចឆ ផ្សំស្រៈ◌ា . | ព្យិ◌ កខចឆ ផ្សំស្រៈ . |
| ៣ | ព្យី◌ កខចឆ ផ្សំស្រៈ . | ព្យឹ◌ កខចឆ ផ្សំស្រៈ . | ព្យឺ◌ កខចឆ ផ្សំស្រៈ . | ព្យុ◌ កខចឆ ផ្សំស្រៈ . | ព្យូ◌ កខចឆ ផ្សំស្រៈ . |
| ៤ | ព្យួ◌ កខចឆ ផ្សំស្រៈ . | ព្យ .កខចឆ ផ្សំស្រៈ ◌ើ | ព្យកខចឆ ផ្សំស្រៈ ◌ឿ . | ព្យកខចឆ ផ្សំស្រៈ ◌ៀ . | ព្យកខចឆ ផ្សំស្រៈ ◌េ . |
| ៥ | ព្យកខចឆ ផ្សំស្រៈ ◌ែ . | ព្យកខចឆ ផ្សំស្រៈ ◌ៃ . | ព្យកខចឆ ផ្សំស្រៈ ◌ោ . | ព្យកខចឆ ផ្សំស្រៈ ◌ៅ . | ព្យុ◌ កខចឆ ផ្សំស្រៈ ំ |
| ៦ | ព្យំ◌ កខចឆ ផ្សំស្រៈ . | ព្យកខចឆ ផ្សំស្រៈ ◌ា ំ | ព្យកខចឆ ផ្សំស្រៈ ◌ះ . | ព្យកខចឆ ផ្សំស្រៈ◌ុ .ះ | ព្យកខចឆ ផ្សំស្រៈ ◌េ .ះ |
| ៧ | ព្យកខចឆ ផ្សំស្រៈ ◌ោ .ះ | ព្យក ផ្សំស្រៈ . | ព្យខ ផ្សំស្រៈ . | ព្យច ផ្សំស្រៈ . | ព្យឆ ផ្សំស្រៈ . |
| ៨ | សាកខចឆ ផ្សំស្រៈ .ព្យ. | ព្យដ ផ្សំស្រៈ . | ព្យឋ ផ្សំស្រៈ . | ព្យណ ផ្សំស្រៈ . | សាដឋណ ផ្សំស្រៈ .ព្យ. |
| ៩ | ព្យត ផ្សំស្រៈ . | ព្យ ថ .ផ្សំស្រៈ | ព្យប ផ្សំស្រៈ . | ព្យ. ផ ផ្សំស្រៈ | សាតថបផ ផ្សំស្រៈ .ព្យ. |
| ១០ | ព្យសផ្សំស្រៈ . | ព្យហ ផ្សំស្រៈ . | ព្យឡ ផ្សំស្រៈ . | ព្យអ ផ្សំស្រៈ . | សាព្យ សហឡអ ផ្សំស្រៈ. |
| ១១ | ព្យគ ជ . | ព្យទ ល . | ព្យិ◌ គជទលផ្សំស្រៈ ◌ា. | ព្យឹ◌ី ◌ គជទលផ្សំស្រៈ . | ព្យុ◌ឺ ◌ គជទលផ្សំស្រៈ . |
| ១២ | ព្យ .គជទលផ្សំស្រៈ ◌ូ ◌ួ | ព្យគជទលផ្សំស្រៈ ◌ើ ◌ឿ . | ព្យគជទលផ្សំស្រៈ ◌ៀ ◌េ . | ព្យគជទលផ្សំស្រៈ ◌ែ ◌ៃ . | ព្យគជទលផ្សំស្រៈ◌ោ ◌ៅ . |
| ១៣ | ព្យ គជទលផ្សំស្រៈ .◌ុំ ◌ំ | ព្យ គជទលផ្សំស្រៈ .◌ាំ ◌ះ | ព្យគជទលផ្សំស្រៈ.◌ុះ ◌េះ | ព្យគជទលផ្សំស្រៈ ◌ោ .ះ | ព្យគ ផ្សំស្រៈ . |
| ១៤ | ព្យ. ឃ ផ្សំស្រៈ | ព្យង ផ្សំស្រៈ . | ព្យ .ជ ផ្សំស្រៈ | ព្យឈ ផ្សំស្រៈ . | ព្យញ ផ្សំស្រៈ . |
| ១៥ | សាគឃងជឈញផ្សំស្រៈ .ព្យ. | ព្យឌ ផ្សំស្រៈ . | ព្យឍ ផ្សំស្រៈ . | ព្យទ ផ្សំស្រៈ . | ព្យធ ផ្សំស្រៈ . |

| | | | | | |
|---|---|---|---|---|---|
| ១៦ | សាឧឈទធ ផ្សំស្រៈ .ព្យ. | ព្យន ផ្សំស្រៈ . | ព្យព ផ្សំស្រៈ . | ព្យភ ផ្សំស្រៈ . | ព្យម ផ្សំស្រៈ . |
| ១៧ | សានពភម ផ្សំស្រៈ .ព្យ. | ព្យ. យ ផ្សំស្រៈ | ព្យរ ផ្សំស្រៈ . | ព្យល ផ្សំស្រៈ . | ព្យ. វ ផ្សំស្រៈ |
| ១៨ | សាពួក អ៊ ផ្សំស្រៈ .ព្យ. | សាពួក អ និងអ៊ ផ្សំស្រៈ.ព្យ. | ចម្រៀង | ព្យង៉ ផ្សំស្រៈ . | ព្យញ៉ ផ្សំស្រៈ . |
| ១៩ | ព្យប៉ ផ្សំស្រៈ . | ព្យម៉ ផ្សំស្រៈ . | ព្យយ៉ ផ្សំស្រៈ . | ព្យរ៉ ផ្សំស្រៈ . | ព្យវ៉ ផ្សំស្រៈ . |
| ២០ | សាង៉ញ៉ប៉ម៉យ៉រ៉វ៉ ផ្សំស្រៈ .ព្យ. | ព្យប៊ ផ្សំស្រៈ . | ព្យស៊ ផ្សំស្រៈ . | ព្យហ៊ ផ្សំស្រៈ . | ព្យអ៊ ផ្សំស្រៈ . |
| ២១ | សាប៊ស៊ហ៊អ៊ ផ្សំស្រៈ .ព្យ. | មេសូត្ររត់មាត់ | ប្រកបនឹង ក(អ) | ប្រកបនឹង ក់(អ) | ប្រកបនឹង ក(អ៊) |
| ២២ | ប្រកបនឹង ក់(អ៊) | ប្រកបនឹង ង(អ) | ប្រកបនឹង ង់(អ) | ប្រកបនឹង ង(អ៊) | ប្រកបនឹង ង់(អ៊) |
| ២៣ | ប្រកបនឹង ច(អ) | ប្រកបនឹង ច់(អ) | ប្រកបនឹង ច(អ៊) | ប្រកបនឹង ច់(អ៊) | ប្រកបនឹង ញ(អ) |
| ២៤ | ប្រកបនឹង ញ់(អ) | ប្រកបនឹង ញ(អ៊) | ប្រកបនឹង ញ់(អ៊) | ប្រកបនឹង ត(អ) | ប្រកបនឹង ត់(អ) |
| ២៥ | ប្រកបនឹង ត(អ៊) | ប្រកបនឹង ត់(អ៊) | ប្រកបនឹង ន(អ) | ប្រកបនឹង ន់(អ) | ប្រកបនឹង ន(អ៊) |
| ២៦ | ប្រកបនឹង ន់(អ៊) | ប្រកបនឹង ប(អ) | ប្រកបនឹង ប់(អ) | ប្រកបនឹង ប(អ៊) | ប្រកបនឹង ប់(អ៊) |
| ២៧ | ប្រកបនឹង ម(អ) | ប្រកបនឹង ម(អ៊) | ប្រកបនឹង យ(អ) | ប្រកបនឹង យ(អ៊) | ប្រកបនឹង ល(អ) |
| ២៨ | ប្រកបនឹង ល់(អ) | ប្រកបនឹង ល(អ៊) | ប្រកបនឹង ល់(អ៊) | ប្រកបនឹង វ(អ) | ប្រកបនឹង វ(អ៊) |
| ២៩ | ប្រកបនឹង ស(អ) | ប្រកបនឹង ស់(អ) | ប្រកបនឹង ស(អ៊) | ប្រកបនឹង ស់(អ៊) | ស្រៈពេញតួ |
| ៣០ | ស្រៈពេញតួ(ត) | ស្រៈពេញតួ(តចប់) | ព្យនិងជើងព្យញ្ជនៈ. | ព្យ(ត)និងជើងព្យញ្ជនៈ. | ព្យ(តចប់)និងជើងព្យញ្ជនៈ. |
| ៣១ | ផ្ញើជើង ក្ត ក្ប ក្ស ក្អ | ផ្ញើជើង ក្ង ក្ន ក្ម ក្រ ក្ល | ផ្ញើជើង ខ្ញ ខ្ង ខ្ត ខ្ន | ផ្ញើជើង ខ្ម ខ្យ ខ្ល ខ្វ ខ្ស | ផ្ញើជើង គ្ន គ្ម គ្រ |
| ៣២ | ផ្ញើជើង ឃ្ង ឃ្ន ឃ្ម ឃ្ល ឃ្វ | ចម្រៀង | ផ្ញើជើង ច្ប ច្ន ច្យ ច្រ | ផ្ញើជើង ឆ្ក ឆ្ង ឆ្ត ឆ្ន | ផ្ញើជើង ឆ្ម ឆ្ល ឆ្វ ឆ្អ |
| ៣៣ | ផ្ញើជើង ជ្រ ជ្វ | ផ្ញើជើង ឈ្ង ឈ្ន ឈ្ម ឈ្ល ឈ្វ | ផ្ញើជើង ត្ប ត្ម ត្រ | ផ្ញើជើង ថ្ក ថ្ង ថ្ន ថ្ម ថ្ល ថ្វ | ផ្ញើជើង ទ្រ ទ្វ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | | | |
|---|---|---|---|---|---|
| ៣៤ | ផ្ញើជើង ធ្វធ្ន ធ្ម | ផ្ញើជើង ប្ត ប្រ ប្ល ប្អ | ផ្ញើជើង ផ្ក ផ្ញ ផ្ទ ផ្វ | ផ្ញើជើង ផ្គ ផ្ដ ផ្ន ផ្ល ផ្យ ផ្អ | ផ្ញើជើង ព្ន ព្យ ព្រ ព្ល |
| ៣៥ | ផ្ញើជើង ភ្ជ ភ្ឈ ភ្វ ភ្ន ភ្ល | ផ្ញើជើង ម្ក ម្ខ ម្ង ម្ដ | ផ្ញើជើង ម្ជ ម្ឆ ម្វ ម្ទ | ផ្ញើជើង ម្ន ម្ភ ម្យ ម្រ ម្ល | ផ្ញើជើង ល្ខ ល្ប ល្ហ ល្អ |
| ៣៦ | ផ្ញើជើង ស្ក ស្ដ ស្គ ស្ប ស្រ | ផ្ញើជើង ស្ង ស្ន ស្ម ស្ល ស្វ ស្អ | ព្យាង្គតម្រួត ង្ក ង្ខ ង្ង ង្ស ង្ហ ង្អ | ព្យាង្គតម្រួត ង្គ ង្ឃ ង្រ | ព្យាតម្រួត ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ញ. |
| ៣៧ | ព្យាង្គតម្រួត ណ្ដ ណ្ណ ញ្ញ | ព្យាង្គតម្រួត ន្យ ន្ទ ន្ធ ន្ស | ព្យាង្គតម្រួត ម្ប ម្ព ម្ភ ម្ម ម្រ ម្ល | ព្យាង្គតម្រួត ង្ក្រ ង្គ្រ | ព្យាង្គតម្រួត ញ្ច្រ ញ្ជ្រ |
| ៣៨ | អ្នកគ្រូខ្ញុំ | សាលារៀនខ្ញុំ | រំឭក | រំឭក | រំឭក |

**សម្គាល់៖**

១- ចាប់ពីសប្តាហ៍ទី១ដល់ទី២០ ខ្លឹមសារនៅដដែលដូចសៀវភៅណែនាំគ្រូថ្នាក់ទី១ភាគ១(កញ្ចប់អំណានថ្នាក់ដំបូង)

២- ចាប់ពីសប្តាហ៍ទី២១ មានបន្ថែមម៉ោងសិក្សា៥០% (ចំពោះមេរៀនប្រកប)ពី២ទៅ៤ម៉ោងសិក្សា។

៣- ចាប់ពីសប្តាហ៍ទី២១តទៅមិនមានមេរៀនសារឡើងវិញទេ។

៤- ខ្លឹមសារមេរៀនពណ៌ក្រហម គឺជាមេរៀនផ្ដាច់ចេញថ្មី។ ឧ.ប្រកបនឹងក(អ) ផ្ដាច់ចេញពី ក ក់(ពួកអ)។មេរៀនទាំងនេះតម្រូវឱ្យសរសេរអត្ថបទខ្លីបន្ថែម។

# សម្ភារៈបង្រៀននិងរៀនបន្ថែម

## បញ្ជីសម្ភារៈបង្រៀន និងរៀន ជាជម្រើសសម្រាប់ម៉ោងបត់បែន និងការហាត់រៀនបន្ថែម

សម្ភារៈខាងក្រោមនេះ ជាជម្រើសដែលអាចប្រើប្រាស់ក្នុងម៉ោងបត់បែន នៅថ្ងៃព្រហស្បតិ៍ ក្នុងពេលម៉ោងចេញលេង និងម៉ោងបណ្ណាល័យ។

| មេរៀន | សម្ភារៈ | គ្រឹះស្ថានបោះពុម្ព | តម្លៃគិតជាឯកតា | របៀបប្រើ |
|---|---|---|---|---|
| ២-២៨ និង មេរៀនបន្ទាប់ | ប័ណ្ណព្យញ្ជនៈ និងស្រៈ  | ធនធានសិក្សា (គ្រូអាចបង្កើតសម្ភារៈដោយខ្លួនឯង) | ១០.០០០ រៀល ១ឈុតសម្រាប់សិស្ស២-៤នាក់ | សូមមើលការណែនាំនៅខាងក្រោយប្រអប់សិស្សអាចប្រើសម្ភារៈនេះដើម្បីតម្រៀបទៅតាមលំដាប់លំដោយនៃអក្ខរក្រមសិស្សអាចមើលនៅក្នុងទំព័រទី៣ និងទី៥ នៃសៀវភៅសិក្សាគោល ដើម្បីជាជំនួយ |
| ២-២៨ និង មេរៀនបន្ទាប់ | ប័ណ្ណព្យញ្ជនៈនិងស្រៈអមជាមួយរូបភាព   | រីដឌីងប៊ុក | ៦៦.០០ រៀល១ឈុតសម្រាប់សិស្ស២-៤នាក់ | ចែកប័ណ្ណព្យញ្ជនៈនិងស្រៈឱ្យសិស្សស្មើៗគ្នា។ សិស្សម្នាក់មើលប័ណ្ណមួយក្នុងដៃរបស់គេ ហើយនិយាយពាក្យ/ពណ៌នារូបភាព។ សិស្សផ្សេងទៀតប្រាប់ឈ្មោះតួអក្សរ។ សិស្សណាដែលប្រាប់ឈ្មោះតួអក្សរត្រូវបានមុនគេ នឹងឈ្នះបាន ប័ណ្ណនោះ។ សិស្សដែលបានប័ណ្ណច្រើនជាងគេ គឺជាអ្នកឈ្នះ។ |
| ២-២៨ និង មេរៀនបន្ទាប់ | ល្បែងឡូតូព្យញ្ជនៈ  | ធនធានសិក្សា | ១២០០០ . រៀល១ឈុតសម្រាប់សិស្ស ៧ នាក់ | សូមមើលការណែនាំនៅខាងក្រោយប្រអប់ |

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| | | | | |
|---|---|---|---|---|
| ២-២៨ និង មេរៀនបន្ទាប់ | ល្បែងឡូតូស្រៈ  | ធនធានសិក្សា | ១២.០០០ រៀល ១ ឈុត សម្រាប់សិស្ស ៦ នាក់ | សូមមើលការណែនាំនៅខាងក្រោយប្រអប់ |
| មេរៀនទី ៥-១៥ ព្យញ្ជនៈផ្សំ | **អានជារង្វង់**: ព្យញ្ជនៈ និង ស្រៈ  | ធនធានសិក្សា | ៩.៥០០ រៀល ១ ឈុត សម្រាប់សិស្សពី ២ ទៅ ៤ នាក់ | សូមមើលការណែនាំនៅខាងក្រោយប្រអប់ |
| មេរៀនទី ៥-១៥ ព្យញ្ជនៈផ្សំ | ល្បែងផ្គូផ្គងស្រៈ និងព្យញ្ជនៈ  | ធនធានសិក្សា | ១៨.០០០ រៀល១ឈុត សម្រាប់សិស្ស៥ នាក់ | សូមមើលការណែនាំនៅខាងក្រោយប្រអប់ |
| ២-២៨ និង មេរៀនបន្ទាប់ | សៀវភៅហ្វឹកហាត់ភាសាខ្មែរ ថ្នាក់ទី១  | គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ | ៦.០០០ រៀល | សម្រាប់កុមារហ្វឹកហាត់សរសេរក្រៅមេរៀន/កិច្ចការផ្ទះ |
| ២-២៨ និង មេរៀនបន្ទាប់ | សៀវភៅលំហាត់សរសេរដៃ  | Book World | ៣.៥០០ រៀល | សម្រាប់កុមារហ្វឹកហាត់សរសេរក្រៅមេរៀន/កិច្ចការផ្ទះ |

| | | | | |
|---|---|---|---|---|
| |  | | | |
| ២-២៨ និង មេរៀនបន្ទាប់ | <br>គន្លឹះ៖ នៅពេលជ្រើសរើស ធ្វើផ្ទាំងព្យញ្ជនៈ/-ប្រើពណ៌ក្រហម និងពណ៌ខៀវរំលេចលើព្យញ្ជនៈ ឃោសៈ និងអឃោសៈ។ | បណ្ណាគារ អន្តរជាតិ / គ្រឹះស្ថានបោះពុម្ព SBS(គ្រូ) អាចបង្កើតសម្ភារៈនេះដោយខ្លួន (ឯង | ៣.៦០០ រៀល | ក្នុងមួយថ្ងៃ ត្រូវរំឭកដោយការចង្អុលព្យញ្ជនៈរយៈពេល ២នាទី ។ ឱ្យសិស្សធ្វើកាយវិការដែលទាក់ទងនឹងតួអក្សរ។ ហ្វឹកហាត់តួអក្សរណាដែលពិបាកមុន។ |
| ២-២៨ និង មេរៀនបន្ទាប់ |  | បណ្ណាគារ អន្តរជាតិ / គ្រឹះស្ថានបោះពុម្ព SBS | ៤.៨០០ រៀល | ក្នុងមួយថ្ងៃ ត្រូវរំឭកដោយការចង្អុលព្យញ្ជនៈរយៈពេល ២នាទី ។ ឱ្យសិស្សធ្វើកាយវិការដែលទាក់ទងនឹងតួអក្សរ។ ហ្វឹកហាត់តួអក្សរណាដែលពិបាកមុន។ |
| មេរៀនទី ៥-១០២ | ល្បែងបង្កើតពាក្យ<br> | ធនធានសិក្សា | ៥២.០០០ រៀល<br>១ឈុតសម្រាប់សិស្ស៥នាក់ | សូមមើលការណែនាំនៅខាងក្រោយប្រអប់ |

sala.moeys.gov.kh t.me/moeysnews youtube.com/moeyscambodia

| | | | | |
|---|---|---|---|---|
| មេរៀនទី ៥-១៥ | ផ្ទាំងរូបភាពព្យញ្ជនៈពួក "អ"  | ធនធានសិក្សា | ៣.៥០០ រៀល<br>សិស្សអាចលេងដោយខ្លួនឯង ឬជាមួយដៃគូ ឬជាមួយក្រុមតូចក៏បាន | ល្បែងផ្គូផ្គង: គ្រូបិទផ្ទាំង រូបភាពព្យញ្ជនៈពួក បាំងតួអក្សរ/នៅលើក្ដារខៀន។ បន្ទាប់មក គ្រូបិទ "អ" នៃរូបភាពម្ដងមួយៗ ហើយឱ្យសិស្សប្រាប់សូរដើមនៃបាំងនោះ/ពាក្យរបស់រូបភាពដែលបិទ |
| មេរៀនទី ៥-១៥, ៦៨-៩៤<br>ផ្សំស្រៈនឹង ព្យញ្ជនៈពួក "អ" | ល្បែងផ្គូផ្គងពាក្យនឹងរូបភាព  | ធនធានសិក្សា | ១៥.០០០ រៀល<br>១ឈុតសម្រាប់សិស្សពី ២ ទៅ ៤ នាក់ | សូមមើលការណែនាំនៅខាងក្រោយប្រអប់<br>គ្រូត្រូវជ្រើសរើសពាក្យដែលសិស្សបានរៀនរួច។ |

# ការផ្តល់ជាគំនិតទាក់ទងសៀវភៅរឿងសម្រាប់សិស្សអាន- ដឹកនាំដោយគ្រូ

គេហទំព័រ និងកម្មវិធីខាងក្រោមនេះ ជាជម្រើសដែលមានសៀវភៅ និងសម្ភារៈអំណានអាចទាញយកដោយសេរី ដែលគ្រូអាចប្រើប្រាស់ក្នុងម៉ោងដោយគ្រូអំណាន ដែលដឹកនាំដោយគ្រូ៖

- ក្រសួង អ.យ.ក. Krou http://www.krou.moeys.gov.kh/kh/
- តោះអាន http://letsreadasia.org/
- កម្មវិធីបណ្ណាល័យខ្មែរ (ស្វែងរក "Khmer Library" on www.play.google.com

| ចំណងជើងរឿង | គ្រឹះស្ថានបោះពុម្ព | តម្លៃ |
|---|---|---|
| ថ្ងៃអាទិត្យ  ណារី និង បូណានៅសាលារៀន  ងូតទឹកភ្លៀង <br>សម្លកកូរបស់ប៉ាប៉ូ  ថ្ងៃមិនល្អរបស់លោកគ្រូសាន  ទៅលេងបុណ្យអុំទូក <br>ដុសធ្មេញ  ជួយធ្វើម្ហូប  ខ្ញុំចង់ក្លាយជា <br>ខែក្តៅ  ទៅផ្សារ  | មាននៅលើ គេហទំព័រ របស់ក្រសួងអប់រំ យុវជន និងកីឡា | ឥតគិតថ្លៃ |

t.me/moeyssnews sala.moeys.gov.kh youtube.com/moeyscambodia

# ការផ្តល់ជាគំនិតទាក់ទងសៀវភៅរឿងសម្រាប់សិស្សអាន- ដឹកនាំដោយសិស្ស

ខាងក្រោមនេះជាចំណងជើងសៀវភៅរឿង បែងចែកទៅតាមប្រភេទមេរៀនដែលសិស្សអាចហាត់អានដោយខ្លួនឯងបាន។

| មេរៀន | ចំណងជើង | គ្រឹះស្ថានបោះពុម្ព |
|---|---|---|
| រឿងងាយៗចាប់ពីមេរៀន ២៧ (ព្យញ្ជនៈផ្សំស្រះ) |   | មាននៅក្នុងគេហទំព័ររបស់ក្រសួង អ.យ.ក. |
| រឿងងាយៗចាប់ពីមេរៀន៣៣ (សញ្ញាមូសិកទន្ត ឬធ្មេញកណ្តុរ) |  | មាននៅក្នុងគេហទំព័ររបស់ក្រសួង អ.យ.ក. |
| រឿងងាយៗ ចាប់ពីមេរៀន ៤២ ទៅ ៦៤ (ប្រកប) |       | មាននៅក្នុងគេហទំព័ររបស់ក្រសួង អ.យ.ក. |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews































































# បញ្ជីសកម្មភាពល្បែងសិក្សាមួយចំនួន

| សកម្មភាព | បំណិន | មេរៀន | សម្ភារៈដែលត្រូវការ | របៀបធ្វើសកម្មភាព |
|---|---|---|---|---|
| រៀនអក្សរ<br>(ការងារដៃគូ) | ស្គាល់តួអក្សរ | ស្រៈ<br>ព្យញ្ជនៈ | ស្រោមសំបុត្រ ដែលមានតួអក្សរនីមួយៗនៅក្នុងនោះ | សិស្សធ្វើការជាដៃគូ រៀបចំស្រៈ ឬតួអក្សរទៅតាមលំដាប់លំដោយនៃអក្ខរក្រម។ |
| រៀនព្យាង្គ និងពាក្យ<br>(ការងារដៃគូ) | សរសេរព្យាង្គ និងពាក្យ | ព្យញ្ជនៈ<br>ផ្សំស្រៈ | ស្រោមសំបុត្រ ដែលមានតួអក្សរនីមួយៗនៅក្នុងនោះ | សិស្សធ្វើការជាដៃគូ។ គ្រូឱ្យសិស្សផ្គុំតួអក្សរឱ្យចេញជាឈ្មោះ ជាពាក្យតាមការកំណត់របស់គ្រូ ដោយផ្អែកតាមខ្លឹមសារមេរៀន។ |
| ការរំឭកសូរ<br>(ថ្នាក់ទាំងមូល ឬជាដៃគូ) | ស្គាល់តួអក្សរ និងសូរ | គ្រប់មេរៀនពាក់ព័ន្ធ | ផ្ទាំងក្រដាសធំដែលមានតួអក្សរ និង<br>ប័ណ្ណអក្សរដូចផ្ទាំងក្រដាសធំ | គ្រូបិទផ្ទាំងក្រដាសធំ ដែលមានតួអក្សរលើជញ្ជាំង។ គ្រូចង្អុលតួអក្សរនីមួយៗលើជញ្ជាំង ហើយសិស្សប្រាប់ឈ្មោះតួអក្សរនោះ។ គ្រូឲ្យសិស្សធ្វើការជាគូដោយប្រើក្រដាសតូច រួចសិស្សចង្អុលឲ្យដៃគូអានតួអក្សរម្តងម្នាក់។ |
| ការរកពាក្យដែលមានសូរដើមតែមួយដូចគ្នា<br>(ថ្នាក់ទាំងមូល) | ស្គាល់សូរ | មេរៀនស្រៈ និងព្យញ្ជនៈដែលត្រូវបង្រៀន | បញ្ជីពាក្យ<br>(សម្រាប់គ្រូ) | សិស្សអង្គុយលើកម្រាលឥដ្ឋ ឬលើកៅអីរបស់ពួកគេ។ គ្រូនិយាយពាក្យមួយឮៗ(ឧ. ចាន) រួចបោះបាល់ឱ្យសិស្សចាប់។ សិស្សដែលចាប់បាល់បាន គិតរកពាក្យដែលមានសូរដើម“ ប “ ឱ្យរហ័ស រួចបោះបាល់ទៅកាន់គ្រូវិញ។ បន្តធ្វើដូចនេះរហូតអស់ម៉ោងកំណត់។ |
| ការញែកពាក្យក្នុងល្បះ<br>(ការងារជាដៃគូ ឬក្រុមតូច) | កំណត់ពាក្យក្នុងល្បះ | គ្រប់មេរៀនពាក់ព័ន្ធ | ក្រដាសរាងការេ ឬដុំក្រួស | ចែកសិស្សជាក្រុមតូច៣-៤នាក់។ ចែកក្រដាសរឹង៥-៦សន្លឹក (ឬដុំក្រួស) ឱ្យក្រុមនីមួយៗ។ គ្រូអានល្បះមួយ រួចឱ្យសិស្សដាក់ចំនួនក្រដាស ឬដុំក្រួសស្មើនឹងចំនួនពាក្យក្នុងល្បះនោះ។ ពេលសិស្សដាក់រួច ឱ្យតំណាង ក្រុមអានល្បះដោយចង្អុលក្រដាសដែលតំណាងពាក្យនីមួយៗបណ្តើរ។ |
| ល្បែងរកពាក្យ | កំណត់សូរដើម ឬ | គ្រប់ | គ្មាន | គ្រូប្រាប់សិស្សថា យើងនឹងលេងល្បែង"រក"។ |

| | | | | |
|---|---|---|---|---|
| (ក្រុមធំ) | សូរចុងនៃពាក្យ | មេរៀន ពាក់ព័ន្ធ | (សិស្សជាអ្នករកឈ្មោះ ឬ វត្ថុផ្សេងៗជុំវិញខ្លួន) | គ្រូបង្ហាញឧទាហរណ៍ "រកអ្នកដែលមានឈ្មោះ ឬវត្ថុជុំវិញខ្លួន ដែលចាប់ផ្តើមជាមួយអក្សរ ក" សិស្សឆ្លើយគ្រប់ចម្លើយដែលអាចមាន។ សិស្សដែលទាយត្រូវ នឹងបន្តប្រាប់ឱ្យគេរក "រកពាក្យដែលចាប់ផ្តើមជាមួយ [សូរ] បន្តទៀត។គ្រូកែតម្រូវ។ |
| ការផ្គូផ្គងសូរស្រៈ ឬព្យញ្ជនៈ នឹងរូបភាព<br>(ការងារក្រុមធំ ការងារជាដៃគូ) | ប្រាប់តួអក្សរ និងសូរស្រៈ | គ្រប់ មេរៀន ពាក់ព័ន្ធ | រូបភាព ឬកាយវិការ | គ្រូបង្ហាញរូបភាព និងអានពាក្យ រួចអានតែស្រៈនិស្ស័យដែលមានក្នុងពាក្យ។ ឧ. គ្រូបង្ហាញរូបភាព តា រួចគ្រូអានពាក្យ តា ហើយគ្រូអានស្រៈ "ា" សិស្សអានតាមគ្រូ គ្រូបិទរូបភាពនៅលើក្តាខៀន។ គ្រូបង្ហាញរូបភាព និងអានពាក្យ រួចអានតែស្រៈនិស្ស័យដែលមានក្នុងពាក្យ។ ឧ. គ្រូបង្ហាញរូបភាព តា រួចគ្រូអានពាក្យ តា ហើយគ្រូអានស្រៈ "ា" សិស្សអានតាមគ្រូ គ្រូបិទរូបភាពនៅលើក្តាខៀន។ |
| ពាក្យមានសូរស្រៈ ឬព្យញ្ជនៈ<br>(ក្រុមធំ) | ការស្គាល់សូរ តាមរយៈការ ប្រើប្រាស់ពាក្យចួន។ | គ្រប់ មេរៀន ពាក់ព័ន្ធ | គ្មាន(សកម្មភាពរំឭកមេរៀនចាស់ និងចាប់ផ្តើមរៀនពាក្យ) | គ្រូហៅពាក្យចួនៗ ឱ្យសិស្សស្តាប់។ បន្ទាប់មកសិស្សថាពាក្យចួនៗជាបន្ត។<br>ឧទាហរណ៍ : គ្រូថាតែ សិស្ស ម្នាក់ថា តែ ចែ សិស្សម្នាក់ទៀតថា តែ ចែ ផែ ម្នាក់ផ្សេងទៀតថាតៗគ្នា តែ ចែ ផែ ថែ...ម៉ែ ដែរ ខែ ខ្វែ ស្រែ ។ល។<br>ឧ." ចឹក" "ផឹក" (ចឹក ផឹក សឹក ដឹក ឪឡឹក) |
| ការចម្រាញ់តួអក្សរ<br>(ការងារជាបុគ្គល) | កំណត់តួអក្សរ ពាក្យ ដែលបានរៀន | គ្រប់ មេរៀន ពាក់ព័ន្ធ | អត្ថបទរឿងងាយៗ (អត្ថបទក្នុង សៀវភៅជំនួយសិស្ស) | គ្រូឱ្យសិស្សបើកអត្ថបទរឿងក្នុងសៀវភៅជំនួយសិស្ស។ សិស្ស ប្រណាំងគ្នាដើម្បីរកតួអក្សរតាមដែលគ្រូចង់បាន រួចគូសរង្វង់លើតួអក្សរនោះ។ សិស្សប្រៀបធៀបជាមួយដៃគូ រួចគ្រូផ្ទៀងផ្ទាត់ចម្លើយ។ |
| ផ្សំសូរតួអក្សរ ទី១<br>(ការងារក្រុមតូច) | ការស្គាល់តួអក្សរ និងសូរ | គ្រប់ មេរៀន ពាក់ព័ន្ធ | ប័ណ្ណព្យញ្ជនៈ និងស្រៈ | សិស្ស (៣ ឬ៤នាក់)កាន់ប័ណ្ណស្រៈនិងព្យញ្ជនៈដែលបានគ្រោងទុកនៅមុខក្តារខៀន ហើយអានតួអក្សរដែលពួកគេបានកាន់ឈរនៅឆ្ងាយពីគ្នា។ សិស្សខិតចូលជិតគ្នា ហើយ |

sala.moeys.gov.kh t.me/moeysnews youtube.com/moeyscambodia

| | | | | |
|---|---|---|---|---|
| | | | | អានស្រៈ និងព្យញ្ជនៈ បន្ទាប់មកផ្សំស្រៈ និងព្យញ្ជនៈនោះឱ្យចេញជាពាក្យ ៩-ស្រៈថ្មីដែលមាន២សមាសធាតុ ៩. ស្រៈ ោ ។ កុមារអាចចូលជិតគ្នាដើម្បីបង្កើតបានជាស្រៈ ោ។ សិស្ស ២នាក់ឈរកាន់ស្រៈសងខាងព្យញ្ជនៈ ដើម្បីបង្ហាញថាវាជាស្រៈតែមួយ ។ **ចំពោះព្យញ្ជនៈពួក អ៊ និងស្រៈវិញ៖** ដំបូង ប្រើពួក អ ជាមួយស្រៈធម្មតា បន្ទាប់មកទៀតប្រើពួក អ៊ ជាមួយស្រៈដូចមុនដដែល។ |
| ការបំបែកព្យាង្គ<br>( ក្រុមធំ ) | សិស្សអាចប្រាប់ពីសូរតួអក្សរ និងព្យាង្គក្នុងពាក្យ | គ្រប់មេរៀនពាក់ព័ន្ធ | ប័ណ្ណពាក្យ | គ្រូអានពាក្យមួយ រួចឱ្យសិស្សប្រាប់ចំនួនសូរនៃពាក្យនោះ ប្រើម្រាមដៃដើម្បីរាប់ចំនួនព្យាង្គក្នុងពាក្យនោះ ហើយទះដៃតាមចំនួនព្យាង្គ។ |
| ឡូតូអក្ខរក្រម ឬ អក្ខរក្រម<br>(Bingo)<br>( ១០នាទី )<br>( ក្រុមធំ ) | រំឭកមេរៀនឬ ពង្រឹងមេរៀនថ្មី | គ្រប់មេរៀនពាក់ព័ន្ធ | គ្រូសិស្សគូសតារាងឱ្យបានយ៉ាងតិច៣ កូឡោនគុណនឹង៣។ | គ្រូឱ្យសិស្សសរសេរតួអក្សរចូលទៅក្នុងតារាងជាបុគ្គល រួចគ្រូអានតួអក្សរ ខ្លាំងៗឱ្យសិស្សស្ដាប់។ សិស្សគូសសញ្ញា លើតួអក្សរណា (√) ដែលបានឮគ្រូអាន។ បើសិស្សណាដែលមានតួអក្សរគ្រប់ចំនួនជួរដេក ជួរឈរ ឬ បញ្ឆិតតាមគ្រប់ចំនួននៃកូឡោនជាអ្នកឈ្នះ ហើយស្រែកថាឈ្នះ ឬ (Bingo)។ គ្រូឱ្យសិស្សដែលឈ្នះអានដោយលើកបង្ហាញ។ |

# ផ្នែកមួយចំនួននៃវេយ្យាករណ៍ខ្មែរ

## វណ្ណយុត្តិ[2]

វណ្ណយុត្តិ ជាពួកសញ្ញាដែលប្រើលើតួអក្សរ ឬប្រើផ្សំជាមួយអក្សរ ដើម្បីបំបែរតួអក្ខរៈ ឬសព្ទដើម ឱ្យមានសំឡេងប្លែកចាកលំនាំដើម។ វណ្ណយុត្តិទាំងអស់មាន ១១ យ៉ាង។ ប៉ុន្តែ ខាងក្រោមនេះ យើងស្រង់យកតែវណ្ណយុត្តិណាដែលយើងប្រើញឹកញាប់ក្នុងថ្នាក់ទី២។

**១- រស្សសញ្ញា ឬ បន្តក់ (់) :** វណ្ណយុត្តិមួយបែប មានសណ្ឋានកំបុតខ្លីយ៉ាងនេះ (់) សម្រាប់ប្រើបំបែរសំឡេងវែង ឱ្យខ្លីកំបុត ធ្ងន់ ប្រើដាក់បានចំពោះតែពីលើតួអក្សរប្រកបរបស់ពាក្យខ្មែរ ដែលជាស្រៈ **អ អា** ពីរនេះ ហើយតួដែលប្រកបនោះជាអក្សរ **ក ង ច ញ ត ន ប ល ស**។

ចំពោះស្រៈ អា ប្រកបនឹង ង មិនត្រូវប្រើបន្តក់ (់) នេះពីលើឡើយ ត្រូវប្រើនិគ្គហិត (ំ) នេះជំនួសវិញ។

ឧ...កុំប្រើ ក្តាង់ ខ្លាំង់ ឃ្លាង់ ច្បាង់ ផ្ទាង់.....ក្តាំង ខ្លាំង ឃ្លាំង ច្បាំង ផ្ទាំង .

**២- មូសិកទន្ត ឬធ្មេញកណ្ដុរ (៉) : វណ្ណយុត្តិមួយបែប មានរូបជាគំនូសក្បៀសពីរ មានសណ្ឋានដូចធ្មេញកណ្ដុរ** (៉) សម្រាប់ប្រើដាក់ពីខាងលើ បំបែរសូរអក្សរឃោសៈ ឱ្យទៅជាសូរអឃោសៈវិញ។ ចំពោះអក្សរ "ប" ដែលជាអឃោសៈស្រាប់ បើដាក់មូសិកទន្តនេះ (៉) នៅពីលើ ក៏គង់នៅតែជា អឃោសៈដដែល តែសូរប្លែកពី"ប" សូរ "ប៉" វិញ។ កាលណាមានពាក្យពីរព្យាង្គ ព្យាង្គខាងដើមជាអក្សរអឃោសៈ ព្យាង្គខាងចុងមិនត្រូវប្រើមូសិកទន្ត (៉) ពីលើឡើយ។ ឧ. សាលា ឆាយា តុលា ប្រមាត់ ក្រវែល ប្រវេងប្រវាង កញ្ញា។ល។

**៣- ត្រីសព្ទ (៊) : វណ្ណយុត្តិមួយបែប មានសណ្ឋានដូចសក់កយ៉ាងនេះ (៊) សម្រាប់ដាក់លើអក្សរ ៤តួ ប ស ហ អ ឱ្យមានសំឡេងធំ ជាៈ ប៊ ស៊ ហ៊ អ៊ (គឺធ្វើសំឡេងអឃោសៈ ឱ្យទៅជាសំឡេងឃោសៈ)។ កាលណាសញ្ញាមូសិកទន្ត ឬត្រីស័ព្ទជួបនឹងស្រៈ ិ ី ឹ ឺ ើ ត្រូវប្រែប្រួលរូបមកជា (ុ) វិញ។ តួ ប៊ កាលបើមានស្រៈនិស្ស័យនៅពីលើ ត្រីសព្ទ (៊) មិនប្តូរទៅជាបុកជើង (ុ) ទេ គឺត្រូវទុកត្រីសព្ទ (៊) នៅដដែល ដើម្បីកុំឱ្យសព្ទនោះក្លាយទៅជាត្រីសព្ទ។**

**៤ -លេខទោ :** (ៗ) វណ្ណយុត្តិមួយបែប មានសណ្ឋានខាងក្បាលដូចលេខ ២ ប៉ុន្តែកន្ទុយយារចុះក្រោម ង ចុងបន្តិចយ៉ាងនេះ ក្មេងៗ ផ្សេងៗ ដដែលៗ។ល។ ចំពោះ .សម្រាប់សរសេរខាងមុខពាក្យដែលត្រូវថាផ្ទួនគ្នាពីរដង។ ឧ (ៗ) ពាក្យបាលីយកមកប្រើជាខ្មែរ ទុកណាជាពាក្យផ្ទួនគ្នា ក៏មិនត្រូវយកលេខទោ មកដាក់ពីមុខឡើយ។ ឧនានា។ .

---

[2] វេយ្យាករណ៍ភាសាខ្មែរ សម្រាប់ថ្នាក់មធ្យមដ្ឋាន និងឧត្តមដ្ឋាន **សាស្ត្រាចារ្យ ពូរ អ៊ុម** បោះពុម្ពលើកទី៥ ព.ស. ២៥១៦ គ.ស. ១៩៧២

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## ខណ្ឌសញ្ញា ឬល្បះ[3]

ខណ្ឌសញ្ញា គឺជាពួកសញ្ញាដែលប្រើខណ្ឌសេចក្ដីឱ្យមានរបៀបជាឃ្លា ជាសង្កាត់ ដើម្បីធ្វើសេចក្ដីឱ្យមានន័យកាន់តែច្បាស់ឡើង។ ខណ្ឌសញ្ញាទាំងអស់មាន ២០ យ៉ាង។ ប៉ុន្តែ ខាងក្រោមនេះយើងស្រង់យកតែខណ្ឌសញ្ញាណាដែលប្រើញឹកញាប់ក្នុងថ្នាក់ទី២។

**ខណ្ឌសញ្ញា (។)** : ខណ្ឌសញ្ញាមួយបែបមានរូបយ៉ាងនេះ សម្រាប់ប្រើដាក់រាំងឃ្លា ប្រយោគ ឬសង្កត់សេចក្ដី (។) មួយឱ្យដាច់ស្រឡះដោយឡែកពីគ្នា។ឧ .គ្រាមួយ មានសត្វក្រសារមួយ ឈរចាំចឹកត្រីនៅមាត់បឹង។ ពេលនោះ .....

**បុច្ឆនសញ្ញា ( ? ) : ខណ្ឌសញ្ញាមួយបែបមានរូបយ៉ាងនេះ ( ? ) សម្រាប់ប្រើដាក់ខាងចុងនៃប្រយោគសួរ ដណ្ដឹងធ្ងល់ ឬសង្ស័យ។ ឧ. អ្នកឈ្មោះអ្វី ?**

**ចំណុចពីរគូស (៖)** : ខណ្ឌសញ្ញាមួយបែបមានរូបយ៉ាងនេះ សម្រាប់ប្រើដាក់ពីមុខសេចក្ដី ដែលបម្រុងនឹង (៖) នេះតាមទម្លាប់ដើមមក ក៏បានដូចគ្នា។ (:) រៀប   រាប់។ បើនឹងប្រើយុគលពិន្ទុ

## ព្យញ្ជនៈផ្សំស្រៈ

ព្យញ្ជនៈទាំង ៣៣ចែកជា ៥ វគ្គ ឬពួក និងសេសវគ្គ ១ រីវគ្គនីមួយៗមានអក្សរ ៥ តួ ឯសេសវគ្គមាន ៨ តួ។ វគ្គទី ១ គឺៈ ក ខ គ ឃ ង។ វគ្គទី ២ គឺៈ ចឆជ ឈ ញ។ វគ្គទី ៣ គឺៈ ដ ឋ ឌ ឍ ណ។ វគ្គទី ៤ គឺៈ ត ថ ទ ធ ន។ វគ្គទី ៥ គឺៈ ប ផ ព ភ ម។ សេសវគ្គគឺៈ យ រ ល វ ស ហ ឡ អ។ ព្យញ្ជនៈទាំងឡាយមានសូរជាពីរពួក ពួកសំឡេងតូចហៅថាអឃោសៈ ពួកសំឡេងធំហៅថាឃោសៈ [4]។

ស្រៈនិស្ស័យមាន ២៣ តួ។ ស្រៈនិស្ស័យមានសូរសំឡេង ២ យ៉ាង គឺសំឡេងតូច និងសំឡេង (អឃោសៈ) " អ " ។ កាលណាបើស្រៈនិស្ស័យផ្សំជាមួយនឹងអក្សរដែលមានសំឡេងតូច ឬព្យញ្ជនៈពួក( ឃោសៈ )ធំ

(អឃោសៈ) ក៏មានសំឡេងតូចតាមអក្សរនោះ។ បើផ្សំជាមួយនឹងអក្សរដែលមានសំឡេងធំ ឬព្យញ្ជនៈពួក " អ៊ " (ឃោសៈ) ក៏មានសំឡេងធំតាមអក្សរនោះដែរ។ ឧ. កា គា កិ គិ ងា ង៉ា ម៉ៃ មៃ.... ។

[3] វេយ្យាករណ៍ភាសាខ្មែរ សម្រាប់ថ្នាក់មជ្ឈិមដ្ឋាន និងឧត្តមដ្ឋាន **សាស្ត្រាចារ្យ ព្រូវ អ៊ុម** បោះពុម្ពលើកទី៥ ព.ស. ២៥១៦ គ.ស. ១៩៧២

## ប្រកប

ព្យាង្គ ឬពាក្យប្រកប គឺជាការផ្សំបញ្ចូលគ្នាសូររវាងព្យញ្ជនៈ ស្រៈ ព្យញ្ជនៈ (ព.ស.ព.) ឱ្យទៅជាព្យាង្គ ឬពាក្យដែលមានសូរលាយចូលគ្នាតែមួយ។ ឧ. កង ចែក លើស ប៉ោត ជួយ បំបែក ចំណង។ ល។ ពាក្យប្រកបអាចមានប្រកបគ្មានបន្តក់ និងមានបន្តក់។ ឧ. ចំណង ចំណង់...ជាដើម។ បន្តក់ ( ់ ) ធ្វើសូរវែងឱ្យទៅជាខ្លី។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## ព្យញ្ជនៈផ្ញើជើង[5]

ផ្ញើជើង គឺជាវិធីយកជើងព្យញ្ជនៈមួយ ទៅផ្សំសូរ ជាមួយនឹងព្យញ្ជនៈមួយទៀត ដើម្បីបង្កើតបានជាសំឡេងផ្សំពីរបញ្ចូល គ្នា ឲ្យលាន់ឮក្នុងព្យាង្គតែមួយ ។ នៅក្នុងភាសាខ្មែរយើង សម្បូរ ពាក្យដែលផ្សំសំឡេងពីររួមបញ្ចូលមកតែមួយព្យាង្គ សម្រាប់អាននិយាយ ចេញមកភ្ជាប់គ្នាដូចជាសំឡេងភ្លោះ ។

អក្សរដែលផ្សំជាមួយនឹងជើងអក្សរឯទៀតផ្សេង មានសំឡេងលាន់ឮទាំង ២ ពីលើចុះមកក្រោម គឺត្រូវថាពីតួលើចុះមកក្រោម ឱ្យឮសូរសំឡេងផ្គោបគ្នាតែមួយ ហៅថាអក្សរផ្ញើជើង។ ប៉ុន្តែត្រង់ជើងអក្សរ ៧ តួ គឺៈ ង ញ ន ម  រ ល វ នេះ បើយកផ្ញើនឹងតួអក្សរមានសំឡេងតូច ( ពួក «អ» ) គឺមានសំឡេងតូចតាមតួលើ ដូចជា ក្ង ខ្វ ច្ន ធ្ម ត្រ ផ្ល ស្វ ជាដើម។

## ព្យាង្គតម្រួត [6]

ក្នុងភាសាខ្មែរអក្សរតម្រួត ឬព្យាង្គតម្រួត មានរបៀបប្រើដូចអក្សរផ្ញើជើងដែរ ប៉ុន្តែអក្សរតម្រួតតួលើជាគូប្រកបរបស់អក្សរខាងដើម ឯតួក្រោមអាចចេញសំឡេងប្រកបនឹងព្យញ្ជនៈ ឬស្រៈ។ ប៉ុន្តែបើគ្មានផ្សំប្រកបនឹង ស្រៈ ឬ ព្យញ្ជនៈទេនោះ វាពុំមានសូរទេ ។

ឧទាហរណ៍៖

១- ចង្កា ( ក អាចចេញសំឡេងបាន )

២- ចង្កោម ( កោ អាចប្រកបនឹង ម បាន )

៣- អង្គ សង្ឃ ខណ្ឌ (អក្សរក្រោមមិនចេញសំឡេង ព្រោះគ្មានតួប្រកប ឬផ្សំស្រៈ។ ភាគច្រើនជាពាក្យកម្ចីពីបាលី-សំស្ក្រឹត។ )

## របៀបផ្សំប្រកប និងធ្វើអក្ខរាវិរុទ្ធ

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួនអំពីផ្សំប្រកប និងអក្ខរាវិរុទ្ធតាមប្រភេទមេរៀននីមួយៗ។

---

[5] កុមារដ្ឋាន **ម៉ម-សុទ្ធ** ១៩៥២

[6] វេយ្យាករណ៍ខ្មែរ សម្រាប់ថ្នាក់បឋមភូមិបំពេញវិជ្ជា អ្នកឧកញ៉ាមហាមន្ត្រី **ញិក នូវ** ព.ស.២៥០១ គ.ស.១៩៥៩

## ១- មេរៀនព្យញ្ជនៈផ្សំស្រៈ

| ការផ្សំប្រកប | អក្ខរវិញ្ញាស |
|---|---|
| ការ  ក អា  កា កា និង រ  [កា] | ការ  មាន  ក  ស្រៈា និង រ |
| គា  គ អ៊ា  គា  [ គា] | គា  មាន  គ  និងស្រៈា |

## ២- មេរៀនប្រកប

| ការផ្សំប្រកប | អក្ខរវិញ្ញាស |
|---|---|
| កាក  ក អា កា កា និងក  [ កាក] | កាក់  មាន ក  ស្រៈា ក និងបន្តក់  ់ |
| កាក់  ក អា កា កា និងក កាក  បន្តក់មួយ [កាក់] | កោ  មាន  ក  និងស្រៈ  ោ |
| គាក  គ អ៊ា គា គា និង ក  [គាក] | គាក់  មាន គ ស្រៈា ក និងបន្តក់  ់ |
| គាក់  គ អ៊ា គា គា និង ក គាក បន្តក់មួយ [គាក់ ] | គោ  មាន  គ  និងស្រៈ  ោ |

## ៣- មេរៀនស្រៈពេញតួ

| ការផ្សំប្រកប | អក្ខរវិញ្ញាស |
|---|---|
| ឧស  អុ និង ស  [ អុស ] | ឧស  មាន ស្រៈពេញតួ ឧ  ស |
| អគារ  អៈ  គ អ៊ា គា គា និង រ គា  [គា-អៈ ] | អគារ  មាន ស្រៈពេញតួ អ  គ  ស្រៈ ា និង រ |
| ឪឡឹក  អូវ  ឡ  អឺ ឡឺ ឡឺ និង ក ឡឹក [ ឡឹក-អូវ ] | ឪឡឹក  មាន ស្រៈពេញតួ ឪ  ឡ  ស្រៈ ឹ  និង ក |
| ឱទាន  អ៊ុ  ទ  អ៊ា ទា  ទា និង ន ទាន  [ ទាន-អ៊ុ ] | ឱទាន  មាន ស្រៈពេញតួ  ឱ  ទ  ស្រៈ ា និង ន |

## ៤- មេរៀនមូសិកទន្ត(៊)និងត្រីសព្ទ (៉)

| ការផ្សំប្រកប | អក្ខរវិញ្ញាស |
|---|---|
| ង៉ាំ  ង សម្លាប់ពីរ ង៉ ង៉  អាំ  [ ង៉ាំ ] | ង៉ាំ  មាន  ង  បុកជើង (ុ) និងស្រៈ ាំ |
| ស៊ី  ស ត្រីសព្ទ ស៊ ស៊  អ៊ី  [  ស៊ី ] | ស៊ី  មាន  ស  បុកជើង (ុ) និងស្រៈ ី |
| ប៉ី  ប សម្លាប់ពីរ ប៉ ប៉  អី  [  ប៉ី ] | ប៉ី  មាន  ប  បុកជើង (ុ) និងស្រៈ  ី |
| ហ៊ី  ហ ត្រីសព្ទ ហ៊  ហ៊  អ៊ី [ ហ៊ី ] | ហ៊ី  មាន  ហ  បុកជើង (ុ) និងស្រៈ ី |

## ៥- មេរៀនផ្ញើជើង

| ការផ្សំប្រកប | អក្ខរវិញ្ញាស |
|---|---|
| ធ្នើរ  ធ ជើង ្ន ធ្ន  ធ្ន  អឺ  ធ្នើ  ធ្នើ និង រ  [ ធ្នើរ] | ធ្នើរ  មាន  ធ ជើង ្ន  ស្រៈ ើ និង រ |
| ម្ទាស់  ម ជើង្ទ ម្ទ ម្ទ អា ម្ទា ម្ទា និងស ម្ទាស បន្តក់មួយ [ម្ទាស់] | ម្ទាស់ មាន ម ជើង ្ទ ស្រៈា និង ស បន្តក់មួយ(់) |
| ជ្រាប ជ ជើង ្រ ជ្រ ជ្រ អ៊ា ជ្រា ជ្រា និង ប [ជ្រាប] | ជ្រាប  មាន  ជ ជើង ្រ  ស្រៈ ា និង ប |
| ថ្នាល  ថ ជើង ្ន ថ្ន ថ្ន អា ថ្នា ថ្នា និង ល [ថ្នាល] | ថ្នាល  មាន  ថ ជើង ្ន  ស្រៈ ា និង ល |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

បោះពុម្ពលើកទី៣ ខែមេសា ឆ្នាំ២០២១

កុមាររៀន
កុមារចេះ
ក ១
២៣

កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

ហាមលក់
NOT FOR SALE